សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University Of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ខេត្តកោះកុង

ស្រាវជ្រាវដោយ

ឈុំ គីរី

វ៉ាន់ ករុណា

សាស្ត្រាចារ្យណែនាំ

លោក ស្រូ រិទ្ធី

បរិញ្ញាបត្រ ទេសចរណ៍ និងបដិសណ្ឋាកិច្ច

២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ឈុំ គីរី និង វ៉ាន់ ករុណា ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច ឆ្នាំទី០៤ ជំនាន់ទី ០៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ក្នុងការរៀបរាប់សារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកអ្នកមានគុណដូចខាងក្រោម៖

- យើងខ្ញុំសូមគោរព និងថ្លែងអំណរគុណចំពោះលោកអ្នកមានគុណរបស់យើងខ្ញុំគឺ លោកឪពុកនិងអ្នកម្តាយដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សាផ្តល់នូវការស្រលាញ់ប្រកបដោយព្រហ្មវិហារធម៌ផ្តល់នូវការទូន្មានអប់រំនិងជម្រុញលើកទឹកចិត្តដល់យើងខ្ញុំឲ្យខិតខំរៀនសូត្រ និងគាំទ្រទាំងកម្លាំងកាយចិត្ត និងហិរញ្ញវត្ថុ រហូតដល់យើងខ្ញុំទាំងពីរនាក់មាននូវចំណេះដឹង និងទទួលបានសមិទ្ធផលដូចថ្ងៃនេះ។
- យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលតែងតែខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តដើម្បីបង្ហាត់បង្រៀនផ្តល់នូវចំណេះដឹងផ្តល់ជាបទពិសោធន៍ និងយោបល់ព្រមទាំងគំនិតល្អៗប្រកបដោយការយកចិត្តទុកដាក់ដល់យើងខ្ញុំតាំងពីចាប់ផ្តើមរហូតដល់ឆ្នាំបញ្ចប់ការសិក្សានេះ ។
- សូមថ្លែងអំណរគុណយ៉ាងពន់ពេកដល់លោកសាស្ត្រាចារ្យ **ស្រូ រិទ្ធី** ជាសាស្ត្រាចារ្យណែនាំដែលបានដឹកនាំ និងបានខិតខំកែលំអរដោយបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងការផ្តល់ជាគំនិតយោបល់ និងមតិល្អៗជាច្រើនដើម្បីភាពងាយស្រួលដល់ការសិក្សាព្រមទាំងការចងក្រងសរសេរសារណាបញ្ចប់ការសិក្សានេះដោយពុំខ្លាចនូវការនឿយហត់ឡើយចាប់ទាំងពីចាប់ផ្តើមរហូតដល់បញ្ចប់ដោយជោគជ័យនេះ ។
- សូមថ្លែងអំណរគុណដល់លោក **អន សុវណ្ណ** ដែលជាប្រធានសមាគមន៍អេកូទេសចរណ៍ជីផាត់ដែលលោកផ្តល់ពេលវេលា យ៉ាងមានតម្លៃក្នុងការផ្តល់បទសម្ភាសន៍ និងឯកសារស្រាវជ្រាវក្នុងការសរសេររបាយការណ៍នេះ។
- សូមថ្លែងអំណរគុណដល់ភ្ញៀវទេសចរណ៍ ដែលបានចែករំលែកនូវមតិយោបល់ផ្ទាល់ខ្លួន។

ចុងបញ្ចប់នេះ យើងខ្ញុំទាំងពីរសូមដល់វត្ថុស័ក្តសិទ្ធិទាំងអស់ក្នុងលោកថែរក្សាការពារ និងប្រសិទ្ធពរជ័យជូនលោកទាំងអស់ ជួបតែក្តីសុខចម្រើន សុខភាពល្អ អាយុយឺនយូរ និងទទួលបានជោគជ័យគ្រប់ភារៈកិច្ចនិងជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញ ទេសចរណ៍ និងបដិសណ្ឋារកិច្ច អស់រយៈពេលបួនឆ្នាំមកនេះ យើងទាំងពីរនាក់បានទទួលនូវចំណេះដឹងយ៉ាងច្រើនទាំងទ្រឹស្តី និងការលើកឡើងជាឧទាហរណ៍ក្នុងសង្គមជាក់ស្តែងដែលបានណែនាំយ៉ាងក្បោះក្បាយ ពីសំណាក់សាស្ត្រាចារ្យល្បីៗ ដែលបានធ្វើអោយការសិក្សារបស់យើងកាន់តែមានភាពរីកចម្រើនឡើង។ ក្នុងចំណោមប្រធានបទទាំងអស់គឺយើងបានចាប់អារម្មណ៍លើប្រធានបទដែលទាក់ទងទៅនឹង ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជាងគេ។

ក្នុងសតវត្សទី២១នេះ និន្នាការអេកូទេសចរណ៍ ជានិន្នាការងើបឡើងថ្មី ដែលមានតម្រូវការខ្ពស់។ ហើយត្រូវបានអង្គការទេសចរណ៍ពិភពលោកព្យាករណ៍ថា និន្នាការអេកូទេសចរណ៍អាចមានកំណើនដល់២០%ជារៀងរាល់ឆ្នាំ។ អេកូទេសចរណ៍ត្រូវបានមើលឃើញថា បានចូលរួមដល់កិច្ចការពារបរិស្ថានប្រកបដោយប្រសិទ្ធភាព ខណៈពេលដែលតំបន់អាស៊ីអាគ្នេយ៍រំពឹងថានឹងក្លាយទៅជាគោលដៅអេកូទេសចរណ៍ដ៏ធំជាងគេនៅលើសកលលោកនាថ្ងៃអនាគត ហើយកម្ពុជាក៏ត្រូវបានវាយតម្លៃជាគោលដៅអេកូទេសចរណ៍អាទិភាពមួយក្នុងតំបន់នេះដែរ។

បច្ចុប្បន្នយើងសង្កេតឃើញថា វិស័យអេកូទេសចរណ៍នៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ទេសចរងាកមកធ្វើដំណើរកំសាន្តតាមបែបផ្សងព្រេង បោះតង់ ទៅកាន់សហគមន៍ផ្សេងៗដើម្បីទទួលយកនូវរសជាតិកំសាន្តបែបផែនថ្មី។ ដោយមើលឃើញពី ចលនានៃការលូតលាស់ឥតឈប់ឈរបែបនេះហើយ គួបផ្សំនឹងទ្រឹស្តីដែលយើងបានរៀននៅសាកលវិទ្យាល័យ ព្រមទាំងបទពិសោធន៍ផ្សេងៗដែលយើងធ្លាប់បានធ្វើដំណើរទៅកាន់សហគមន៍ជាច្រើនដែលមាននៅក្នុងកម្ពុជាយើងផ្ទាល់ ធ្វើឱ្យយើងមានការសម្រេចចិត្តប្រកបដោយសុភវិនិច្ឆ័យជ្រើសរើសយកប្រធានបទ ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ធ្វើជាប្រធានបទក្នុងការបញ្ចប់ថ្នាក់សិក្សាបរិញ្ញាបត្ររបស់យើង។

ជាចុងក្រោយ យើងសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថាសារណានេះ និងផ្តល់ជាសំណេរ ក៏ដូចជាគំនិតល្អៗ ដើម្បីបានជាឯកសារដែលមានប្រយោជន៍ដល់សង្គមជាតិទាំងមូល ដើម្បីអាចស្វែងយល់ឲ្យបានស៊ីជម្រៅបន្ថែមទៀតជាមួយនឹងប្រធានបទដែលយើងបានស្រាវជ្រាវមួយនេះនិងផ្តល់អត្ថប្រយោជន៍ដល់បណ្ឌានិស្សិតជំនាន់ក្រោយទុកជាឯកសារសម្រាប់ស្រាវជ្រាវបន្តទៀត។ ទោះជាយ៉ាងណាក៏ដោយ ការចងក្រងឯកសារមួយនេះច្បាស់ណាស់នឹងមានកង្វះខាត និងកំហុសខុសឆ្គងទាំងអត្ថន័យ និងអក្ខរាវិរុទ្ធជាយជៀសមិនផុតឡើយ។ ដូចនេះ ក្រុមយើងខ្ញុំនឹងទទួលនូវមតិរិះគន់ ក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យ មិត្តនិស្សិតគ្រប់រូបដើម្បីបំពេញនូវកង្វះខាតទាំងឡាយ ព្រមទាំងកែលម្អស្នាដៃមួយនេះឲ្យកាន់តែប្រសើរឡើង។

# មាតិកា

ទំព័រ

បញ្ជីតារាង ........ x

អក្សរកាត់........ xi

បញ្ជីរូបភាពនៃក្រាហ្វិក........xii

បញ្ជីឧបសម្ព័ន្ធ ........xiv

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........២

៣. គោលបំណងនៃការស្រាវជ្រាវ ........២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ........៣

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........៣

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ........ ៥

## ជំពូកទី១

## រំលឹកទ្រឹស្តីដែលពាក់ព័ន្ធ

១.១ ប្រវត្តិដើមនៃទេសចរណ៍ ........ ៦

១.១.១ យុគសម័យចក្រភព........៧

១.១.២ យុគសម័យកណ្តាល និងការកកើតថ្មី........៧

១.១.៣ យុគដំបូងនៃការរីកចម្រើនទេសចរណ៍ ........ ៨

១.១.៤ យុគសម័យចលភាព ........ ៨

១.១.៥ យុគសម័យទំនើប ........ ៨

១.២ សារហេតុនៃការធ្វើដំណើរ........ ៩

១.២.១ ការធ្វើដំណើរដោយមិនចាត់ទុកជាទេសចរណ៍ ........ ១០

១.២.២ គោលបំណងទេសចរណ៍ ........ ១០

១.៣  និយមន័យពាក់ព័ន្ធទេសចរណ៍ ........ ១១

១.៣.១ អ្វីទៅជាទេសចរ ........ ១១

១.៣.២ អ្នកណាជាទេសចរ ........ ១២

១.៤ មុខងារទេសចរណ៍ ........ ១៥

១.៤.១ មុខងារសង្គមរបស់ទេសចរណ៍ ........ ១៥

១.៤.២ មុខងារសេដ្ឋកិច្ចរបស់ទេសចរណ៍ ........ ១៥

១.៤.៣ មុខងារមនុស្សជាតិរបស់ទេសចរណ៍ ........ ១៦

១.៥ អេកូទេសចរណ៍ ........ ១៦

១.៥.១ និយមន័យអេកូទេសចរណ៍ ........ ១៦

១.៥.២ គោលការណ៍នៃអេកូទេសចរណ៍ ........ ១៧

១.៥.៣ សារសំខាន់នៃអេកូទេសចរណ៍ ........ ១៨

១.៥.៤ ទិសដៅអេកូទេសចរណ៍ ........ ១៩

១.៦ សហគមន៍អេកូទេសចរណ៍ ........ ២០

១.៦.១ និយមន័យសហគមន៍ ........ ២០

១.៦.២ តួនាទីសហគមន៍ក្នុងអេកូទេសចរណ៍ ........ ២១

១.៦.៣ ផលប្រយោជន៍ និងផលប៉ះពាល់អវិជ្ជមានចំពោះសហគមន៍ ........ ២២

១.៧ សក្តានុពលនៃវិស័យទេសចរណ៍ ........ ២៣

១.៧.១ ធនធានទាក់ទាញ ........ ២៣

ក. ធនធានធម្មជាតិ ........ ២៣

ខ. ជំនឿ សាសនា ........ ២៣

គ. ធនធានកែច្នៃ ........ ២៣

១.៨ សម្បទាទេសចរណ៍ និងសេវាកម្មទេសចរណ៍ ........ ២៣
១.៨.១ សេវាកម្មស្នាក់នៅ ........ ២៣
១.៨.២ សេវាកម្មម្ហូបអាហារ ........ ២៤
១.៨.៣ សេវាកម្មដឹកជញ្ជូន ........ ២៤
១.៨.៤ សកម្មភាពកម្សាន្តផ្សេងៗ ........ ២៤
១.៩ ហេដ្ឋារចនាសម្ព័ន្ធដែលបម្រើអោយវិស័យទេសចរណ៍ ........ ២៤
១.៩.១ ការដឹកជញ្ជូន ........ ២៤
១.៩.២ ប្រព័ន្ធទឹកស្អាត ........ ២៥
១.៩.៣ ប្រព័ន្ធអគ្គិសនី ........ ២៥
១.៩.៤ ប្រព័ន្ធទូរគមនាគមន៍ ........ ២៥
១.៩.៥ ការគ្រប់គ្រងកាកសំណល់ ........ ២៥
១.១០ វិស័យសំខាន់ៗចូលរួមអភិវឌ្ឍន៍ ........ ២៥
១.១០.១ វិស័យឧស្សាហកម្ម និងសិប្បកម្ម ........ ២៥
១.១០.២ វិស័យកសិកម្ម ........ ២៦
១.១០.៣ វិស័យសុខាភិបាល ........ ២៦
១.១០.៤ វិស័យអប់រំ ........ ២៦
១.១១ ភាគីពាក់ព័ន្ធក្នុងវិស័យអេកូទេសចរណ៍ ........ ២៦
១.១១.១ អ្នកគ្រប់គ្រងតំបន់ ........ ២៧
១.១១.២ សហគមន៍មូលដ្ឋាន ........ ២៧
១.១១.៣ ឧស្សាហកម្មទេសចរណ៍ ........ ២៨
១.១១.៤ មន្ត្រីរដ្ឋាភិបាល ........ ២៨
១.១១.៥ អង្គការក្រៅរដ្ឋាភិបាល ........ ២៩
១.១១.៦ ភាគីគាំទ្រ ........ ៣០

ក. ម្ចាស់ជំនួយ ........ ៣០
ខ. ស្ថាប័នអប់រំ ........ ៣០
១.១១.៧ ទេសចរ ........ ៣១
១.១២ យុទ្ធសាស្ត្រការគ្រប់គ្រងអេកូទេសចរណ៍ ........ ៣១
១.១២.១ និយមន័យនៃការគ្រប់គ្រង ........ ៣១
១.១២.២ មុខងារនៃការគ្រប់គ្រង ........ ៣១
១.១២.៣ កត្តាជះឥទ្ធិពលលើការអភិវឌ្ឍទេសចរណ៍ ........ ៣២
១.១៣ ការអភិវឌ្ឍអេកូទេសចរណ៍ ........ ៣៣
១.១៣.១ និយមន័យការអភិវឌ្ឍ ........ ៣៣
១.១៣.២ ធាតុផ្សំនៃជោគជ័យអេកូទេសចរណ៍ ........ ៣៤
១.១៣.៣ និរន្តរភាពនៃអេកូទេសចរណ៍ ........ ៣៤
១.១៤ ទីផ្សារទេសចរណ៍ ........ ៣៤
១.១៤.១ និយមន័យទីផ្សារទេសចរណ៍ ........ ៣៤
១.១៤.២ មូលហេតុនៃការកំណត់ម៉ាឃីតទីងទេសចរណ៍ ........ ៣៦
១.១៤.៣ ធាតុផ្សំម៉ាឃីតទីងទេសចរណ៍ ........ ៣៦
១.១៤.៤ យុទ្ធសាស្ត្រទីផ្សារ ........ ៣៧

## ជំពូកទី២

## ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត

២.១ ស្ថានភាពទូទៅនៃខេត្តកោះកុង ........ ៣៩
២.១.១ ប្រវត្តិខេត្តកោះកុង ........ ៣៩
២.១.២ ទីតាំងភូមិសាស្ត្រខេត្តកោះកុង ........ ៣៩
២.១.៣ លក្ខណៈប្រជាសាស្ត្រ ........ ៤០
២.២ ស្ថានភាពទូទៅរបស់សហគមន៍អេកូទេសចរណ៍ជីផាត ........ ៤០

២.២.១ ប្រវត្តិ និងទីតាំងសហគមន៍........................................................................................................៤០
២.២.២ សណ្ឋានដីក្នុងសហគមន៍ ..............................................................................................................៤១
២.២.៣ អាកាសធាតុក្នុងសហគមន៍ ...........................................................................................................៤២
២.២.៤ លក្ខណៈប្រជាជនក្នុងសហគមន៍ ....................................................................................................៤២
២.៣ រចនាសម្ព័ន្ធ និងតួនាទីការងារនៅក្នុងសហគមន៍ .....................................................................................៤២
២.៣.១ រចនាសម្ព័ន្ធគ្រប់គ្រង ......................................................................................................................៤២
២.៣.២ តួនាទីការងារនៅក្នុងសហគមន៍.................................................................................................... ៤៣
២.៤ ធនធាន និងសេវាកម្មទាក់ទាញទេសចរនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត............................៤៦
២.៤.១ ធនធានធម្មជាតិ ..............................................................................................................................៤៦
២.៤.២ ធនធានមនុស្ស ............................................................................................................................. ៤៧
២.៤.៣ សេវាកម្មកំសាន្តផ្សេងៗ.....................................................................................................................៤៨
២.៤.៤ សេវាកម្ម និងសម្បទានទេសចរណ៍ ..............................................................................................៤៩
ក. សេវាកម្មម្ហូបអាហារ ..........................................................................................................................៤៩
ខ. សេវាកម្មស្នាក់នៅ...............................................................................................................................៥០
២.៥ ហេដ្ឋារចនាសម្ព័ន្ធដែលបម្រើអោយវិស័យទេសចរណ៍......................................................................៥០
ក. ការដឹកជញ្ជូន.......................................................................................................................................៥០
ខ. ប្រព័ន្ធគមនាគមន៍...............................................................................................................................៥២
គ. ប្រព័ន្ធទឹកស្អាត ..................................................................................................................................៥២
ឃ. ប្រព័ន្ធអគ្គិសនី ..................................................................................................................................៥២
ង. ប្រព័ន្ធទូរគមនាគមន៍..........................................................................................................................៥២
ច. ការគ្រប់គ្រងកាកសំណល់.....................................................................................................................៥២
២.៦ ទស្សនៈវិស័យ និងគោលបំណង ........................................................................................................ ៥៣
២.៦.១ ទស្សនៈវិស័យនៃការគ្រប់គ្រង.......................................................................................................... ៥៣

២.៦.២ គោលបំណង ........ ៥៣

២.៦.៣ ស្ថានភាពសេដ្ឋកិច្ចសង្គម ........ ៥៤

ក. ស្ថិតិទេសចរណ៍ ចំណូល និងចំណាយរបស់សហគមន៍អេកូទេសចរណ៍ជីផាត ........ ៥៤

ខ. សមិទ្ធផលសំខាន់ៗដែលសហគមន៍បានសម្រេចកន្លងមក ........ ៥៤

គ. បញ្ហាជួបប្រទះ ........ ៥៥

២.៧ វិស័យសំខាន់ៗដែលបម្រើអោយវិស័យទេសចរណ៍នៅក្នុងសហគមន៍ ........ ៥៦

ក. វិស័យសេដ្ឋកិច្ច ........ ៥៦

ខ. វិស័យអប់រំ ........ ៥៦

គ. វិស័យសុខាភិបាល ........ ៥៦

ឃ. វិស័យសិប្បកម្ម ........ ៥៦

ង. វិស័យកសិកម្ម ........ ៥៧

២.៨ ផ្នែកផ្សេងៗដែលជាភាគីចូលរួមពាក់ព័ន្ធ ........ ៥៧

២.៨.១ វិស័យឯកជន ........ ៥៧

២.៨.២ រាជរដ្ឋាភិបាល និងអាជ្ញាធរដែនដី ........ ៥៧

២.៨.៣ ការចូលរួមពីអង្គការ សហគមន៍ក្នុង និងក្រៅរដ្ឋាភិបាល ........ ៥៨

២.៨.៤ ការចូលរួមពីប្រជាជនក្នុងតំបន់ ........ ៥៨

២.៨.៥ ការចូលរួមពីទេសចរ (ក្នុងស្រុក និងបរទេស) ........ ៥៩

២.៩ ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ........ ៥៩

២.៩.១ ការវិភាគយុទ្ធសាស្ត្រគ្រប់គ្រងសហគមន៍ ........ ៥៩

២.៩.១.១ ការគ្រប់គ្រងសកម្មភាពទេសចរ និងការបំពេញចិត្តទេសចរ ........ ៥៩

២.៩.១.២ ការគ្រប់គ្រងបរិស្ថាន និងនិរន្តរភាពទេសចរណ៍ ........ ៦០

២.៩.១.៣ ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ........ ៦០

២.៩.១.៤ ការគ្រប់គ្រងវិបត្តិរបស់សហគមន៍ ........ ៦១

២.៩.១.៥ ទិសដៅប្រជាសាស្ត្រ និងយុទ្ធសាស្ត្រទាក់ទាញ...........................................................................៦១
២.៩.១.៦ ការធានាសុវត្ថិភាពនៅក្នុងសហគមន៍អេកូទេសចរណ៍...................................................................៦២
២.៩.២ ការដឹកនាំនៅក្នុងសហគមន៍...................................................................................................... ៦៣
២.៩.២.១ ការកសាងសមត្ថភាព និងពង្រឹងយន្តការសហគមន៍..................................................................... ៦៣
២.៩.២.២ យន្តការគាំទ្រ គ្រប់គ្រងហិរញ្ញវត្ថុ និងបែងចែកផលប្រយោជន៍........................................ ៦៣
២.៩.២.៣ ការអភិវឌ្ឍធនធានមនុស្សក្នុងសហគមន៍..................................................................................៦៤
២.៩.៣ ផែនការអភិវឌ្ឍន៍ផលិតផល និងសេវាកម្ម.......................................................................................៦៥
២.៩.៣.១ ការអភិវឌ្ឍផលិតផលយ៉ាងសំបូរបែប និងពង្រឹងគុណភាពសេវាកម្មរបស់សហគមន៍ ..........៦៥
២.៩.៣.២ ការបង្កើតផលិតផលថ្មីនៅក្នុងសហគមន៍ ..................................................................................៦៦
២.៩.៣.៣ ការសិក្សាទីផ្សារទេសចរណ៍របស់សហគមន៍ ............................................................................៦៦
២.៩.៣.៤ ការកំណត់ថ្លៃសេវាកម្ម...................................................................................................... ៦៧
២.៩.៤ ការអភិរក្ស និងគ្រប់គ្រងធនធានរបស់សហគមន៍...............................................................................៦៨
២.៩.៤.១ ការការពារ អភិរក្សធនធានធម្មជាតិ បរិស្ថាន ...........................................................................៦៨
២.៩.៤.២ ការការពារ អភិរក្សធនធានវប្បធម៌.........................................................................................៦៨
២.៩.៥ ការផ្សព្វផ្សាយរបស់សហគមន៍.....................................................................................................៦៩
២.៩.៥.១ យុទ្ធសាស្ត្រជម្រុញ ផ្សព្វផ្សាយទីផ្សារក្នុងស្រុក................................................................................៦៩
២.៩.៥.២ ការជំរុញការផ្សព្វផ្សាយទាក់ទាញទេសចរណ៍...............................................................................៦៩
ក. ការបង្កើតសកម្មភាពផ្សព្វផ្សាយទេសចរណ៍នានា..........................................................................៦៩
ខ. បង្កើតប្រព័ន្ធផ្សព្វផ្សាយតាមប្រព័ន្ធសារអេឡិចត្រូនិក និងគេហទំព័រ ....................................... ៧០
២.៩.៥.៣ ការបង្កើតព្រឹត្តិការណ៍ផ្សេងៗ................................................................................................ ៧០
ក. ការបោះជំរុំ ............................................................................................................... ៧០
ខ. ការដាំដើមឈើ ............................................................................................................ ៧១
គ. ពិព័រណ៌ទេសចរណ៍.......................................................................................................... ៧១

# ជំពូកទី៣

# ការវិភាគលើលទ្ធផលនៃបែកគំហើញ

៣.១ វិភាគលើកម្រងសំណួរ ........ ៧២

៣.១.១ វិភាគលើភេទទេសចរ ........ ៧២

៣.១.២ វិភាគលើអាយុទេសចរ ........ ៧២

៣.១.៣ វិភាគទៅលើភ្ញៀវធ្លាប់ទៅកំសាន្តនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត ........ ៧៣

៣.១.៤ វិភាគទៅលើភ្ញៀវដែលទៅសហគមន៍អេកូទេសចរណ៍ជីផាតជាមួយអ្នកណា ........ ៧៤

៣.១.៥ វិភាគលើមធ្យោបាយធ្វើដំណើររបស់ភ្ញៀវទេសចរណ៍ ........ ៧៤

៣.១.៦ វិភាគទៅលើគោលបំណងនៃភ្ញៀវដែលមកកំសាន្ត ........ ៧៥

៣.១.៧ វិភាគលើចំនួនដងដែលភ្ញៀវទេសចរណ៍បានមកកំសាន្ត ........ ៧៦

៣.១.៨ វិភាគទៅលើចំនួនថ្ងៃដែលភ្ញៀវមកកំសាន្ត ........ ៧៦

៣.១.៩ វិភាគទៅលើពេលវេលាដែលភ្ញៀវមកកំសាន្ត ........ ៧៧

៣.១.១០ វិភាគទៅលើលក្ខណៈភ្ញៀវមកកំសាន្តជាមួយ ........ ៧៨

៣.១.១១ វិភាគទៅលើស្ថានភាពផ្លូវធ្វើដំណើរទៅកាន់សហគមន៍ ........ ៧៩

៣.១.១២ វិភាគទៅលើប្រភេទនៃការទទួលទានអាហាររបស់ភ្ញៀវ ........ ៧៩

៣.១.១៣ វិភាគទៅលើការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ........ ៨០

៣.១.១៤ វិភាគទៅលើធនធានទាក់ទាញនៅក្នុងសហគមន៍ ........ ៨១

៣.១.១៥ វិភាគទៅលើការគ្រប់គ្រងកាកសំណល់នៅក្នុងសហគមន៍ ........ ៨១

៣.១.១៦ វិភាគទៅលើសន្តិសុខ និងសុវត្ថិភាពនៅក្នុងសហគមន៍ ........ ៨២

៣.១.១៧ វិភាគទៅលើបរិស្ថាននៅក្នុងសហគមន៍ ........ ៨៣

៣.១.១៨ វិភាគលើសេវាកម្មដែលផ្តល់ដោយប្រជាសហគមន៍ ........ ៨៣

៣.១.១៩ វិភាគទៅលើអាកប្បកិរិយារបស់ប្រជាសហគមន៍ ........ ៨៤

៣.១.២០ វិភាគលើការយល់ឃើញរបស់ភ្ញៀវចំពោះស្លាកសញ្ញាបង្ហាញទិសដៅមានគ្រប់គ្រាន់ឬទេ? ........ ៨៥

៣.១.២១ វិភាគទៅលើការពេញចិត្តរបស់ភ្ញៀវទេសចរណ៍........................................................................៨៥
៣.១.២២ វិភាគទៅលើការមិនពេញចិត្តរបស់ភ្ញៀវទេសចរណ៍..................................................................៨៦
៣.១.២៣ វិភាគទៅលើសេវាកម្ម ម្ហូបអាហារ និងភេសជ្ជៈឬសេវាកម្មផ្សេងៗទៀត..................................... ៨៧
៣.២ ការវិភាគលើភាពខ្លាំង ភាពខ្សោយ ឱកាស និងការគម្រាបកំហែង ....................................................៨៨
៣.២.១ ការវិភាគលើភាពខ្លាំង.............................................................................................................៨៩
៣.២.២ ការវិភាគលើភាពខ្សោយ .........................................................................................................៨៩
៣.២.៣ ឱកាស.......................................................................................................................................៩០
៣.២.៤ ការគម្រាមកំហែង.......................................................................................................................៩១

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន .............................................................................................................................. ៩៣
២. អនុសាសន៍.......................................................................................................................................៩៤
ឯកសារយោង
ឧបសម្ព័ន្ធ

# បញ្ជីតារាង

តារាងទី០១ រចនាសម្ព័ន្ធគ្រប់គ្រង........................................................................................ ៤៣
តារាងទី០២. ស្ថិតិទេសចរណ៍ ចំណូល និងចំណាយរបស់សហគមន៍អេកូទេសចរណ៍ជីផាត ...................៥៤

# អក្សរកាត់

គ.ម : គីឡូម៉ែត្រ

ស.ម : សង់ទីម៉ែត្រ

ម.ម :  មីលីម៉ែត្រ

UNWTO : United Nation World Tourism Organization

WTO : World Trade Organization

IUCN : International Union for Conservation of Nature

# បញ្ជីរូបភាពនៃក្រាភិច


ក្រាភិច៣.១ ដែលធ្វើការវិភាគលើភេទទេសចរ ...... ៧២

ក្រាភិច៣.២ ដែលធ្វើការវិភាគលើអាយុទេសចរ ...... ៧៣

ក្រាភិច៣.៣ ដែលធ្វើការវិភាគទៅលើភ្ញៀវធ្លាប់ទៅកំសាន្តនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត ...... ៧៣

ក្រាភិច៣.៤ ដែលធ្វើការវិភាគទៅលើភ្ញៀវដែលទៅសហគមន៍អេកូទេសចរណ៍ជីផាតជាមួយអ្នកណា ...... ៧៤

ក្រាភិច៣.៥ ដែលធ្វើការវិភាគលើមធ្យោបាយធ្វើដំណើររបស់ភ្ញៀវទេសចរណ៍ ...... ៧៤

ក្រាភិច៣.៦ ដែលធ្វើការវិភាគទៅលើគោលបំណងនៃភ្ញៀវដែលមកកំសាន្ត ...... ៧៥

ក្រាភិច៣.៧ ដែលធ្វើការវិភាគលើចំនួនដងដែលភ្ញៀវទេសចរណ៍បានមកកំសាន្ត ...... ៧៦

ក្រាភិច៣.៨ ដែលធ្វើការវិភាគទៅលើចំនួនថ្ងៃដែលភ្ញៀវមកកំសាន្ត ...... ៧៦

ក្រាភិច៣.៩ ដែលធ្វើការវិភាគទៅលើពេលវេលាដែលភ្ញៀវមកកំសាន្ត ...... ៧៧

ក្រាភិច៣.១០ ដែលធ្វើការវិភាគទៅលើលក្ខណៈភ្ញៀវមកកំសាន្តជាមួយ ...... ៧៨

ក្រាភិច៣.១១ ដែលធ្វើការវិភាគទៅលើស្ថានភាពផ្លូវធ្វើដំណើរទៅកាន់សហគមន៍ ...... ៧៩

ក្រាភិច៣.១២ ដែលធ្វើការវិភាគទៅលើប្រភេទនៃការទទួលទានអាហាររបស់ភ្ញៀវ ...... ៧៩

ក្រាភិច៣.១៣ ដែលធ្វើការវិភាគទៅលើការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ...... ៨០

ក្រាភិច៣.១៤ ដែលធ្វើការវិភាគទៅលើធនធានទាក់ទាញនៅក្នុងសហគមន៍ ...... ៨១

ក្រាភិច៣.១៥ ដែលធ្វើការវិភាគទៅលើការគ្រប់គ្រងកាកសំណល់នៅក្នុងសហគមន៍ ...... ៨១

ក្រាភិច៣.១៦ ដែលធ្វើការវិភាគទៅលើសន្តិសុខ និងសុវត្ថិភាពនៅក្នុងសហគមន៍ ...... ៨២

ក្រាភិច៣.១៧ ដែលធ្វើការវិភាគទៅលើបរិស្ថាននៅក្នុងសហគមន៍ ...... ៨៣

ក្រាភិច៣.១៨ ដែលធ្វើការវិភាគលើសេវាកម្មដែលផ្តល់ដោយប្រជាសហគមន៍ ...... ៨៤

ក្រាភិច៣.១៩ ដែលធ្វើការវិភាគទៅលើអាកប្បកិរិយារបស់ប្រជាសហគមន៍ ...... ៨៤

ក្រាភិច៣.២០ ដែលធ្វើការវិភាគលើការយល់ឃើញរបស់ភ្ញៀវចំពោះស្លាកសញ្ញាបង្ហាញទិសដៅមានគ្រប់គ្រាន់ឬនៅ? ...... ៨៥

ក្រាភិច៣.២១ ដែលធ្វើការវិភាគទៅលើការពេញចិត្តរបស់ភ្ញៀវទេសចរណ៍ ...... ៨៥

ក្រាភិច៣.២២ ដែលធ្វើការវិភាគទៅលើការមិនពេញចិត្តរបស់ភ្ញៀវទេសចរណ៍........................................៨៦
ក្រាភិច៣.២៣ ដែលធ្វើការវិភាគទៅលើសេវាកម្ម ម្ហូបអាហារ និងភេសជ្ជៈឬសេវាកម្មផ្សេងៗទៀត ............. ៨៧

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ "ក" កម្រងសំណួរ

ឧបសម្ព័ន្ធ "ខ" ឯកសាររបស់សហគមន៍អេកូទេសចរណ៍ជីផាត

ឧបសម្ព័ន្ធ "គ" រូបភាពរបស់សហគមន៍អេកូទេសចរណ៍ជីផាត

# សេចក្តីផ្តើម

## ១. លំនាំនៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសមួយដែលសម្បូរទៅដោយ អរិយធម៌ វប្បធម៌ សិល្បៈ ប្រពៃណី និងទំនៀមទម្លាប់ដ៏ល្អផូរផង់ជាច្រើន ដែលបានបន្សល់ទុកជាកេរ្តិ៍ដំណែលពីដូនតារៀងមក។ ហើយក៏ជាប្រទេសមួយដែលគេទទួលស្គាល់ថាជាដែនដីសុវណ្ណភូមិ និងជាដែនដីអច្ឆរិយៈនៃប្រទេសកម្ពុជាផងដែរ។ ដោយសារភាពសម្បូរបែបយ៉ាងនេះហើយ ទើបយើងសង្កេតឃើញ នាពេលបច្ចុប្បន្ន ប្រទេសយើងក្លាយជាប្រទេសមួយដែលសម្បូរទៅដោយរមណីយដ្ឋានជាច្រើនប្រភេទ មានទាំងរមណីយដ្ឋានបែបធម្មជាតិ រមណីយដ្ឋានបែបវប្បធម៌ ប្រវត្តិសាស្ត្ររមណីយដ្ឋានកែច្នៃជាដើម ដែលកំពុងតែទាក់ទាញទាំងភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិ អោយចូលមកកម្សាន្តជាហូរហែ។ លើសពីនេះទៅទៀត កម្ពុជា ជាប្រទេសមួយដែលមានការគ្រប់គ្រងយ៉ាងល្អប្រសើរ ជាហេតុនាំអោយមានការផ្លាស់ប្តូរ និងរីកចម្រើនគ្រប់ផ្នែកគ្រប់វិស័យ។ ចំពោះការគ្រប់គ្រងនេះផងដែរ ធ្វើអោយមានកំណើនសន្ទុះនៃការអភិវឌ្ឍយ៉ាងខ្លាំងក្លា ជាហេតុផលក្នុងការអន្ទងទាក់ទាញដល់វិនិយោគទុនទាំងក្នុងស្រុកនិងក្រៅស្រុកអោយចូលមកបណ្តាក់ទុនស្ទើរតែគ្រប់វិស័យទាំងអស់ ជាពិសេសវិស័យទេសចរណ៍។

វិស័យទេសចរណ៍ គឺជាវិស័យអាទិភាពមួយដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ មិនតែប៉ុណ្ណោះ វាបានដើរតួជា **"មាសបៃតង"** រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមរយៈការបង្កើត និងបង្កើនឱកាសការងារ បង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋដោយផ្ទាល់ និងដោយប្រយោលលើកកម្ពស់ជីវភាពរស់នៅ ជំរុញការនាំចេញនៅនឹងកន្លែង ជំរុញកំណើនសេដ្ឋកិច្ច បង្កើនចំណូលជាតិ ចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ ពិសេសចូលរួមដល់ការឆ្លើយតបនឹងបញ្ហាបំរែបំរួលអាកាសធាតុ ដែលជាបញ្ហាប្រឈមជាសាកល។ វិស័យទេសចរណ៍ ត្រូវបានទទួលស្គាល់ថាជា វិស័យដែលអាចរកប្រាក់ចំណូលបានច្រើនបន្ទាប់ពីវិស័យកសិកម្ម។ ភាពរីកចម្រើននៃវិស័យទេសចរណ៍នេះផងដែរ ក៏បាននាំអោយមានការកសាង ឬបង្កើតឡើងនូវសណ្ឋាគារ ផ្ទះសំណាក់ ផ្ទះស្នាក់ក្រុមហ៊ុនទេសចរណ៍ ក្រុមហ៊ុនអាកាសចរហេដ្ឋារចនាសម្ព័ន្ធមន្ទីរពេទ្យ សាលារៀន ប្រៃសណីយ៍ ក៏ដូចជាប្រព័ន្ធទូរគមនាគមន៍ផ្សេងៗជាច្រើនទៀត។ ក្រឡេកមើលពីសន្ទុះនៃការរីកចម្រើនវិញ យើងសង្កេតឃើញថា ខេត្តកោះកុងបាននឹងកំពុងបន្តព្យាយាម រៀបចំផែនការ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ដើម្បីទទួលបាននូវប្រសិទ្ធផល។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ការគ្រប់គ្រងមួយចំនួននៅមានការគំរាមកំហែង និងបញ្ហាប្រឈមជាបន្តបន្ទាប់នៅឡើយ។

ខេត្តកោះកុង ជាខេត្តមួយក្នុងចំណោមខេត្តជាប់សមុទ្រទាំងបួន និងស្ថិតនៅភាគនិរតីបំផុតនៃប្រទេសកម្ពុជា មានចំងាយ២៩០គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ធ្វើដំណើរតាមផ្លូវជាតិលេខ០៤ និងផ្លូវជាតិលេខ៤៨ ។ខេត្តនេះ ត្រូវបានបង្កើតឡើងក្នុងសម័យសង្គមរាស្ត្រនិយមនៃរជ្ជកាលព្រះបាទនរោត្តម សុរាម្រឹត។ ខេត្តកោះកុងមានព្រំប្រទល់ ខាងជើងជាប់នឹងខេត្តពោធិ៍សាត់ ខាងកើតជាប់នឹងខេត្តកំពង់ស្ពឺ កំពត ខាងត្បូងជាប់ព្រះសីហនុ និងខាងលិចជាប់នឹងឈូងសមុទ្រថៃ និងមួយផ្នែកនៃ ចង្វាតត្រាច(ខេត្តត្រាច)ប្រទេសថៃ។ ខេត្តនេះបែងចែកជាក្រុងចំនួន០១ គឺក្រុងខេមរភូមិន្ទ មាន០៣សង្កាត់ និងស្រុកចំនួន២៦ គឺស្រុកស្រែអំបិល ស្រុកកោះកុង ស្រុកថ្មបាំង បទុមសាគរ ស្រុកគីរីសាគរ និងស្រុកមណ្ឌលសីមា ស្មើនឹង២៦ឃុំ និង១១៩ភូមិ និងមានប្រជាពលរដ្ឋរស់

នៅសរុបចំនួន ១៣៧៣៩០នាក់ ដោយប្រកបរបរពាណិជ្ជកម្ម កម្មកររោងចក្រ នេសាទ និងធ្វើស្រែចំការ រកអនុផលព្រៃឈើ និងវារីវប្បកម្ម។ ខេត្តកោះកុងមានអំណោយផលល្អដោយមានព្រែកធម្មតាចំនួន០៥កន្លែង គឺព្រែកកោះប៉ោ ព្រែកតាតៃ ព្រែកត្រពាំងរូង ព្រែកអណ្តូងទឹក និងព្រែកស្រែអំបិល ដែលព្រែកទាំងនេះជាប្រឡាយដោះទឹកជំនន់ដ៏សំខាន់ ចាក់ចូលសមុទ្រ និងមានជីវចម្រុះគ្រប់ប្រភេទ នៅតាមដងព្រែក និងព្រៃកោងកាង ដែលជាជម្រកសត្វស្លាប និងដែនជម្រកមច្ឆាជាតិ ជីវចម្រុះ មានផ្សោតសមុទ្រ ព្រមទាំងសម្រស់ធម្មជាតិដ៏ស្រស់ត្រកាល និងស្រស់បំព្រងនៃព្រៃភ្នំ ទឹកធ្លាក់ ព្រែក ស្ទឹង ដងអូរយ៉ាងច្រើន។ លើសពីនេះទៅទៀត ខេត្តនេះមានសក្តានុពលយ៉ាងខ្លាំងទៅលើ វិស័យទេសចរណ៍ដែលសម្បូរទៅដោយធនធានធម្មជាតិ មានរមណីយដ្ឋានទេសចរណ៍ និងសហគមន៍អេកូទេសចរណ៍ជាច្រើនកន្លែងដែលជាគោលដៅទេសចរណ៍របស់ភ្ញៀវទេសចរណ៍។ បរិវេណរមណីយដ្ឋានទាំងអស់គ្រប់ដណ្តប់ទៅដោយតំបន់ភ្នំ ខ្ពង់រាប មានទេសភាពដ៏ស្រស់បំព្រងព័ទ្ធជុំវិញទៅដោយទឹក ព្រៃឈើយ៉ាងខៀវស្រងាត់ដែលមានដុះជាជួរៗហូរហែរ និងមានហ្វូងបក្សាបក្សីហោះហើរយ៉ាងត្រសង ហាក់បីធម្មជាតិកំពុងមានក្តីសុខ ដែលបង្កបរិយាកាសកាន់តែអស្ចារ្យ នៅពេលដែលពន្លឺព្រះសូរិយារៀបអស្តង្គត និងពន្លឺព្រះអាទិត្យចាប់រះឡើង និងមានតំបន់ឆ្នេរល្អសស្អាតយ៉ាងវែងអន្លាយ គួបផ្សំនឹងកោះតូច កោះធំជាច្រើនផ្សេងទៀតដែលសុទ្ធសឹងជាមូលហេតុ ធ្វើអោយតំបន់សហគមន៍អេកូទេសចរណ៍ ក៏ដូចជារមណីយដ្ឋានដទៃទៀតទាំងអស់នៅក្នុងខេត្តកោះកុង ទទួលបានការសាទរ និងមកទស្សនាកំសាន្តជាច្រើនកុះករពីមួយឆ្នាំទៅមួយឆ្នាំ។ ថ្វីត្បិត ខេត្តមួយនេះ មានធនធាន និងសម្បទាទេសចរណ៍យ៉ាងណាក្តី ក៏ប្រភពចំណូលនៅមានកម្រិតនៅឡើយ តែក៏វាបានជួយជម្រុញ និងកាត់បន្ថយភាពក្រីក្រ និងបង្កើត ឱកាសការងារដល់ប្រជាជនក្នុងមូលដ្ឋានផងដែរ។

ដោយសង្កេតមើលឃើញពីសក្តានុពលនៃវិស័យទេសចរណ៍ក្នុងខេត្តកោះកុងមានការរីកចម្រើន ជាពិសេសការគ្រប់គ្រងបានយ៉ាងល្អប្រសើររបស់សហគមន៍អេកូទេសចរណ៍ និងដើម្បីស្វែងយល់អោយកាន់តែស៊ីជម្រៅ ព្រមទាំងជាស្ពានផ្សារភ្ជាប់រវាងទ្រឹស្តី និងការអនុវត្តទើបយើងខ្ញុំបានសម្រេចចិត្តលើកយកប្រធានបទ"**ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ខេត្តកោះកុង**"។ ដើម្បីធ្វើការសិក្សាស្រាវជ្រាវទទួលបាននូវប្រសិទ្ធិភាព សុក្រិតភាព និងមានប្រយោជន៍ខ្ពស់នោះ ក្រុមសិក្សាស្រាវជ្រាវយើងខ្ញុំបានអនុវត្តន៍តាមគោលការណ៍ វិធីសាស្រ្តនៃការស្រាវជ្រាវដែលមានដំណើរការ និងសកម្មភាពបន្តបន្ទាប់ដូចខាងក្រោម។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជីផាត គឺជាសហគមន៍អេកូទេសចរណ៍មួយប្រកបដោយសក្តានុពល ដែលបម្រើអោយវិស័យទេសចរណ៍ក្នុងខេត្តកោះកុង។ ដូច្នេះដើម្បីឲ្យមានភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ ក្រុមសិក្សាស្រាវជ្រាវបានចោទជាសំណួរទៅលើសហគមន៍អេកូទេសចរណ៍ជីផាត ដើម្បីធ្វើការសិក្សា និងស្វែងយល់ពីរបៀបនៃការគ្រប់គ្រង។

តើសហគមន៍អេកូទេសចរណ៍ជីផាត មានការគ្រប់គ្រងយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងអ្វីដែលប្រធានបទបានលើកឡើងខាងលើនេះ និងដើម្បីអោយការសិក្សាស្រាវជ្រាវមានដំណើរការទៅបានត្រឹមត្រូវតាមគោលដៅ រួមព្រមទាំងមានភាពរលូនច្បាស់លាស់ដែលអាចទុកជាប្រយោជន៍សម្រាប់ការប្រើប្រាស់នៅពេលក្រោយ ជាពិសេសដល់អ្នកជំនាន់ក្រោយដែលមានគោលបំណងចង់បម្រើការក្នុងវិស័យទេសចរណ៍ ក៏ដូចជាប្រយោជន៍ផ្សេងៗដទៃទៀតនោះ ព្រមទាំងបង្កើតនូវទស្សនៈវិស័យថ្មីៗដែលជាគន្លឹះសំខាន់នានាសម្រាប់សហគមន៍អេកូទេសចរណ៍ជីផាត។ ក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវលើគោលដៅសំខាន់ៗ ដែលផ្តោតទៅលើ៖

- ស្ថានភាពទូទៅរបស់សហគមន៍អេកូទេសចរណ៍ជីផាត ធនធាន និងសេវាកម្មទេសចរណ៍ក្នុងសហគមន៍អេកូទេសចរណ៍ជីផាត
- យុទ្ធសាស្ត្រ និងផែនការនៃការគ្រប់គ្រងរបស់សហគមន៍អេកូទេសចរណ៍ជីផាត
- ការផ្សព្វផ្សាយអំពីសក្តានុពលទេសចរណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត
- ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគម្រាមកំហែងនៃសហគមន៍អេកូទេសចរណ៍ជីផាត

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សានេះត្រូវបានលើកឡើងយ៉ាងច្បាស់លាស់ ដោយផ្តោតទៅលើការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាតតែប៉ុណ្ណោះ។ ចំពោះដែនកំណត់នៃការស្រាវជ្រាវគឺផ្តោតទាំងស្រុងទៅលើទិន្នន័យដែលប្រមូលបានពីការបំពេញកម្រងសំណួរដោយផ្ទាល់មាត់ ជាមួយប្រធានមន្ទីរទេសចរណ៍ ប្រធានសហគមន៍ និងម្ចាស់ផ្ទះស្នាក់ និងតាមរយៈការសង្កេតដោយផ្ទាល់ពីសំណាក់ទេសចរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សម្រាប់ការសិក្សា ប្រធានបទខាងលើដែលក្រុមអ្នកសិក្សាស្រាវជ្រាវបានលើកយកមកធ្វើការសិក្សាលទ្ធផលរបស់វានឹងផ្តល់សារប្រយោជន៍សំខាន់ៗ ទៅលើគោលដៅចំនួន ៤ ក្រុមដូចខាងក្រោម៖

### ៥.១ ចំពោះសង្គម

ការសិក្សានេះនឹងជួយលើកស្ទួយការយល់ដឹងរបស់ប្រជាជន និងភាគីដែលពាក់ព័ន្ធពីសារៈប្រយោជន៍នៃវិស័យទេសចរណ៍ ជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនក្នុងវិស័យទេសចរណ៍តាមរយៈការប្រើប្រាស់កម្លាំងពលកម្មក្នុងតំបន់ និងជួយគាំទ្រផលិតផលក្នុងស្រុកពីសំណាក់ទេសចរ និងមានចំណែកចូលរួមជួយក្នុងការថែរក្សាការពារបរិស្ថានអភិរក្សធនធានវប្បធម៌ និងប្រពៃណីក្នុងតំបន់អោយកាន់តែមាននិរន្តរភាព។

### ៥.២ ចំពោះអង្គភាព(គ្រប់គ្រងតំបន់ផ្ទាល់)

ការសិក្សានេះ នឹងលាតត្រដាងពីចំណុចខ្វះខាតលើការគ្រប់គ្រងនៅក្នុងតំបន់ទាក់ទាញទេសចរណ៍មួយនេះហើយ នឹងរកអោយឃើញនូវដំណោះស្រាយដ៏ល្អមួយសម្រាប់អង្គភាពនិងជួយផ្សព្វផ្សាយពីតំបន់ទាក់ទាញទេសចរណ៍ដ៏មានសក្តានុពលមួយនេះអោយប្រជាជនកម្ពុជាគាត់បានដឹងបានស្គាល់ហើយអាចសម្រេចចិត្តចូលមកទស្សនាតំបន់នេះ។ ការសិក្សានេះក៏នឹងរកអោយឃើញនូវបញ្ហាដែលកំពុងប្រឈមនាពេលបច្ចុប្បន្ន

និងធ្វើយ៉ាងណារកដំណោះស្រាយដើម្បីទទួលបាននូវចំនួនភ្ញៀវទេសចរណ៍ចូលមកទស្សនាបានកាន់តែច្រើនឡើងថែមទៀត។

### ៥.៣ ចំពោះក្រុមអ្នកស្រាវជ្រាវផ្ទាល់

ការសិក្សាស្រាវជ្រាវនេះនឹងចូលរួមក្នុងការរឹតចំណងមិត្តភាពកាន់តែជិតស្និតជាមួយសមាជិកក្រុមផ្ទាល់ ក៏ដូចជាប្រជាជន អ្នកគ្រប់គ្រងតំបន់ទេសចរណ៍និងសាស្ត្រាចារ្យដឹកនាំសារណាផងដែរ។ សមាជិកនីមួយៗបានយល់ដឹងពីសារៈប្រយោជន៍របស់ទេសចរក្នុងស្រុកកាន់តែប្រសើរឡើង ព្រោះពួកគាត់ជាកម្លាំងចលករមួយដ៏សំខាន់ក្នុងការរុញច្រានសេដ្ឋកិច្ចប្រជាជននិងសេដ្ឋកិច្ចជាតិអោយមានសកម្មភាពខ្លាំងឡើយ។ ពិសេសអ្នកស្រាវជ្រាវកាន់តែយល់ដឹងបានច្បាស់ពីតម្រូវការរបស់ទេសចរនូវអ្វីមួយដែលពួកគាត់ចង់បាន អាចអោយសិក្សាស៊ីជម្រៅជាមួយទ្រឹស្តីនៅសាលាដើម្បីផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែងដោយបានយល់ច្បាស់ពីស្ថានភាពនៃការគ្រប់គ្រងទូទៅនៅក្នុងតំបន់សហគមន៍ទេសចរណ៍ជីផាត នឹងអាចធ្វើអោយវិវត្តន៍ខ្លួនទៅជាអ្នករៀបចំគម្រោងធ្វើអាជីវកម្មម្នាក់ប្រសើរជាងមុនព្រមទាំងអាចកែប្រែខ្លួនជាបុគ្គលិកនៅក្នុងតំបន់មួយនេះនាថ្ងៃអនាគតផងដែរ។

### ៥.៤ ចំពោះមិត្តអ្នកអាន

សៀវភៅនេះអាចនឹងក្លាយទៅជាឯកសារមួយសំខាន់សម្រាប់និស្សិត ឬសិស្សានុសិស្សជំនាន់ក្រោយសិក្សាបន្តដើម្បីបង្កើននូវចំណេះដឹងអោយបានទូលំទូលាយក្នុងការសិក្សាដើម្បីផ្តល់អោយអ្នកអានមាននូវគំនិតនិងទស្សនៈថ្មីៗបានទូលំទូលាយសម្រាប់ជាចំណេះដឹងបន្ថែមទាក់ទងទៅនឹងការគ្រប់គ្រងភាពទាក់ទាញទេសចរណ៍។ ឯកសារនេះផងដែរ វាក៏អាចជាមគ្គុទេសក៏មួយក្នុងការជួយបង្ហាញផ្លូវដល់អ្នកវិនិយោគដែលមានបំណងចង់រកស៊ីក្នុងវិស័យទេសចរណ៍នៅតំបន់ដែលមិនសូវទាន់មានការអភិវឌ្ឍនេះផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ក. ប្រភពទិន្នន័យ

ទិន្នន័យដែលយកមកស្រាវជ្រាវនេះគឺបានដកស្រង់ចេញពី បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បណ្ណាល័យសាកលវិទ្យាល័យន័រតុន មន្ទីរទេសចរណ៍ក្រុងភ្នំពេញ មន្ទីរទេសចរណ៍ខេត្តកោះកុង ការិយាល័យផ្ទុកឯកសារសហគមន៍អេកូទេសចរណ៍ជីផាត ប្រព័ន្ធទំនាក់ទំនងសង្គម និងប្រព័ន្ធអ៊ីនធើណេត។

### ខ. ការប្រមូលទិន្នន័យ

ក្នុងការស្រាវជ្រាវនេះផងដែរយើងខ្ញុំ បានប្រមូលទិន្នន័យពីការសម្ភាសន៍ផ្ទាល់ជាមួយនឹងប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុង និងប្រធានសហគមន៍អេកូទេសចរណ៍ជីផាតជាមួយ និងឯកសារនានាដែលយើងខ្ញុំទទួលបានព្រមទាំងការធ្វើបទសម្ភាសន៍មួយចំនួនជាមួយភ្ញៀវទេសចរណ៍ និងប្រជាជនដែលរស់នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត។

### គ. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ គឺធ្វើឡើងដោយផ្អែកលើភស្តុតាង និងស្ថានភាពដែលមានជាក់ស្តែងក្នុងឯកសារក៏ដូចជាទិដ្ឋភាពពិតៗជាក់ស្តែង។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះមានរចនាសម្ព័ន្ធដូចតទៅ៖

**សេចក្តីផ្តើម:** ដែលក្នុងនោះជាអត្ថបទបង្ហាញឲ្យស្គាល់ពីប្រធានបទ ចំណោទបញ្ហានៃប្រធានបទ គោលបំណងនៃការជ្រើសរើសយកប្រធានបទ ទំហំនិងដែនកំណត់នៃប្រធានបទ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្រ្តនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ

**ជំពូកទី ១** : រំលឹកទ្រឹស្តីដែលពាក់ព័ន្ធ

**ជំពូកទី ២** : ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត

**ជំពូកទី ៣** : ការវិភាគលើលទ្ធផលនៃរបកគំហើញ

**ជំពូកទី ៤** : សេចក្តីសន្និដ្ឋាន និងអនុសាសន៍ នេះជាផ្នែកធ្វើការសរុបទិន្នន័យទាំងអស់ដែលទទួលបាន និងធ្វើការផ្តល់ជាយោបល់ ការយល់ឃើញ ឬជាដំបូន្មានដើម្បីធ្វើការសរុបសេចក្តី។

**ឯកសារពិគ្រោះ :** នេះជាទំព័របង្ហាញពីឯកសារ និងប្រភពឯកសារដែលបានលើកយកមកស្រាវជ្រាវក្នុងសារណានេះ។

**ឧបសម្ព័ន្ធ** : ទាក់ទងនឹងលិខិតអនុញ្ញាតិពីមូលដ្ឋានណាមួយក្នុងការសុំចុះស្រាវជ្រាវ សម្ភាសន៍ ផ្តិតកម្រងរូបភាព ទទួលយកឯកសារពាក់ព័ន្ធនានាដោយស្របច្បាប់។

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១ ប្រវត្តិដើមនៃទេសចរណ៍

ពាក្យជាទេសចរណ៍ មានន័យទូលំទូលាយណាស់ហើយ និយមន័យវាត្រូវបានជួបប្រទះផ្សេងគ្នាជាច្រើននៅក្នុងប្រភពឯកសារ។ ពាក្យថា ទេសចរណ៍បានកើតឡើងពីភាសាអង់គ្លេស Tourism(Tour) មានន័យថាការដើរកំសាន្តតាមរយៈដំណើរថ្មើរជើង រឺយានដ្ឋជំនិះណាមួយហើយវិលមករក ទីកន្លែងដែលចេញដំណើរវិញក្រោយពេលបញ្ចប់សកម្មភាពនោះ។មានការកំណត់ផ្សេងទៀតថា ទេសចរណ៍ជាការធ្វើដំណើរ រឺជាប្រភេទចលនារបស់ប្រជាពលរដ្ឋ ដែលមិនទាក់ទងដល់ការផ្លាស់ប្តូរទីកន្លែងរស់នៅនិងការងារ។ ដោយមានន័យជាធ្វើដំណើរក្នុងបំណងសម្រាកលំហែកាយ និងកម្សាន្ត។ ទាំងអស់នេះបានបង្ហាញអោយឃើញថា ទេសចរណ៍កើតឡើងពីការធ្វើដំណើរនឹងដោយសារការធ្វើដំណើរនេះមានការចំណាយរយៈ ពេលចាប់ពីមួយយប់ឡើងទៅនាំអោយមានសកម្មភាពថ្មីមួយទៀតគឺ រកទីស្នាក់នៅ ទទួលទាន កម្សាន្តសប្បាយ និងលំហែ។ ការធ្វើដំណើរទេសចរណ៍ បដិសណ្ឋារកិច្ច(Travel, Tourism and Hospitality) និយមន័យបី ដែលមានទំនាក់ទំនងនឹងគ្នាដោយមិនអាចបំបែកបាននិងដើម្បីអោយជីវិតរស់នៅរបស់មនុស្សមានភាពស្រស់ថ្លា ដែលពួកគេប្រាថ្នាចង់បានដោយខានមិនបាន។ ការកើនឡើងនៃការធ្វើដំណើរ មិនអាចត្រូវបានកំណត់ច្បាស់លាស់ទេ។ ការសិក្សាបង្ហាញថា ការកើតឡើងនេះចាប់ផ្តើមឡើងតាំងពីយុគសម័យគឺនៅពេលដែលមនុស្សចាប់មានកំណើតលើផែនដីបន្ទាប់ពីបំប្លែងពីសត្វក្នុងរយៈពេលដ៏យូរអង្វែង ដែលមនុស្សបានវិវត្តន៍ពីសត្វស្វាដែលមានការលំបាកយ៉ាងខ្លាំងក្នុងការប្រឆាំងនឹងធម្មជាតិ ដើម្បីជីវិតរស់នៅនិងការកកើតនៃអរិយធម៌ក្នុងសង្គមរបស់មនុស្ស។ ការស្គាល់និងការយល់ដឹងពីបរិស្ថានជុំវិញ បានចាប់ផ្តើមកកើត ឡើងនៅពេលដែលមនុស្សដំបូងបានធ្វើដំណើរចាកចេញពីតំបន់មួយទៅតំបន់មួយ ដើម្បីស្វែងរកអាហារចិញ្ចឹមជីវិត។ ជាមួយគ្នានឹងការកើតឡើងនូវសត្វពាហនៈ និងសត្វព្រៃផ្សេងៗ មនុស្សមានការចេះចង់ដឹងអំពីតំបន់ដែលពួកគេអាចរកអាហារសម្រាប់សត្វទាំងនេះ និងដើម្បីស្វែងរកតំបន់វាលស្មៅដែលជាអាហារសត្វពាហនៈទាំងនេះ ពួកគេត្រូវធ្វើដំណើរក្នុងរយៈចម្ងាយមួយហើយចំណាំផ្លូវនេះទុក។ ជាមួយនឹងការរីកដុះដាលការធ្វើចម្ការដំណាំក៏មានការរីកដុះដាលនូវសណ្តានចិត្តស្វែងរកតំបន់ណាមួយថ្មីទៀតសម្រាប់ពង្រីកការដាំដុះ។ ចំណុចទាំងនេះទាមទារអោយមានការប្រើប្រាស់ការធ្វើដំណើររយៈពេលវែង ដើម្បីស្វែងរកប្រភេទដីដែលគេចង់បាន។ ការស្វែងរកចំណីអាហារសម្រាប់ចិញ្ចឹមជីវិតរបស់មនុស្ស បានតម្រូវអោយមនុស្សធ្វើដំណើរក្នុងរយៈចម្ងាយកាន់តែឆ្ងាយឡើងៗ និងដើម្បីស្វែងយល់ច្បាស់លាស់ពីទីកន្លែងដែលពួកគេត្រូវការនេះ។ តាមការស្រាវជ្រាវរបស់ទស្សនៈវិទូ និងប្រវត្តិវិទូបានបង្ហាញថា ចាប់តាំងពីមានកំណើតឡើងមកមនុស្សលោកបានស្នាក់និងរស់នៅក្នុងតំបន់ណាមួយតែមួយរយៈពេលប៉ុណ្ណោះព្រោះថាគេត្រូវការរកតំបន់ផ្សេងៗទៀតដែលអាចរស់នៅបានមានចំណីអាហារ អាចធ្វើចម្ការ រឺដាំដំណាំ។ល។ ទាំងអស់នេះបានតម្រូវអោយគេស្វែងរក និងធ្វើដំណើរដើម្បីបន្តការរស់រានមានជីវិតបាន។ ជាមួយនឹងការកកើតឡើងនូវកុលសម្ព័ន្ធផ្សេងៗ ការទំនាក់ទំនងរវាងពួកគេបានធ្វើអោយមានការបង្កើតឡើងនូវផ្លូវដំណើរ សម្រាប់ធ្វើការប្រាស្រ័យទាក់ទង រវាងតំបន់មួយទៅតំបន់មួយ រឺពីភូមិមួយទៅភូមិមួយ និងពីតំបន់ដែលមានកុលសម្ព័ន្ធមួយរស់នៅ ទៅតំបន់ដែលមាន

កុលសម្ព័ន្ធផ្សេងទៀតរស់នៅ។ ផ្លូវដំណើរដែលជ្រើសរើស និងប្រើប្រាស់សំខាន់ៗក្នុងរយៈកាលនោះ គឺមានការធ្វើដំណើរតាមផ្លូវគោក និងផ្លូវទឹក ដោយមធ្យោបាយពិសេសណាមួយតាមរយៈផ្លូវទាំងអស់នេះហើយ ដែលក្រោយមក( សម័យថ្មី) មានការសាងសង់ផ្លូវជាតិតូចធំ ផ្លូវរថភ្លើង។ល។ ក្នុងចំណោមអ្នកដែលធ្វើដំណើរ (Traveler ) មុនគេបង្អស់ក្រៅអ្វីដែលយើងបាននិយាយខាងលើគឺ មានអ្នកជំនួញនិងអ្នកផ្សព្វផ្សាយសាសនា។ ប្រវត្តិវិទូជនជាតិក្រិកឈ្មោះ Gerodot ចាប់តាំងពីសតវត្សទី៥ មុនគ្រិស្តសករាជគាត់បានចងក្រងជាឯកសារអំពីការធ្វើដំណើររបស់គាត់ និងអ្វីថ្មីៗ ដែលគាត់បានឃើញនិងជួបប្រទះក្នុងសៀវភៅមួយឈ្មោះថា“ទាំងអស់អំពីមហាសមុទ្រ”។

### **១.១.១ យុគសម័យចក្រភព**

ការកំណត់អោយច្បាស់លាស់អំពីការ ដែលទេសចរណ៍បានវិវត្តន៍ពីភាពធម្មតា ទៅរកភាពសម្បូរបែបនោះហាក់បីដូចជាមានភាពពិបាកបន្តិច។ តែទោះបីជាយ៉ាងណាក៏ដោយវិស័យទេសចរណ៍ ត្រូវបានគេស្មានថាមានការរីកចម្រើននៅក្នុងសម័យចក្រភព បន្តនូវការរីកចម្រើនចាប់ពីជនជាតិអេហ្សីប ជនជាតិក្រិច ហើយបន្តរហូតមកដល់ចក្រភពរ៉ូមាំង។ នៅកំឡុងពេលនោះមនុស្សបានធ្វើដំណើរយ៉ាងសន្ធឹកសន្ធាប់ក្នុងគោលបំណងផ្សេងៗគ្នាតាមរយៈការងារផ្លូវការធ្វើជំនួញ ការសិក្សាស្រាវជ្រាវ និងសកម្មភាពសាសនាដោយកាតព្វកិច្ច និងមិនមែនកាតព្វកិច្ច។ រាជាណាចក្រអេហ្សីប(៤៨៥០ទៅ៧១៥មុនគ.ស )ជាអារ្យធម៌មួយល្បីល្បាញ និងមានអំណាចគ្រប់គ្រង ក្តោបក្តាប់ នៅជុំវិញមជ្ឈឹមតំបន់។ ការធ្វើទេសចរណ៍ទៅតំបន់នេះអាចផ្តល់នូវលក្ខណៈងាយស្រួលជាពិសេសដោយសារ តែគេអាចធ្វើដំណើរបានតាម ទន្លេនីល ដែលហូរឆ្ពោះទៅទិសខាងជើង ប៉ុន្តែទទួលនូវចរន្តខ្យល់បក់បញ្ច្រាស ជាទៀងទាត់ឆ្ពោះទៅទិសខាងត្បូង។ នៅពេលនោះការធ្វើដំណើរតាផ្លូវទឹកពុំត្រូវការប្រើប្រាស់ចង្វាទៀតទេ គឺអាចធ្វើដំណើរបានយ៉ាងរហ័សពីទិសខាងត្បូងទៅទិសខាងជើង ហើយត្រឡប់មកវិញដោយប្រើក្តោង។ ចក្រភពក្រិច(៩០០ទៅ២០០មុនគ.ស) បានជំរុញអោយមានការប្រើប្រាស់ភាសារបស់ខ្លួន នៅលើតំបន់ជាច្រើននៃអនុតំបន់មេឌីទែរ៉ាណេ លើសពីនេះទៅទៀតរូបិយប័ណ្ណដែលអាចប្តូរជាទូទៅបាន។ រដ្ឋដែលស្ថិតក្នុងចក្រភពក្រិចបានក្លាយទៅជាទីកន្លែងមួយដែលមានការទាក់ទាញ ដោយសារការផ្តល់អោយអ្នកទេសចរណ៍ នូវការទទួលបាននូវភាពរីករាយជាច្រើន ក្នុងខណៈពេលដែលពួកគេចាកចេញពីផ្ទះ។ ការទិញទំនិញការបរិភោគអាហារនិងភេសជ្ជៈ ការទស្សនាកីឡាពិសេសៗ ការតាំងពិព័រណ៍ផ្សេងៗគ្រាន់តែជាសកម្មភាពមួយចំនួនក្នុងសកម្មភាព ជាច្រើនទៀត នៃវិស័យទេសចរណ៍ដែលបានកកើត និងវិវត្តន៍ទៅមុខជាប្រចាំ។ ការរីកចម្រើននៃចក្រភពរ៉ូមាំងនៅឆ្នាំ (៥០០មុនគ.ស ដល់៣០០នៃគ.ស) បានជួយពង្រីកឱកាសសម្រាប់ការធ្វើដំណើរជាទេសចរណ៍នៃប្រជាជនទាំងអ្នកមានកម្រិតជីវភាពមធ្យម និងអ្នកមានកម្រិតខ្ពស់។ ផ្លូវទឹក ផ្លូវគោកដែលល្អបានបង្កលក្ខណៈងាយស្រួលសម្រាប់ការធ្វើដំណើរជាទេសចរណ៍។ នៅឯកន្លែងស្នាក់នៅ និងនៅតាមស្ថានីយ៍ គេក៏អាចជួលសេះសម្រាប់ជិះបាន។ គេអាចធ្វើដំណើរបានរហូតដល់ ១២៥ ម៉ាយល៍ ក្នុងមួយថ្ងៃដោយជិះសេះ ហើយថែមទាំងអាចរកកន្លែងស្នាក់នៅ និងទទួលទានបានដោយងាយស្រួល។

### **១.១.២ យុគសម័យកណ្តាល និងការកកើតថ្មី**

ការធ្វើដំណើរទេសចរណ៍ទើបតែបានលេចឡើងនៅក្នុងកំឡុងសម័យកាលកណ្តាល(សតវត្សទី០៥ទី១៤) នៅខណៈពេលដែលការគ្រប់គ្រងរបស់ចក្រភពរ៉ូមត្រូវបានបែកបាក់។ ការធ្វើដំណើរបានក្លាយជាគ្រោះថ្នាក់

និងមិនទៀងទាត់។ ប្រព័ន្ធសក្តិភូមិដែលបានមកជួយច្បាប់របស់រ៉ូម បាននាំមកនូវរដ្ឋស្វ័យ័តផ្សេងៗជាច្រើន។ ការបរាជ័យនៃការបាត់ និងត្រួតពិនិត្យរបស់សង្គមមុនបានធ្វើអោយមានការបំបែកប្រព័ន្ធដឹកជញ្ជូន រូបិយប័ណ្ណ និងភាសា។ ទាំងអស់នេះបានធ្វើអោយការធ្វើដំណើរជួបប្រទះនូវការលំបាកនិងពេលខ្លះ ពោពេញដោយបទពិសោធន៍ដ៏សែនគ្រោះថ្នាក់ទៀតផង។ ក្តីប៉ងប្រាថ្នាក្នុងការសិក្សា និងយកបទពិសោធន៍ពីវប្បធម៌ដទៃបានធ្វើអោយកាន់តែប្រសើរឡើងនូវអត្ថប្រយោជន៍ខាងអប់រំ និងចំណេះដឹងដែលទទួលបានពីការធ្វើដំណើរ និងនាំឆ្ពោះទៅរកយុគសម័យទេសចរណ៍ទំនើប។

**១.១.៣ យុគសម័យដើមដំបូងនៃការរីកចំរើនវិស័យទេសចរណ៍**

សម័យកាលដំបូងនៃការរីកចម្រើនរបស់វិស័យទេសចរណ៍ ត្រូវបានគេស្គាល់ថានៅឆ្នាំ ១៦១៣ទៅ ១៧៨៥។ វាជាសម័យកាលមួយដែលសកម្មភាពទេសចរណ៍ និងការធ្វើដំណើរស្ថិតក្នុងស្ថានភាពប្រណិតៗ មានដើមកំណើតនៅប្រទេសអង់គ្លេស និងបានបង្កើនល្បឿនយ៉ាងឆាប់រហ័សហើយបានក្លាយទៅជាគំរូនៃការអនុវត្តន៍មួយយ៉ាងទំនើបក្នុងចំណោមប្រទេសនានា ដែលមានពេលវេលា និងថវិកាគ្រប់គ្រាន់។ បទពិសោធន៍នៃការធ្វើដំណើរ និងចំណេះដឹងផ្សេងៗ ដែលផ្តល់អោយពីការធ្វើដំណើរបានក្លាយទៅជានិមិត្តរូបតំណាងចុងក្រោយមួយ នៅក្នុងបទពិសោធន៍សង្គម និងការអប់រំ។ អ្នកចូលរួមក្នុងយុគសម័យនោះ បានធ្វើដំណើរចាកចេញពីទ្វីបអឺរ៉ុប ដើម្បីស្វែងយល់ពីបទពិសោធន៍ វប្បធម៌ អារ្យធម៌ក្នុងពិភពលោក ហើយទទួលយកចំណេះដឹងខាងផ្នែកសិល្បៈ និងវិទ្យាសាស្ត្រពីប្រទេសដែលពួកគេបានទៅទស្សនានោះ។ ការធ្វើដំណើររបស់ពួកគេបានទៅដល់ទីតាំងផ្សេងៗដូចជា ៖ ប្រទេសបារាំង ប្រទេសស្វីស ប្រទេសអ៊ីតាលី និងប្រទេសអាឡឺម៉ង់ ហើយតែងតែចំណាយពេលវេលាច្រើនទៀតផង។

**១.១.៤ យុគសម័យចលភាព**

ការរីកចម្រើនខាងសេដ្ឋកិច្ច និងការនាំមកនូវឱកាសសម្រាប់សម្រាកដូចជា ការផ្តល់អោយនូវអត្ថប្រយោជន៍ ពីការធ្វើដំណើរដែលបណ្តាលអោយទេសចរមានលទ្ធភាពទទួលយកការបង្ហាញពីសម័យកាលថ្មីៗនៃប្រវត្តិវិស័យទេសចរណ៍។ មនុស្សលោកបន្ទាប់ពីការងារប្រចាំថ្ងៃនៃជីវិតក្នុងកសិដ្ឋានរបស់ខ្លួនតែងតែមានការនឿយហត់ និងតែងតែបានចាប់ផ្តើមរិះរកវិធីថ្មីៗ ដើម្បីចំណាយពេលខ្លះក្នុងការលំហែ កម្សាន្តដោយទៅរកស៊ីនៅទីឆ្ងាយៗពីកន្លែងធ្វើការក្នុងហាង និងរោងចក្ររបស់ពួកគេ។ សម័យកាលចលភាព(ពីឆ្នាំ១៨០០ ដល់ឆ្នាំ១៩៤៤) បានបង្ហាញអោយឃើញពីការធ្វើដំណើរឆ្ពោះទៅកាន់ទីតាំងថ្មី។ សកម្មភាពឧស្សាហកម្មទេសចរណ៍ បានចាប់ផ្តើមកើតមានឡើងនៅខណៈពេលដែលមានផ្លូវថ្មីៗ ជាច្រើនមានការរីកចម្រើនឡើងនូវយានយន្ត រថភ្លើងដឹកអ្នកដំណើរនិងកប៉ាល់ទឹក។ ហេតុការណ៍នេះជាទស្សនៈវិស័យមួយ ដ៏សំខាន់នៅដើមឆ្នាំ១៨០០។ ចក្រភពអង់គ្លេស និងប្រទេសបារាំងបានធ្វើការអភិវឌ្ឍប្រព័ន្ធផ្លូវថ្នល់ និងដែកបានយ៉ាងទូលំទូលាយមុខប្រទេសកាណាដា និងសហរដ្ឋអាមេរិក។ ការរីកចម្រើន និងការអភិវឌ្ឍផ្លូវថ្នល់ ផ្លូវដែកបានជួយអោយមានការកើនឡើងនូវជម្រើសជាច្រើនសម្រាប់ការដឹកជញ្ជូន និងជួយកាត់បន្ថយនូវចំណាយថ្លៃដើម ហើយបង្កើននូវភាពទាក់ទាញប្រជាជនកាន់តែច្រើនឡើងៗអោយមានគំនិតធ្វើដំណើរ។

**១.១.៥ យុគសម័យទំនើប**

ទំនោរទៅរកតម្រូវការលើវិស័យទេសចរណ៍ដ៏ច្រើនលើសលុប ជាបាតុភូតថ្មីដែលវិវត្តន៍បន្ទាប់ពីសង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់ (ឆ្នាំ១៩៤៥ ដល់បច្ចុប្បន្ន)។ នៅក្នុងកំឡុងពេលនៃសង្គ្រាមមនុស្សរាប់លាននាក់បានចាកចេញឆ្ពោះទៅកាន់គ្រប់ទីកន្លែងក្នុងពិភពលោក ឧទាហរណ៍ ប្រជាជនរបស់កាណាដា និងសហរដ្ឋអាមេរិចជាង ១៧លាននាក់បានឆ្ពោះទៅតំបន់ថ្មីៗផ្សេងៗគ្នា និងប្លែកទៀតខណៈពេលដែលពួកគេបំរើអោយកិច្ចការយោធា។ សកម្មភាពរបស់កងទ័ពបានបង្ខំឲ្យប្រជាជនមួយចំនួនដែលមិនធ្លាប់បានធ្វើដំណើរពីមុនមកអោយធ្វើដំណើរ ហើយពួកគេបានផ្តល់នូវបទពិសោធន៍ទាំងនោះទៅដល់ក្រុមគ្រួសារ និងមិត្តភក្តិនៅពេលដែលពួកគេត្រឡប់មកផ្ទះវិញ។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់កត្តាបន្ថែមមួយចំនួនជួយជំរុញដល់ការលូតលាស់នៃទេសចរណ៍។ រថយន្តបានចាប់ផ្តើមផលិតម្តងទៀត ក្នុងបរិមាណមួយយ៉ាងច្រើនឧស្ម័នមិនត្រូវបានកំណត់នៅក្នុងការផ្គត់ផ្គង់ឡើយហើយភាពជោគជ័យបានវិលត្រឡប់មកវិញដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មមួយចំនួននៅក្នុងប្រទេស។ការចាប់ផ្តើមក្នុងការធ្វើដំណើរតាមរយៈយន្តហោះមាននៅក្នុងឆ្នាំ១៩៥០ហើយត្រូវបានទទួលនូវប្រជាប្រិយភាពនៅឆ្នាំ១៩៦០។ ទាំងអស់នេះ ជាមូលហេតុដែលធ្វើអោយមានការលូតលាស់លឿនទាំងការធ្វើដំណើរក្នុងស្រុក និងលក្ខណៈអន្តរជាតិ។ ពេលវេលា លុយកាក់ សុវត្ថិភាព និងសេចក្តីប្រាថ្នាក្នុងការធ្វើដំណើរនេះត្រូវបានរាប់បញ្ចូលគ្នាដើម្បីបង្ហាញអោយឃើញ ពីសម័យកាលរីកចម្រើននៃវិស័យទេសចរណ៍ប្រកបដោយភាពមិនស្មើគ្នាចេះតែ បន្តរហូតមកដល់សព្វថ្ងៃ។

**១.២ សារហេតុនៃការធ្វើដំណើរ**

សារហេតុនៃការធ្វើដំណើរ គឺជាគោលបំណងរបស់ទេសចរដែលធ្វើអោយពួកគេចូលរួមក្នុងប្រភេទណាមួយនៃទេសចរណ៍ទាំងឡាយ ដែលគេចង់ទៅ។ យើងអាចបែងចែកសារហេតុទាំងនោះជា៥ក្រុមរួមមាន៖១. ការស្វែងយល់ពីវប្បធម៌ ដែលទេសចរតែងងឿងឆ្ងល់ និងចង់ដឹង ចង់យល់ពីប្រទេសផ្សេងៗនៅលើពិភពលោក គេតែងមានការចាប់អារម្មណ៍ និងទំនៀមទំលាប់ សិល្បៈ និងចម្លាក់ខុសៗគ្នា។ ២. ការស្វែងយល់ពីទំនាក់ទំនងរបស់មនុស្ស មានការសួរសុខទុក្ខបងប្អូនញាតិមិត្ត។ ៣. ការស្វែងយល់ ពីចិត្តសាស្ត្រ ដោយការចង់ដឹង ចង់ឃើញ ចង់យល់នូវអ្វីៗដែលប្លែកពីការរស់នៅប្រចាំថ្ងៃរបស់មនុស្សជាតិ។ ៤. ការស្វែងយល់ពីវប្បកម្ម ការលំហែលកម្សាន្ត ទេសចរណ៍បែបកីឡា ការសម្រាកលំហែ និងព្យាបាលជំងឺ។៥. ការស្វែងយល់ពីមោទនភាព គឺជាទេសចរណ៍បែបជំនួញ ទេសចរណ៍សន្និសិទជាដើម។ បើតាមការសិក្សាកន្លងមកការធ្វើដំណើររបស់ទេសចរត្រូវបានបែងចែកជា៤ធំៗតាមធ្យោបាយធ្វើដំណើរគឺ៖ ៦. ការធ្វើដំណើរតាមផ្លូវគោក ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដែលអ្នកទេសចរណ៍ចាំបាច់ត្រូវប្រើប្រាស់ពេលវេលានៃការធ្វើដំណើរទេសចរណ៍ពីតំបន់មួយទៅតំបន់មួយទៀត ៧. ការធ្វើដំណើរតាមផ្លូវទឹក ជាការធ្វើដំណើរតាមនាវា ហើយវាក៏ជាកិច្ចការមួយ ដែលមនុស្សបានធ្វើដំណើរមកពីយូរលង់ណាស់មកហើយក្រោយពីមនុស្សបានរកឃើញប្រភពទឹកទន្លេ ហើយបានយល់ថាទឹកជាផ្លូវមួយដែលអាចប្រើប្រាស់ក្នុងការបំលាស់ទីនិងដឹកជញ្ជូនសម្ភារៈផ្សេងៗទៀតផងដែរ។ ៨. ការធ្វើដំណើរតាមផ្លូវអាកាស គឺឧស្សាហកម្មហោះហើរត្រូវបានចាត់ទុកជាប្រភេទនៃការដឹកជញ្ជូនដែលមានភាពទាន់សម័យនាពេលបច្ចុប្បន្ន។ នេះដោយសារការហោះហើរមានល្បឿនលឿនដែលអោយអ្នកទេសចរណ៍អាចធ្វើដំណើរពីតំបន់មួយទៅតំបន់មួយពីប្រទេសមួយទៅប្រទេសមួយ និងពីទ្វីបមួយទៅទ្វីបមួយទៀត។ ៩. ការធ្វើដំណើរតាមផ្លូវដែកការធ្វើដំណើរតាមផ្លូវដែកនេះសម្រាប់ប្រទេសកម្ពុជាយើង គឺនៅមានកម្រិតនៅឡើយតែនៅប៉ុន្មានឆ្នាំចុង

ក្រោយនេះមានការរីកចម្រើនគួរអោយកត់សម្គាល់។ ការធ្វើដំណើរតាមផ្លូវនេះទៀតសោត គឺប្រើប្រាស់សម្រាប់ដឹកជញ្ជូនសម្ភារៈ ដែលបម្រើអោយវិស័យទេសចរណ៍ទៀតសោតគឺប្រើប្រាស់សម្រាប់ដឹកជញ្ជូនសម្ភារៈ ដែលបម្រើអោយវិស័យទេសចរណ៍ និងវិស័យដទៃទៀត។ ប៉ុន្តែសម្រាប់តែភ្ញៀវទេសចរណ៍ដែលមានចំណង់ចំណូលចិត្ត ទស្សនាព្រៃព្រឹក្សា សត្វ ប្រភេទ អេកូទេសចរណ៍ ឬជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

**១.២.១ ការធ្វើដំណើរដែលមិនចាត់ទុកជាទេសចរណ៍**

យើងដឹងហើយថាការធ្វើដំណើរក្នុងរយៈពេលណាមួយបានស្នាក់នៅមួយយប់ (ក្នុងប្រទេស ក្នុងតំបន់ និងខេត្តរបស់ខ្លួន ) ដែលបានមកដល់ក្នុងគោលបំណងទេសចរណ៍ និងមិនលើសពីមួយឆ្នាំ។ ក្នុងស្ថិតិទេសចរណ៍ប្រភេទនេះត្រូវបានបញ្ចូលជនជាតិបរទេសដែលរស់នៅក្នុងប្រទេសនេះ (លើសពីមួយឆ្នាំ) ហើយធ្វើដំណើរកម្សាន្តជាទេសចរណ៍ និងស្នាក់នៅក្នុងតំបន់។ អ្នកដែលមិនចាត់ទុកជាទេសចរក្នុងប្រទេសមាន៖

- ប្រជាពលរដ្ឋក្នុងតំបន់ ដែលធ្វើដំណើរក្នុងប្រទេសរបស់ខ្លួនដើម្បីស្វែងរកទីលំនៅ
- បុគ្គលដែលធ្វើដំណើរក្នុងប្រទេស សម្រាប់បំពេញសកម្មភាពកាងារស្វែងរកប្រាក់ចំណូល
- បុគ្គលធ្វើដំណើរទៅតំបន់ផ្សេងទៀតក្នុងប្រទេស ដើម្បីបំពេញការងារអោយអង្គភាពរបស់ខ្លួន
- បុគ្គលធ្វើដំណើរពីតំបន់មួយទៅតំបន់មួយ ក្នុងគោលដៅធ្វើការសិក្សាស្រាវជ្រាវ
- ពលទាហាន និងគ្រួសាររបស់គេចេញបំរើកាតព្វកិច្ចក្នុងតំបន់ណាមួយក្នុងប្រទេស
- អ្នកធ្វើដំណើរ ជនភៀសខ្លួន អ្នកដំណើរតាមនាវា រថយន្ត ឬរថភ្លើងធំៗ
- អ្នកបើកបរដែលទទួលដំណោកក្នុងយានយន្តរបស់ខ្លួន និងក្នុងតំបន់ដែលមកដល់ ចំពោះទេសចរ(អន្តរជាតិ) ជាបុគ្គលដែលមក ក្នុងរយៈពេលដែលបានស្នាក់នៅក្នុងតំបន់ដែលមកដល់មិនលើសពីមួយឆ្នាំ ហើយពុំបានធ្វើសកម្មភាពការងារសំរាប់សេដ្ឋកិច្ចនិងជីវភាពផ្ទាល់ខ្លួន។ ជនជាតិបរទេសដែលមកដល់ប្រទេសណាមួយ ហើយពុំត្រូវបានចាត់ទុកជាទេសចរមាន៖
- កម្មករបរទេស និងជនជាតិបរទេសដែលមកស្វែងរកការងារ
- អ្នកមកសិក្សាក្នុងរយៈពេលលើសពី៦ខែ
- ពលទាហាននិងគ្រួសាររបស់អ្នកដែលមកដល់ក្នុងទិសដៅមិនមែនទេសចរណ៍
- ស្ថានទូត និងតំណាងរបស់គេ និងគ្រួសារ អ្នកបំរើការងារជាបុគ្គលិកក្នុងស្ថានទូត
- ជនភៀសខ្លួនជាជនជាតិបរទេសដែលមកដល់
- អ្នកធ្វើដំណើរឆ្លងកាត់
- អ្នកធ្វើដំណើរតាមរថយន្ត រថភ្លើង នាវាសមុទ្រធំៗ ដែលទទួលដំណោកក្នុងយានយន្តរបស់ខ្លួន
- អ្នកបើកបរយានយន្ត ដូចរៀបរាប់ខាងលើ ហើយទទួលដំណោកក្នុងយានយន្ត
- អ្នកបើកបរយន្តហោះក្នុងប្រទេសដែលមកដល់

**១.២.២ គោលបំណងនៃការធ្វើដំណើរ**

ការធ្វើដំណើរគឺត្រូវបានចាត់ថាជាចលនារបស់មនុស្សក្នុងអំឡុងពេលណាមួយដោយមិនគិតពីរយៈពេលចម្ងាយ(ជិតឬឆ្ងាយ)ទិសដៅនិងមធ្យោបាយធ្វើដំណើរនោះទេ។ ការធ្វើដំណើរនេះទៀតសោតក្នុងគោលបំណងផ្លាស់ប្តូរទីលំនៅប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ។ ជាទូទៅមនុស្សធ្វើដំណើរជាទេសចរជាមួយនិងគោលបំណងសំ

ខាន់ៗប្រាំមួយរួមមាន៖ ១. ទេសចរស្វែងយល់ទស្សនា និងសកម្មភាពកម្សាន្តជាប្រភេទទេសចរ ដែលកំណត់ទៅតាមតម្រូវការលើការពង្រីកកម្លាំងកាយ និងកម្លាំងចិត្ត និងបំរើសេវាកម្មអោយចំណង់លើការបង្កើននូវការស្វែងយល់ដឹងពីមជ្ឈដ្ឋានប្លែកៗនៅជុំវិញ។ ទេសចរប្រភេទនេះមានទិដ្ឋភាពប្លែកៗដូចជា៖ កំសាន្តលំហែអារម្មណ៍ជាមួយភាពយន្តល្ខោន ការតាំងពិព័រណ៍ ការបរបាញ់សត្វ នេសាទ សិក្សាស្រាវជ្រាវវប្បធម៌ ប្រវត្តិសាស្រ្ត សាសនា អរិយធម៌សំរាកលេងតាមតំបន់ឆ្នេរ យល់ដឹងពីវប្បធម៌ប្រពៃណីទំនៀមទំលាប់ ទស្សនាប្រាសាទបុរាណ។ ២. ទេសចរណ៍សុខភាពនិងព្យាបាល ជាប្រភេទទេសចរណ៍ដែលធ្វើឡើងដើម្បីភ្ញៀវទេសចរណ៍ ក្នុងគោលបំណង តម្រូវការព្យាបាល ពង្រឹងសុខភាព កម្លាំងកាយ ចិត្ត និងបន្ធូរអារម្មណ៍។ ទេសចរប្រភេទនេះកំណត់លើតម្រូវការ ធាតុអាកាស តំបន់ សមុទ្រ តំបន់កីឡា ព្យាបាល និងថែរក្សាសុខភាព ថ្នាំបុរាណ។ ៣. ទេសចរកីឡាជាប្រភេទទេសចរណ៍ដែលកំណត់បានដោយការធ្វើដំណើរដើម្បីហាត់លេងកីឡាដើម្បីចូលរួមប្រកួត ទស្សនាការលេងកីឡា ការប្រកួតប្រជែងលេងកីឡា ដូចជាបាល់ទាត់ តេនីស បាល់បោះ ប្រដាល់ ឡើងភ្នំ លេងទឹក រត់ម៉ារាតុង ការជិះកង់ បោះប៊ូល ជាដើម។ ៤. ទេសចរអាជីវកម្ម ជាប្រភេទទេសចរណ៍ដែលធ្វើដំណើរ ក្នុងគោលបំណងកំណត់បញ្ជាក់ និងបង្កើតទំនាក់ទំនងការងារអាជីវកម្ម ជាមួយអ្នកមានលទ្ធភាពជាដៃគូ និងចូលរួម ក្នុងពិធីធំៗការប្រជុំតូចធំ សន្និបាត ពិធីតាំងពិព័រណ៍។ ទេសចរណ៍អាជីវកម្មធ្វើឡើងដោយស្វែងយល់ និងសិក្សាពីលក្ខន្តិកៈសម្រាប់ធ្វើការងារអាជីវកម្ម និង ត្រៀមទំនិញសម្រាប់យកទៅធ្វើពាណិជ្ជកម្ម។ ៥.ទេសចរសាសនា ជាប្រភេទទេសចរណ៍ដែលធ្វើឡើងតម្រូវការលើការគោរពសាសនានិងស្វែងយល់ពីសាសនា។ ទេសចរប្រភេទនេះត្រូវបានបែងចែកជាការធ្វើដំណើរ ដើម្បីទស្សនាស្ថាត្យកម្មសំណង់ប្រាសាទបុរាណរូបចម្លាក់និងអាគារសាសនាចូលរួមក្នុងពិធីបុណ្យសាសនានិងពិធីគោរពបូជាលាងកំហុសជាដើម។៦.ទេសចរណ៍សួរសុខទុក្ខញាតិសន្តាន និងមិត្តភ័ក្តិជាប្រភេទទេសចរណ៍ធ្វើដំណើរដើម្បីមក ជួបជុំបងប្អូនញាតិមិត្ត និងជួបជាមួយមនុស្សដែលជាទីគាប់ចិត្ត និងស្រលាញ់ទិញវត្ថុអនុស្សាវរីយ៍និងជំនូន។

### ១.៣ និយមន័យពាក់ពន្ធ័នឹងទេសចរណ៍

#### ១.៣.១ អ្វីទៅជាទេសចរ

ទេសចរ សំដៅដល់សកម្មភាពទាំងឡាយណារបស់បុគ្គលដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីសម្រាប់រយៈពេលមួយកំណត់ដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នា ដើម្បីសម្រាកលំហែកម្សាន្ត ធុរកិច្ចនិងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត។ ក្នុងនោះដែរទេសចរណ៍ រួមមានដូចជា: ទេសចរណ៍ ជាសកម្មភាពដែលផ្សារភ្ជាប់ជាមួយការស្នាក់នៅមួយយប់ មានន័យថាអ្នក ដែលធ្វើដំណើរជាទេសចរណ៍ មានតំរូវការលើការប្រើប្រាស់ទីកន្លែងសំណាក់។ ទេសចរណ៍ធ្វើឡើងនៅពេលទំនេរ (ក្រៅពីទេសចរណ៍អាជីវកម្ម Business Tourism) ដោយសារមានជាចាំបាច់នៅលក្ខខណ្ឌពីរ ១ នៅពេលទំនេរពីការងារនិង ២ នយោបាយ ។ ទេសចរណ៍ ជាសកម្មភាពរបស់បុគ្គល(គ្រប់ជនជាតិ ភេទ សាសនា ភាសា) ធ្វើដំណើរជាមួយនិងគោលបំណងស្វែងយល់ដឹង ទស្សនា ព្យាបាល ធុរកិច្ច និងមិនធ្វើ សកម្មភាពណាដែលទាក់ទងនឹងនយោបាយ តាំងទីលំនៅ ដើម្បីសេដ្ឋកិច្ចផ្ទាល់ខ្លួនក្នុងតំបន់ដែលបានមកដល់។ ហេតុដូចបានបញ្ជាក់លើតំរូវអោយការកំណត់និយមន័យទេសចរណ៍ពិភពលោក។ នៅដំណាច់ឆ្នាំ១៩៩០ អង្គការសហប្រជាជាតិបានកំណត់និយមន័យដោយ ទេសចរណ៍ ជាការធ្វើសកម្មភាពទេសចរណ៍ ត្រូវបានធ្វើឡើង

ដោយការយកចិត្តទុកដាក់ពិសេសទៅលើលក្ខណៈពិសេសនៃសេដ្ឋកិច្ច និងសង្គមរស់នៅ។ ដូចបង្ហាញខាងលើនិយមន័យទេសចរណ៍ ត្រូវកំណត់ដោយសំដៅទៅលើលក្ខណៈសេដ្ឋកិច្ចរបស់វា ដែលបញ្ជាក់ពីអត្ថប្រយោជន៍ក្នុងកិច្ចការនៃការជំរុញល្បឿននៃការអភិវឌ្ឍន៍ នៃសេដ្ឋកិច្ចសង្គមនិងយោងទៅតាមឯកសារគោលកំណត់ដោយអង្គការទេសចរណ៍ពិភពលោក(WTO)ដែលរៀបរៀងស្ថិតិកម្សាន្ត ដែលមានឥទ្ធិពលទៅលើការពង្រឹងសុខភាពការរីកចម្រើន និងអភិវឌ្ឍន៍កំលាំងកាយ និងចិត្តរបស់មនុស្សដែលធ្វើចលនាឬធ្វើដំណើរចេញពីកន្លែងរស់នៅប្រចាំថ្ងៃក្នុងរយៈពេលមួយកំណត់។ គួរបញ្ជាក់ផងដែរថានៅបណ្តាលប្រទេសអភិវឌ្ឍន៍ទេសចរណ៍ទាំងឡាយ ការកំណត់និយមន័យមានភាពផ្សេងៗគ្នាមិនដូចគ្នាទាំងស្រុងទេហើយការចាត់ថ្នាក់និងវិភាគខាងលើនេះ ត្រូវបានធ្វើឡើងដោយយកចិត្តទុកដាក់លើករណីសំខាន់ៗពីរ គឺឥទ្ធិពលនយោបាយនិងសេដ្ឋកិច្ច។ នៅឆ្នាំ១៩៩៣ គណៈកម្មការសហប្រជាជាតិបានអនុម័តជាថ្មីនូវការរៀបរៀងស្ថិតិទេសចរណ៍ដែលធ្វើឡើងដោយអង្គការទេសចរណ៍ពិភពលោក។ យោងតាមមតិណែនាំនេះទេសចរណ៍ត្រូវបានកំណត់ថាជាបណ្តាសកម្មភាពរបស់បុគ្គលដែលធ្វើដំណើរនិងការស្នាក់នៅទីកន្លែងក្រៅពីបរិយាកាសធម្មតារបស់ពួកគេក្នុងរយៈពេលមិនលើពីរមួយឆ្នាំជាប់ៗគ្នាដើម្បី លំហែកំសាន្តកីឡា សាសនា ព្យាបាលជំងឺ សួរសុខទុក្ខ ធុរកិច្ចនិងគោលបំណងផ្សេងៗទៀត។ ការវិភាគបង្ហាញថាការកំណត់ន័យអោយទេសចរណ៍ ត្រូវធ្វើឡើងតាមរយៈចរិតលក្ខណៈពិសេសរបស់វា ដូចខាងក្រោមថា ទេសចរណ៍ ជាលទ្ធផលនៃការធ្វើចលនារបស់មនុស្សតាមខ្សែទស្សនកិច្ចផ្សេងៗ។ ទេសចរណ៍ ជាការធ្វើដំណើរទៅចំណុចដែលជាគោលដៅ និង ស្នាក់នៅតំបន់នោះ។ ទេសចរណ៍ ជាការធ្វើដំណើរចាកចេញមួយរយៈពីកន្លែងដែលអ្នកដំណើររស់នៅ។ ទេសចរណ៍ ជាការធ្វើដំណើរកំសាន្តមួយ ហើយវិលត្រលប់មកកន្លែងរស់នៅប្រចាំថ្ងៃវិញ។ ទេសចរណ៍ ជាការធ្វើដំណើរដែលមិនរាប់បញ្ចូលនៅសកម្មភាពរកប្រាក់កម្រៃផ្ទាល់ខ្លួន។ ទេសចរណ៍ ជាការធ្វើដំណើរដើម្បីស្វែងរកបទពិសោធន៍ថ្មីៗ និងចែករំលែកបទពិសោធន៍អោយគ្នាទៅវិញទៅមក។ ទេសចរណ៍ ជាការចង់ឃើញចង់ដឹងនៅអ្វីប្លែកៗនិងថ្មីដែលពួកគេមិនធ្លាប់ឃើញពីមុនមក។ យោងតាមគោលការណ៍គណៈកម្មាធិការស្ថិតិអង្គការសហប្រជាជាតិលក្ខខណ្ឌចាំបាច់ និងចរិតលក្ខណៈពិសេសៗរបស់ទេសចរណ៍ និយមន័យពិតប្រាកដរបស់ទេសចរណ៍ សំដៅដល់សកម្មភាពទាំងឡាយណារបស់បុគ្គល ដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់គេ សំរាប់ពេលកំណត់ជាក់លាក់មួយ (មិនតិចជាងមួយយប់មួយថ្ងៃនិងមិនលើសពីមួយឆ្នាំ ) ក្នុងគោលបំណងទេសចរណ៍។ ដោយឡែកគោលបំណងទេសចរណ៍ច្បាប់ស្តីពី "ការគ្រប់គ្រងវិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា" ចែងថាគោលបំណងទេសចរណ៍សំដៅដល់គោលបំណងសំខាន់ៗ ដូចជា សំរាកលំហែ កំសាន្ត ទស្សនា និងកីឡា សាសនា ធុរកិច្ចសាកសួរសុខទុក្ខញាតិសន្តាន ព្យាបាលជំងឺ និងបំណងទេសចរណ៍ស្របច្បាប់ផ្សេងទៀត"។

**១.៣.២ អ្នកណាជាទេសចរ**

ក្នុងវិស័យទេសចរណ៍ អ្នកដែលទទួលប្រើប្រាស់សេវាកម្មមានតែមួយគឺទេសចរ។ ទេសចរជាអ្នកទទួលនិងប្រើប្រាស់នូវផលិផលទេសចរណ៍(កម្មវិធីដំណើរកំសាន្ត ខ្សែទស្សនកិច្ច សេវាកម្ម និង ទំនិញ) និងត្រូវបានកំណត់ថាជាកម្មវត្ថុបំណងនៃសកម្មភាពការងាររបស់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍។ ភាពខុសគ្នាពីទីផ្សារទំនិញ និងទីផ្សារហិរញ្ញវត្ថុដែលផលិតផលជាអ្នកស្វែងរកអតិថិជននៅលើទីផ្សារទេសចរណ៍អ្នកប្រើប្រាស់

(ទេសចរ) ជាអ្នកស្វែងរកផលិតផល និងសេវាកម្មដោយខ្លួនឯង។ ទេសចរមិនអាចដឹង និងស្គាល់ពីខ្សែទស្សន កិច្ចនិងសេវាកម្ម ដែលគេប្រើប្រាស់ពីនោះទេ ផលិតផលទេសចរណ៍ត្រូវបានគេផ្ដល់ និងវាយតម្លៃក្នុងរយៈពេល នៃការប្រត្តិបត្តិ និង ដំណើរការទទួលការប្រើប្រាស់ប៉ុណ្ណោះ។ បទពិសោធន៍បង្ហាញថាប្រសិទ្ធភាពនៃការអភិវឌ្ឍវិ ស័យទេសចរណ៍ទាំងមូល ធ្វើឡើងតាមរយៈការព្រមព្រៀងរវាងអាជីវករនិងអាជីវករ រវាងរដ្ឋ និងរដ្ឋ ហើយវាក៏មិន អាចកើតមានឡើងបើសិនគ្មានការកំណត់ច្បាស់លាស់ពីទេសចរនោះទេ។ កិច្ចព្រមព្រៀងជាលក្ខណៈអន្តរជាតិ រវាងរដ្ឋនិង រដ្ឋត្រូវធ្វើឡើងដោយយោងទៅតាមគោលការណ៍ និងគោលដៅលើការដោះដូរទេសចរជាលក្ខណៈ អន្តរជាតិប៉ុណ្ណោះទេគឺបន្ថែមទាំងការកាត់បន្ថយបន្ថយពន្ធ និងបែបបទគយ ដែលបង្កើតអោយមានជាលក្ខខណ្ឌ សមស្របសំរាប់ទេសចរឆ្លងកាត់ព្រំដែនប្រទេសលក្ខខណ្ឌធានារ៉ាប់រងទេសចរ បទបញ្ញតិ និងលក្ខខណ្ឌផ្សេងៗ សំរាប់ការស្នាក់នៅ និងការធ្វើដំណើរឆ្លងកាត់។ ពាក្យទេសចរ ត្រូវបានគេលើកយកមកអនុម័ត និងផ្តល់និយម ន័យជាច្រើនលើកមកហើយ នៅក្នុងពេលបច្ចុប្បន្ននេះពុំទាន់បានត្រូវបញ្ចប់ជាស្ថាពរនោះទេ ព្រោះសកម្មភាព ទេសចរណ៍តែងតែវិវត្តន៍ស្របនឹងការវិវត្តនៃសង្គមមនុស្ស និងចិត្តគំនិតរបស់អ្នកទេសចរណ៍។ និយមន៍ដំបូង របស់ទេសចរត្រូវបានគេកំណត់នៅក្នុងសម័យប្រជុំរបស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៣៧ នាទីក្រុងហ្សឺ ណែវ ថា ទេសចរ ជាបុគ្គល ដែលស្ថិតនៅមិនតិចជាង ២៤ ម៉ោងក្នុងតំបន់និងប្រទេសដែលគាត់មិនបានរស់ នៅ។ ការវិភាគបង្ហាញថានិយមន័យនេះមានន័យទូលំទូលាយពេក ព្រោះវាអាចប្រើប្រាស់បានគ្រប់ជនជាតិ ដែលស្ថិតនៅប្រទេសណាមួយលើសពី ២៤ ម៉ោង(អ្នកដំណើរឆ្លងកាត់ ជនភៀសខ្លួន ជនទុចរិត ។ល។ បញ្ហានេះ បានជំរុញជាច្រើនលើកច្រើនសារអោយអង្គការសហប្រជាជាតិពិនិត្យ និងលើកយកវាមកពិចារណាឡើងវិញ។ ច្បាប់គយពិភពលោកអនុម័តអោយអង្គការសហប្រជាជាតិ នៅឆ្នាំ ១៩៥៤ នៅក្នុងមាត្រា១ មានការផ្តល់និយម ន័យថ្មីមួយទៀតសម្រាប់ទេសចរ។ ទេសចរគឺបុគ្គលគ្រប់ប្រភេទមិនប្រកាន់សាសនាដែលបានទៅដល់តំបន់ឬ ទឹកដីប្រទេសណាមួយតាមរយៈកិច្ចព្រមព្រៀង (កិច្ចព្រមព្រៀមដោះដូរទេសចរណ៍រវាងប្រទេសនិងប្រទេស) ក្រៅ ពីប្រទេសដែលគេរស់នៅ ប្រចាំថ្ងៃហើយស្ថិតនៅតិចជាងពី២៤ម៉ោង និងមិនលើសពី៦ខែក្នុងគោលបំណង ព្យាបាលកីឡាទទួល ភាពរីករាយលំហែកាយ សិក្សា សាសនា អាជីវកម្ម និង កិច្ចការគ្រួសារ ដែលអាចធ្វើបាន ក្រៅពីការភៀសខ្លួន។ តាមរយៈនិយមន័យនេះទេសចរជាជនជាតិបរទេសដែលឆ្លងកាត់ព្រំប្រទល់ប្រទេសណា មួយ ដោយមិនមានគោលដៅរស់នៅប្រចាំ(ជនភៀសខ្លួន) និយមន័យនេះ មានលក្ខណៈទូលំទូលាយណាស់ដែរ ព្រោះថាពាក្យទេសចរអាចចាត់ទុកជាអ្នកបរទេសដែលធ្វើដំណើរមកដល់ប្រទេសណាមួយដើម្បីស្វែងរកការងា រ។ បញ្ហាដែលកើតឡើងនេះបានជំរុញអោយអង្គសន្និសិទរបស់អង្គការសហប្រជាជាតិស្ដីអំពី "ទេសចរនិងការធ្វើ ដំណើរ" ដែលប្រារព្ធឡើងនៅឆ្នាំ១៩៦៣ កំណត់នៅនិយមន័យថ្មីមួយទៀត ទេសចរ ជាអ្នកដែលមកដល់តំបន់ ណាមួយក្នុងរយៈពេលណាមួយមិនតិចជាង២៤ម៉ោង រីឯគោលបំណងនៃការធ្វើដំណើរគឺសម្រាកព្យាបាល សាសនា កីឡា ធុរកិច្ច ចូលរួមក្នុងសិក្ខាសាលា សិក្សា សន្និសីទ ការងារគ្រួសារ។ ឯអ្នកដែលធ្វើដំណើរទៅកាន់ តំបន់ឬប្រទេសណាមួយក្នុងគោលបំណងធុរកិច្ចផ្លូវការ (ទស្សនកិច្ចអ្នកដឹកនាំឬអង្គការណាមួយសភាជាតិ សមាជិកស្ថានទូតស្ថានកុងស៊ុល)ឬអ្នកដំណើរស្រាវជ្រាវវិទ្យាសាស្ត្រ ភូមិវិទ្យាប្រវត្តិវិទ្យា មហាសមុទ្រវិទ្យាស្វែង រកកំណាប់ស្វតព្រៃ។ល។ ពុំត្រូវបានបញ្ចូលក្នុងស្ថិតិទេសចរនោះទេ។ ផ្ទុយទៅវិញនិស្សិតដែលកំពុងសិក្សានៅ បរទេស ត្រូវបានគិតថាជាទេសចរផងដែរ។ នៅក្នុងទ្រឹស្ដីទេសចរ(អាចប្រើប្រាស់បាន) ទេសចរ អាចត្រូវបាន

កំណត់ថា ជាអ្នកប្រើប្រាស់ ឬទិញកម្មវិធីដំណើរកំសាន្តផលិតផលនិងសេវាកម្មទេសចរណ៍។ ជាបុគ្គលមិនប្រកាន់ជនជាតិ ភេទ សាសនា ភាសាដែលមកដល់តំបន់ណាមួយក្នុងរយៈពេលណាមួយហើយស្នាក់នៅក្នុងតំបន់នោះ( ស្ថិតនៅក្រៅកន្លែងដែលខ្លួនរស់នៅប្រចាំ ) ក្នុងសមាគមទីស្នាក់ណាមួយអោយខ្លួនឯងឬជាក្រុមមិនតិចជាង២៤ម៉ោងតែមិនលើសពីមួយឆ្នាំក្នុងគោលបំណងស្វែងយល់ដឹង ទស្សនា ព្យាបាល អាជីវកម្ម នឹងមិនធ្វើសកម្មភាព ណាទាក់ទងនឹងនយោបាយ និងសេដ្ឋកិច្ចផ្ទាល់ខ្លួនក្នុងតំបន់ដែលមកដល់។ ការស្រាវជ្រាវបង្ហាញថាការកំណត់និយមន័យច្បាស់លាស់ អាចធ្វើបានលុះត្រាតែពិនិត្យលើធាតុផ្សំរបស់វា។ **ទីមួយ** ទេសចរ ជាអ្នកប្រើប្រាស់ផលិតផលទេសចរណ៍ (សេវាកម្ម ការងារ និងទំនិញ) ដែលត្រូវបានការពារដោយច្បាប់ "ច្បាប់ការពារអតិថិជន"ដែលមាននៅគ្រប់ប្រទេសក្នុងពិភពលោក។ ទេសចរកើតមានឡើងដោយសារមានតម្រូវការលើការសំរាកលំហែ ធ្វើដំណើរ។ល។ បើគ្មានទេសចរក៏គ្មានទេសចរណ៍ដែរ។ សព្វថ្ងៃនេះមានអង្គការជាច្រើនដែលសិក្សា និងវាយតំលៃលើការអនុវត្តច្បាប់ការពារសិទ្ធិរបស់អតិថិជនព្រោះថាមានទេសចរជាច្រើនលាននាក់ក្នុងមួយឆ្នាំៗមិនពេញចិត្តនិងលក្ខខណ្ឌកំសាន្តសំរាក និងការធ្វើដំណើររបស់ខ្លួនហើយបានអោយដឹងក្រោយពីបញ្ចប់ការធ្វើដំណើរជាទេសចរណ៍របស់ខ្លួន(ដោយសារកាផ្តល់សេវាមិនសមស្របនឹងកម្មវិធីដំណើរ ឬគុណភាពដែលអ្នកលក់បានសន្យា)។ **ទីពីរ** ទេសចរ ជាអ្នកដែលបានស្នាក់នៅយប់ ក្រៅពីកន្លែងរស់នៅរបស់ខ្លួន តែមិនលើរយៈពេល៣៦៥ថ្ងៃ។ អ្នកមកដល់ហើយស្នាក់នៅលើសពី ៣៦៥ ថ្ងៃជាបន្តបន្ទាប់ និងមិនត្រូវបានចាត់ទុកជាទេសចរទេ។ តាមកត្តាផ្សេងៗការធ្វើដំណើរជាទេសចរណ៍ ត្រូវបានបែងចែក (១) ការធ្វើដំណើរនៅថ្ងៃទំនេរWeekend Holiday ត្រូវស្ថិតក្នុងរយៈពេលពី ១- ៣ថ្ងៃ។ ចរិតលក្ខណៈនៃដំណើរនេះ បង្ហាញពីកំរិតចំណាយតិចបំផុតលើការធ្វើដំណើរ ដែលសំដៅទៅតំបន់លំហែកាយ អារម្មណ៍ មជ្ឈមណ្ឌលវប្បធម៌និងរមណីយដ្ឋានទេសចរណ៍ (២) ដំណើរក្នុងរយៈពេល ៥-៧ថ្ងៃ ត្រូវបានរីកដុះដាល និងពេញនិយមយ៉ាងខ្លាំងនៅក្នុងពិភពលោក (៣) ដំណើរក្នុងរយៈពេល ៨- ១២ ថ្ងៃ សំរាប់ប្រភេទណាមួយនៃទេសចរណ៍។ ដំណើរក្នុងរយៈពេលនេះត្រូវបានបន្ថយតំលៃយ៉ាងច្រើន និងមានការចំណាយតិច (៤) ដំណើរក្នុងរយៈពេលយូរលើកចាប់ពីពីរសប្តាហ៍ (មិនលើសពី ៣៦៥ថ្ងៃ)។ ការធ្វើដំណើរប្រភេទនេះភាគច្រើនធ្វើឡើងទៅតាមប្រភេទទេសចរណ៍ពិសេសៗដូចជា Crossing Tour និង Adventure Tour ជាដើម។ **ទីបី** ទេសចរ ត្រូវបានកំណត់ទៅតាមគោលបំណកដំណើរនិងវ័យ។ វ័យចំណាស់ជ្រុលអាចនាំអោយមានការលំបាកលើការថែរក្សា និងជួយដល់សុខភាពគាត់។ សំរាប់ស្ថិតិទេសចរណ៍ ទេសចរត្រូវបានបែងចែកជាប្រភេទមួយចំនួន ដូចជា៣-១២ឆ្នាំ យុវវ័យ ១៨-២៨ឆ្នាំ និស្សិត ២៦-៤៤ ឆ្នាំ មនុស្សពេញវ័យ៤៥-៦៤ ឆ្នាំ មនុស្សវ័យជរាមធ្យម ៦៥ ឆ្នាំ និងលើស (មនុស្សចាស់ចូលនិវត្តន៍ )។ សំរាប់ការមានផែនការរៀបចំផលិតផល វ័យមានសារៈសំខាន់បំផុត ព្រោះវាអាចជួយដល់ការវាយតំលៃ និងជ្រើសរើសប្រភេទនៃសកម្មភាពទេសចរណ៍។ ការកំណត់និយមន័យអោយទេសចរអាស្រ័យអោយគោលបំណងនៃការធ្វើដំណើរមួយទៀត។ បើសិនគោលបំណងនេះ មិនស្របទៅនឹង កត្តាដែលកំណត់នោះ អ្នកដំណើរត្រូវបានទទួលស្គាល់ថាជាទេសចរនោះទេ។ មានន័យថា ហាមធ្វើសកម្មភាពការងារសំរាប់ ប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងតំបន់ដែលមកដល់ បើសិនអ្នកដំណើរនោះជាទេសចរ។ ទេសចរ ពុំត្រូវបាន អនុញ្ញាតអោយប្រកបការងារ និងស្វែងរកប្រាក់ចំណូលក្នុងតំបន់ដែលទៅដល់នោះទេ។ ទេសចរត្រូវចំណាយប្រាក់ខែដែលខ្លួនបានពីការងារនៅក្នុងតំបន់ទេសចណ៍ដែលខ្លួនបានមកដល់ជាថ្នូរនឹងសេវាលំហែ សំរាក និងផ្សេងៗ។ រីឯសម្រាប់ សេដ្ឋកិច្ច ការងារ គ្រួសារ ប្រាក់

ចំណូលពីការផ្តល់សេវាកម្ម ការបម្រើភ្ញៀវ លក់ទំនិញ។ល។ ជាលទ្ធភាពដល់ពលរដ្ឋដែលជាម្ចាស់ស្រុក ឬម្ចាស់តំបន់។ យោងដូចបានបង្ហាញខាងលើច្បាប់ស្តីពី"ការគ្រប់គ្រងវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា "បានកំណត់និយមន័យអោយទេសចរថា" ទេសចរសំដៅដល់បុគ្គលទាំងឡាយដែលមកដល់តំបន់ផ្សេងពីបរិយាកាសប្រក្រតីរបស់គេស្នាក់នៅទីនោះចាប់ពី២៤ម៉ោងឡើងទៅ និងមិនលើសពីរយៈពេល កំណត់ក្នុងគោលបំណងទេសចរ និងមិនទាក់ទងដល់គោលបំណងតាំងទីលំនៅឬធ្វើសកម្មភាពណាមួយដែលទទួលបានប្រាក់កម្រៃនៅទីនោះ។

**១.៤ មុខងារទេសចរណ៍**

វិស័យទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជាមាសបៃតងនិងជាការនាំចេញនៅនឹងកន្លែង។ វិស័យនេះបានចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមតាមរយៈការបង្កើតប្រាក់ចំណូលជូនជាតិ បង្កើតការងារ ទាក់ទាញការវិនិយោគ និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ លើសពីនេះទៀតទេសចរណ៍ក៏បានចូលរួមចំណែកលើកកម្ពស់ ថែរក្សានិងអភិរក្សសម្បត្តិវប្បធម៌និងធម្មជាតិរបស់ប្រទេសកាត់បន្ថយនូវការកើនឡើងកំដៅភពផែនដី និងជាកាតាលីករមួយដ៏សំខាន់ក្នុងការជំរុញសាកលភាវូបនីយកម្មនិងសមាហរកម្មតំបន់ផងដែរ។ បើយោងតាមការសិក្សាស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រ ក្នុងពិភពលោកបានបង្ហាញថា វិស័យទេសចរណ៍ គឺជាវិស័យមួយដ៏សំខាន់សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ ហើយក៏កំពុងតែបំពេញនូវមុខងារសំខាន់បីយ៉ាងមានដូចជា៖ ក. មុខងារសង្គម ខ. មុខងារសេដ្ឋកិច្ច គ. មុខងារមនុស្សជាតិ ។

**១.៤.១ មុខងារសង្គមរបស់ទេសចរណ៍**

ការធ្វើដំណើរកំសាន្តបែបទេសចរណ៍ របស់មនុស្សគ្រប់ជាតិសាសន៍ជាផ្នែកមួយដែលជាជំនួយដល់ប្រជាពលរដ្ឋនៅតាមតំបន់ទេសចរណ៍បង្កើត ឲ្យមានការងារធ្វើនិងបង្កើនជីវភាពរស់ នៅកាត់បន្ថយភាពក្រីក្រ និងជួយដល់សង្គមជាតិ។ តាមរយៈវិស័យទេសចរណ៍នេះផងដែរក៏នាំយកការហូរចូលរូបិយប័ណ្ណអន្តរជាតិ បង្កើនចំណូលជូនជាតិ កាត់បន្ថយភាពក្រីក្រតាមរយៈការបង្កើតការងារធ្វើដល់ប្រជាពលរដ្ឋបង្កើនការយល់ដឹងដល់ប្រជាជន ការរីកចំរើននូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងជម្រុញការពង្រីកផលិតផលក្នុងស្រុកបង្កើតទីផ្សារក្នុងស្រុកទាក់ទាញអ្នកវិនិយោគជាតិនិងអន្តរជាតិសេវាផ្សេងៗ ដូចជាគមនាគមន៍ ប្រៃសណីយ៍ ហាងទំនិញ សណ្ឋាគារ ភោជនីយដ្ឋាន សេវាកម្មដឹកជញ្ជូន ការរីកចម្រើនក្រុមហ៊ុនទេសចរណ៍ រមណីយដ្ឋានកម្សាន្ត សហគមន៍ធម្មជាតិ ដែលទាំងនេះប្រជាជនក្នុងតំបន់រកប្រាក់ចំណូលបានដោយផ្ទាល់និងប្រយោលហើយនាំមកនៅការអភិវឌ្ឍនៃសេដ្ឋកិច្ច និងសង្គមជា ជាតិផងដែរ។

**១.៤.២ មុខងារសេដ្ឋកិច្ចរបស់ទេសចរណ៍**

ទេសចរណ៍ បានរួមចំណែកយ៉ាងខ្លាំងក្នុងការកសាង និងជំរុញឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ច ព្រោះវាជាប្រភពដ៏សំខាន់មួយក្នុងការរកប្រាក់ចំណូលដល់ពលរដ្ឋនៅក្នុងតំបន់ទេសចរណ៍តាមរយៈការបម្រើការងារដោយផ្ទាល់ឬដោយប្រយោលការលក់ផលិតផល និងសកម្មភាពផ្គត់ផ្គង់ផលិតជាទំនិញ និងសេវាកម្មទេសចរណ៍។ ហើយវាជាឃ្លាំងសម្រាប់ជំរុញការអភិវឌ្ឍអាជីវកម្ម កន្លែងកម្សាន្ត រមណីយដ្ឋាន សួនកម្សាន្តសហគមន៍ ធម្មជាតិ ដែលជាជំរកសត្វព្រៃ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងទីកម្សាន្តសប្បាយដទៃផ្សេងៗទៀត។ ម៉្យាងទៀតវាក៏ជាកម្លាំងធ្វើឲ្យមានការយកចិត្តដាក់រៀបចំ សម្ភារៈទំនើបថ្មីៗទៀតសម្រាប់ទទួលភ្ញៀវដោយភាពកក់ក្តៅការពារសន្តិ

សុខសុវត្ថិភាព និង និងថែរក្សាសម្បត្តិធម្មជាតិបង្កើតឧត្តមគតិស្នេហាជាតិលើកកម្ពស់និងមោទនភាពជាតិ។ មួយវិញទៀតប្រាសាទ រូបបដិមា វិមាន ប្រវត្តិសាស្ត្រ។ មិនតែប៉ុណ្ណោះ ក៏ជំរុញឲ្យមានការរីកដុះដាលខ្លាំងនូវអាជីវកម្មដឹកជញ្ជូន ពង្រីកកន្លែងផ្តល់សេវាគមនាគមន៍ដូចជា កន្លែងលាងនិងជួសជុលរថយន្ត ស្ថានីយ៍ចាក់ប្រេង គុណភាពផ្លូវនៅតំបន់ទេសចរណ៍ត្រូវបានតភ្ជាប់ដែលជាតម្រូវការចាំបាច់។ នាំឲ្យមានការហូរចូលមកក្នុងតំបន់ និងប្រទេសអភិវឌ្ឍន៍ទេសចរណ៍បាននូវរូបិយប័ណ្ណបរទេស និងនាំចំណូលដល់រដ្ឋ។

**១.៤.៣ មុខងារមនុស្សជាតិរបស់ទេសចរណ៍**

ក្រៅពីបានផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច និងសង្គមជាតិ ទេសចរណ៍បានបំពេញនូវតួនាទីដ៏សំខាន់មួយទៀត គឺមនុស្សជាតិព្រោះថាវាបានជំរុញឲ្យមានការចូលរួមពីសំណាក់ មហាជនក្នុងដំណើរកម្សាន្តសម្រាកលំហែកាយ និងតាមរយៈការធ្វើដំណើរទស្សនាស្វែងយល់ នាំឲ្យមហាជនបានស្គាល់ពីជីវិតវប្បធម៌ប្រវត្តិសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់របស់ជាតិខ្លួន និងក៏ដូចជារបស់ជាតិ និងពលរដ្ឋដទៃទៀតដែរ។ កត្តាទាំងអស់នេះបានផ្តល់ដល់ពលរដ្ឋនូវការរីកច្រើន ពង្រីកការយល់ដឹង និងបង្កើតឡើងនូវសតិសម្បជញ្ញៈស្នេហាជាតិ និងមាតុភូមិ។ ជំរុញឲ្យមានការពង្រីក និងរៀបចំឡើងវិញនូវសន្តិសុខក្នុងសង្គមមនុស្សមានទំនាក់ទំនងល្អ និងយោគយល់គ្នារវាងមនុស្សនិងមនុស្ស ពលរដ្ឋក្នុងប្រទេស និងតំបន់ ពលរដ្ឋប្រទេសនិងពលរដ្ឋជនជាតិមួយផ្សេងទៀត។ បង្កើននូវការអប់រំយល់ដឹងដែលជាមូលដ្ឋានដល់កូនចៅជំនាន់ក្រោយ។ កម្មវិធីដំណើរល្អៗអាចបង្កើតឲ្យមានអារម្មណ៍ល្អចិត្តគំនិតល្អដល់ក្មេងៗប្រសិទ្ធភាពក្នុងការរីកលូតលាស់ដល់គេនូវសិល្បវិធីល្អៗ ស្គាល់ពីតម្លៃរបស់មនុស្ស និងសង្គម ។ល។

## ១.៥ អេកូទេសចរណ៍

### ១.៥.១ និយមន័យអេកូទេសចរណ៍

បញ្ហាបរិស្ថានជារឿងសំខាន់នៅក្នុងលោកបច្ចុប្បន្ន ហើយទូទាំងពិភពលោកក៏កំពុងព្យាយាមដោះស្រាយបញ្ហាបរិស្ថានដែលកើតមានឡើង។ បញ្ហាបរិស្ថានក្នុងឧស្សាហកម្មទេសចរណ៍ពុំត្រូវព្រងើយកន្តើយឡើយ ដែលការអភិវឌ្ឍត្រូវមានការយកចិត្តទុកដាក់ និងចាប់អារម្មណ៍ទៅលើការជំរុញអភិវឌ្ឍន៍នៃទេសចរណ៍ ដើម្បីជួយដល់ការអភិវឌ្ឍបរិស្ថានរួមទាំងព្យាយាមអោយទេសចរណ៍មានការប៉ះពាល់ដល់បរិស្ថានតិចតួចបំផុត ដើម្បីអោយសមស្របជាមួយការផ្លាស់ប្តូរ និងការប្រព្រឹត្តទៅនៃការវិវត្តនៃសង្គមជាតិ និងសាកលភាវូបនីយកម្ម។ ការភ្ញាក់រលឹករបស់អ្នកទេសចរណ៍កំពុងបង្ខំអោយមានការផ្លាស់ប្តូរទំរង់នៃទេសចរណ៍ពីការបំផ្លាញមកពីការអភិរក្ស និងការពារ ដែលបានលើកឡើងអំពី"អេកូទេសចរណ៍ ឬទេសចរណ៍បៃតង"។ មានអ្នកអោយនិយមន័យនៃពាក្យ"អេកូទេសចរណ៍" ថាទេសចរណ៍ដែលមានទិសដៅ ដើម្បីការសិក្សា និងយល់ដឹងអំពីធម្មជាតិ និងវប្បធម៌របស់តំបន់ដោយគ្រាន់យកការគោរពនូវកិត្តិយសនៃប្រព័ន្ធបរិស្ថាន(Ecology) ហើយផ្តល់ផលប្រយោជន៍ និងឱកាសសេដ្ឋកិច្ចដល់ប្រជាជនក្នុងតំបន់។ អេកូទេសចរណ៍មានន័យស៊ីជម្រៅលើសពីការដាក់ស្នើលើទំនិញទេសចរណ៍បែបថ្មី ដើម្បីទាក់ទាញអ្នកទេសចរណ៍។ ទ្រឹស្តីនេះជាការទំនាក់ទំនងដើម្បីផលប្រយោជន៍ និងតំរូវការអភិរក្សបរិស្ថានទាំងធម្មជាតិ ទាំងវប្បធម៌សង្គម រួមជាមួយការអភិវឌ្ឍទេសចរណ៍ឆ្លើយតបតំរូវការសេដ្ឋកិច្ច។ ជាការពិតណាស់អេកូទេសចរណ៍ជាទំរង់នៃទេសចរណ៍ដែលជួយជំរុញនូវការថែរក្សាធម្មជាតិ និងវឌ្ឍនធម៌ ហើយក៏ជាឧបករណ៍សំខាន់មួយបែបក្នុងការទ្រទ្រង់អភិវឌ្ឍន៍វិស័យទេសចរណ៍ផងដែរ។

លោក Hector Ceballos-Lascurian បានអោយនិយមន័យអេកូទេសចរណ៍ថា"ជាការធ្វើដំណើរដោយរក្សាបាននូវបរិស្ថាន និងការទស្សនាដែលទាក់ទងទៅនឹងតំបន់ធម្មជាតិមិនរំខានដើម្បីសប្បាយរីករាយ ការសិក្សា និងការពេញចិត្តនឹងធម្មជាតិ និងលក្ខណៈវប្បធម៌ដែលជំរុញអោយមានការអភិរក្សដែលវាមានផលប៉ះពាល់ជាអវិជ្ជមាន និងផ្តល់ប្រយោជន៍ជានិរន្តរភាពដែលទាក់ទងនឹងសេដ្ឋកិច្ច សង្គមរបស់ប្រជាជននៅក្នុងតំបន់នេះ។

បើយើងពិនិត្យទៅលើពាក្យ Eco-Tourism នេះឃើញថាពាក្យ Eco គឺបានមកពីពាក្យ Ecology ដែលមានន័យថា"បរិស្ថានវិទ្យា" ចំណែកឯពាក្យ Tourism គឺមានន័យថា "ទេសចរណ៍" ។ ដូចនេះពាក្យទាំងពីរនេះរួមបញ្ចូលគ្នា ទើបមានន័យថា "Eco-tourism" ដែលមានន័យថា "ទេសចរណ៍+បរិស្ថាន រឺ ទេសចរណ៍បរិស្ថាន"។ ដូច្នេះទេសចរណ៍នៅពេលនេះគឺជាប្រភេទទេសចរណ៍បរិស្ថាន ឬ គេអាចនិយាយបានម្យ៉ាងទៀតថា គឺជាប្រភេទទេសចរណ៍ដែលមានការថែរក្សា និងមានទំនាក់ទំនងជាមួយការអភិវឌ្ឍដល់ធនធានធម្មជាតិ ហើយវាសឹងតែគ្មានឆ្លោះទៅជាមួយនឹងឧស្សាហកម្មទេសចរណ៍ទេ។

លោក វ៉ាល់ បាល់យេ នាយកសាកលវិទ្យាល័យអន្តរជាតិផ្នែកស្រាវជ្រាវទេសចរណ៍បរិស្ថានរបស់ប្រទេសអូស្ត្រាលី បានអោយនិយមន័យទេសចរណ៍បរិស្ថានគឺជា "និរន្តរភាពនៃការគ្រប់គ្រងដោយផ្អែកលើមូលដ្ឋានធម្មជាតិ ផ្តល់ជូននូវវប្បធម៌និងបរិស្ថាននៃការអប់រំ ដើម្បីរួមវិភាគទានលើការអភិរក្ស និងធ្វើអោយប្រសើរនូវវិស័យទេសចរណ៍"។

លោក ភីលីព ឌាខែន នាយកសាកលវិទ្យាល័យ វិកតូរីយ៉ា បានបញ្ជាក់ថា"ជាកិច្ចការពារ និងអភិរក្សប្រកបដោយនិរន្តរភាពនៃប្រជាពលរដ្ឋមូលដ្ឋាន និងជីវចម្រុះបរិស្ថាន ដូចគ្នាដែរនឹងការផ្តល់ការអប់រំផ្នែកសារធាតុដែលមានក្នុងទេសចរណ៍បរិស្ថាន"។

ដូចនេះ "ទេសចរណ៍បរិស្ថាន រឺទេសចរណ៍បៃតង" គឺជាទស្សនៈវិស័យមួយដែលមានការរីកចម្រើនអំពីតម្រូវការ ដើម្បីធ្វើតាមគោលដៅមួយនៃការអភិរក្សធនធានធម្មជាតិ ដោយមានការទទួលស្គាល់យ៉ាងទូលំទូលាយ និងមានលក្ខណៈត្រឹមត្រូវពីសំណាក់មហាជនដែលបានរស់នៅក្នុងតំបន់នីមួយៗ។ ទន្ទឹមនឹងនេះផងដែរ ទេសចរណ៍បរិស្ថានគឺជាតំបន់ការពារធនធានធម្មជាតិ ដើម្បីបំរើដល់ការទស្សនាកំសាន្តនូវទស្សនីយភាពធម្មជាតិ និងវប្បធម៌សង្គមនៃតំបន់ណាមួយដែលជាគោលបំណងរបស់ភ្ញៀវក្នុងការស្វែងយល់ពីធម្មជាតិ ការសប្បាយរីករាយ និងដើម្បីរួមចំណែកក្នុងការជួយលើកស្ទួយបរិស្ថានធម្មជាតិ និងដើម្បីរួមចំណែកក្នុងការជួយលើកស្ទួយបរិស្ថានសង្គមធម្មជាតិ និងបរិស្ថានសង្គមវប្បធម៌ អោយមានការការរីកចម្រើនដល់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ដាច់ស្រយាល និងដើម្បីអោយពួកគេយល់ដឹងពីសារៈសំខាន់នៃទេសចរណ៍បរិស្ថាន។

### ១.៥.២ គោលការណ៍នៃអេកូទេសចរណ៍

ដោយសារតែអេកូទេសចរណ៍ គ្រាន់តែជាគំនិតមួយ មិនមែនជាការរៀបរយ ក្រុមហ៊ុនជំនួញ និងរដ្ឋាភិបាលជាច្រើនបានផ្សព្វផ្សាយអេកូទេសចរណ៍គ្មានយល់ពីគោលការណ៍ជាមូលដ្ឋានរបស់វា។ ការបង្កើតគោលការណ៍ និងវិធីនៃការទទួលស្គាល់ដែលអាចទទួលយកបានជាលក្ខណៈជាតិនិងអន្តរជាតិដែលបានធ្វើឡើងក្នុងទស្សវត្សទី៩០ក្នុងជំហ៊ានមួយយឺតៗ ពីព្រោះដំណើរការទាក់ទិននឹងម្ចាស់អាជីវកម្មពីតំបន់នានា ទាក់ទិននឹងការរៀបរយ និងពង្សាវតារ។ តំបន់នីមួយៗដែលមានឥទ្ធិពល ដោយអេកូទេសចរណ៍គួរតែអភិវឌ្ឍគោលការណ៍ និង

និតិវិធីនៃការទទួលស្គាល់ផ្ទាល់របស់ខ្លួនដោយផ្អែកលើសម្ភារៈដែលមានលក្ខណៈអន្តរជាតិ។ ដំណើរការនៃការបង្កើតគោលការណ៍ទទួលស្គាល់ជាលក្ខណៈអន្តរជាតិ គឺមិនទាន់ត្រូវបានបំពេញនោះទេ។

នៅពេលដែលគោលការណ៍ទេសចរណ៍ត្រូវបានគេអភិវឌ្ឍន៍ វាមានសារៈសំខាន់ដើម្បីពិចារណាពីបញ្ហាខ្លះដែលមិនបានបញ្ជាក់យ៉ាងពេញលេញដោយអនុវត្តដូចជា៖

១ ការត្រួតពិនិត្យពីសហគមន៍ជនជាតិដើមត្រូវរក្សា នៅពេលដែលអេកូទេសចរណ៍ត្រូវបានអភិវឌ្ឍន៍ក្នុងតំបន់ធម្មជាតិដែលពួកគេរៀបចំ និងតាំងទីលំនៅ

២. ប្រសិទ្ធភាព និងភាពត្រឹមត្រូវនៃទស្សនៈចំពោះតំបន់ដែលបានការពារ (ដែលជាចំណុចកណ្តាលចំពោះអេកូទេសចរណ៍) សម្រាប់ការអភិវឌ្ឍវប្បធម៌ និងជីវចម្រុះ។

៣. ភាពគ្រោះថ្នាក់ ដែលទេសចរមិនរៀបរយបានចូលរួមចំណែកដល់ការបន្ថយធនធាន និងចំណេះដឹងខាងទំនៀមទម្លាប់ប្រពៃណីដែលជាកម្មសិទ្ធិរបស់សហគមន៍។

៤. តើធ្វើយ៉ាងណាដើម្បីអោយមានតុល្យភាពពីសេចក្តីត្រូវការរបស់អ្នកវិនិយោគទ្រង់ទ្រាយធំនិងមធ្យម ដែលភាគច្រើនអ្នកវិនិយោគពីខាងក្រៅ ដោយសង្ឃឹមថាមានការចូលរួមរបស់ប្រជាជនក្នុងស្រុក។

**គោលការណ៍នៃអេកូទេសចរណ៍**

- កាត់បន្ថយឥទ្ធិពលអវិជ្ជមានមានចំពោះវប្បធម៌ និងធម្មជាតិដែលអាចបំផ្លាញដល់ទិសដៅទេសចរ
- អប់រំអ្នកធ្វើដំណើរពីសារៈសំខាន់នៃការអភិរក្ស
- គូសបញ្ជាក់ពីសារៈសំខាន់នៃជំនួញដែលមានការទទួលខុសត្រូវដែលធ្វើការរួមគ្នាជាមួយអាជ្ញាធរក្នុងស្រុក និងមនុស្សដែលឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជនក្នុងស្រុក និងផ្តល់នូវផលប្រយោជន៍ដល់ការអភិរក្ស
- ត្រូវមានប្រាក់ចំណូលផ្ទាល់ចំពោះការអភិរក្ស និងការគ្រប់គ្រងនៃតំបន់ធម្មជាតិ និងតំបន់ដែលបានការពារ
- គូសបញ្ជាក់ពីតំបន់ទេសចរណ៍ និងផែនការគ្រប់គ្រងទេសចរដែលបង្កើតសំរាប់តំបន់ផ្សេងៗ និងតំបន់ធម្មជាតិដែលត្រូវបានរៀបចំអោយក្លាយទៅជាទិសដៅអេកូទេសចរណ៍
- គូសបញ្ជាក់ពីការប្រើប្រាស់ និងការសិក្សាពីបរិស្ថាន និងសង្គមព្រមទាំងកម្មវិធីត្រួតពិនិត្យរយៈពេលវែងដើម្បីឈានដល់ការកាត់បន្ថយឥទ្ធិពល
- ជំរុញអោយមានផលប្រយោជន៍កាន់តែច្រើនសម្រាប់ប្រទេសម្ចាស់ជំនួញក្នុងស្រុក និងសហគមន៍ ជាពិសេសប្រជាជនដែលរស់នៅក្នុងនិងក្បែរតំបន់ធម្មជាតិ និងតំបន់ដែលបានការពារ
- ស្វែងរកដើម្បីធានាថា ការអភិវឌ្ឍវិស័យទេសចរណ៍កុំអោយប៉ះពាល់ដល់បរិស្ថាន និងសង្គមដែលបានកំណត់ដោយស្រាវជ្រាវនិងប្រជាជនក្នុងស្រុក
- ដោយផ្អែកលើហេដ្ឋារចនាសម្ព័ន្ធដែលបានអភិវឌ្ឍន៍មិនប៉ះពាល់ដល់បរិស្ថាន កាត់បន្ថយជាតិផ្សេង អភិរក្សរុក្ខជាតិនិងសត្វព្រៃក្នុងតំបន់ និងដែលសមស្របជាមួយបរិស្ថានធម្មជាតិ និងវប្បធម៌។

### ១.៥.៣ សារៈសំខាន់អេកូទេសចរណ៍

សារៈសំខាន់ជាច្រើនដែលបានកើតចេញពីអេកូទេសចរណ៍គឺមានដូចជា៖ តាមរយៈសកម្មភាពរបស់ទេសចរណ៍ក្នុងសហគមន៍ដែលទទួលបានមូលនិធិ និងសកម្មភាពសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រផ្តល់ការអភិវឌ្ឍន៍ជីវៈចម្រុះ។ ប្រជាជនក្នុងសហគមន៍នឹងទទួលបានសិទ្ធិអំណាចក្នុងការគ្រប់គ្រងធនធានរបស់ពួកគេ។ ប្រជាជននៅក្នុងសហគមន៍ នឹងទទួលបានកម្រយ៉ាងច្រើនក្នុងសកម្មភាពរបស់ទេសចរណ៍ដូចជា៖ សេវាកម្មស្នាក់នៅ សេវាកម្មម្ហូបអាហារនិងភេសជ្ជៈ ផលិតផលកសិកម្ម ការសាងសង់ និងសកម្មភាពដឹកជញ្ជូន។ ប្រាក់ចំណូលបានមកពីការលក់សំបុត្រចូលទស្សនា និងថ្លៃការពារសុវត្ថិភាព ត្រូវផ្តល់ចំណូលថវិកាជាតិតាមរយៈការបង់ពន្ធ។ លើសពីនេះទៅទៀតប្រជាជនក្នុងសហគមន៍ទទួលបាននូវបទពិសោធន៍ថ្មីៗ និងបន្ថែមទៀតទៅលើចំណេះដឹង ភាសា និងសកម្មភាពលក់ផលិតផលដល់ភ្ញៀវ។ ការផ្តល់ពីចំណេះដឹងថ្មីៗអំពីប្រព័ន្ធអេកូឡូស៊ីទាំងអ្នកទស្សនា និងប្រជាជនមូលដ្ឋានតាមរយៈការរកឃើញថ្មីៗរបស់អ្នកស្រាវជ្រាវទៅតាមតំបន់នោះ។ ការផ្សព្វផ្សាយក្រោយពីការទទួលបាននូវការបកស្រាយអំពីផលប្រយោជន៍នៃប្រព័ន្ធអេកូឡូស៊ីដល់ប្រទេសទាំងមូលស្តីអំពីធនធានធម្មជាតិដែលមាននៅក្នុងតំបន់ទេសចរណ៍។

### ១.៥.៤ ទិសដៅអេកូទេសចរណ៍

អេកូទេសចរណ៍ ស្វែងរកបទពិសោធន៍ផ្សេងៗដែលផ្តល់ភាពទាក់ទាញយ៉ាងជិតស្និតទៅនឹងធម្មជាតិ និងសហគមន៍ក្នុងស្រុក។ ទិសដៅដែលទាក់ទាញទេសចរណ៍ទាំងអស់នេះ ត្រូវការពារធនធានរបស់ខ្លួននៅពេលសំរួលបញ្ចូលជាមួយសហគមន៍ក្នុងស្រុក។ វាមានលក្ខណៈជារួម ប៉ុន្តែមិនត្រឹមត្រូវដែលផ្នែកឯកជនមិនមានការទទួលខុសត្រូវក្នុងការការពារបរិស្ថាន និងសហគមន៍ក្នុងស្រុក។ ទោះបីជាយ៉ាងណាក៏ដោយ វាជាការពិតដែលថាការធ្វើអន្តរាគមន៍របស់ម្ចាស់អាជីវកម្មទាំងអស់គឺតំរូវអោយមាន។ ជាដំបូង រាជរដ្ឋាភិបាល គឺទទួលខុសត្រូវការរៀបចំផែនការ ការបង្កើតគោលនយោបាយ និងការកំណត់តំបន់ទេសចរណ៍ដែលធានាថា ទិសដៅទាំងអស់នេះ គឺមិនបានសាងសង់លើសគោលការណ៍។ រាជរដ្ឋាភិបាលក៏ទទួលខុសត្រូវផងដែរ អំពីប្រព័ន្ធកាកសំណល់និងប្រព័ន្ធចំរុះទឹកស្អាត និងធនធានថាមពល។ ប្រសិនបើគ្មានចូលជាធរមាន និងការអនុវត្តច្បាប់បរិស្ថានដែលមានស្រាប់ និងប្រសិនបើតំបន់ធម្មជាតិទាំងនេះត្រូវបានអនុវត្តន៍ដោយគ្មានការប្រមើលមើលច្បាស់លាស់សម្បទានទាំងអស់នោះប្រាកដនឹងត្រូវបានគេសាងសង់មិនត្រឹមត្រូវក្នុងកន្លែងនោះ។ សូម្បីក្នុងតំបន់ដាច់ស្រយាលដែលអេកូទេសចរណ៍ត្រូវបានគេអភិវឌ្ឍន៍ វាជាការចាំបាច់ត្រូវកំណត់ពី ស្តង់ដានៃការអភិវឌ្ឍដែលបានយល់ព្រមក្នុងការសហការជាមួយម្ចាស់អាជីវកម្មក្នុងស្រុក ជាពិសេសអ្នកតំណាងសហគមន៍ក្នុងស្រុក។ ប្រសិនបើសំណង់ទេសចរណ៍ធំៗត្រូវបានគេសាងសង់ អាគារជញ្ជាំងខ្ពស់ៗ តារាងវាយកូនហ្គោល ក្លិបសំរាប់ភ្ញៀវ និងសេវាកម្មតំរង់ជួរ ផ្នែកទាំងអស់នេះ គឺមិនសមរម្យសំរាប់អេកូទេសចរណ៍ទេ។ ទស្សនៈនៃទិសដៅអេកូទេសចរណ៍គឺថ្មី និងគ្មានគោលការណ៍កំណត់អំពីវា។ វាបានលេចឡើងយ៉ាងច្បាស់ ពីព្រោះរាជរដ្ឋាភិបាល គិតថាផ្សព្វផ្សាយអេកូទេសចរណ៍ក្នុងទិសដៅដែលបានអភិវឌ្ឍន៍រួចជាស្រេចដោយគ្មានគោលការណ៍ជាមូលដ្ឋានដែលអាចទាក់ទាញភ្ញៀវអេកូទេសចរណ៍បាន និងនៅពេលនោះដែរ គ្មានការគោរពដល់បរិស្ថាន ឬសហគមន៍ក្នុងស្រុក។ គំរូមិនត្រឹមត្រូវនៃការអភិវឌ្ឍទិសដៅប្រភេទនេះ ដែលត្រូវបានគេយកការណ៍ពីតំបន់អាស៊ីអាគ្នេយ៍ដែលមានករណីមួយ គឺជនជាតិដើមរាប់លាននាក់ត្រូវបានអោយតាំងលំនៅថ្មីពីទឹកដីកំណើតរបស់ពួកគេ ហើយត្រូវបានគេផ្តល់សំណងជាការងារក្នុងផ្នែកអេកូទេសចរណ៍ក្នុងទីកន្លែងថ្មី។ នេះមិនបានបញ្ជាក់ច្បាស់ថា ជាអេកូ

ទេសចរណ៍ និងបានបង្ហាញថា អេកូទេសចរណ៍អាចត្រូវបានគេកំណត់ខុស និងដោះស្រាយមិនត្រឹមត្រូវរបស់រាជរដ្ឋាភិបាល។

ការរៀបចំផែនការ និងគ្រប់គ្រងទិសដៅនឹងកំណត់ថា តើអេកូទេសចរណ៍អាចជំរុញអោយបានល្អនៅទីនោះយ៉ាងដូចម្តេច?

ទោះបីជាយ៉ាងណាក៏ដោយ វាគឺកម្រណាស់ដែលឃើញនូវការធ្វើផែនការ និងការគ្រប់គ្រងទេសចរណ៍ថ្នាក់តំបន់បញ្ចូលគ្នាដែលមិនបានលើកអំពីយុទ្ធសាស្ត្រ។ ការធ្វើផែនការអំពីទិសដៅអេកូទេសចរណ៍ គឺពឹងផ្អែកលើទិន្នន័យជាមូលដ្ឋាននៃកត្តាបរិស្ថាននិងសង្គមយុទ្ធសាស្ត្រកំណត់តំបន់ទេសចរណ៍ និងបញ្ញត្តិផ្សេងៗដែលអាចការពារពីការបំផ្លាញប្រព័ន្ធអេកូទេសចរណ៍ ការចូលរួមរបស់ប្រជាជនក្នុងស្រុក ក្នុងការអភិវឌ្ឍស្តង់ដារួមមួយ និងការត្រួតពិនិត្យរយៈពេលវែង។

**លក្ខណៈសម្បត្តិនៃទិសដៅអេកូទេសចរណ៍**

- លក្ខណៈធម្មជាតិដែលត្រូវបានការពារក្នុងតំបន់អភិរក្ស
- ការអភិវឌ្ឍតំបន់ដង់ស៊ីតេទាប ខណៈដែលតំបន់ធម្មជាតិគឺមានច្រើន និងទេសភាពដែលមាន គឺមិនបានគ្រប់គ្រង
- ភស្តុតាងបង្ហាញថា ទេសចរណ៍ គឺមិនត្រូវប៉ះពាល់ដល់ប្រព័ន្ធធម្មជាតិ ដូចជាផ្លូវទឹក តំបន់ឆ្នេរ តំបន់ដីសើម និងសត្វព្រៃ
- ជំនួញតូចៗក្នុងសហគមន៍ដែលកំពុងលូតលាស់រួមមាន បញ្ឈរលក់ម្ហូបអាហារ និងសហគ្រាសសិប្បកម្មផ្សេងៗដែលជាកម្មសិទ្ធិរបស់ប្រជាជនក្នុងស្រុក
- តំបន់កំសាន្តជាច្រើន ដែលត្រូវបានកំណត់ដើម្បីការពារធនធានដែលងាយទទួលរងរួមមានផ្លូវសំរាប់ជិះកង់ និងផ្លូវផ្សេងៗដែលបានចូលរួមដោយប្រជាជនក្នុងស្រុក និងភ្ញៀវ
- ការលូតលាស់ផ្នែកផ្ទះសំណាក់ សណ្ឋាគារ ភោជនីយដ្ឋាន និងជំនួញផ្សេងៗដែលគ្រប់គ្រង ដោយប្រជាជនក្នុងស្រុកបានផ្តល់នូវការធ្វើបដិសណ្ឋារកិច្ចរាក់ទាក់យ៉ាងពិតៗ និងបុគ្គលិកមានជំនាញយ៉ាងប៉ិនប្រសព្វ
- ព្រឹត្តិការណ៍ និងពិធីបុណ្យក្នុងស្រុកផ្សេងៗ ដែលបង្ហាញពីគំនិតអភិវឌ្ឍន៍តំលៃបរិស្ថានធម្មជាតិក្នុងសហគមន៍ និងកេរ្តិ៍តំណែលវប្បធម៌
- ការសំអាត និងសម្ភារសាធារណៈសំរាប់ភ្ញៀវទេសចរណ៍ និងប្រជាជនក្នុងស្រុកត្រូវរួបរួមថែរក្សាដូចជាបន្ទប់ទឹកបង្គន់អនាម័យសាធារណៈ
- ការទំនាក់ទំនងយ៉ាងរាក់ទាក់រវាងប្រជាជនក្នុងស្រុក និងភ្ញៀវទេសចរណ៍នៅតាមកន្លែងធម្មជាតិដូចជានៅតាមហាងក្នុងស្រុក ឬតាមបង់ក្បែរមាត់សមុទ្រ។

## ១.៦ សហគមន៍អេកូទេសចរណ៍

### ១.៦.១ និយមន័យសហគមន៍

ពាក្យថា«សហគមន៍» ត្រូវបានគេផ្តល់និយមន័យជាច្រើនបែបផ្អែកតាមលក្ខខណ្ឌនានានៃកម្មវត្ថុជាសារវន្តរបស់អ្នកប្រាជ្ញ ស្ថាប័ននានា និងមុខវិជ្ជាសិក្សា។ ពាក្យ"សហគមន៍"ត្រូវបានគេប្រទះឃើញនិងប្រើប្រាស់ជាញឹក

ញាប់នៅក្នុងជីវភាពរស់នៅធម្មតា និងក្នុងមុខវិជ្ជាមួយចំនួនដូចជា បរិស្ថានវិទ្យា ភូមិវិទ្យា ផែនដីវិទ្យា សង្គមវិទ្យា ចិត្តវិទ្យា និងសេដ្ឋកិច្ចវិទ្យា។ ក្នុងអក្សរសាស្ត្រខ្មែរ "សហគមន៍" មានន័យថាការប្រមូលផ្តុំ ការទៅជាមួយ ដំណើរជាមួយគ្នា ប្រជុំភូមិ ឬអ្នកស្រុកប្រកបរបរចូលគ្នា។ វិទ្យាសាស្ត្រផែនដីវិទ្យាផ្តល់ន័យឲ្យ សហគមន៍ ថាជាបណ្តាភាវៈនៃសារពាង្គកាយមានជីវិត រួមមានសត្វ រុក្ខជាតិ និងមីក្រូសារពាង្គកាយ ស្ថិតក្នុងមជ្ឈដ្ឋានរស់នៅមួយ និងមានលក្ខខណ្ឌជីវិតប្រហាក់ប្រហែលគ្នា។ យោងតាមការយល់ឃើញរបស់សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវជាច្រើនរូបនៅលើពិភពលោកគេក៏បានច្របាច់បញ្ចូលនូវអត្ថន័យដែលមានលក្ខណៈស្រដៀងគ្នាទៅតាមការបកស្រាយរបស់ពួកគេ និងយោងទៅតាមច្បាប់ស្តីពីទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា សហគមន៍ឧស្សាហកម្មទេសចរណ៍ ត្រូវបានសំដៅដល់នីតិបុគ្គលជាតំណាងឲ្យ ក្រុមអាជីវកម្មទេសចរណ៍ ដែលមានប្រភេទ និងសកម្មភាពប្រហាក់ប្រហែលគ្នាហើយបង្កើតឡើងក្នុងគោលបំណងជំរុញ និងការពារផលប្រយោជន៍រួមរបស់ក្រុមខ្លួន។

### ១.៦.២ តួនាទីសហគមន៍ក្នុងអេកូទេសចរណ៍

ការរីកចម្រើននៃបរិបទ និងផ្នត់គំនិតនាំដល់ការយកចិត្តទុកដាក់ខ្ពស់អំពីផលអវិជ្ជមាន ដែលអាចកើតមានឡើងដោយសារតែការអភិវឌ្ឍគ្មានតម្លាភាពស្របពេលជាមួយគ្នា និងការមើលឃើញអំពីសារប្រយោជន៍ នៃវត្តមានសហគមន៍ក្នុងការអភិវឌ្ឍអេកូទេសចរណ៍ និងការធានាបាននិរន្តរភាពបានជំរុញនិន្នាការចូលរួមរបស់សហគមន៍កាន់តែខ្ពស់ឡើងៗ។ ការអភិវឌ្ឍអេកូទេសចរណ៍ដោយមានការចូលរួមពីសហគមន៍ជាបុព្វហេតុមួយនាំឲ្យមានការយល់ដឹងកាន់តែច្រើនរបស់សហគមន៍អំពីកាលានុវត្តភាព( opportunities) នៃវត្តមានអេកូទេសចរណ៍។ នៅកន្លែងសហគមន៍បានរៀបចំបានល្អ និងមានកម្មសិទ្ធដីធ្លីដែលជាកេរ្តិ៍ដំណែល គេពិនិត្យឃើញថា សហគមន៍នោះទទួលបានជោគជ័យច្រើន ក្នុងការទាញយកនូវផលប្រយោជន៍សេដ្ឋកិច្ចពីអេកូទេសចរណ៍នៅតំបន់ធម្មជាតិ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ប្រជាជនអន្តោគ្រាមជាច្រើន និងសហគមន៍ផ្សេងៗទៀតបានស្ម័គ្រចិត្តទទួលយកអេកូទេសចរណ៍ និងចាត់ថាវិស័យនេះមានតម្លៃជាផ្នែកមួយក្នុងយុទ្ធសាស្ត្រអភិវឌ្ឍរបស់ខ្លួន។ ជាការពិតណាស់ សហគមន៍ ឬសមាជិកសហគមន៍មិនមែនទាំងអស់សុទ្ធតែមានបំណងចូលរួមក្នុងសកម្មភាពអេកូទេសចរណ៍ទេ។ បែបនេះអ្នករៀបចំផែនការ និងអ្នកអភិវឌ្ឍន៍( Developer) ឬតួអង្គអភិវឌ្ឍន៍ ( Develop Actor)គួរតែគោរពសេចក្តីសម្រេចចិត្តរបស់អ្នកទាំងនោះផង។ ទោះជាយ៉ាងនេះសម្រាប់អ្នកទាំងឡាយណាដែលមានចំណែកពាក់ព័ន្ធ គឺអាចជ្រើសរើសប្រភេទនៃការចូលរួមរបស់ខ្លួនតាមលំដាប់កម្រិតមួយចំនួនដូចជាៈ

- ✓ ជួលដីទៅឲ្យប្រតិបត្តិករដើម្បីអភិវឌ្ឍន៍
- ✓ ធ្វើការជាបុគ្គលិកពេញម៉ោង ឬក្រៅម៉ោងឬតាមរដូវកាលនៅក្នុងក្រុមហ៊ុនទេសចរណ៍
- ✓ ផ្តល់សេវាកម្មដល់ប្រតិបត្តិករទេសចរណ៍
- ✓ បង្កើតសម្ព័ន្ធអាជីវករជាមួយនឹងការីទេសចរណ៍ដោយសហគមន៍ជាអ្នកបម្រើសេវាកម្មភាគច្រើនក្នុងខណៈពេលដែលដៃគូធ្វើការជាអ្នករៀបចំគ្រប់គ្រងម៉ាឃីតធីង ទីផ្សា ភស្តុភារមគ្គុទ្ទេសក៍ទេសចរណ៍
- ✓ ប្រតិបត្តិការជាកម្មវិធីសហគមន៍ឯករាជ្យ
- ✓ មុខងារតួនាទីទាំងអស់ដែលត្រូវជ្រើសរើសដោយសហគមន៍គួរតែផ្តល់ផលប្រយោជន៍ សមត្ថភាព

✓ រៀបចំ បទពិសោធន៍ ការចាប់អារម្មណ៍លើវប្បធម៌ វត្តមាននៃភាពជាអ្នកដឹកនាំពូកែ គុណភាពនៃធនធានវប្បធម៌ និងធម្មជាតិ តម្រូវការទេសចរណ៍កាលានុវត្តភាពនៃការហ្វឹកហ្វឺនភាពអាចរកបាននូវដៃគូ និងផលប្រយោជន៍ឯកជន។

### ១.៦.៣ ផលប្រយោជន៍ ផលអវិជ្ជមានចំពោះសហគមន៍

ក.ផលប្រយោជន៍

- **និរន្តរភាពប្រាក់ចំនូល** ៖ នៅពេលដែលសហគមន៍មានចំណែកពិតប្រាកដក្នុងដំណើរការអភិវឌ្ឍអេកូទេសចរណ៍ ប្រភពចំណូលត្រូវបានបង្កើតឡើងសម្រាប់សហគមន៍ដោយសារឱកាសការងារ។
- **ការលើកកម្ពស់សេវាកម្ម** ៖ គោលបំណងចម្បងនៃការរៀបចំអភិវឌ្ឍន៍ អេកូទេសចរណ៍គឺមានមុខព្រួញភ្ជាប់ជាសំខាន់លើការអភិរក្សបរិស្ថាន និងការលើកស្ទួយកម្រឹតជីវភាពរស់នៅរបស់សហគមន៍។ អេកូទេសចរណ៍បានជួយកាត់បន្ថយការកាប់ព្រៃឈើ និងការប្រមាញ់សត្វព្រៃ និងត្រូវបានតម្រូវសហគមន៍ឲ្យដាំដើមឈើឡើងវិញ ជំរុញសហគមន៍ចូលរួមចំណែកក្នុងការថែរក្សាព្រៃឈើ និងសត្វព្រៃដែលធ្លាប់មាននៅក្នុងតំបន់។
- **អំណាចនៃការដោះដូរខាងវប្បធម៌** ៖ ទស្សនៈកិច្ចចំពោះវប្បធម៌ និងទំនៀមទំលាប់អន្តោគ្រាមជារឿយៗមានក្នុងខ្សែទស្សនៈកិច្ចដែលឆ្ពោះទៅតំបន់ធម្មជាតិ។ ឱកាសស្វែងយល់អំពីវប្បធម៌ និងទំនៀមទំលាប់កំពុងតែទទួលបានបន្ថែមតម្លៃជាពិសេសនៅក្នុងកម្មវិធីអេកូទេសចរណ៍។ ពេលមានការចូលទៅលេងតែទទួលបានការឲ្យតម្លៃ រីឯការចូលរួមរបស់សហគមន៍កម្សាន្ត គេសង្កេតឃើញថា សហគមន៍ហាក់បីដូចជាមានអារម្មណ៍យល់ថាពួកគាត់មានកិត្តិយសដោយសារមានមនុស្សមកពីខាងក្រៅចង់ស្វែងយល់អំពីទំនៀមទម្លាប់ពួកគេ តែពួកគេក៏ដឹងដែរថាក្នុងការធ្វើដំណើររបស់ភ្ញៀវមួយចំនួនគឺក៏មានបំណងចង់ផ្សព្វផ្សាយវប្បធម៌របស់ខ្លួនទៅកាន់សហគមន៍វិញផងដែរ។

ខ. ផលអវិជ្ជមាន

- **កំណើនថ្លៃ** ៖ ថ្លៃអាចក្លាយជាបញ្ហាចម្បងមួយនៅពេលដែលភ្ញៀវ និងសហគមន៍ត្រូវការទំនិញ សម្ភារៈប្រើប្រាស់។ ថ្លៃនិងកើនឡើងដល់កម្រឹតកំពូលនៅពេលដែលសហគមន៍ឃើញថាអ្នកមកពីក្រៅស្ម័គ្រចិត្តចំណាយប្រាក់ច្រើនទៅលើទំនិញ សម្ភារៈ និងសេវាកម្មនានាដែលខុសពីសហគមន៍។
- **ការគ្រប់គ្រងរបស់អ្នកខាងក្រៅ** ៖ ការគំរាមកំហែងដ៏ធំបំផុតដែលបណ្តាលឲ្យសហគមន៍បាត់បង់នូវភាពជាម្ចាស់កម្មសិទ្ធលើទឹកដីដែលខ្លួនមានគឺដោយសារតែកំណើនថ្លៃដី។ ពេលថ្លៃដីកើនឡើងសហគមន៍អាចនាំគ្នាលក់ដីដែលខ្លួនមានឲ្យទៅពួកអ្នកអភិវឌ្ឍ និងអ្នកវិនិយោគខាងក្រៅ។ ដោយសារវាបានក្លាយទៅជាកម្មសិទ្ធរបស់អ្នកខាងក្រៅ ឥទ្ធិពលអវិជ្ជមានចំពោះសហគមន៍នឹងកើនឡើងព្រោះផ្តល់ទំនិញ និងសេវាកម្មសំខាន់ៗនិងត្រូវស្ថិតក្រោមការត្រួតត្រារបស់ពួកគេ សហគមន៍និងត្រូវបាត់បង់ឱកាសអាជីវកម្ម។
- **ភាពផ្ទុះផ្លាយនៃសេដ្ឋកិច្ច** ៖ ភាពផ្ទុះផ្លាយនៃសេដ្ឋកិច្ចគឺជាលំហូរចេញនៃរូបិយប័ណ្ណទៅក្រៅប្រទេស។ វាអាចកើនឡើងដោយសារការប្រកួតប្រជែងរវាងផលិតផលដែលលក់ក្នុងស្រុក និងផលិតផលនៅ

បរទេសហើយគ្រោះថ្នាក់នឹងកើតមានឡើង បើសិនជាភ្ញៀវមានអារម្មណ៍ថាផលិតផលនាំចូលមានគុណភាព ឬប្រណីតជាង។

- **ការផ្លាស់ប្តូរវប្បធម៌** ៖ នៅពេលចំនួនភ្ញៀវកាន់តែកើនឡើងការជ្រាតចូលនៃវប្បធម៌ចំរុះក៏មានឡើងកាន់តែច្រើន ហើយនៅពេលដែលប្រជាជននៅក្នុងសហគមន៍មានអារម្មណ៍សុំ និងវប្បធម៌ដែលខ្លួនមាន ហើយមានចំណាប់អារម្មណ៍ទៅលើវប្បធម៌ទំនើបដែលភ្ញៀវនាំចូលមកវិញនោះគំនិតនៃការចង់ផ្លាស់ប្តូរវប្បធម៌ និងកើតមានឡើង (ភាគច្រើនយុវវ័យក្នុងសហគមន៍) នោះហានិភ័យនឹងកើតមានឡើងព្រោះភ្ញៀវទេសចរណ៍ខ្លះពួកគេចង់មកកម្សាន្តនៅទីនោះគឺមានគោលបំណងមួយទៀតចង់សិក្សាពីវប្បធម៌រស់នៅដើមក្នុងសហគមន៍នោះតែនៅពេលដែលអ្វីៗត្រូវបានផ្លាស់ប្តូរពួកគេ និងលែងមានបំណងមកកម្សាន្តជាមិនខាន។

## ១.៧ សក្តានុពលនៃវិស័យទេសចរណ៍

### ១.៧.១ ធនធានទាក់ទាញទេសចរណ៍

**ក. ធនធានធម្មជាតិ**

ធនធានធម្មជាតិ ពិតជាមានសារៈសំខាន់ណាស់ក្នុងគោលដៅបម្រើអោយវិស័យទេសចរណ៍ដែលមានដូចជា ទឹកជ្រោះ ផ្លូវទឹក រុក្ខជាតិនិងសត្វព្រៃ ជាសក្តានុពលដែលបម្រើដល់វិស័យទេសចរណ៍។ ប្រទេសកម្ពុជាមានទេសភាពខុសៗគ្នាជាច្រើនផ្សេងទៀត គឺ ព្រៃតំបន់ខ្ពង់រាប (រួមមានតំបន់ភ្នំក្រវាញ ដងរែក និងភ្នំឆ្លង ព្រៃលិចទឹក បឹងទន្លេសាប និង ប្រព័ន្ធទន្លេមេគង្គ វាលទំនាប ខាងកើត ឬតំបន់ខ្ពង់រាប ព្រៃឈើកណ្តាល តំបន់ឆ្នេរសមុទ្រដែលរួមមានដីល្បាប់ កោងកាង និង កោះ ឈូងសមុទ្រថៃ។

**ខ. ជំនឿសាសនា**

ប្រជាជននៅទីនោះគោរពបូជាព្រះពុទ្ធសាសនា គ្រឹស្តសាសនា ឥស្លាមសាសនា ស្របតាមជំនឿជឿជាក់របស់ប្រជាជនរៀងៗខ្លួន។

**គ. ធនធានកែច្នៃ**

ធនធានកែច្នៃត្រូវបានបែងចែកចេញជាពីរដូចខាងក្រោម៖

- មូលដ្ឋានសម្ភារៈ មានដូចជាសណ្ឋាគារ ភោជនីយដ្ឋានប្រតិបត្តិការ ដំណើរកំសាន្តសេវាកម្ម ព័ត៌មានទេសចរណ៍ រង្គសាល ខារ៉ាអូខេ។ល។
- ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ រួមមានការដឹកជញ្ជូន គមនាគមន៍ ការផ្គត់ផ្គង់ទឹកស្អាត ថាមពលអគ្គិសនី ការគ្រប់គ្រងកាកសំណល់ ទូរគមនាគមន៍ និងប្រៃសណីយ៍។ល។

## ១.៨ សម្បទាទេសចរណ៍ និងសេវាកម្មទេសចរណ៍

### ១.៨.១សេវាកម្មស្នាក់នៅ

សេវាកម្មស្នាក់នៅជាសមាសធាតុដ៏មានសារៈសំខាន់បំផុត សម្រាប់សេចក្តីត្រូវការរបស់អ្នកដំណើរ និងទេសចរណ៍ ប្រសិនបើគ្មានសេវាស្នាក់នៅទេសចរណ៍ក៏មិនអាចប្រព្រឹតនៅបានដែរ។ ព្រោះថាជាមធ្យោបាយស្នាក់អាស្រ័យ ជាសមាសធាតុមួយដ៏សំខាន់បំផុតរបស់ផលិតផលទេសចរណ៍ភ្ញៀវនៅពេលដែលធ្វើដំណើរចាក

ចេញពីលំនៅដ្ឋានអចិន្ត្រៃយ៍របស់ពួកគេនៅក្នុងតំបន់គោលដៅទេសចរណ៍ផ្សេងទៀត មធ្យោបាយផ្សេងគ្នាជាច្រើនដើម្បីធ្វើការចាត់ថ្នាក់ប្រភេទ នៃកន្លែងស្នាក់នៅ។ កន្លែងស្នាក់នៅ ត្រូវបានកំណត់ដូចខាងក្រោមៈ

- សណ្ឋាគារ
- ម៉ូតែល
- សណ្ឋាគារ
- ផ្ទះភ្ញៀវ

**១.៨.២ សេវាកម្មម្ហូបនិងអាហារ**

មូលដ្ឋានសេវាកម្មហូបចុកមានសារៈសំខាន់សម្រាប់បំពេញនូវសេចក្តីត្រូវការម្ហូបអាហាររបស់មនុស្សទូទៅពិសេសទេសចរ។ លក្ខណៈពិសេសនៃសេចក្តីត្រូវការទាំងឡាយរបស់ទេសចរ គឺទាមទារធ្វើយ៉ាងណាអោយមានកន្លែងហូបចុកស្ថិតនៅជិតបំផុតពីកន្លែងស្នាក់នៅរបស់ខ្លួន នៅក្នុងនោះមិនមែនមានន័យថា រាល់ការស្នាក់នៅទាំងអស់ ត្រូវតែមានមូលដ្ឋានសេវាកម្មម្ហូបអាហារនោះទេ ក៏ប៉ុន្តែជាទូទៅអាជីវកម្មស្នាក់នៅដូចជាសណ្ឋាគារ និងផ្ទះសំណាក់មួយចំនួនដែលធ្វើសកម្មភាពគួរតែភ្ជាប់នូវសេវាកម្មម្ហូបអាហារ។

**១.៨.៣ សេវាកម្មដឹកជញ្ជូន**

មធ្យោបាយដឹកជញ្ជូន ជាចំណុចកណ្តាល ឬចំណុចបេះដូងនៃឧស្សាហកម្ម ដែលវាជាប់ទាក់ទងរវាងគេហដ្ឋានទៅកាន់គោលដៅទេសចរណ៍ កន្លែងស្នាក់នៅ កន្លែងទាក់ទាញទេសចរណ៍ និងកន្លែងផ្សេងៗទៀត ទៅនឹងការធ្វើដំណើររបស់ទេសចរ។ ប្រសិទ្ធភាពនៃការដឹកជញ្ជូន គឺភាពងាយស្រួលសុវត្ថិភាព ទៀងទាត់ពេលវេលាហើយរាល់ការចំណាយរបស់ម្នាក់គឺច្រើនតែចំណាយទៅលើការដឹកជញ្ជូននេះផងដែរ។ ការដឹកជញ្ជូនទាំងនោះមានដូចជា ការដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវដែក ផ្លូវថ្នល់ និងការដឹកជញ្ជូនតាមផ្លូវអាកាស។

**១.៨.៤ សកម្មភាពកម្សាន្តផ្សេងៗ**

ជាមួយនឹងលក្ខណៈពិសេសនៃការរីកចម្រើនខាងវិស័យទេសចរណ៍ នាសម័យនេះគឺនាំអោយប្រជាពលរដ្ឋទូទៅក៏ដូចជាទេសចរ កាន់តែបញ្ចេញនូវសកម្មភាពខ្លាំងក្លាដើម្បីធ្វើការកម្សាន្តផ្សេងៗ។ ការផ្លាស់ប្តូរនៃរចនាបទការរស់នៅ ការជំនួសអោយធ្វើការដោយកម្លាំងប្រាជ្ញាជាមួយនឹងកត្តាវប្បធម៌ អរិយធម៌ក្នុងពេលទំនេរបានធ្វើអោយពួកគេយកចិត្តទុកដាក់ក្នុងការបញ្ចេញនូវសកម្មភាពកំសាន្តក្នុងទម្រង់នៃសកម្មភាពកម្លាំងទេសចរ ហេតុនេះបានធ្វើឲ្យអ្នកដែលចង់ទាញយកប្រយោជន៍ពីទេសចរណ៍ នៅគ្នាបង្កើតឡើងនូវសេវាកម្មទាំងឡាយដែលបង្កលក្ខណៈងាយស្រួលដល់ការធ្វើអោយសម្រេចនូវសេចក្តីត្រូវការរបស់ទេសចរ ដែលទាក់ទងនឹងសេវាកម្មទាំងនោះ។ សេវាកម្មដែលរៀបចំ ឬបានបង្កើតឡើងដូចបានបង្ហាញនិងរៀបរាប់ និងអត្ថន័យទាក់ទងនឹងសង្គម សុខមាលភាពសេដ្ឋកិច្ច។

## ១.៩ ហេដ្ឋារចនាសម្ព័ន្ធដែលបម្រើអោយវិស័យទេសចរណ៍

### ១.៩.១ ការដឹកជញ្ជូន

ការដឹកជញ្ជូន ជាសក្តានុពលដ៏សំខាន់ដល់ការអភិវឌ្ឍវិស័យទេសចរណ៍ ព្រោះបានបម្រើដល់ទេសចរណ៍ទេសភាពប្លែកៗ ដូចជា ធនធានជីវៈចម្រុះ បក្សាបក្សី និងសកម្មភាពផ្សេងៗរបស់ប្រជាជនដែលរស់

នៅអាស្រ័យលើធនធានទាំងអស់នោះ។ អ្វីដែលសំខាន់នោះ គឺបម្រើដល់ការដោះដូរទំនិញ ការបញ្ជៀសដល់ការកកស្ទះចរាចរណ៍ រួមទាំងជួយសម្រួលដល់បរិស្ថានផងដែរ។

**១.៩.២ ការផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាត**

ប្រព័ន្ធទឹកស្អាត គឺជាតម្រូវការជាចាំបាច់សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងគ្រប់ផ្នែកទាំងអស់។ រីឯក្នុងវិស័យទេសចរណ៍វិញ ប្រព័ន្ធទឹកស្អាតត្រូវបានគេយកទៅប្រើប្រាស់នៅតាមសេវាកម្មទេសចរណ៍ផ្សេងៗទៀតជាចាំបាច់។ ផែនការផ្គត់ផ្គង់ទឹកដល់គ្រប់ទិសទី ផែនការជីកអណ្តូងនៅតាមភូមិឃុំ និងតំបន់ដែលនៅឆ្ងាយៗសម្រាប់សេចក្តីត្រូវការរបស់ប្រជាជន និងសម្រាប់បម្រើអោយវិស័យទេសចរណ៍ផងដែរ។

**១.៩.៣ ការផ្គត់ផ្គង់ប្រព័ន្ធអគ្គិសនី**

ថាមពលអគ្គិសនី បានដើរតួនាទីយ៉ាងសំខាន់សម្រាប់ការប្រើប្រាស់នៅក្នុងឧស្សាហកម្ម និងសិប្បកម្មជាដើម។ រីឯនៅក្នុងវិស័យទេសចរណ៍វិញ ថាមពលអគ្គិសនីត្រូវបានគេប្រើប្រាស់នៅតាមបណ្តាសណ្ឋាគារ ភោជនីយដ្ឋាន រង្គសាល រមណីយដ្ឋានទេសចរណ៍ និងប្រើប្រាស់នូវតាមសេវាកម្មទេសចរណ៍ផ្សេងៗទៀតជាចាំបាច់។ ផែនការចំពោះការបែងចែកបណ្តាញអគ្គិសនីអោយដល់ប្រជាពលរដ្ឋ ដល់ការប្រើប្រាស់ក្នុងវិស័យកសិកម្ម ឧស្សាហកម្មនោះ គឺមានគម្រោងរួចជាស្រេចក្នុងការបែងចែកទៅគ្រប់តំបន់ដាច់ស្រយាល និងតំបន់ជារមណីយដ្ឋានដើម្បីជួយសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និងស្ថាប័នផ្សេងៗ។

**១.៩.៤ ប្រព័ន្ធទូរគមនាគមន៍**

ផ្នែកប្រៃសណីយ៍ និងទូរគមនាគមន៍មានតួនាទី និងភារកិច្ចជួយជម្រុញ និងចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ព្រោះថាតាមរយៈផ្នែកប្រៃសណីយ៍ និងទូរគមនាគមន៍បានផ្តល់ព័ត៌មានអោយគ្នាទៅវិញទៅមកក្នុងគោលបំណងសួរសុខទុក្ខកិច្ចការជំនួញ និងបញ្ហាផ្សេងៗទៀតតាមរយៈការផ្ញើសំបុត្រ ការនិយាយទូរស័ព្ទ ការផ្ញើសារជាដើម។ ដូចនេះគម្រោងផែនការនៅក្នុងតំបន់ដែលមានវិស័យទេសចរណ៍ ទូរគមនាគមន៍ដែលជាផ្នែកមួយជម្រុញអោយវិស័យទេសចរណ៍មានការអភិវឌ្ឍជឿនលឿន នោះដូចជា ផែនការរៀបចំបណ្តាញអ៊ីនធឺណេត អ៊ីម៉ែលអោយបានគ្រប់គ្រាន់ ដើម្បីបម្រើដល់សេចក្តីត្រូវការរបស់ទេសចរ និងប្រជាពលរដ្ឋក្នុងតំបន់។ ផែនការអភិវឌ្ឍន៍ ការបម្រើសេវាកម្មនៅក្នុងប្រៃសណីយ៍អោយកាន់តែរហ័សទាន់ចិត្ត។

**១.៩.៥ ការគ្រប់គ្រងកាកសំណល់**

ការគ្រប់គ្រងកាកសំណល់ ជារឿងដែលចាំបាច់ត្រូវគិតគូរ។ ការបែងចែកប្រភេទកាកសំណល់បានត្រឹមត្រូវជាលទ្ធផលមួយដែលបញ្ជាក់អោយឃើញពីភាពស្រស់ស្អាត និងថែទាំដល់បរិស្ថាន ដែលជាគោលបំណងរបស់ទេសចរ ក្រៅពីសេវាកម្មផ្សេងៗទៀត ដែលបម្រើអោយវិស័យទេសចរណ៍។ ក្នុងវិស័យទេសចរណ៍ មានបែងចែកធុងសម្រាមអោយទេសចរបោះចោលកាកសំណល់ទៅតាមប្រភេទរឹង ប្រភេទរាវ ដាច់ដោយឡែកពីគ្នាដែលមានដាក់នៅតាមរមណីយដ្ឋានទេសចរណ៍ ភោជនីយដ្ឋាន និងតំបន់កម្សាន្តនានា។ អ្វីដែលសំខាន់ការគ្រប់គ្រងកាកសំណល់បានយ៉ាងត្រឹមត្រូវ។

**១.១០ វិស័យសំខាន់ៗចូលរួមអភិវឌ្ឍន៍**

**១.១០.១ វិស័យឧស្សាហកម្ម និងសិប្បកម្ម**

វិស័យឧស្សាហកម្ម ក៏ជាវិស័យដែលចូលរួមចំណែកយ៉ាងសំខាន់ផងដែរ ក្នុងការអភិវឌ្ឍប្រទេសជាតិអោយបានរីកចំរើន។ រីឯវិស័យទេសចរណ៍វិញ ក៏មិនអាចខ្វះបាននូវវិស័យឧស្សាហកម្មដែរ បានចូលរួមក្នុងបណ្តាការងារទាំងអស់ដូចជា ការបំពាក់នូវគ្រឿងបរិក្ខារ សម្ភារៈបច្ចេកទេសផ្សេងៗទៀតនៅក្នុងសណ្ឋាគារ សេវាកម្មម្ហូបអាហារ សេវាកម្មធ្វើដំណើរ និងសេវាកម្មមួយចំនួនផ្សេងទៀតដែលបម្រើអោយវិស័យទេសចរណ៍។ ក្នុងនោះផងដែរ វិស័យសិប្បកម្មក៏ជា សិប្បកម្មទេសចរណ៍ជាប្រភេទសិប្បកម្មដែលធ្វើដោយដៃ ក្នុងនោះមានដូចជា សិប្បកម្មសំណង់ ចម្លាក់ គ្រឿងលំអ និងការតុបតែងរចនាផ្សេងៗទៀត សម្រាប់ដាក់តាំងលក់ជូនទេសចរ ដែលជាចំណែកក្នុងការទាក់ទាញទេសចរផងដែរ។

### ១.១០.២ វិស័យកសិកម្ម

វិស័យកសិកម្ម គឺជាវិស័យមួយដ៏មានសារៈសំខាន់សម្រាប់មនុស្សគ្រប់រូប និងចំពោះការអភិវឌ្ឍទេសចរណ៍ ព្រោះវិស័យនេះគឺមានតួនាទីសម្រាប់ផលិតស្បៀងអាហារដូចជា ត្រី សាច់ បន្លែនិងគ្រាប់ធញ្ញជាតិជាដើម។ វិស័យកសិកម្មក៏មានតួនាទីផងដែរ ក្នុងការផលិតនូវវត្ថុធាតុដើមមួយចំនួន សម្រាប់បម្រើវិស័យឧស្សាហកម្ម ហើយវិស័យឧស្សាហកម្មក៏បានផលិតឧបករណ៍ប្រើប្រាស់ផ្សេងៗ សម្រាប់បម្រើវិស័យកសិកម្មវិញ។ ដូច្នេះត្រូវខិតខំជម្រុញវិស័យកសិកម្មនេះអោយមានការរីកចម្រើនកាន់តែខ្លាំង ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្សគ្រប់រូប ក៏ដូចជាវិស័យទេសចរណ៍ផងដែរ។ មួយវិញទៀតវិស័យកសិកម្ម ក៏ជាធនធានទេសចរណ៍គួរអោយចាប់អារម្មណ៍ដូចជា រុក្ខជាតិ សត្វ ដំណាំផ្សេងៗដែលសុទ្ធតែជាធនធានទេសចរណ៍ដ៏សំខាន់។

### ១.១០.៣ វិស័យសុខាភិបាល

មនុស្សគ្រប់រូបដែលរស់នៅលើលោកនេះ តែងតែប្រាថ្នាចង់បានសេចក្តីសុខ សុភមង្គល ជាពិសេសសុខភាពដើម្បីអភិវឌ្ឍន៍ សង្គម គ្រួសាររបស់ពួកគេអោយកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ទោះបីជាការឈឺថ្កាត់ ការជួបបញ្ហាសុខភាព មិនមែនជាបំណងប្រាថ្នារបស់មនុស្សគ្រប់រូបក៏ដោយក៏គ្មាននរណាម្នាក់អាចជៀសផុតបានឡើយ។ ដូចនេះពួកគេត្រូវការជាចាំបាច់នូវមណ្ឌលសុខភាព ដើម្បីបម្រើដល់ពួកគេ និងជាពិសេសសម្រាប់វិស័យទេសចរណ៍ផងដែរ។ វិស័យនេះមិនអាចខ្វះបានឡើយ ព្រោះវាជាផ្នែកមួយជួយជម្រុញអោយវិស័យទេសចរណ៍កាន់តែមានសន្តិភាព សន្តិសុខ។

### ១.១០.៤ វិស័យអប់រំ

ការសិក្សាជារឿងចម្បងដែលមនុស្សគ្រប់រូបត្រូវតែទទួលយកចំណេះដឹងដែលមិនអាចខ្វះបាន។ វិស័យអប់រំជាឬសគល់ដ៏សំខាន់ផងដែរក្នុងការពង្រឹងនូវចំណេះដឹង ទាំងចំណេះជំនាញ។ បច្ចុប្បន្ន គ្រប់តំបន់នៃប្រទេសមានសាលារៀនជាច្រើន ក៏ដូចជាសាកលវិទ្យាល័យដែលផ្តល់ឱ្យក្មេងៗ និងប្រជាពលរដ្ឋបានសិក្សារៀនសូត្រដែលនៅថ្ងៃអនាគតគឺជា ទំពាំងស្នងឫស្សីដ៏រឹងមាំនៃប្រទេសជាតិ។ ជាក់ស្តែងក៏មាននិស្សិតជាច្រើនដែលកំពុងសិក្សាទៅលើជំនាញទេសចរណ៍ផងដែរ និងមានខ្លះទៀតកំពុងតែបម្រើការងារក្នុងវិស័យនេះយ៉ាងសកម្ម ហើយក៏ជាចំណែកដ៏សំខាន់ដែលទ្រទ្រង់ដល់វិស័យទេសចរណ៍អោយមានការរីកចម្រើនខ្លាំង។

## ១.១១ ភាគីពាក់ព័ន្ធក្នុងវិស័យអេកូទេសចរណ៍

មានភាគីពាក់ព័ន្ធជាច្រើនដែលមានចំណាប់អារម្មណ៍ និងគោលបំណងផ្សេងៗគ្នាបានចូលរួមនៅក្នុងអេកូទេសចរណ៍ អ្នកខ្លះបានដើរតួនាទីសំខាន់ជាងអ្នកខ្លះ ប៉ុន្តែអ្នកទាំងអស់នោះសុទ្ធតែជាអ្នកតំណាងក្នុងការ

អភិវឌ្ឍ និងគ្រប់គ្រងអេកូទេសចរណ៍។ ចំណុចសំខាន់ក្នុងការទទួលជោគជ័យ នៅក្នុងការអភិវឌ្ឍអេកូទេសចរណ៍ គឺការបង្កើតនូវភាពជាដៃគូឲ្យបានខ្លាំងដើម្បីជាគោលបំណងនៃការអភិរក្ស និងការអភិវឌ្ឍមួយប្រកបដោយសមធម៌ អាចទទួលជោគជ័យទៅបាន។ ភាពជាដៃគូអាចមានការលំបាកព្រោះភាគីពាក់ព័ន្ធជាច្រើនបានចូលរួម ហើយពួកគេមានតម្រូវការផ្សេងៗគ្នា ប៉ុន្តែការបង្កើតទំនាក់ទំនងសំខាន់សម្រាប់ក្រុមហ៊ុនឯកជន មន្ត្រីរាជការ និងអង្គការក្រៅរដ្ឋាភិបាល។ អន្តរទំនាក់ទំនងដ៏មានប្រសិទ្ធិភាពរបស់ពួកគេ គឺជាគន្លឹះជោគជ័យនៃអេកូទេសចរណ៍។

### ១.១១.១ អ្នកគ្រប់គ្រងតំបន់

អ្នកគ្រប់គ្រងតំបន់ការពារ ហើយកន្លែងទាំងនោះគឺមានបញ្ហាប្រឈមមុខជាច្រើន។ បុគ្គលិកតំបន់ការពារច្រើនជាអ្នកអភិរក្ស ហើយជាអ្នកជំនាញផ្នែកបរិស្ថានព្រោះការងាររបស់ពួកគេ គឺជាអ្នកការពារធនធានធម្មជាតិ និងតំបន់ជុំវិញដែលស្ថិតនៅក្នុងការទទួលខុសត្រូវរបស់គេ។ ភារកិច្ចស្នូលរបស់គេជារឿយៗពាក់ព័ន្ធទៅនិងការសិក្សា ការធ្វើបញ្ជីសារពើភ័ណ្ឌ និងការគ្រប់គ្រងចំនួនសត្វ និងការរក្សានូវសម្បទាហេដ្ឋារចនាសម្ព័ន្ធនានា។ អេកូទេសចរណ៍ប្រកបដោយជោគជ័យយ៉ាងណាក៏ដោយ ទាមទារឲ្យមានបុគ្គលិកតំបន់ការពារទាំងនោះអាចធ្វើការយ៉ាងជិតស្និទ្ធិហើយមានចំណេះដឹងសមល្មមជាមួយនឹងប្រជាជនសហគមន៍ និងប្រធានសហគមន៍ក៏ដូចជាអ្នកតំណាងឧស្សាហកម្មទេសចរណ៍ដទៃទៀត រួមទាំងភ្នាក់ងារទេសចរណ៍ ការីទេសចរណ៍ មគ្គុទេសក៍ទេសចរណ៍ និងភ្នាក់ងាររដ្ឋាភិបាលដទៃទៀត។ បុគ្គលិកតំបន់ការពារត្រូវតែអាចណែនាំ ហើយពេលខ្លះណែនាំ និងសម្របសម្រួលជម្លោះជាមួយភាគីពាក់ព័ន្ធដទៃទៀតដើម្បីឲ្យពួកគេរួបរួមគ្នាធ្វើការដើម្បីផលប្រយោជន៍រួមនៅក្នុងតំបន់ការពារ និងគោលដៅអភិរក្សរួម។ ការងារនេះគឺមានការលំបាកខ្លាំងណាស់ ប៉ុន្តែមិនអាចបោះបង់ចោលបាននោះទេ។ នៅក្នុងករណីខ្លះ អង្គការក្រៅរដ្ឋាភិបាលអាចដើរតួនាទីបែបនេះ បើសិនជាមានសំណូមពរពីអាជ្ញាធរតំបន់ការពារ។ អ្នកគ្រប់គ្រងតំបន់ការពារ និងបុគ្គលិករបស់គេមានតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យអេកូទេសចរណ៍។

ក្នុងនាមអាជ្ញាធរដែលមានតួនាទីការពារធនធានធម្មជាតិ រុក្ខជាតិ សត្វព្រៃ ពួកគេចូលរួមចំណែកយ៉ាងខ្លាំងនៅក្នុងការបង្កើតកម្មវិធីអប់រំបរិស្ថាន។ ក្នុងនាមអ្នកគ្រប់គ្រងជួរមុខ បុគ្គលិកតំបន់ការពារជាមនុស្សដំបូងក្នុងការកត់សម្គាល់ការផ្លាស់ប្តូរនានាទៅលើធនធានធម្មជាតិដូចជា ការបាក់បែកបរិស្ថាន ដែលបណ្តាលមកពីការអភិវឌ្ឍវិស័យទេសចរណ៍។

### ១.១១.២ សហគមន៍មូលដ្ឋាន

ប្រជាជនដែលរស់នៅជិត ឬនៅក្នុងតំបន់ការពារមិនមែនសុទ្ធតែជាមនុស្សមួយក្រុមដូចៗគ្នានោះទេ។ ជាការពិតទោះបីជាសហគមន៍តូចមួយ តែមានទស្សនៈ និងបទពិសោធន៍ផ្សេងៗគ្នា។ ប៉ុន្តែយើងអាចយល់ស្របជាទូទៅមួយអំពីប្រជាជនមូលដ្ឋាន និងទំនាក់ទំនងរបស់ពួកគេនៅក្នុងអេកូទេសចរណ៍។ ទី ១ សហគមន៍ជនបទខ្លះដែលធ្លាប់រស់នៅក្នុងជីវភាពស្ងប់ស្ងាត់កំពុងតែគិតថា ឥឡូវនេះពួកគេកំពុងស្ថិតនៅក្នុងនិន្នាការមួយពាក់កណ្តាលអន្តរជាតិ។ ទេសចរអន្តរជាតិកំពុងតែឈ្លានពានទឹកដីរបស់ពួកគេ ប៉ុន្តែជារឿយៗពួកគេកំពុងតែឆ្លងកាត់ប៉ុណ្ណោះ។ ជាធម្មតា ពួកគេគ្រាន់តែឆ្លងកាត់ភូមិរបស់ពួកគេដោយមិនបានជួបប្រជាជនដោយផ្ទាល់។ ប្រជាមូលដ្ឋានអាចមានប្រតិកម្មច្របូកច្របល់ទៅនឹងការឈ្លានពាននេះ។ អ្នកខ្លះមិនចង់បានអ្វីពីទេសចរទេ

ដោយអ្នកខ្លះចង់បានភាពស្ងប់ស្ងាត់ហើយមិនចង់ស្វាគមន៍ការផ្លាស់ប្តូរនូវអ្វីដែលទេសចរបាននាំមកនោះទេ ផ្ទុយពីអ្នកខ្លះដែលចាប់អារម្មណ៍ហើយចង់អភិវឌ្ឍន៍វា។ វិស័យទេសចរណ៍ អាចនឹងមានការទាក់ទាញសម្រាប់អ្នកខ្លះដែលចង់បានការងារធ្វើ។ សហគមន៍ជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បានប្រើទេសចរហើយបង្កើតកម្មវិធីអេកូទេសចរណ៍នេះឡើង។ ពេលខ្លះទឹកចិត្តរបស់គេគឺដើម្បីការពារធនធានធម្មជាតិជុំវិញភូមិឋានរបស់ពួកគេ។ សម្រាប់អ្នកផ្សេងទៀត និងមើលឃើញនោះគ្រង់ផលប្រយោជន៍សេដ្ឋកិច្ច ដែលជាមធ្យោបាយមួយក្នុងការទទួលប្រាក់ចំណូលដោយសហគមន៍ជាច្រើនបានរៀបចំកម្មវិធីអេកូទេសចរណ៍ដោយផ្ទាល់ខ្លួនពួកគេ។

### ១.១១.៣ ឧស្សាហកម្មទេសចរណ៍

ឧស្សាហកម្មទេសចរណ៍មានទ្រង់ទ្រាយធំហើយពាក់ព័ន្ធនឹងមនុស្សជាច្រើនដូចជាការីទេសចរណ៍ ភ្នាក់ងារទេសចរណ៍ដែលរៀបចំដំណើរកម្សាន្តក្រុមហ៊ុនអាកាសចរណ៍ ក្រុមហ៊ុនដឹកជញ្ជូន(ផ្លូវទឹក ផ្លូវគោក) និងបុគ្គលិកដែលធ្វើការក្នុងវិស័យទេសចរណ៍ អ្នកបើកបរ បុគ្គលិកសណ្ឋាគារ និងសមាជិកគ្រួសារដែលផ្តល់សេវាកម្មស្នាក់នៅ អ្នកធ្វើសិប្បកម្ម ម្ចាស់សណ្ឋាគារ ម្ចាស់ភោជនីយដ្ឋាន អ្នកនាំភ្ញៀវ និងប្រជាជនផ្សេងៗទៀតដែលផ្តល់សេវាកម្ម និងទំនិញដល់ទេសចរផ្ទាល់ និងប្រយោល។ ភាពស្មុគស្មាញនៃវិស័យនេះ បង្ហាញពីការលំបាកសម្រាប់បុគ្គលិកតំបន់ការពារ និងសហគមន៍ឲ្យរៀនយល់អំពីការបង្កើតភាពជាដៃគូជាមួយឧស្សាហកម្មទេសចរណ៍។

អ្នកប្រើប្រាស់មានទំនាក់ទំនងជាមួយសមាជិកឧស្សាហកម្មទេសចរណ៍ តាមរយៈដំណើរកម្សាន្តរបស់គេចំពោះដំណើរកម្សាន្តជាអន្តរជាតិ អ្នកដំណើរជារឿយៗប្រទះទំនាក់ទំនងលើកដំបូងជាមួយការីទេសចរណ៍ ដែលមានទីតាំងនៅក្នុងប្រទេស ភ្ញៀវដែលធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយក្រុមហ៊ុនទេសចរណ៍ នៅក្នុងប្រទេសដែលទេសចរចង់ទៅកម្សាន្ត។

ក្រុមហ៊ុនទេសចរណ៍បរទេសភាគច្រើនជាផ្នែកមួយដែលចងភ្ជាប់ផ្នែកពាណិជ្ជកម្មទាំងអស់ នៅក្នុងឧស្សាហកម្មទេសចរណ៍ គឺការចង់បានផលចំណេញខាងផ្នែកហិរញ្ញវត្ថុ និងមានការលើកទឹកចិត្តបន្ថែមបន្តទៀតសម្រាប់មុខជំនួញខ្លះ ជាពិសេសគឺអ្នកដែលពាក់ព័ន្ធនឹងអេកូទេសចរណ៍។

សមាជិកឧស្សាហកម្មទេសចរណ៍ខ្លះមានតួនាទីសំខាន់ ក្នុងវិស័យទេសចរណ៍លើហេតុផលមួយចំនួនះ

- ពួកគេយល់ដឹងពីនិន្នាការទេសចរណ៍ និងដឹងពីអ្វីដែលអតិថិជនត្រូវការ
- ឧស្សាហកម្មទេសចរណ៍មានឥទ្ធិពលដល់អ្នកធ្វើដំណើរក្នុងការលើកទឹកចិត្តឲ្យមានឥរិយាបថល្អ និងការកំណត់ផលប៉ះពាល់អវិជ្ជមានណាមួយនៅក្នុងតំបន់ការពារ
- ឧស្សាហកម្មទេសចរណ៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយអេកូទេសចរណ៍។ ពួកគេយល់ដឹងពីរបៀបក្នុងការធ្វើការបោះពុម្ពផ្សាយអ៊ីធើណែតសារព័ត៌មានឬមធ្យោបាយដទៃទៀត ដូច្នេះវាផ្តល់ទំនាក់ទំនងរវាងតំបន់គោលដៅអេកូទេសចរណ៍ និងអ្នកប្រើប្រាស់។

### ១.១១.៤ មន្ត្រីរដ្ឋាភិបាល

មន្ត្រីរដ្ឋាភិបាលមកពីនាយកដ្ឋាន ឬក្រសួង ឬស្ថាប័នផ្សេងៗបានចូលរួមក្នុងការធ្វើផែនការការអភិវឌ្ឍ និងការគ្រប់គ្រងអេកូទេសចរណ៍។ ផ្នែកទាំងនោះមានក្រសួងបរិស្ថាន ក្រសួងអប់រំ ការអភិវឌ្ឍសហគមន៍ រដ្ឋបាល

ព្រៃឈើ ផ្នែកដឹកជញ្ជូន និងហរិញ្ញវត្ថុ។ អេកូទេសចរណ៍បានបញ្ចូលមន្ត្រីជាច្រើននាក់ពីកម្រិតជាតិ និងកម្រិតខេត្ត កម្រិតមូលដ្ឋានដើម្បីចូលរួមអភិវឌ្ឍន៍អេកូទេសចរណ៍។

មន្ត្រីរដ្ឋាភិបាលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍអេកូទេសចរណ៍ ដោយពួកគេបានផ្តល់នូវភាពជាអ្នកដឹកនាំ។ ពួកគេជាអ្នកសម្របសម្រួល និងបង្កើតនូវគោលដៅសម្រាប់ការអភិវឌ្ឍអេកូទេសចរណ៍ ហើយពួកគេបានផ្តល់ចក្ខុវិស័យសម្រាប់ឧស្សាហកម្មនេះ។ ពួកគេអាចធ្វើការស្នើឲ្យមានផែនការអេកូទេសចរណ៍ជាតិ មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ អាចនឹងបង្កើតគោលនយោបាយជាក់លាក់មួយសម្រាប់តំបន់ការពារ។ ឧទាហរណ៍ មន្ត្រីរដ្ឋាភិបាល អាចសម្រេចប្រព័ន្ធយកថ្លៃពីទេសចរនៅតំបន់ការពារ ហើយគោលនយោបាយរបស់គេបានកំណត់ពីប្រព័ន្ធមួយចំនួនដែលនិងត្រូវបង្កើតឡើង និងពីវិធីដែលបានចំណូលពីវិស័យទេសចរណ៍ត្រូវបានបែងចែក និងគ្រប់គ្រង។ ពួកគេអាចនិងលើកស្ទួយ និងគាំទ្រដល់វិស័យឯកជន។ ឧទាហរណ៍ ការីទេសចរណ៍អាចនិងត្រូវបានតម្រូវឲ្យប្រើប្រាស់អ្នកនាំភ្ញៀវមូលដ្ឋាន នៅក្នុងតំបន់ដែលគ្រប់គ្រងដោយសហគមន៍។ គោលនយោបាយរដ្ឋាភិបាលត្រូវបានណែនាំដល់សកម្មភាពអេកូទេសចរណ៍ ហើយអាចលើកទឹកចិត្តដល់កំណើនទេសចរណ៍។

បន្ថែមពីនេះទៅទៀត មន្ត្រីរដ្ឋាភិបាលទទួលខុសត្រូវលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធខាងក្រៅ និងខាងក្នុងជុំវិញតំបន់ការពារ ដែលផ្តល់សម្បទាផ្នែកទេសចរណ៍នៅក្នុងទីក្រុងធំៗ និងប្រព័ន្ធផ្លូវដឹកជញ្ជូនទៅក្នុងតំបន់ដាច់ស្រយោល។ ជាទូទៅរដ្ឋាភិបាលបានដើរតួនាទីឈានមុខនៅក្នុងផ្នែកដឹកជញ្ជូន រួមនិងបញ្ហានានា។ រដ្ឋាភិបាលក៏បានផ្តល់សេវាកម្មសំខាន់ៗផងដែរដល់អេកូទេសចរណ៍ដូចជា ប្រព័ន្ធសុខាភិបាលនៅក្នុងតំបន់ដាច់ស្រយោលជាដើម។ រដ្ឋាភិបាលបានផ្សព្វផ្សាយពីអេកូទេសចរណ៍ ហើយពេលខ្លះការផ្សព្វផ្សាយ គឺជាផ្នែកមួយនៃយុទ្ធនាការទេសចរណ៍ជាតិរបស់រដ្ឋាភិបាល ហើយពេលខ្លះទៀត ការផ្សព្វផ្សាយផ្តល់តួនាទីយ៉ាងសំខាន់ដល់ការរីកចម្រើននៃអេកូទេសចរណ៍។

### ១.១១.៥ អង្គការក្រៅរដ្ឋាភិបាល

អង្គការក្រៅរដ្ឋាភិបាល គឺជាអ្នកដើរតួនាទីយ៉ាងសំខាន់មួយទៀត នៅក្នុងដំណើរការនៃទេសចរណ៍ ពួកគេផ្តល់នយោបាយទំនាក់ទំនងជាមួយនឹងមនុស្សចាប់អារម្មណ៍ផ្សេងៗទៀតជាច្រើន។ អង្គការទាំងនេះជាចលករសម្រាប់នាំភាគីផ្សេងៗទៀតមក ធ្វើការរួមគ្នាក្នុងវិស័យអេកូទេសចរណ៍។ អង្គការក្រៅរដ្ឋាភិបាលអាចដើរតួនាទីផ្សេងៗក្នុងការអភិវឌ្ឍអេកូទេសចរណ៍ដោយផ្ទាល់គឺអ្នកគ្រប់គ្រងកម្មវិធី ឬអ្នកគ្រប់គ្រងតំបន់ទេសចរណ៍ ឬសហគមន៍ទេសចរណ៍ហើយកាលៈទេសៈពិសេសផ្សេងទៀតជាអ្នកផ្តល់សេវាកម្មទេសចរណ៍។ មានប្រភេទខុសគ្នាជាច្រើនក្នុងចំណោមសហគមន៍អេកូទេសចរណ៍ដូចជានៅក្នុងប្រទេសដេលីស កូស្តារីកា អេក្វាឌ័រជាដើម ដែលបញ្ចុះបញ្ចូលភាគីផ្សេងៗឲ្យមកធ្វើការនិងពិភាក្សាគ្នានៅក្នុងការផ្សព្វផ្សាយអេកូទេសចរណ៍។ អង្គការក្រៅរដ្ឋាភិបាលទាំងនេះ ជារឿយមានសមាជិកដែលយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ការងារអភិរក្សបរិស្ថាន តាមរយៈការបោះពុម្ពដូចជា ព្រឹត្តិប័ត្រព័ត៌មាន ទស្សនាវដ្តីជាដើម។ សហគមន៍ និងអង្គការទាំងនេះជារឿយៗ មានប្រសិទ្ធិភាពក្នុងការធ្វើឲ្យឧស្សាហកម្មទេសចរណ៍ បានទទួលព័ត៌មានជាក់លាក់ពីនិន្នាការថ្មីៗ និងព្រឹត្តិការណ៍ថ្មីៗ។ ប្រភេទអង្គការក្រៅរដ្ឋាភិបាលថ្មីផ្សេងទៀតដែលពាក់ព័ន្ធនឹងអេកូទេសចរណ៍រួមមាន សហគមន៍ ឬអង្គការឯកជនដែលមិនរកផលកម្រៃ ផ្តោតលើការងារអភិរក្ស អភិវឌ្ឍន៍ ឬអាចផ្តោតសំខាន់លើការងារអេកូទេសចរណ៍តែម្តង។ ការចាប់អារម្មណ៍របស់ពួកគេមានកម្រិតមូលដ្ឋាន ឬអន្តរជាតិ។ ជារឿយៗ អង្គការទាំងនេះដើរតួនាទីសម្រប

សម្រួលរវាងតំបន់ការពារសហគមន៍ និងអ្នកដែលពាក់ព័ន្ធដទៃទៀតក្នុងអេកូទេសចរណ៍ ហើយពេលខ្លះជាអ្នកផ្តល់ហិរិញ្ញវត្ថុ និងបច្ចេកទេសផ្ទាល់ដល់តំបន់ការពារផងដែរ។ អង្គការមិនមែនរដ្ឋាភិបាលខ្លះដើរតួនាទីក្នុងការអប់រំ និងផ្សព្វផ្សាយពីអេកូទេសចរណ៍។

**១.១១.៦ ភាគីគាំទ្រ**

**ក. ម្ចាស់ជំនួយ**

ក្រុមហ៊ុនជាច្រើនផ្សេងទៀត អាចផ្តល់ការគាំទ្រផ្នែកហិរិញ្ញវត្ថុ និងបច្ចេកទេសក្នុងការអភិវឌ្ឍអេកូទេសចរណ៍តាមរយៈការផ្តល់កម្ចី និងផ្តល់ជំនួយឥតសំណងជាហិរិញ្ញវត្ថុ និងបច្ចេកទេសរួមទាំងការវិនិយោគទុនទ្វេភាគី ឬពហុភាគីដូចជាធានាគារអភិវឌ្ឍពិភពលោក ធានាគារអភិវឌ្ឍអន្តរជាតិ និងធានាគារអភិវឌ្ឍអាស៊ី វិនិយោគទុនឯកជន និងមូលនិធិសម្រាប់មុខជំនួញដូចជា អង្គការមូលនិធិវិនិយោគទុនអេកូអ៊ីនធើប្រាយ និងធានាគារឯកជនជាដើម។ ការចូលរួមការចូលរួមទាំងអស់នេះមានសារៈសំខាន់ចំពោះតំបន់ការពារដែលអនុវត្តន៍អេកូទេសចរណ៍។ មានការសិក្សាដែលបានធ្វើឡើងសម្របសម្រួល និងបង្កើតនូវហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបង្កើតការបណ្តុះបណ្តាល កសាងសមត្ថភាពបុគ្គលិក និងសហគមន៍។ ជាមួយនឹងថវិកាតំបន់ការពារដែលមានកំណត់មូលនិធិខាងក្រៅជាការចាំបាច់ណាស់។ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយចំនួនដែលមានទីតាំងនៅសហរដ្ឋអាមេរិក និងអឺរ៉ុបបានផ្តល់មូលនិធិ និងបច្ចេកទេសដល់គម្រោងអេកូទេសចរណ៍ក្នុងប្រទេសអភិវឌ្ឍន៍។ អង្គការភាគច្រើន គឺបានប្រើប្រាស់មូលនិធិដែលផ្តល់ដោយរដ្ឋាភិបាលរបស់ប្រទេសខ្លួនដូចជាតាមរយៈ ជំនួយសហរដ្ឋអាមេរិក អាឡឺម៉ង់ អង់គ្លេសជាដើម។ អង្គការអភិរក្សធម្មជាតិតាមរយៈមូលនិធិសហរដ្ឋអាមេរិក បានជួយឧបត្ថម្ភគាំទ្រដល់អង្គការក្នុងស្រុកជាច្រើនដើម្បីអភិវឌ្ឍន៍គម្រោងអេកូទេសចរណ៍ដែលពាក់ព័ន្ធនឹងតំបន់ការពារ។ ថ្មីៗនេះគេបានបង្កើតនូវមូលនិធិមុខជំនួញអេកូមួយដែលផ្តល់នូវមូលនិធិដល់គម្រោងជាច្រើន។ គ្រឹះស្ថានហិរញ្ញវត្ថុជាទូទៅ មិនបានចូលរួមធ្វើផែនការអភិវឌ្ឍអេកូទេសចរណ៍ ឬនៅក្នុងការសម្រេចចិត្តអំពីអ្វីដែលសមស្របជាក់លាក់អំពីតំបន់ការពារនោះទេ។ ក្នុងន័យនេះ ពួកគេអាចពិចារណាថាជាភាគីទីពីរ នៅក្នុងវិស័យអេកូទេសចរណ៍ ប៉ុន្តែពួកគេក៏ជាអ្នកសំខាន់ផងដែរ។

**ខ. ស្ថាប័នអប់រំ**

ស្ថាប័នអប់រំដូចជាសាកលវិទ្យាល័យ មានតួនាទីសំខាន់ផងដែរក្នុងវិស័យអេកូទេសចរណ៍។ តួនាទីរបស់ពួកគេគឺធ្វើការស្រាវជ្រាវនៅក្នុងវិស័យអេកូទេសចរណ៍ និងបណ្តុះបណ្តាលអប់រំអេកូទេសចរណ៍។ វាជាក្រុមដែលជួយកំណត់បញ្ហាអេកូទេសចរណ៍ និងបង្កើតសំណួរដើម្បីធ្វើឲ្យប្រាកដថាអេកូទេសចរណ៍បានដល់គោលដៅដែលបានកំណត់ទុក។ អ្នកស្រាវជ្រាវ និងអ្នកអប់រំ បានជួយសម្របសម្រួលក្នុងការរៀនសូត្រតាមរយៈការសួរសំណួរដូចជា តើអ្នកណាជាអ្នកទទួលផលប្រយោជន៍ពិតប្រាកដពីវិស័យអេកូទេសចរណ៍? តើយើងអាចវាស់ស្ទង់ផលប្រយោជន៍ទាំងនេះបានដូចម្តេច? តើអេកូទេសចរណ៍បានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងការអភិរក្សបានកម្រិតណា? តើមានទំនាក់ទំនងអ្វីខ្លះ រវាងអេកូទេសចរណ៍?អ្នកស្រាវជ្រាវអាចផ្តោតទៅលើរូបភាពធំៗ និងជួយយើងឲ្យយល់ពីរបៀបដែលអេកូទេសចរណ៍មានទំនាក់ទំនងជាមួយនឹងទ្រឹស្តីនិងការអនុវត្តន៍ក៏ដូចជានិន្នាការសាកលលោក។

បន្ថែមពីនេះទៅទៀត ពួកគេអាចជួយបង្កើតទ្រឹស្តីផងដែរ។ អ្នកអប់រំ ឬអ្នកធ្វើការស្រាវជ្រាវអាចធ្វើការស្រាវជ្រាវ និងសម្របសម្រួលជាមួយអង្គការក្រៅរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន។ ពួកគេក៏អាចៈ

- បង្កើត និងអនុវត្តន៍ការស្រាវជ្រាវអំពីចំណាង់ ចំណូលចិត្ត និងឆន្ទៈរបស់ភ្ញៀវក្នុងការបង់ថ្លៃចូលទស្សនា
- បង្កើតបញ្ជីសារពើភ័ណ្ឌអំពីរុក្ខជាតិ និងសត្វ
- កត់ត្រាផលប៉ះពាល់ទេសចរណ៍ និងចែករំលែកលទ្ធផលដើម្បីបង្កើតនូវព័ត៌មានដ៏ល្អមួយ
- ផ្តល់ជាសម្ភារៈដើម្បីណែនាំឲ្យយើងនៅក្នុងកិច្ចពិភាក្សា និងការបូកសរុបអំពីអេកូទេសចរណ៍
- សម្របសម្រួល និងចែករំលែកព័ត៌មានទាំងនោះ និងគំនិតបែបទ្រឹស្តីតាមរយៈសិក្ខាសាលា សន្និបាត និងការបោះពុម្ពផ្សាយ ឬប្រព័ន្ធអ៊ីនធើណែតជាដើម។
- បង្កើតទិន្នន័យអំពីទម្រង់បែបផែនការទេសចរណ៍។

**១.១១.៧ ទេសចរ**

អ្នកធ្វើដំណើរ ឬទេសចរមានតួនាទីយ៉ាងពិសេសនៅក្នុងវិស័យទេសចរណ៍។ ពួកគេជាអ្នកចូលរួមយ៉ាងសំខាន់នៅក្នុងឧស្សាហកម្មទេសចរណ៍ ហើយផ្តល់នូវកម្លាំងចិត្តសម្រាប់មនុស្សគ្រប់គ្នា។ មិនតែប៉ុណ្ណោះជម្រើសដែលពួកគេបានធ្វើនៅពេលដែលពួកគេជ្រើសរើសតំបន់គោលដៅទេសចរណ៍ គឺជ្រើសរើសភ្នាក់ងារ និងការីទេសចរណ៍ ហើយជាប្រភេទដំណើរកម្សាន្តដែលពួកគេចង់ចូលរួម ហើយមានផលប៉ះពាល់យ៉ាងធំធេងទៅលើជោគជ័យ ឬបរាជ័យលើគម្រោងអេកូទេសចរណ៍។ ជារួមអេកូទេសចរណ៍ គឺជាពហុវិស័យដែលមានភាគីពាក់ព័ន្ធផ្សេងៗ ចូលរួមទាមទានូវការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការច្រើនក្នុងចំណោមភាគីពាក់ព័ន្ធឯទៀត ដែលមានផលប្រយោជន៍ និងគោលបំណងផ្សេងគ្នា។

## ១.១២ យុទ្ធសាស្ត្រការគ្រប់គ្រងអេកូទេសចរណ៍

យុទ្ធសាស្ត្រនៃការគ្រប់គ្រងគឺជាសិល្បៈ និងវិទ្យាសាស្ត្រនៃការបង្កើនឡើង ការអនុវត្ត និងការវាយតម្លៃការសម្រេចចិត្តនៃមុខងារចម្រុះដែលពាក់ព័ន្ធគ្នាដែលអាចធ្វើបានរបស់អង្គភាព អាជីវកម្មមួយដើម្បីសម្រេចគោលដៅ។ ការគ្រប់គ្រង គឺជាដំណើរការជាមួយនឹងមនុស្សនិងធនធានដទៃទៀតដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព។អ្នកដែលគ្រប់គ្រងខ្លាំងពូកែត្រូវសមត្ថភាពនិងប្រសិទ្ធភាព។ សមត្ថភាពគឺជាការសម្រេចគោលដៅដោយ ដឹងថាការចំណាយធនធានដូចជាមនុស្ស ប្រាក់វត្ថុធាតុដើម និងពេលវេលាតិចបំផុតដែល ដែលអាចធ្វើទៅបាន។ ប្រសិទ្ធភាព គឺជាការសម្រេចគោលដៅ នៃអង្គភាពដោយមិនគិតពីចំណាយ។ អ្នកគ្រប់គ្រងទាំងអស់បរាជ័យគឺបណ្តាលមកពីគ្មានសមត្ថភាពនិងប្រសិទ្ធភាពនេះឯង។

**១.១២.១ និយមន័យ ការគ្រប់គ្រង**

ការគ្រប់គ្រង គឺជាដំណើរការដែលជាប់ពាក់ព័ន្ធទៅនឹងបណ្តាមុខងារ និងសកម្មភាពមួយចំនួនដែលអ្នកគ្រប់គ្រងត្រូវតែប្រែប្រតិបត្តិការដើម្បីសម្រេចបាននូវគោលដៅចុងក្រោយរបស់សហគ្រាស ឬអង្គភាពណាមួយ។

**១.១២.២ មុខងារនៃការគ្រប់គ្រង**

**មុខងារនៃការគ្រប់គ្រង** គឺជាសកម្មភាពដ៏ធំទូលាយ ដែលអ្នកគ្រប់គ្រងទាំងឡាយ (គ្រប់លំដាប់ថ្នាក់) ត្រូវប្រតិបត្តិដើម្បីធ្វើអោយសម្រេចបាននូវគោលដៅរបស់អង្គភាព។ ដែលមុខងារទាំងនោះរួមមាន ការធ្វើផែនការ (Planning) ការរៀបចំចាត់ចែង (Organizing) ការដឹកនាំ (leading) និង ត្រួតពិនិត្យ (Controlling) ។ មុខងារ

មូលដ្ឋានទាំងបួននេះគឺជាឧបករណ៍ដ៏សក្តិសិទ្ធរបស់អ្នកគ្រប់គ្រង សម្រាប់យកទៅប្រើប្រាស់ដើម្បីសម្រេចបាននូវគោលដៅ គោលបំណង ដែលបានកំណត់ដោយក្រុមហ៊ុន(ថ្នាក់លើ)។ មុខងារទាំងបួននៃការគ្រប់គ្រងនេះ ត្រូវរកឃើញដោយលោក Henry Fayol ដែលជាអ្នកប្រកបមុខវិជ្ជាជីវៈ និងជាអ្នកទ្រឹស្តីនៃការគ្រប់គ្រង ជនជាតិបារាំង។

- ការធ្វើផែនការ (Planning) ការធ្វើផែនការ គឺជាការកំណត់គោលដៅដែលស្ថាប័នមួយចង់សម្រេចបាន ហើយថាតើសម្រេចបានដោយរបៀបណា(មធ្យោបាយ)។ ការធ្វើផែនការ មានន័យថា ការកំណត់ទិសដៅសម្រាប់ការអនុវត្តការងារ ក្នុងពេលអនាគតហើយសម្រេចនូវទិសដៅបានកំនត់ទុកនោះ។
- ការចាត់ចែង (Organizing) ចាត់តាំងគឺជាមុខងារសំខាន់ បន្ទាប់ពីផែនការ ព្រោះវាជាការរៀបចំចាត់ចែងទំនាក់ទំនងរវាងមនុស្សនិងមនុស្សក្នុងដំណើរការការងារ។ ការចាត់ចែងរួមមានការប្រគល់ការងារអោយតាមផ្នែកគ្រប់គ្រង និងអោយបុគ្គលិកក្រោមបញ្ជាទាំងអស់ ដើម្បីសម្រួលអោយគេធ្វើការងារតាមផ្នែក(តួនាទី-ភារកិច្ច) របស់គេបានយ៉ាងសមស្រប។ ការចាត់ចែងទាក់ទងនឹងការបែងចែកការងារ ការដាក់ការងារទៅតាមផ្នែកនីមួយៗ និងការផ្តល់ធនធានមនុស្ស ឬរៀបចំធនធានមនុស្ស និងធនធានដទៃទៀតទៅតាមផ្នែកនិងទៅតាមជំនាញ។
- ការដឹកនាំ (Leading) ការដឹកនាំ គឺជាសកម្មភាព ឬមុខងារគ្រប់គ្រងដ៏សំខាន់បំផុតក្នុងរចនាសម្ព័ន្ធចាត់ចែង។ ការដឹកនាំ បង្ហាញអោយឃើញនូវសមត្ថភាពរបស់អ្នកគ្រប់គ្រងដែលបានចូលរួមផ្ទាល់ក្នុងការជំរុញ ណែនាំសកម្មភាពរបស់អ្នកក្រោមបង្គាប់អោយប្រព្រឹត្តតាមគោលដៅដែលបានកំណត់។ ការដឹកនាំ គឺជាការងារទំនាក់ទំនងចូលរួមផ្ទាល់ជាមួយនិយោជិត បង្ហាត់បង្រៀនពួកគេអោយស្គាល់ខុសត្រូវ។
- ការត្រួតពិនិត្យ (Controling) ការត្រួតពិនិត្យ គឺជាការងារចុងក្រោយនៃការគ្រប់គ្រង ដែលទាមទារអោយអ្នកគ្រប់គ្រងធ្វើការប្រមូលផ្តុំ ប្រៀបធៀបវាយតម្លៃ វិនិច្ឆ័យលើបណ្តាសកម្មភាពទាំងឡាយនៃផែនការ ដើម្បីកែតម្រូវឬបង្កើនគុណភាព ពង្រឹងផែនការអោយសមស្រប និងមានប្រសិទ្ធភាពខ្ពស់។ ការត្រួតពិនិត្យ គឺជាមុខងារគ្រប់គ្រង នៃការកំណត់បទដ្ឋានដែលបានកំណត់ ហើយធ្វើការកែតម្រូវប្រសិនបើវាចាំបាច់។ ហើយដំណើរការនៃការត្រួតពិនិត្យមាន៤ជំហានសំខាន់ៗ

១. កំណត់បទដ្ឋានសម្រាប់ពេលវេលា បរិមាណ គុណភាពផលិតផល...។

២. វាស់វែងសកម្មភាពការងារ

៣. ប្រៀបធៀបសកម្មភាពការងារជាក់ស្តែងជាមួយបទដ្ឋាន

៤. ធ្វើការកែតម្រូវប្រសិនបើមានភាពចាំបាច់។

### ១.១២.៣ កត្តាដែលជះឥទ្ធិពលលើការអភិវឌ្ឍន៍វិស័យទេសចរណ៍

**កត្តាចលនា**

- ❖ ភូមិសាស្ត្រ
- ❖ អាកាសធាតុ
- ❖ សម្បត្តិធម្មជាតិ

- ❖ វប្បធម៌
- ❖ ប្រវត្តិសាស្ត្រ
- ❖ ជំនឿសាសនា
- ❖ បេតិកភណ្ឌជាតិ
- ❖ ទេសភាព

**កត្តាអចលនា**

- ❖ នយោបាយ
- ❖ សេដ្ឋកិច្ច
- ❖ សង្គម
- ❖ ពលរដ្ឋ
- ❖ វប្បធម៌
- ❖ សំភារៈបច្ចេកទេស
- ❖ ទីផ្សារទេសចរណ៍
- ❖ ធនធានមនុស្ស

**កត្តាបង្អាក់ដំណើរការនៃការវិវត្តនៃទេសចរណ៍**

- ❖ វិបត្តិសេដ្ឋកិច្ច
- ❖ វិបត្តិនយោបាយ
- ❖ អសន្តិសុខ និងសុវត្ថិភាព
- ❖ សង្គ្រាម និងជំលោះ
- ❖ កង្វះខាតសោភ័ណភាព
- ❖ បញ្ហាបរិស្ថាន
- ❖ បញ្ហាឆ្លងកាត់ព្រំដែន។

## ១.១៣ ការអភិវឌ្ឍទេសចរណ៍

### ១.១៣.១ និយមន័យការអភិវឌ្ឍ

ការអភិវឌ្ឍ គឺជាការកែប្រែ អ្វីដែលមិនទាន់មានឱ្យមាន និងកែប្រែអ្វីដែលមិនទាន់ល្អឱ្យល្អ ឧទាហរណ៍ កែប្រែមនុស្ស និងធនធានមនុស្ស កែប្រែសម្ភារៈ និងមធ្យោបាយប្រើប្រាស់ កែប្រែរបៀបប្រើប្រាស់នូវបណ្តាធនធានធម្មជាតិឱ្យកាន់តែប្រសើរឡើង។ ការអភិវឌ្ឍ គឺជាការដំណើរការពហុមាត្រាដ្ឋាន រួមបញ្ចូលនូវការផ្លាស់ប្តូរ និងការវិវត្តទាំងបរិមាណ និងទាំងគុណភាព។

ការអភិវឌ្ឍអេកូទេសចរណ៍ ត្រូវគិតគូដល់កត្តា៨យ៉ាងជាចាំបាច់៖

- **ទី១** មិននាំអោយមានការសឹករិចរិលធនធាន និងត្រូវគ្រប់គ្រងបរិស្ថានសំឡេងឱ្យបានល្អក្នុងតំបន់អភិវឌ្ឍន៍

- **ទី២** ផ្តល់អត្ថប្រយោជន៍ដល់បណ្តាធនធាន ដល់សហគមន៍ និងដល់ឧស្សាហកម្មទេសចរណ៍រយៈពេលយូរ
- **ទី៣** អប់រំភាគីពាក់ព័ន្ធទាំងអស់អំពីការអភិវឌ្ឍអេកូទេសចរណ៍
- **ទី៤** ផ្តល់សិទ្ធិអំណាច ការចូលរួម និងបទពិសោធន៍ល្អៗ
- **ទី៥** លើកទឹកចិត្តដល់គ្រប់ផ្នែក និងលើកតម្លៃវិសេសវិសាល នៃធនធានទាំងឡាយ
- **ទី៦** ទទួលយក និងទទួលស្គាល់នូវដែនកំណត់ធនធានដែលទាក់ទងនឹងការគ្រប់គ្រង តម្រង់ទិសសម្រាប់ផ្គត់ផ្គង់
- **ទី៧** ជំរុញការយល់ដឹង និងទំនាក់ទំនងភាពជាដៃគូរវាងអ្នកពាក់ព័ន្ធ (ចំណងទាក់ទងជាមួយរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ អ្នកវិទ្យាសាស្ត្រ និងសហគមន៍)
- **ទី៨** ជំរុញការទទួលខុសត្រូវប្រកបដោយគុណធម៌ ក្រមសីលធម៌ និងមានឥរិយាបថរស់នៅគាំពារបរិស្ថានធម្មជាតិ និងវប្បធម៌ក្នុងចំណោមអ្នកពាក់ព័ន្ធ។

### ១.១៣.២ ធាតុផ្សំនៃជោគជ័យអេកូទេសចរណ៍

ប្រសិទ្ធភាព និងជោគជ័យក្នុងការអភិវឌ្ឍអេកូទេសចរណ៍ត្រូវមានទំនាក់ទំនងជាសំខាន់ជាមួយនឹង ការរៀបចំផែនការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់អេកូទេសចរណ៍បានល្អ។ យន្តការ កសាងផែនការគ្រប់គ្រង និងតំបន់អេកូទេសចរណ៍អាចដំណើរការបានល្អ ឬមិនល្អគឺមានអាស្រ័យដោយអ្នកពាក់ព័ន្ធនានា ដូចជាឧស្សាហកម្មអេកូទេសចរណ៍ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ អាជ្ញាធរជាតិ និងតំបន់ និងភ្នាក់ងារអភិវឌ្ឍន៍អេកូទេសចរណ៍។

### ១.១៣.៣ និរន្តរភាពនៃការអភិវឌ្ឍអេកូទេសចរណ៍

ការអភិវឌ្ឍប្រកបដោយនិរន្តរភាព អាចដំណើរការទៅបានទាមទារអោយមានការចូលរួមពីគ្រប់ផ្នែកនៃអ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀតដូចជា អង្គការទេសចរណ៍ពិភពលោក អង្គការក្នុងតំបន់រាជរដ្ឋាភិបាល ផ្នែកឯកជន និងសហគមន៍។ មានវិធីសាស្ត្រជាច្រើន អាចប្រើប្រាស់ដើម្បីអភិវឌ្ឍន៍អេកូទេសចរណ៍ប្រកបដោយនិរន្តរភាពដែល៖

- គឺការចូលរួមចំណែករបស់សហគមន៍
- គឺការប្រើប្រាស់ពលកម្មមូលដ្ឋានផ្គត់ផ្គង់ទំនិញ និងសេវាកម្ម
- គឺការបែងចែកផលប្រយោជន៍សមស្រប
- គឺការអភិរក្សបណ្តាញធនធានដែលមិនអាចកើតឡើងវិញបាន
- គឺការផ្តល់អំណាចដល់សហគមន៍

## ១.១៤ ទីផ្សារទេសចរណ៍

### ១.១៤.១ និយមន័យទីផ្សារទេសចរណ៍

សកម្មភាពដែលហៅថាទីផ្សារទេសចរណ៍គឺ ជាសកម្មភាពនៃការងារសរុបក្នុងការរៀបចំធ្វើដំណើរកម្សាន្ត និងអាជីវកម្មដែលធ្វើឡើងដើម្បីបំពេញជូនអតិថិជន ឬសេវាកម្មស្នាក់នៅរបស់ភ្ញៀវទេសចរណ៍អាហារ និងឧស្សាហកម្ម បដិសណ្ឋារកិច្ច ការសម្រាកលេងល្បែងកំសាន្ត។ល។ វិស័យទេសចរណ៍ ទាមទារនូវកម្រិតមុខ

ងារនិងគុណភាព ការងាររបស់ទីផ្សារមានការយល់ដឹងស៊ីជម្រៅនូវបញ្ហាដ៏ធំទូលាយ និងមានសមត្ថភាពគ្រប់គ្រាន់។

ក្នុងការឆ្លើយតបទៅនឹងការកើនឡើងរបស់អតិថិជនចេះច្នៃប្រឌិតផលិតផលសេវាកម្មដោយប្រាថ្នា និងប្រើប្រាស់យុទ្ធសាស្ត្រដែលបានរំពឹងទុកទៅលើចំណេះដឹងផ្នែកទីផ្សារ។

វិស័យទេសចរណ៍មានលក្ខណៈពិសេសប្លែកពីទម្រង់និងទ្រង់ទ្រាយផ្សេងៗនៃវិស័យសេដ្ឋកិច្ច។ ក្រៅពីជំនួញផ្នែកសេវាកម្មមានទាំងការលក់ទំនិញផ្សេងទៀត។ អ្នកស្រាវជ្រាវទេសចរណ៍ក្នុងពិភពលោកបានអោយដឹងថា លទ្ធផលដែលទទួលបានពីការលក់សរុបពីសេវាកម្មនៅក្នុងវិស័យទេសចរណ៍មាន៧៥% រីឯទំនិញ ២៥%។ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រច្រើននាក់បានអោយនិយមន័យប្លែកៗពីគ្នា។

- លោក RLunkor nigelak R.oner អ្នកស្រាវជ្រាវជនជាតិបារាំងបានបញ្ជាក់ថា "ម៉ាឃីតទីងទេសចរណ៍គឺជាឧបករណ៍មួយដែលបង្កើតឡើងដើម្បីសិក្សាស្រាវជ្រាវវិភាគ និងដោះស្រាយនៅគោលដៅមួយគឺបំពេញនឹងតម្រូវការទេសចរដោយមានការគិតគូហ្មត់ចត់អំពីការកែច្នៃ និងរៀបចំអោយបានសមស្របទៅតាមគម្រោងទឹកប្រាក់សំរាប់ដំណើរការសហគ្រាសទេសចរណ៍មួយ។
- លោក E.gripendoff ជាជនជាតិស្វីសបានអោយនិយមន័យម៉ាឃីតទីងទេសចរណ៍ប្រកបដោយលក្ខណៈ សកលភាវូបនីយកម្មហួសហេតុ ម៉ាឃីតទីងទេសចរណ៍ គឺជាប្រព័ន្ធបំលាស់ប្តូរនឹងការពាក់ព័ន្ធការងាររបស់ក្រុមហ៊ុនទេសចរណ៍ ហើយក៏ជានយោបាយរបស់ក្រុមហ៊ុនឯកជន និងរដ្ឋាភិបាលក្នុងវិស័យទេសចរណ៍សំរាប់បំពេញការងារក្នុងប្រទេសនិងក្រៅប្រទេស។ ទិសដៅនៃការផ្លាស់ប្តូរនេះគឺស្ថិតនៅលើការធ្វើយ៉ាងណាអោយមានការបំពេញតំរូវការអតិថិជនក្រុមណាមួយព្រមទាំងទទួលបាននៅលើទឹកប្រាក់។ ដើម្បីកំណត់ន័យអោយម៉ាឃីតទីងអង្គការទេសចរណ៍ពិភពលោក(UNWTO) បានចែកមុខងារម៉ាឃីទីងទេសចរណ៍ ជាបីផ្នែកគឺទី១ ការរៀបចំអោយមានទំនាក់ទំនងជាមួយអតិថិជនដែលមានន័យថា មានគោលបំណងយ៉ាងណាអោយមានគេជឿជាក់នឹងទទួលបាននូវអ្វីដែលគេ នឹងទទួលបានក្នុងតំបន់ដែលគេនឹងទៅអោយដល់។ ទី២ ការរីកចម្រើននិងការអភិវឌ្ឍដែលមានន័យថាការរៀនចំណេះដឹងធ្វើយ៉ាងណាអោយមានការអភិវឌ្ឍថ្មីៗនូវអ្វីដែលស្នើលក់របស់អតិថិជន និងបង្កើតបរិមាណលក់សេវាកម្មទាំងនោះ។ ទី៣ ការកែសំរួលនិងត្រួតពិនិត្យដែលមានន័យថាសំដៅទៅលើការវិភាគលទ្ធផលការងារដែលបានធ្វើដើម្បីជំរុញសេវាកម្មទីផ្សារនិងត្រួតពិនិត្យថា តើលទ្ធផលដែលទទួលបាននេះប្រាកដជាល្អសមស្របទៅតាមលទ្ធភាពដែរឬទេ។
- លោក D.Ismaev អ្នកវិទ្យាសាស្ត្រជនជាតិរុស្សីបានផ្តល់និយមន័យម៉ាឃីទីងទេសចរណ៍ គឺជាប្រព័ន្ធសកម្មភាពបង្កើត និងធ្វើអាជីវកម្មដែលមានទិសដៅបំពេញសេចក្តីត្រូវការរបស់អតិថិជន តាមរយៈការវិភាគពីតម្រូវការប្រើប្រាស់សេវាកម្មទេសចរណ៍ និងដើម្បីបំពេញគោលបំណងទទួលបានប្រាក់កម្រៃខ្ពស់។
- អ្នកស្រាវជ្រាវអាល្លឺម៉ង់ឈ្មោះ V.Riger P.Rot និងលោក A.shrand បានរួមគ្នាកំណត់ម៉ាឃីតទីងទេសចរណ៍ថា គឺជាការគ្រប់គ្រងទីផ្សារសកម្មភាព សំដៅសំរេចគោលបំណងសហគ្រាសក្នុងការធ្វើអោយការងារមានប្រសិទ្ធភាពជាងដៃគូប្រកួតប្រជែង និងបំពេញបំណងរបស់អតិថិជនចង់បាន។ ក្នុង

ករណីនេះម៉ាឃីតទីងទេសចរណ៍អាចត្រូវបានប្រើប្រាស់ក្នុងកម្រិតទីភ្នាក់ងារទេសចរណ៍ និងកម្រិតស្ថាប័នទេសចរណ៍ដែលប្រមូលផ្តុំថ្នាក់តំបន់និងថ្នាក់ជាតិ។ ជាការពិតណាស់ផលិតផលទេសចរណ៍ ត្រូវបានរៀបចំឡើង និងយកចិត្តទុកដាក់ដើម្បីងាយស្រួលក្នុងការបម្រើសេវាកម្មនិងជាពិសេសដើម្បីជំរុញនិងលើកទឹកចិត្តអោយមានការសម្រេចចិត្តប្រើប្រាស់ហើយពេញចិត្ត។ ម៉ាឃីតទីងក្នុងសម័យនេះដើរតួជាអ្នកបំពេញតួនាទីសកម្មភាពការងារទៅតាមលំដាប់លំដោយ ដើម្បីអោយសហគ្រាសទេសចរណ៍សម្រេចបាននូវបំណងប្រាថ្នា។ តាមរយៈការបង្ហាញខាងលើ និងការសិក្សាខាងលើកន្លងមកនិយមន័យម៉ាឃីតទីងទេសចរណ៍ត្រូវបានកំណត់ដូចខាងក្រោម៖

**ម៉ាឃីតទីងទេសចរណ៍** គឺជាប្រព័ន្ធការងារដែលសមស្របនឹងទាន់ពេលវេលាមួយដែលត្រូវបានប្រើប្រាស់សំរាប់ ការផ្គត់ផ្គង់សេវាកម្មដែលមានតម្រូវការនៅក្នុងទីផ្សារ និងសហគ្រាសទេសចរណ៍មានលទ្ធភាពស្មើឡើងអាចទទួលយកប្រាក់ចំណេញសំរាប់ខ្លួនឯងនឹងមានប្រសិទ្ធិភាពជាងគូប្រកួតប្រជែង។

### ១.១៤.២ មូលហេតុនៃការកំណត់ម៉ាឃីតទីងទេសចរណ៍

មូលហេតុនៃការកំណត់និយមន័យម៉ាឃីតទីងដូចខាងក្រោមនេះ ត្រូវបានធ្វើឡើងដោយពិចារណាទៅលើគោលគំនិតជាច្រើនដូចបង្ហាញខាងក្រោម៖

ម៉ាឃីតទីង មិនមែនមួយប្រភេទដោយឡែកនោះទេ វាជាសកម្មភាពដែលធ្វើឡើងដោយចង្អោមដើម្បីសម្រេចអោយបាននូវគោលបំណងនេះ។ ជាការពិតណាស់ ម៉ាឃីតទីងមិនមែនជាសកម្មភាពផ្សព្វផ្សាយ និងលក់សេវាកម្ម ឬមួយបង្កើតសេវាកម្មប៉ុណ្ណោះទេ វាជាប្រព័ន្ធប្រមូលផ្តុំរាល់មុខងារដែលវាមាននឹងធ្វើសកម្មភាពស្របជាមួយសកម្មភាពម៉ាឃីតទីង។

**ម៉ាឃីតទីង** គឺជាឧបករណ៍មួយដែលត្រូវបានប្រើប្រាស់សំរាប់ការបំពេញរាល់សំណូមពររបស់អតិថិជនស្មើឡើង។ ដូចដែលបានបង្ហាញរួចខាងលើម៉ាឃីតទីងត្រូវបានកំណត់រាល់បញ្ហាសំរាប់បច្ចុប្បន្ននិងអនាគត។ វាត្រូវបានព្យាករណ៍ឬមួយបង្កើតគោលគំនិតអោយបានត្រឹមត្រូវថាតើអតិថិជនចង់បានអ្វីដែលខានពុំបាន។ ហើយធ្វើសកម្មភាពដែលតម្រូវ ឬបង្ខំអោយអ្នកដទៃយកចិត្តទុកដាក់នឹងសម្រេចប្រើប្រាស់សេវាកម្ម ដែលសហគ្រាសស្មើឡើង។

### ១.១៤.៣ ធាតុផ្សំម៉ាឃីតទីងទេសចរណ៍

នៅឆ្នាំ១៩៧៨ លោក Mark Karti បានស្នើទស្សនៈរបស់ខ្លួនចំពោះធាតុផ្សំរបស់ម៉ាឃីតទីង"4P" ដែលបានបង្កើតឡើងតាមតួអក្សរនៃភាសាអង់គ្លេស Product (ផលិតផល) Price (តម្លៃ) Promotion (ការផ្សព្វផ្សាយ) Place (ទីកន្លែង) មួយរយៈក្រោយមកមានអ្នកនិពន្ធជាច្រើនបានខិតខំរិះរកមធ្យោបាយផ្សេងៗ ដើម្បីបំបែក និងជំរុញអោយមានការអភិវឌ្ឍទៅមុខ។

នៅឆ្នាំ១៩៨១ លោក Boom និងលោក Btner បានបង្ហាញអោយដឹងថាទស្សនាទានម៉ាឃីតទីង"4P" នេះសមស្របល្អសំរាប់ ចំពោះវិស័យផលិតផលទំនិញជាសម្ភារៈ(មិនមែនជាសេវាកម្ម) តែវិស័យសេវាកម្មត្រូវបានបង្ហាញទៅលើ"4P"នេះ"3P"ទៀតគឺ People (មនុស្ស) Physical (ចរិតលក្ខណៈតំបន់) process (ដំណើរការ) ពួកគាត់បានបន្ថែមទៀតថា"4P"មិនមែនពិនិត្យទៅលើកត្តាមនុស្ស។

- ✓ **ផលិតផល** អ្នកសិក្សា និងបណ្ដាអ្នកអនុវត្តការងារម៉ាឃីតទីង ត្រូវយល់ដឹងជាសំខាន់ថា ផលិតផលក្នុងសម័យនេះមានជាប់ពាក់ព័ន្ធនឹងកត្តាមូលដ្ឋានរបស់វាមួយចំនួនគឺ ប្រភេទ គុណភាពម៉ាកឬផ្លាក សញ្ញា សេវាកម្មផ្សេងៗនឹងបញ្ហាក្រោយពេលលក់។
- ✓ **ថ្លៃ** កត្តាដែលត្រូវយល់ដឹងសំខាន់គឺ កម្រិតតម្លៃ ការចុះបន្ថយតម្លៃ ការឧបត្ថម្ភ លក្ខណៈបង់ប្រាក់ អារម្មណ៍ចំពោះការទិញ ភាពជាសមមូលរវាងគុណភាព និងតម្លៃ។
- ✓ **ការផ្សព្វផ្សាយ** កត្តាត្រូវយល់ដឹងសំខាន់គឺ ផ្សព្វផ្សាយពាណិជ្ជកម្ម ការជំរុញការលក់ ការឃោសនាលក់ដោយបុគ្គលិក ទំនាក់ទំនងជាសាធារណៈ ការតាំងពិព័រណ៍។
- ✓ **ទីកន្លែង** កត្តាដែលត្រូវដឹងសំខាន់គឺទីស្នាក់ការការលក់ តំបន់ដែលអាចឈរជើងបាន ខ្សែរយៈបែកចែកចែកចាយ និងបណ្ដាញចែកចាយជាសំងាត់។
- ✓ **មនុស្ស** កត្តាដែលត្រូវដឹងទីមួយនោះគឺ បុគ្គលិកការងារ (ការបង្ហាត់បង្រៀន សីលធម៌ និងចំណេះដឹង) ទីពីរគឺ អតិថិជន(ទេសចរ ដែលពាក់ព័ន្ធនឹងចរិតលក្ខណៈទំនិញ កម្រិតចង់ដឹង ចង់ឃើញ ចង់សប្បាយ ការធ្វើទំនាក់ទំនងជាមួយនឹងអ្នកលក់)។
- ✓ **ចរិតលក្ខណៈតំបន់** កត្តានេះត្រូវយល់ដឹងសំខាន់ទៅលើ បញ្ហាបរិស្ថានមជ្ឈដ្ឋាន (បរិយាកាស) ខាងក្នុង ពន្លឺ កម្រិតនៃការបង្កើត សំឡេងអ៊ូអរ ភាពងាយស្រួលរបស់ទំនិញ ឬផលិតផល។
- ✓ **ដំណើរការ** កត្តាដែលត្រូវដឹងសំខាន់នោះគឺនយោបាយ ដំណើរវិវត្តន៍នៃការងារ ភាពជាស្វ័យប្រវត្តិលទ្ធភាពអ្នកទិញ ទិសដៅ ឬគោលនយោបាយរបស់អ្នកទិញ។

### ១.១៤.៤ យុទ្ធសាស្រ្តទីផ្សារ

ផ្នែកមួយដ៏សំខាន់នៃភារកិច្ចម៉ាឃីតទីងរបស់សហគ្រាសអាស្រ័យលើការកំណត់ពីលទ្ធភាពជាទ្រង់ទ្រាយធំ សំរាប់គម្រោងនៃសកម្មភាពការងារ។ ការងារត្រូវធ្វើឡើងតាមរយៈ ការជ្រើសរើសយុទ្ធសាស្រ្តម៉ាឃីតទីងដែលល្អប្រសើរ។ វាមានអត្ថប្រយោជន៍ខ្លាំងក្នុងការកំណត់អោយបាននូវរាល់ឧបសគ្គដែល នឹងត្រូវជួបប្រទះ នៅក្នុងការធ្វើសកម្មភាពម៉ាឃីតទីងនឹងអាចកំណត់បានច្បាស់លាស់អំពីធនធានដែលមាន ត្រូវប្រើប្រាស់សំរាប់ទិសដៅដែលត្រូវបានជ្រើសរើស។ ការអនុវត្តផ្ទាល់ទៅលើយុទ្ធសាស្រ្តម៉ាឃីតទីង ដែលដាក់ឡើងនេះមានទំនាក់ទំនងទៅនឹងការជ្រើសរើសសម្ភារៈផ្សេងៗ សំរាប់បំពេញអោយបាននៅគោលដៅ និងភារកិច្ចដែលបានកំណត់ឡើង។ ទាំងអស់នេះបញ្ជាក់អំពីតួនាទីដ៏សំខាន់ក្នុងសកម្មភាពម៉ាឃីតទីង ការបង្កើត ឬធ្វើឡើងនៅបណ្ដាញការងារម៉ាឃីតទីង។ ការងារបណ្ដាញទាំងនេះមានឥទ្ធិពលទៅលើទីផ្សារគោលដៅនឹងទាក់ទាញអោយមានការទទួលខុសត្រូវខ្ពស់ចំពោះភារកិច្ចដែលដាក់ឡើង។ តាមលក្ខណៈពិសេសរបស់បណ្ដាញការងារម៉ាឃីតទីងនៅក្នុងចង្កោមយុទ្ធសាស្រ្តម៉ាឃីតធីងសហគ្រាសត្រូវចាំបាច់រៀបចំយុទ្ធសាស្រ្តគោលដៅលំអិតតាមផ្នែកផ្សេងៗនៃបណ្ដាញការងារម៉ាឃីតធីង និងគុណភាពខ្ពស់ដូចជា យុទ្ធសាស្រ្តផលិតផល យុទ្ធសាស្រ្តថ្លៃ យុទ្ធសាស្រ្តចែកចាយផលិតផល និងយុទ្ធសាស្រ្តប្រាស្រ័យទាក់ទង។

១. **យុទ្ធសាស្រ្តផលិតផល** ត្រូវបានរៀបចំឡើង ដើម្បីបែងចែកអោយមានការកំនត់នូវប្រភេទ នៃផលិតផលដែលត្រូវការបំរុង នឹងផលិតផលរំពឹងទុកផលិតផលដែលត្រូវការផលិតនឹងរៀបចំដំណើរការនៃការផលិត នូវ

ផលិតផលប្រភេទណាមួយដែលទីផ្សារត្រូវការនឹងសមស្របទៅតាមតម្រូវការរបស់អតិថិជនបង្កើតផលិតផលទេសចរណ៍ថ្មីដែលមានគុណភាពល្អសំរាប់ផ្គត់ផ្គង់ទីផ្សារ។

២. **យុទ្ធសាស្ត្រថ្លៃ** រៀបចំឡើង ក្នុងគោលបំណងកំណត់ថ្លៃផលិតផលដែលបង្កើតឡើងហើយ មានប្រសិទ្ធភាពដោយអាចទាក់ទាញអ្នកទិញក្នុងរយៈខ្លី និងរយៈពេលយូរអង្វែងសម្រាប់ផលិតផលប្រភេទណាមួយនិងសំរាប់កំណត់ទីផ្សារមួយ។

៣. **យុទ្ធសាស្ត្រជំរុញការផលិតផល** ត្រូវបានរៀបចំឡើងដើម្បីកំណត់ផ្លូវ ទ្រង់ទ្រាយ ទម្រង់ និងវិធីណាមួយដែលនឹងធ្វើឡើងសម្រាប់ជំរុញ និងធ្វើឱ្យអតិថិជនបានដឹង ស្គាល់ លើផលិតផលបានរៀបចំឡើង។

៤. **យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង** គឺជាកំណត់នៅគោលដៅច្បាស់លាស់សំរាប់សកម្មភាពការងារសហគ្រាសទេសចរណ៍ក្នុងការបង្ហាញ និងផ្សព្វផ្សាយអំពីខ្លួននិងផលិតផលរបស់ខ្លួន។ សកម្មភាពទាំងនេះរួមមានផ្សាយពាណិជ្ជកម្មផ្សព្វផ្សាយជំរុញការលក់ផលិតផល យុទ្ធនាការផ្សព្វផ្សាយចូលរួមក្នុងពិធីតាំងពិចារណាបង្ហាញពិព័រណ៍លក់ បង្កើនកិត្តិយសរបស់សហគ្រាសនៅក្នុងទីផ្សារ។

# ជំពូកទី២
# ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត

## ២.១ ស្ថានភាពទូទៅនៃខេត្តកោះកុង

### ២.១.១ ប្រវត្តិខេត្តកោះកុង

ខេត្តកោះកុងត្រូវបានបង្កើតឡើងក្នុងសម័យសង្គមរាស្ត្រនិយមនៃរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តម សុរាម្រឹតដោយ ព្រះរាជក្រមលេខ ២៤៦ន.ស.ចុះថ្ងៃទី១៣ខែមករាឆ្នាំ១៩៥៨ ដែលបានកាត់ចេញពីខេត្តកំពត និងតាំងនៅកន្លែងមួយ ហៅថា«ចាំយាម» ក្នុងឃុំ កោះប៉ោមានផ្ទៃដីទំហំ ៦០៦.៦៤០ហិចតា និងមានស្រុកចំនួន ២កាលជំនាន់នោះគឺកំពង់សោម និងកោះកុង។

ខេត្តកោះកុងត្រូវបានកែប្រែ និងបង្កើតជាខេត្តមួយហៅថា ខេត្តកោះកុងដែលមានទីតាំងនៅភូមិបាង ចាកក្នុងឃុំពាមក្រសោប ដោយព្រះរាជក្រមលេខ ៣៣២-ន.ស.ចុះថ្ងៃទី១៣ សីហា គ.ស ១៩៥៩ នៃរជ្ជកាល ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រឹត វិសុទ្ធមហាខត្តិយវង្សវិសិដ្ឋហរិពង្ស គុណាតិរេក ធម្មចរិយោត្តម បរមបពិត្រ ព្រះចៅព្រះរាជអាណាចក្រកម្ពុជា ជាអម្ចាស់ជីវិតលើត្បូង។

### ២.១.២ ទីតាំងភូមិសាស្ត្រខេត្តកោះកុង

ខេត្តកោះកុង ស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជារួមមានកំពត កែប ព្រះសីហនុ និងកោះកុង។ ជាខេត្តមួយក្នុងចំណោមរាជធានីខេត្តទាំង២៥នៃព្រះរាជាណាចក្រកម្ពុជាមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះសីហនុនិងខេត្តកំពង់ស្ពឺ ខាងលិចជាប់នឹងឈូងសមុទ្រ ខាងជើងជាប់នឹងខេត្តពោធិ៍សាត់និង ខាងត្បូងជាប់នឹងឈូងសមុទ្រ ។ ខេត្តកោះកុង ស្ថិតនៅចម្ងាយ២៧១គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ តាមផ្លូវជាតិលេខ៤និង៤៨ កាត់ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ។ ខេត្តនេះចែកចេញជា០៦ស្រុកនិង០១ក្រុង ឃុំចំនួន ២៦ សង្កាត់មានចំនួន ០៣ និងមានចំនួន ១១៧ភូមិ។ មានផ្ទៃដីសរុប១០,០៤៥,៥៨ គីឡូម៉ែត្រការ៉េ ជាប់លំដាប់ទី០៦បណ្តាផ្ទៃដីនៃរាជធានីខេត្តទាំង២៥។ មានឆ្នេរសមុទ្រប្រវែង៣៣៤គីឡូម៉ែត្រ។ ខេត្តនៅចុងនិរតីបំផុតនៃប្រទេសកម្ពុជានេះ មានខ្សែឆ្នេរសមុទ្រដ៏វែងដែលមិនទាន់បានអភិវឌ្ឍន៍ និង ទីខាងក្នុងព្រៃ ភ្នំ ដែលមិនអាចចូលទៅដល់ដ៏ធំល្វឹងល្វើយហ៊ុំព័ទ្ធដោយផ្នែកនៃជួរភ្នំក្រវាញ ឧទ្យានជាតិដ៏ធំបំផុតរបស់កម្ពុជា គឺឧទ្យានជាតិបទុមសាគរ និងក៏ជាផ្នែកមួយនៃឧទ្យានជាតិគីរីរម្យ។

ស្ថានភាពភូមិសាស្ត្រនៅក្នុងខេត្តកោះកុងនេះមានលក្ខណៈអំណោយផលល្អដោយមានផ្លូវទឹកតាមសមុទ្រមានដៃសមុទ្រឆ្លងស្ពានចំនួន០៥ដូចជាៈ ស្ពានព្រែកកោះប៉ោស្ពានតាតៃ ស្ពានត្រពាំងរូង ស្ពានអណ្តូងទឹក ស្ពានស្រែអំបិល ហើយដែលនៅក្នុងតំបន់នេះទៀតសោត ជាប្រភពធនធានដ៏សំបូរបែបរួមមានៈ ជីវចម្រុះគ្រប់ប្រភេទនៅតាមដងព្រែក តំបន់ទាំសារ (ព្រៃកោងកាងដែនជំរកសត្វស្លាប ដែនជំរកមច្ឆាជាតិជីវៈសមុទ្រ ព្រមទាំងសម្រស់ធម្មជាតិដ៏ត្រកាលនិងស្រស់បំព្រងនៃព្រៃភ្នំ ទឹកជ្រោះធ្លាក់ ព្រែក ស្ទឹង ដងអូរ កោះ ប្រជុំកោះដែលមានឆ្នេរខ្សាច់ស្អាតៗនៅគ្រប់រដូវ ។

មិនតែប៉ុណ្ណោះ ខេត្តកោះកុងជាខេត្តមួយក្នុងចំណោមខេត្តបីដទៃទៀត ដែលត្រូវបានប្រសិទ្ធនាមថាជា តារារះនាទិសនិរតីក្នុងន័យជាឆ្នេរសមុទ្រស្អាតកម្ពុជា។

### ២.១.៣ លក្ខណៈប្រជាជនខេត្តកោះកុង

ខេត្តកោះកុង មានប្រជាជនសរុប ១៣១,០៩៨នាក់ ស្រី ៦២,៩៣៥ នាក់ មាន ដង់ស៊ីតេប្រជាជន ១២ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។ មានកំណើនប្រជាជនប្រចាំឆ្នាំប្រមាណ១,១៤%។ មានស្រុកចំនួន០៦ ឃុំចំនួន ២៦ សង្កាត់ចំនួន០៣ និងភូមិចំនួន១១៧។ គ្រួសារសរុបចំនួន២៨,៨៨៩គ្រួសារ(គិតត្រឹមថ្ងៃទី០៣ ខែ មីនាឆ្នាំ ២០១៧)។ ខេត្តកោះកុងក្នុងចំណោមគ្រួសារសរុប(២៨,៨៨៩) ក្នុងនោះមានគ្រួសារជាជនជាតិដែលភាគរយខ្ពស់ជាងគេបន្ទាប់ពីជនជាតិខ្មែរគឺជនជាតិចិន២,៧% ថៃ១,៨% គ្រួសារជាជនជាតិវៀតណាម១,១% និងគ្រួសារជាជនជាតិភាគតិច០,៣%។ ខេត្តកោះកុងមានគ្រួសារប្រមាណជាង ៦៩,៣១% នៃគ្រួសារសរុបរស់នៅជនបទប្រកបរបរកសិកម្មជាចម្បងក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងខេត្ត ក្នុងនោះគ្រួសារដែលធ្វើស្រែចំការមាន២៤,៤៨% ដាំដំណាំរយៈពេលវែងមាន៤,០៣% ដាំដំណាំរយៈពេលខ្លីមាន ២,៨៦% ដាំបន្លែមាន ១,៨២% ចិញ្ចឹមសត្វមាន៣,៦៧% រកអនុផលព្រៃឈើមាន ០,៩២% និងមុខរបរនេសាទមាន ១៣,៩២% ។ ក្រៅពីវិស័យកសិកម្ម ដែលជាស្នូលក៏មានវិស័យផ្សេងៗទៀតដូចជាវិស័យឧស្សាហកម្ម ៦,៨២% និង វិស័យសេវាកម្មប្រមាណ ២៩,៥៣% ' ដែលជាមូលដ្ឋានបង្កើតការងារជូនប្រជាពលរដ្ឋ ។

## ២.២ ស្ថានភាពទូទៅរបស់សហគមន៍អេកូទេសចរណ៍ជីផាត

### ២.២.១ ប្រវត្តិ និងទីតាំងសហគមន៍

នៅក្នុងខេត្តកោះកុង មានឈ្មោះសហគមន៍មួយឈ្មោះថាសហគមន៍អេកូទេសចរណ៍ជីផាត ដែលឈ្មោះនេះមានតំណាលមកថាកើតចេញពីឈ្មោះតាជី និងយាយផាត ដែលជាអ្នកមករស់នៅតំបន់នេះមុនដំបូងគេ។ លោក រី សាំងប៊ិន មគ្គុទ្ទេសក៍ទេសចរនៅតំបន់សហគមន៍អេកូទេសចរណ៍ជីផាតនៃស្រុកថ្មបាំង ខេត្តកោះកុងបានបញ្ជាក់ថា តាមចាស់ៗនិយាយតៗគ្នាមក តំបន់នេះគេដាក់ឈ្មោះតាយាយពីរនាក់ ដែលមករស់នៅទីនេះ គឺតាជីនិងយាយផាត។ ដើមឡើយតំបន់នេះ មិនមានភូមិនោះទេ វាជាព្រៃឬស្សី ហើយតាជី និងយាយផាតបានមកកាប់ឆ្ការ លុះពេលដែលតាយាយទាំងពីរស្លាប់ទៅ គេក៏យកឈ្មោះគាត់ទាំងពីរមកដាក់តែម្តង ពោលគឺគេហៅតំបន់នេះថា «**ជីផាត**»ចាប់តាំងពីពេលនោះមក។

មុនឆ្នាំ២០០៧ តំបន់នេះពោរពេញទៅដោយការកាប់បំផ្លាញធនធានធម្មជាតិយ៉ាងធ្ងន់ធ្ងរក្រោយសង្គ្រាមស៊ីវិលចប់ កន្លែងនេះជាកន្លែងរោងចក្រអារឈើ មានការកាប់ព្រៃឈើ កាប់ចម្ការពនេចរនៅពេញទីកន្លែងក្នុងតំបន់នេះ។ ចំណែកសត្វព្រៃមានការចាប់លក់គ្រប់កន្លែង។

លុះដល់ឆ្នាំ២០០៧ សហគមន៍អេកូទេសចរណ៍ជីផាតបានបង្កើតឡើង ក្រោមការជួយឧបត្ថម្ភគាំទ្រពីមូលនិធិអង្គការសម្ព័ន្ធមិត្តសត្វព្រៃ និងមានការចូលរួមពីប្រជាជនក្នុងឃុំ ជីផាត(ភូមិជីផាត ភូមិកំលត ភូមិជាំស្លា និងភូមិទឹកល្អក់) ក្នុងគោលបំណងការពារធនធានធម្មជាតិរក្សាតម្លៃវប្បធម៌ខ្មែរ និងលើកស្ទួយជីវភាពប្រជាជនអោយបានកាន់តែប្រសើរឡើងបន្ថែមទៀត ដោយបញ្ឈប់ការប្រកបអាជីវកម្មបំផ្លាញធនធានធម្មជាតិ ឈប់បរ

បាញ់សត្វ កាប់បំផ្លាញព្រៃឈើ ជាពិសេសផ្តល់ឱកាសអោយប្រជាជន ក៏ដូចជាភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិ បានចែករំលែកនូវបទពិសោធន៍គ្នាទៅវិញទៅមក ថែមទាំងបានផ្តល់នូវសិទ្ធិអំណាចដល់អាជ្ញាធរ ក្នុងការគ្រប់គ្រងអេកូទេសចរណ៍អាស្រ័យដោយសហគមន៍។ ឆ្នាំ២០០៧ រហូតដល់បច្ចុប្បន្នអង្គការសម្ព័ន្ធមិត្តសត្វព្រៃបានចំណាយថវិកាជាង១លានដុល្លាក្នុងការរៀបចំ កសាងសហគមន៍រួមទាំងរៀបចំគណៈកម្មការគ្រប់គ្រងសហគមន៍ និងរចនាសម្ព័ន្ធផ្សេងៗ សម្រាប់ជួយជ្រោមជ្រែងទាំងអស់។

សហគមន៍អេកូទេសចរណ៍ ឃុំជីផាត សរសេរជាអក្សរខ្មែរកាត់ថា **ស អ ជ** និងមានឈ្មោះ ជាភាសាអង់គ្លេសថា (Chi Phat Community Based Eco-tourism) សរសេរអក្សរកាត់ថា "CBET"។ សហគមន៍អេកូទេសចរណ៍ឃុំជីផាតត្រូវមាននិមិត្តសញ្ញាជាផ្លូវការរបស់ខ្លួន ដែលមានខ្សែរង្វង់ពីរជាន់ពណ៌មាស តំណាងឲ្យទ្រព្យសម្បត្តិ ភាពសម្បូររុងរឿងត្រចះត្រចង់ក្នុងសហគមន៍។ ផ្ទៃចន្លោះខ្សែរង្វង់ពីរជាន់ពណ៌ស និងរូបដើមក្រវាញ តំណាងឲ្យធនធានធម្មជាតិ ក្នុងតំបន់ជួរភ្នំក្រវាញដែលបន្សល់ពីបុព្វបុរសជំនាន់មុននឹងត្រូវបានថែរក្សាការពារពីកូនចៅជំនាន់ក្រោយជានិរន្តរ៍។

- ជាន់ទី១ សរសេជាអក្សរខ្មែរថា "សហគមន៍អេកូទេសចរណ៍ឃុំជីផាត"។
- ជាន់ទី២ សរសេរជាអក្សរអង់គ្លេសថា CHI PHAT COMMUNITY BASED- ECOTOURISM។
- ដោយអក្សរទាំងពីរឃ្លា (សហគមន៍អេកូទេសចរណ៍ឃុំជីផាត) និង CHI PHAT COMMUNITY BASED-ECOTOURISM ខាងលើដែលមានពណ៌ ខៀវដិតតំណាងឲ្យមេត្រីភាព កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិលើវិស័យទេសចរណ៍។
- និមិត្តសញ្ញារូប ដំរី តំណាងឲ្យសត្វព្រៃកម្រ និងជិតផុតពូជសល់ក្នុងតំបន់។
- និមិត្តសញ្ញារូប ពាង តំណាងឲ្យធនធានវប្បធម៌។
- ផ្ទៃពណ៌បៃតងដែលមានពន្លឺចេញចំកណ្តាលនៃផ្ទៃរង្វង់ខាងក្នុងតំណាងឲ្យធនធានធម្មជាតិ បរិស្ថាន អនាម័យ ដែលមានសម្រស់ស្រស់បំព្រង។

សហគមន៍អេកូទេសចរណ៍ជីផាតមានទីតាំងស្ថិតនៅក្នុងភូមិជីផាត ឃុំជីផាត ស្រុកថ្មបាំង ខេត្តកោះកុងនាទិសនិរតីនៃប្រទេសកម្ពុជា។ វាមានចម្ងាយប្រហែល ១០០ គីឡូម៉ែត្រពីទីរួមខេត្តកោះកុងនិងមានចម្ងាយ ១៩០ គីឡូម៉ែត្រ ពីភ្នំពេញ។ ដែលអាចធ្វើដំណើរទៅកាន់តំបន់នោះតាមផ្លូវជាតិលេខ៤៨ ត្រង់ចំណុចផ្លូវបំបែកហួសស្ពានអណ្តូងទឹកប្រហែល៥គ.ម រួចបន្តដំណើរតាមផ្លូវគ្រួសក្រហមរហូតដល់ភូមិជីផាតតែម្តង។ ជីផាត គឺជាតំបន់ដីគោកដែលនៅសេសសល់ធំជាងគេបង្អស់នៅអាស៊ីអាគ្នេយ៍ដែលស្ថិតនៅចំកណ្តាលបេះដូងនៃជួរភ្នំក្រវាញក្នុងប្រទេសកម្ពុជាមានផ្ទៃដីប្រមាណ ១,០០០,០០០ ហិចតានិងនៅជិតព្រំដែននឹងប្រទេសថៃ។ ឃុំជីផាតទាំងមូលមានផ្ទៃដីប្រមាណ៥០០០ហិចតា(ទំហំផ្ទៃដីសហគមន៍អេកូទេសចរណ៍ជីផាតទាំងមូលពុំបានកំណត់នោះទេ)។

### ២.២.២ សណ្ឋានដីក្នុងសហគមន៍

បើនិយាយពីសណ្ឋានដីស្រុកថ្មបាំងទាំងមូលក៏ដូចជាសហគមន៍អេកូទេសចរណ៍ជីផាត ដែលជាទឹកដីខេត្តកោះកុងជិតតំបន់ជាប់ព្រំដែនកម្ពុជា-ថៃ។ ទីនោះភាគច្រើនជាប្រភេទដីក្រហមមាន ជីវជាតិងាយស្រួលដល់

ប្រជាពលរដ្ឋដាំដុះដំណាំ។ ដោយសារសណ្ឋានដីអំណោយផលបែបនេះហើយទើបមានប្រជាជនប្រកបរបរកសិករប្រមាណ៩០ភាគរយ។ រឹតតែពិសេសជាងនេះទៅទៀត នៅទីនេះសម្បូរទៅដោយដំណាំហូបផ្លែមាន ចេក ល្ហុង ត្រាវ ទុរេន រួមទាំងដំណាំផ្សេងទៀត។

### ២.២.៣ អាកាសធាតុក្នុងសហគមន៍

ប្រទេសកម្ពុជារងឥទ្ធិពលអាកាសធាតុពីខ្យល់ត្រូពិច និងទទួលរងឥទ្ធិពលពីកត្តាខុសគ្នាជាច្រើន ដែលរួមទាំងទីតាំងដែលស្ថិតនៅក្នុងតំបន់ជួបគ្នានៃអាកាសធាតុត្រូពិច និងខ្យល់មូសុង។ ដូចគ្នានឹងប្រទេសទាំងមូលផងដែរ ខេត្តកោះកុងមានរដូវខុសគ្នាចំនួនពីរដូចជា៖ រដូវប្រាំង ពីខែវិច្ឆិកា ដល់ខែមេសា មានខ្យល់មូលសុងឦសានស្ងួត និងត្រជាក់ ដោយមានខែកុម្ភៈស្ងួតជាងគេ។ រដូវវស្សា ពីខែឧសភា ដល់ខែតុលា ក្នុងនោះមានភ្លៀងធ្លាក់ភាគច្រើនបានមកពីខ្យល់មូសុង និរតីដែលបក់មកពីមហាសមុទ្រឥណ្ឌាមកលើដែនដីគោក ខែមេសា និងខែតុលា គឺជាខែដែលស្ថិតនៅចន្លោះរវាងរដូវមូសុងទាំងពីរ ដែលមានសីតុណ្ហភាពមធ្យម អប្បបរមានៅខេត្តកោះកុង គឺមាន២២អង្សាសេ និងមធ្យមអតិបរមា ៣២អង្សាសេ។ ខែមេសាជាខែក្តៅខ្លាំងជាងគេ ហើយខែមករាជាខែត្រជាក់ជាងគេនៃខែនីមួយៗ។ កំពស់ទឹកភ្លៀងប្រចាំឆ្នាំមានពី១៧,៣ ស.ម ដល់៩២៦,៩ម.ម។ នៅខេត្តកោះកុងពុំមានស្ថានីយ៍ឧតុនិយមដើម្បីកត់ត្រាទឹកជោរ ឬនាចឡើយ។ ទោះជាយ៉ាងណាក៏ដោយ ទឹកសមុទ្រពិតជាទាបនៅក្នុងរដូវវស្សា និងប្រែប្រួលប្រមាណ០,៧០ម៉ែត្រ ចំណែកនៅក្នុងខែធ្នូ និងមករា ទឹកជោរ ដល់កម្រិតកំពូលប្រមាណ២ម៉ែត្រ។ កម្រិតប្រែប្រួលជាខ្លាំងរវាងរដូវវស្សានិងរដូវប្រាំង ដែលមានកំហាប់អំបិលពី១ភាគពាន់ដល់៣៥ភាគពាន់។ កំហាប់អុកស៊ីសែនប្រែប្រួលតិចតួច។

### ២.២.៤ លក្ខណៈប្រជាជនក្នុងសហគមន៍

នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត មានប្រជាជនសរុបប្រមាណជាង ២,២៨៣ នាក់ ស្មើនឹង ៦៣២ គ្រួសារ(គិតត្រឹមឆ្នាំ២០២១)។ ភាគច្រើនប្រជាពលរដ្ឋស្រុកថ្មបាំងមានជីវភាពសមល្មម ដោយអ្នករស់នៅទីនេះ ភាគច្រើនប្រកបរបរធ្វើស្រែចំការ ដាំដំណាំហូបផ្លែ បន្លែបង្កាធម្មជាតិ និងមុខរបរ មួយទៀត គឺឡើងភ្នំប្រមូលអនុផលព្រៃឈើ។ ចំណែកឯ ប្រជាជននៅក្នុងសហគមន៍មានជំនឿទៅលើព្រះពុទ្ធសាសនា ប្រជាជនខ្លះជឿទៅលើគ្រិស្តសាសនា និងមួយចំនួនទៀតជឿទៅលើឥស្លាមសាសនា។ ម្យ៉ាងវិញទៀតនោះ ប្រជាសហគមន៍នៅទីនេះ ចម្រុះដោយជាតិសាសន៍ មានដូចជា ជនជាតិខ្មែរ ជនជាតិចិន ជនជាតិថៃ ជនជាតិវៀតណាម និងជនជាតិភាគតិច។ ប៉ុន្តែ ទោះបីជាយ៉ាងណា ពួកគាត់និយាយភាសាខ្មែរជាប្រចាំថ្ងៃ និងការស្លៀកពាក់ក៏តាមបែបប្រពៃណី ទំនៀមទម្លាប់ខ្មែរផងដែរ។

## ២.៣ រចនាសម្ព័ន្ធ និងតួនាទីការងារនៅក្នុងសហគមន៍

### ២.៣.១ រចនាសម្ព័ន្ធគ្រប់គ្រង




### ២.៣.២ តួនាទីភារៈការងារនៅក្នុងសហគមន៍

**ចំណុចទី០១៖**

ការអភិវឌ្ឍ និងការគ្រប់គ្រងផលិតផលដែលមានស្រាប់ និងបង្កើតផលិតផលថ្មី

- អភិវឌ្ឍន៍ផលិតផលដែលបានរកឃើញ និងស្វែងរកផលិតផលថ្មីៗដែលមានក្នុងផែនទីសហគមន៍
- ពិភាក្សាជាមួយសហគមន៍ និងដាក់ផែនការ
- ការកំណត់តំលៃសម្រាប់ផលិតផល
- ការបែងចែកផលប្រយោជន៍ រវាងមូលនិធិសហគមន៍ និងអ្នកផ្តល់សេវាកម្ម
- ធ្វើកិច្ចព្រមព្រៀងជាមួយម្ចាស់ផលិតផល
- រៀបចំការបណ្តុះបណ្តាលសម្រាប់អ្នកផ្តល់សេវាកម្ម
- កំណត់ពេលវេលាសម្រាប់ការបង្ហាញនូវផលិតផល
- ជ្រើសរើសអ្នកទទួលខុសត្រូវសម្រាប់ផលិតផល និងសេវាកម្ម
- លើកគំរោងស្នើរសុំថវិកា ដើម្បីរៀបចំផលិតផលថ្មីៗ ប្រសិនបើចាំបាច់
- អនុវត្តគម្រោងធ្វើផលិតផលថ្មីៗតាមផែនការការងារ
- សំរេចធ្វើការផ្សព្វផ្សាយ និងលក់ដូរផលិតផល។

**ចំណុចទី០២៖**

រៀបចំចាត់ចែងភ្ញៀវទេសចរណ៍ ផលិតផល សេវាកម្ម និងសកម្មភាព

- ស្វាគមន៍ភ្ញៀវ និងតំរូវឱ្យភ្ញៀវចុះឈ្មោះក្នុងសៀវភៅ
- ផ្តល់ព័ត៌មានដល់ភ្ញៀវ
- រៀបចំអាហារ និងការស្នាក់នៅជូនភ្ញៀវ
- រៀបចំដំណើរកំសាន្ត (ស្វែងរកអ្នកនាំភ្ញៀវ ចុងភៅព្រៃ រៀបចំសម្ភារៈនិង សម្ភារៈសង្គ្រោះបឋមជាដើម)
- សរសេរព័ត៌មានសកម្មភាព ដែលភ្ញៀវបានកក់ ដាក់លើក្តារខៀនសម្រាប់ភ្ញៀវកក់
- ផ្ញើវិក័យប័ត្រឱ្យភ្ញៀវ និង តំរូវឱ្យភ្ញៀវកក់៥០%
- ត្រូវចេះដោះស្រាយរាល់បញ្ហាដែលភ្ញៀវត្រូវជួបដោយចៃដន្យ
- រក្សាសុវត្ថិភាពជូនភ្ញៀវ
- ត្រូវឲ្យភ្ញៀវបំពេញព័ត៌មានពេលត្រលប់មកពីការកំសាន្តវិញ ។

**ចំណុចទី០៣៖**

ការគ្រប់គ្រងមូលនិធិ (ឧបសម្ព័ន្ធទី៦)

- គ្រប់ប្រធាន ក្រុមសេវាកម្មទាំងអស់ ត្រូវរាយការណ៍ប្រចាំខែឲ្យច្បាស់លាស់ពីប្រាក់ចំណូល និង ចំណាយដល់សហគមន៍
- ការបង់ចូលមូលនិធិ ត្រូវមានការយល់ព្រមរវាងគណៈកម្មការ និងសមាជិកគ្រប់សេវាកម្មទាំងអស់ ចាំបាច់ត្រូវបង់ចូលមូលនិធិសហគមន៍
- ប្រសិនបើត្រូវការបង្កើនតំលៃថ្មីលើសេវាកម្មទាំងអស់ដើម្បីបង្កើនការបង់ចូលមូលនិធិសហគមន៍ គណៈកម្មការ សមាជិក និងអ្នកផ្តល់សេវាកម្មត្រូវប្រជុំឯកភាពគ្នា។

**ចំណុចទី០៤៖**

ការត្រួតពិនិត្យ ការគ្រប់គ្រងប្រាក់ចំណូល និងចំណាយសហគមន៍

- គណៈកម្មការអាចប្រើប្រាស់ថវិកាក្នុងដៃត្រឹម១,២០០,០០០ រៀលប៉ុណ្ណោះនៅក្នុងការិយាល័យ ដើម្បីទុកដូរជូនភ្ញៀវ បើលើសពីនេះត្រូវតំកល់ទុកក្នុងធនាគារ ។
- គណៈកម្មការ និងអាជ្ញាធរមូលដ្ឋានត្រូវត្រួតពិនិត្យប្រាក់ឲ្យច្បាស់លាស់ មុននឹងបញ្ជូនប្រាក់ទៅធនាគារ ។

**ចំណុចទី០៥៖**

តំណាងគណៈកម្មការ នឹងធ្វើការជាមួយដៃគូពាក់ព័ន្ធដូចជា អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារទេសចរណ៍ អន្តរការីទេសចរណ៍ និងម្ចាស់ជំនួយ

- ប្រធាន អនុប្រធាន គណៈកម្មការ ឬប្រធានគណនេយ្យ (ក្នុងករណីជ្រើសរើសដោយមានការពេញចិត្ត) អាចតំណាងឲ្យគណៈកម្មការធ្វើការជាដៃគូពាក់ព័ន្ធដូចជាអាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារទេសចរណ៍ អន្តរការីទេសចរណ៍ និងម្ចាស់ជំនួយ

- អ្នកតំណាងអាចសម្រេចចិត្តដោះស្រាយដោយខ្លួនឯង រាល់កិច្ចការតូចតាចប៉ុន្តែរាល់កិច្ចការធំៗ ត្រូវប្រជុំពិភាក្សាជាមួយជួរគណៈកម្មការធ្វើការសម្រេចចិត្ត
- ប្រធានគណៈកម្មការ ត្រូវប្រកាន់ភាពអព្យាក្រឹត្យមិនលំអៀងទៅខាងសមាជិកណាមួយឡើយ ។

**ចំណុចទី០៦៖**

ការធ្វើការរួមគ្នាជាមួយអាជ្ញាធរមូលដ្ឋាន

- មានការយល់ព្រមពីអាជ្ញាធរមូលដ្ឋានក្នុងការបើកសហគមន៍
- មានការយល់ព្រមរបស់អាជ្ញាធរមូលដ្ឋានក្នុងការធ្វើសកម្មភាពសហគមន៍
- មានការយល់ព្រមពីអាជ្ញាធរមូលដ្ឋាន ទទួលស្គាល់គណៈកម្មការ និងសមាជិកសហគមន៍
- មានការយល់ព្រមរបស់អាជ្ញាធរមូលដ្ឋាន និងការគាំទ្រសហគមន៍ អភិវឌ្ឍន៍ផែនការប្រចាំខែ និងឆ្នាំ
- មានការយល់ព្រមរបស់អាជ្ញាធរមូលដ្ឋាន ទៅលើការការពារធនធានធម្មជាតិក្នុងតំបន់ ។

**ចំណុចទី០៧៖**

ធ្វើការជាមួយដៃគូដូចជាអង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយផ្សេងៗទៀត

- ធ្វើការជាមួយអង្គការបណ្តុះបណ្តាលចំណេះដឹងលើគ្រប់សេវាកម្ម
- ទទួលជំនួយជាសម្ភារៈ និងថវិកាពីអង្គការមិនមែនរដ្ឋាភិបាល សប្បុរសជនស្ថាប័នផ្សេងៗ ។

**ចំណុចទី០៨៖**

ធ្វើការជាមួយភ្នាក់ងារទេសចរណ៍ និងអន្តរការីទេសចរណ៍

- ធ្វើការជាមួយភ្នាក់ងារទេសចរណ៍ និងអន្តរការីទេសចរណ៍ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍
- ធ្វើការជាមួយភ្នាក់ងារទេសចរណ៍ និងអន្តរការីទេសចរណ៍ដើម្បីធ្វើផលិតផលថ្មីនឹងទទួលបទពិសោធន៍ផ្សេងៗពីពួកគេ
- ធ្វើការជាមួយពួកគេ ផ្សព្វផ្សាយពីសហគមន៍អេកូទេសចរណ៍ដីផាត។

**ចំណុចទី១១៖**

ត្រូវផ្សព្វផ្សាយឲ្យសមាជិកទាំងអស់គោរពតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

**ចំណុចទី១២៖**

គណៈកម្មការត្រូវតាមដានមើលសកម្មភាពសមាជិករបស់ខ្លួនដូចជា កែលំអផ្លូវដើរព្រៃ ការកែលំអផ្ទះស្នាក់អាហារដ្ឋាន ផ្នែកល្បាតជាដើម ។

**ចំណុចទី១៣៖**

គណៈកម្មការត្រូវពិនិត្យលើ មតិវាយតំលៃរបស់ភ្ញៀវ ដើម្បីកែលំអសមាជិកសេវាកម្ម និងផលិតផលរបស់ខ្លួន ។

**ចំណុចទី១៤៖**

គណៈកម្មការត្រូវដាក់ពិន័យលើសមាជិក ដែលមិនគោរពតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង (ជំពូកទី១១)។

**ចំណុចទី១៥៖**

សមាជិកគណៈកម្មការ ត្រូវរៀបចំការប្រជុំប្រចាំខែ អំពីដំណើរការអភិវឌ្ឍសហគមន៍ និងមូលនិធិ

- ប្រធានគណៈកម្មការត្រូវជំរាបអ្នកចូលរួមអំពីប្រធានបទប្រជុំ។

## ២.៤ ធនធាន និងសេវាកម្មទាក់ទាញទេសចរនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត

### ២.៤.១ ធនធានធម្មជាតិ

ធនធានទេសចរណ៍ គឺជាមូលដ្ឋានគ្រឹះសម្រាប់វិស័យទេសចរណ៍នៅគ្រប់តំបន់ទាំងអស់ដែលសំដៅទៅលើបែបផែនផ្សេងៗនៃការទាក់ទាញប្រកបដោយសក្តានុពលដែលមានស្រាប់និងបណ្តាសកម្មភាពដទៃទៀត។ ចំពោះសហគមន៍អេកូទេសចរណ៍ជីផាត ក៏ដូចគ្នាយ៉ាងនេះដែរគឺអាចគ្រប់គ្រង និងធ្វើអោយរីកចម្រើននូវវិស័យទេសចរណ៍ទៅបានត្រូវពឹងផ្អែកលើកត្តាជាច្រើន។ តែធនធានទេសចរណ៍គឺជាកត្តាមួយដែលមិនអាចខ្វះបានឡើយ។

សហគមន៍អេកូទេសចរណ៍ជីផាត គឺពោពេញទៅដោយទេសភាពធម្មជាតិដ៏ស្រស់ត្រកាល និងអេកូឡូស៊ីយ៉ាងសម្បូរបែប។ អេកូទេសចរណ៍ជីផាត ជារមណីយដ្ឋានទេសចរណ៍បែបសហគមន៍ទេសចរណ៍ដែលមានទីតាំងស្ថិតនៅក្នុងភូមិជីផាត ឃុំជីផាត ស្រុកថ្មបាំងខេត្តកោះកុង មានចម្ងាយ ១២៦គ.មពីក្រុងខេមរភូមិន្ទ។ ភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិអាចធ្វើដំណើរទៅកាន់តំបន់នោះតាមផ្លូវ ជាតិលេខ៤៨ ត្រង់ចំណុចផ្លូវបំបែកហួសស្ពានអណ្តូងទឹកប្រហែល៥គ.មរួចបន្តដំណើរតាមផ្លូវគ្រួសក្រហម រហូតដល់ភូមិជីផាតតែម្តង។

សហគមន៍អេកូទេសចរណ៍ជីផាតហ៊ុមព័ទ្ធទៅដោយធនធានធម្មជាតិជាច្រើន ដែលបានលាក់ខ្លួនពួនសំងំតាមកន្លែងផ្សេងៗគ្នារង់ចាំភ្ញៀវទេសចរមកកំសាន្តដើម្បីបង្អួតនូវសម្រស់ដ៏ស្រស់ត្រកាលរបស់ខ្លួនមួយនេះ។ តំបន់អេកូទេសចរណ៍ជីផាត មានកន្លែងកម្សាន្តបែបធម្មជាតិជាច្រើន ដូចជាផ្នូរបុរាណមានអាយុកាលប្រមាណជា ៥០០ឆ្នាំ ពាងបុរាណ មើលថ្ងៃលិចពីកំពូលភ្នំ លេងទឹកជ្រោះដ៏ស្រស់ស្អាត ជាច្រើនកន្លែង ការចាក់បង្គងពេលរាត្រី មើលអំពិលអំពែក ជិះទូកកម្សាន្តតាមដៃសមុទ្រ មើលថ្ងៃរះ រូងប្រចៀវ អូរទឹកវេទ អូរពាមក្រវាញ អូរក្រូច អូរម្លូ វាលប្រាក់ វាលមាស ត្រពាំងកិត ដំណាក់ខុស ភ្នំត្រងោល ឆាយខ្ពស់ ឆាយជ្រៃ ហើយក៏ជាដែនជម្រកសត្វព្រៃ និងព្រៃទឹកភ្លៀងដ៏ធំមួយក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

បើនិយាយអំពីជ្រោះជ្រង ជ្រលងដងអូរ នៅទីនោះប្រជុំទៅដោយទឹកធ្លាក់មានទេសភាពប្លែកៗពីគ្នាជាច្រើនកន្លែងដែលទឹកជ្រោះទាំងនោះហូរចាក់ពីលើភ្នំបំណងជ្រែកផ្ទាំងសិលា មុននឹងបន្ទាបខ្លួនចុះមកក្រោម។ ទឹកធ្លាក់ដ៏ថ្លាយង់ហូររណ្តំបោះពួយយ៉ាងលឿនបុកជាមួយនឹងដុំថ្មតូចធំក្រាលក្របតម្រៀមគ្នាក្នុងជ្រលង បង្កើតជាសន្ធឹកសំឡេងរំពងពេញព្រៃ ប្រៀបដូចនឹងថាមពលម្យ៉ាងដែលផ្តល់អោយភ្ញៀវទេសចរកាន់តែមានកម្លាំង

គយគន់ទេសភាពទឹកធ្លាក់ត្រជាក់ភ្នែក ស្រូបយកនូវខ្យល់អាកាសដ៏បរិសុទ្ធ។ រីតតែពិសេសជាងនេះ លុះដល់ព្រហាមថ្ងៃរះអង្គព្រះសូរិយាយាងចរនាបូព៌ាទិសបានចាប់ផ្តើមជះពន្លឺបន្តិចម្តងៗ បង្កជាបាតុភូតិធម្មជាតិដោយផ្សែងទឹកជ្រោះបង្កើតដោយ ទឹកធ្លាក់ បុកជាមួយព្រៃឈើ លេចឡើងជា ឥន្ទធនូ នៅក្នុងពន្លឺថ្ងៃ ។ នៅជុំវិញទឹកជ្រោះមានព័ទ្ធជុំវិញ ទៅដោយ វល្លិ ដើមឈើធំៗ និងរុក្ខជាតិខៀវខ្ចីផ្សេងៗដុះ ព្រេចៗពេញដី។ លុះដល់អារុណោតីកាលណាសំឡេងបក្សាបក្សីយំយ៉ាងគ្រលួចលាន់ឮរំពងនៅតាមព្រឹក្សា ហាក់បីដូចនាំយើងអោយស្ថិតនៅក្នុងពិភពធម្មជាតិដ៏ស្រស់ត្រកាលនាកណ្តាលវេហាមួយផ្សេងទៀតអ៊ីចឹង។ មិនតែប៉ុណ្ណោះ ភ្ញៀវទេសចរណ៍ក៏អាចចុះលេងតាមខ្សែទឹកវិចៗតាមផ្ទាំងសិលាដែលមានភាពថ្លាចាំងឆ្លុះដល់បាត។ ទឹកធ្លាក់ចុះពីជ្រលងមានភាពបរិសុទ្ធប៉ះជាមួយនឹងដុំថ្មតូចធំធ្វើអោយទឹកកាន់តែមានភាពត្រជាក់ នៅពេលទេសចរបានចុះលេងកំសាន្តធ្វើអោយមានអារម្មណ៍ស្រស់ស្រាយបាត់អស់នូវរាល់ទុក្ខកង្វល់ផ្សេងៗក្នុងឱរាមួយរំពេច។

ក្រៅពីទឹកធ្លាក់ដែលជាសម្បត្តិធម្មជាតិ នៅទីនេះក៏អាចអន្ទងដួងចិត្តភ្ញៀវទេសចរណ៍អោយទៅកាន់គោលដៅដទៃផ្សេងទៀតបានដូចជា ការឡើងភ្នំ ទស្សនាវត្តបុរាណដែលមានអាយុកាលជាង៥០០ឆ្នាំ ក៏ដូចជាកន្លែងលបមើលសត្វព្រៃជាដើម ដែលវាសុទ្ធសឹងជាទស្សនីយភាពធម្មជាតិដ៏ពិសិដ្ឋបង្កប់ខ្លួនក្នុងជ្រលងបព្វតា។

យើងអាចធ្វើដំណើរឡើងភ្នំ ដើម្បីផ្តិតយកនូវកម្រងរូបភាពសម្រាប់បំពេញខ្សែចក្ខុយ៉ាងស្រស់ស្អាតពីទេសភាពធម្មជាតិដ៏ស្រស់ត្រកាលឡោមព័ទ្ធដោយព្រៃឈើខៀវស្រងាត់ និងទិដ្ឋភាពជុំវិញភ្នំ ជ្រលងភ្នំ ដែលទាំងអស់នេះបានជួយកំដរអារម្មណ៍ និងផ្តល់ជាចំណីចក្ខុដល់អ្នកដំណើរអោយជាប់ចិត្តមិនអាចបំភ្លេចបាន។ ជាពិសេសនាពេលព្រះសូរិយារៀបនឹងបាត់អស់នូវរស្មីសែង ទេសចរក៏អាចរង់ចាំគយគន់នូវសម្រស់ថ្ងៃលិចរំលេចដោយរស្មីពណ៌មាសឆ្អិនឆ្អៅដែលកំពុងត្រៀមខ្លួនយាងចុះបន្តិចម្តងៗកាត់នឹងព្រៃព្រឹក្សាលតាវល្លិ៍ដ៏ធំល្វឹងល្វើយនៃដែនធម្មជាតិរបស់សហគមន៍អេកូទេសចរណ៍ជីផាត។ អ្វីដែលគួរអោយចាប់អារម្មណ៍ជាងនេះទៅទៀត គឺការទស្សនាវត្តបុរាណដែលមានអាយុកាលជាង៥០០ឆ្នាំមកម្ល៉េះពោលគឺតាំងពីអំឡុងឆ្នាំ១៥៥៨ ដល់១៥៦៩នៃគ.ស។ ពាងចំនួន១១ និងម្ឈូសបូរាណចំនួន១១ វាបានបង្កប់នូវជំនឿ ទំនៀមទម្លាប់ដ៏យូរលង់នៃការបញ្ចុះសពរបស់ខ្មែរ-មន។ បន្ថែមពីនេះទៅទៀត សម្រាប់ភ្ញៀវទេសចរណ៍ដែលចង់ឃើញដោយផ្ទាល់ពីទិដ្ឋភាពជីវិតរបស់ភាវរស់ផ្សេងៗដែលកំពុងរស់នៅក្នុងព្រៃពិតៗ ពួកគេអាចទៅកាន់វាលមាស ឬក៏វាលប្រាក់ ដើម្បីរង់ចាំឃ្លាំមើលពីដំណើររបស់សត្វព្រៃទាំងអស់មិនថាជាប្រភេទសត្វកម្រក៏ដោយ ហើយត្រូវបានការពារសុវត្ថិភាពដោយម្ចាស់តំបន់ផ្ទាល់តែម្តង។

ស្ថិតក្នុងលក្ខខណ្ឌធម្មជាតិដ៏ល្អកម្រយ៉ាងនេះហើយធ្វើអោយសហគមន៍អេកូទេសចរណ៍ជីផាតក្លាយទៅជាតំបន់គោលដៅដ៏ពិសិដ្ឋសម្រាប់ទេសចរណ៍បែបធម្មជាតិ និងបានទាក់ទាញក្រសែភ្នែកភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិអោយលង់ចិត្តនឹងសម្រស់ធម្មជាតិនៅទីនេះ ហើយពោលពាក្យសរសើរមិនដាច់ពីមាត់។

### ២.៤.២ ធនធានមនុស្ស

ដោយការសង្កេតឃើញជាក់ស្តែង បច្ចុប្បន្ននេះវិស័យទេសចរណ៍ កំពុងតែមានការរីកចម្រើននិងអភិវឌ្ឍន៍យ៉ាងខ្លាំង។ ទន្ទឹមនឹងនេះផងដែរកត្តាមនុស្ស ក៏ជាធនធានមួយយ៉ាងសំខាន់ក្នុងការជម្រុញបន្ថែមអោយមាន

ការអភិវឌ្ឍលើវិស័យទេសចរណ៍ អោយកាន់តែរលូនទៅមុខ។ តាមការសង្កេតឃើញធនធានមនុស្សនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតមួយចំនួនធំកំពុងតែបំរើការ និងផ្តល់សេវាកម្ម សម្រាប់ភ្ញៀវទេសចរណ៍នៅក្នុងសហគមន៍ទាំងមូលដែលក្នុងនោះមានដូចជា អ្នករត់ទូក អ្នកធ្វើកសិកម្ម អាជីវករ អ្នកនេសាទ អ្នកលក់សំបុត្រ អ្នកផ្តល់សេវាកម្មដឹកជញ្ជូន អ្នកផ្តល់សេវាកម្មស្នាក់នៅ ម្ហូបអាហារនិងភេសជ្ជៈ និងមានការងារជាច្រើនទៀតដែលប្រជាពលរដ្ឋកំពុងបំរើការនៅក្នុងសហគមន៍ទាំងមូល។ ធនធានមនុស្សទាំងអស់នេះហើយដែលធ្វើអោយសហគមន៍អេកូទេសចរណ៍ជីផាត មានភ្ញៀវទេសចរណ៍មកទស្សនាកាន់តែច្រើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ មិនត្រឹមតែប៉ុណ្ណោះការងារទាំងនេះបានផ្តល់ប្រាក់ចំណូល និងមុខរបរ ចិញ្ចឹមជីវិតសម្រាប់ប្រជាជននៅក្នុងតំបន់។

### ២.៤.៣ សេវាកម្មកំសាន្តផ្សេងៗ

ការប្រកបអាជីវកម្ម ដែលបម្រើអោយសេវាកម្មកម្សាន្តមានដូចជា រង្គសាល ខារ៉ាអូខេ កន្លែងម៉ាស្សា កន្លែងកម្សាន្តសម្រាប់ក្មេងៗ កន្លែងសម្រាប់សម្រាកបរិភោគអាហារថ្ងៃត្រង់ផ្សេងៗ ដែលបានរួមចំណែកយ៉ាងច្រើននៅ ក្នុងវិស័យទេសចរណ៍ដើម្បីបម្រើដល់ការកម្សាន្តសប្បាយរបស់ភ្ញៀវ ក៏ដូចជាសម្រាប់មនុស្សទូទៅផងដែរ។ ដោយឡែកចំពោះសហគមន៍អេកូទេសចរណ៍ជីផាតវិញ ក្រុមសិក្សាស្រាវជ្រាវបានសង្កេតឃើញថាសេវាកម្មដែលបានផ្តល់អោយទៅភ្ញៀវដែលបានមកសម្រាកលំហែមានលក្ខណៈខុសប្លែកពីសេវាកម្មដែលបានរៀបរាប់ខាងលើដូចជា៖

- **ដំណើរកំសាន្តតាមទូក ៖** អ្នកទេសចរណ៍កាលដែលបានមកកំសាន្តនៅទីនេះហើយមិនគួររំលងក្នុងការជិះកាយ៉ាក់ឡើយ។ ទេសចរអាចចែវទូកកៃយ៉ាក់មើលទេសភាពតាមដងព្រែកដោយខ្លួនឯងផ្ទាល់ ដើម្បីផ្ចិតយកនូវទិដ្ឋភាពដ៏ល្អអស្ចារ្យដែលយើងសឹងមិនជឿថាមានក្នុងសន្និវាសយើងនេះ។ សម្រាប់នាព្រឹកព្រលឹម ផ្ទាំងពពកដេរដាស និងរលកអ័ព្ទសស្គុសរសាត់តាមខ្យល់ជំនោរហាក់បីដូចជាទស្សនីយភាពក្នុងរឿងនិទាន។ ដល់ពេលសន្ធិយាឈាងចូលមកដល់ ភ្ញៀវទេសចរណ៍ក៏អាចគយគន់ពន្លឺព្រះសុរិយារៀបអស្តង្គតក្រោមកម្រាលពណ៌មាសរំលេចដោយរស្មីឆ្អិនឆ្អៅដែលចាំងជះនៅលើផ្ទៃជលសា។ លុះស្បៃរាត្រីចុះមកកាលណា ទេសចរក៏អាចមើលអំពិលអំពែក ដែលបានបញ្ចេញពន្លឺព្រិចៗនៅលើដើមឈើប្រៀបដូចកំពុងបំភ្លឺរាត្រី ឬក៏អាចជិះទូកចុះចាក់បង្កងតាមដងព្រែកពេលយប់ ដែលទាំងអស់នេះសុទ្ធសឹងតែជារសជាតិថ្មីមួយសម្រាប់បន្ថែមអោយជីវិតយើងកាន់តែមានន័យ។ ភ្ញៀវទេសចរណ៍ក៏អាចមានជម្រើសមួយផ្សេងទៀតគឺការជិះកាណូតគយគន់សម្រស់ធម្មជាតិដ៏ស្រស់ត្រកាល និងហ្វូងសត្វស្លាបតូចធំដែលហោះហើរប្រដេញគ្នាយ៉ាងជក់ជិត ជាមួយនឹងខ្យល់អាកាសដ៏ត្រជាក់បក់ឆ្លងកាត់ព្រៃព្រឹក្សាដ៏ខៀវស្រងាត់រាប់ម៉ឺនហិចតាដែលលាតសន្ធឹងនឹងដងភ្នំដ៏វែងអន្លាយ។ តាមរយៈការជិះទូកនេះផងដែរ ទេសចរក៏អាចស្វែងយល់ពីជីវភាពរស់នៅពិតៗរបស់ប្រជាពលរដ្ឋក្នុងតំបន់។
- **បោះតង់ ៖** សម្រាប់អ្នកដែលមានបំណងចង់ធ្វើដំណើរបែបផ្សងព្រេង ឬដើរព្រៃ ចូលចិត្តបែបស្ងប់ស្ងាត់ ចង់ទទួលបាននូវភាពស្រស់ស្រាយប្លែកអារម្មណ៍តាមរយៈការផ្លាស់ប្តូរបទពិសោធន៍ថ្មីនៃដំណើរកំសាន្ត។ នៅសហគមន៍អេកូទេសចរណ៍ជីផាតក៏មានអោយភ្ញៀវទេសចរណ៍ធ្វើដំណើរកម្សាន្តចូលក្នុងព្រៃរិលល្ងាច ឬបោះតង់សម្រាកកំសាន្តក្នុងព្រៃក៏បានដែរ។ ភ្ជាប់ជាមួយនឹងទេសភាពក្នុងព្រៃគួរអោយចង់រស់

នៅ ភ្ញៀវទេសចរណ៍អាចមកកំសាន្តជាមួយនឹងគូស្នេហ៍ គ្រួសារ ឬមិត្តភក្តិជាដើម។ នាពេលរាត្រីមានការជួបជុំគ្នានិយាយលេង ច្រៀងសប្បាយក្បែរភ្នក់ភ្លើង ក្រោមពន្លឺចន្ទ្រា ហើយសម្លឹងមើលផ្កាយពេលរាត្រី ស្តាប់សំឡេងសត្វយំ បណ្តែតអារម្មណ៍ជាមួយនឹងធម្មជាតិ បង្កើតបរិយាកាសដ៏អស្ចារ្យ និងក្លាយជាកម្រងអនុស្សាវរីយ៍ដែលដក់ជាប់ក្នុងចិត្តរបស់ទេសចរគ្រប់រូប។

- **ជិះកង់** ៖ នៅសហគមន៍អេកូទេសចរណ៍ជីផាតក៏មានសេវាកម្មខ្ចីកង់ដល់ភ្ញៀវទេសចរណ៍ ដែលមានបំណងចង់ជិះកម្សាន្តលំហែអារម្មណ៍ ជម្រះភាពស្មុគស្មាញ មើលទិដ្ឋភាពក្នុងភូមិ ឬទេសភាពក្នុងព្រៃជាដើម។ ការកម្សាន្តបែបនេះវាក៏អាចជួយអោយទេសចរកាន់តែយល់ច្បាស់ពីជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋក្នុងភូមិ ការបង្កើតភាពស្និទ្ធស្នាលរវាងទេសចរនិងប្រជាសហគមន៍ ដើម្បីអោយទេសចរទទួលបាននូវអារម្មណ៍កាន់តែកក់ក្តៅហាក់បីដូចជាកំពុងរស់នៅភូមិរបស់ខ្លួនផ្ទាល់។ សេវាកម្មដ៏ល្អវិចិត្រដែលបានរៀបចំ និងទទួលស្វាគមន៍ភ្ញៀវទេសចរណ៍យ៉ាងកក់ក្តៅ ធ្វើអោយទេសចរដែលមកសម្រាកកំសាន្តនៅទីនេះទទួលបានការតបស្នងត្រឡប់ទៅវិញនូវស្នាមញញឹម ព្រោះទីនេះប្រៀបដូចឋានសួគ៌ក្រោមមេឃរបស់មនុស្សគ្រប់ៗគ្នា។

## ២.៤.៤ សេវាកម្ម និងសម្បទានទេសចរណ៍

នៅគ្រប់ទីកន្លែង មិនថាកន្លែងតូច ឬកន្លែងធំអោយតែមានភ្ញៀវទេសចរណ៍ គឺត្រូវមានប្រភេទសេវាកម្មដើម្បីបម្រើដល់សេចក្តីត្រូវការរបស់ភ្ញៀវដែលក្នុងនោះមានដូចជា សេវាកម្មសណ្ឋាគារ ផ្ទះសំណាក់ ផ្ទះស្នាក់ ភោជនីយដ្ឋាន រង្គសាល កន្លែងលក់ទំនិញ កន្លែងលេងកីឡា និងកន្លែងកម្សាន្តផ្សេងៗជាច្រើនទៀត។ ដូចនេះចំពោះសហគមន៍អេកូទេសចរណ៍ជីផាត ក៏ដូចជាតំបន់ទេសចរណ៍នានាផ្សេងៗទៀតដែរ តម្រូវឱ្យមានប្រភេទសេវាកម្មដែលបម្រើអោយទេសចរណ៍។ តាមរយៈការតាមដានធ្វើការសង្កេតដោយផ្ទាល់របស់ ក្រោយមកសិក្សាស្រាវជ្រាវនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត ពាក់ព័ន្ធជាមួយនឹងសេវាកម្មដែលបានផ្តល់អោយទៅ ភ្ញៀវទេសចរដែលមកកម្សាន្តក្នុងគោលបំណងចង់ស្គាល់នូវធនធានទេសចរណ៍ដ៏ស្រស់ត្រកាល និងទទួលបាននូវបម្រើសេវាកម្មខាងលើទាំងអស់នៅក្នុងសហគមន៍មួយនេះផងដែរ។

### ក. សេវាកម្មម្ហូបអាហារ

យើងបានដឹងហើយថា សេវាកម្មម្ហូបអាហារតែងតែមានតួនាទីយ៉ាងសំខាន់ ដែលមិនអាចខ្វះបាននៅក្នុងផ្នែកឧស្សាហកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចផងដែរ។ ជាក់ស្តែងការបម្រើសេវាកម្មម្ហូបអាហារនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត មានការបម្រើអាហារយ៉ាងសំបូរបែបដែលត្រូវបានរៀបចំជូនដោយប្រជាសហគមន៍នៅទីនេះផ្ទាល់ ដោយសហគមន៍មានទាំងចុងភៅក្នុងភូមិ ព្រមទាំងចុងភៅព្រៃ។ ចុងភៅក្នុងភូមិសំដៅដល់ចុងភៅដែលយកបន្លែ សាច់ដែលមានស្រាប់ស្រស់ៗនៅក្នុងភូមិយកមកច្នៃធ្វើជាម្ហូបជូនភ្ញៀវ។ ចំណែកចុងភៅព្រៃ ជា ចុងភៅដែលចម្អិនអាហារក្នុងព្រៃសម្រាប់ឲ្យភ្ញៀវទេសចរណ៍ទទួលទាននៅពេលធ្វើដំណើរផ្សងព្រេង ។ បើតាមលោកទុយ វណ្ណៈមគ្គុទេសក៍ទេសចរចុងភៅព្រៃនេះធ្វើម្ហូបតាមរដូវកាលដែលសម្បូររុក្ខជាតិ និងបន្លែដុះនៅក្នុងព្រៃ ។ ជាពិសេស ចុងភៅព្រៃ ស្គាល់រុក្ខជាតិជាច្រើននៅក្នុងព្រៃដែលអាចយកមកធ្វើម្ហូបបាន ។ នៅពេលដែលភ្ញៀវទេសចរណ៍មានគម្រោងស្នាក់នៅ ក្នុងព្រៃនោះនឹងមានចុងភៅព្រៃទៅជាមួយដើម្បីចម្អិនម្ហូបអាហារឲ្យ

ពួកគាត់ ។ ចុងភៅព្រៃអាចផ្សំបន្លែ ធម្មជាតិ និងរុក្ខជាតិមួយចំនួនដែលដុះនៅក្នុងព្រៃយកមកធ្វើជាម្ហូប ។ ហើយ រដូវណាដែលសម្បូរត្រីវិញ ចុងភៅព្រៃនឹងនាំភ្ញៀវទៅ ស្ទូចត្រីយកមកអាំងហូប។

### ខ. សេវាកម្មស្នាក់នៅ

បើយើងក្រឡេកមកមើលសេវាកម្មស្នាក់នៅវិញគឺ វាដើរតួនាទីយ៉ាងសំខាន់នៅក្នុងផ្នែកឧស្សាហកម្ម ទេសចរណ៍និង បដិសណ្ឋារកិច្ច។ នាពេលបច្ចុប្បន្ន ការបម្រើសេវាកម្មស្នាក់នៅក្នុងសហគមន៍អេកូទេសចរណ៍ជី ផាតមានលក្ខណៈជាផ្ទះស្នាក់ ផ្ទះសំណាក់ និងបឹងកាឡូ ស្រស់ស្អាតនិងតម្លៃសមរម្យ ។ បន្ទាប់ពី កម្សាន្ត អារម្មណ៍ ជាមួយនឹងធម្មជាតិក្នុងព្រៃ និងតាមព្រែកសមុទ្រជីផាត នៅទីនេះក៏មានការស្វាគមន៍អោយភ្ញៀវ ទេសចរណ៍ស្នាក់នៅយ៉ាងមេត្រីភាព ព្រមទាំងប្រកបដោយផាសុកភាពផងដែរ ។ ក្នុងសហគមន៍អេកូ ទេសចរណ៍ជីផាត មានបឹងកាឡូស្រស់ស្អាតចំនួន ១៣ ផ្ទះស្នាក់ ចំនួន ១៤ និងផ្ទះសំណាក់ ចំនួន ១១ ។ បើ តាម លោកអន សុវណ្ណ ដែលជាប្រធានសហគមន៍អេកូទេសចរណ៍ជីផាត ការស្នាក់នៅបឹងកាឡូក្នុង ១ យប់តម្លៃ ចាប់ពី១០ដុល្លា ដល់៤០ដុល្លា , ផ្ទះស្នាក់ តម្លៃ ៧ ឬ៨ដុល្លា និងផ្ទះសំណាក់តម្លៃ ៧ ដុល្លា ។

ម្យ៉ាងវិញទៀត ផ្ទះស្នាក់ដែលបានដាក់អោយប្រើប្រាស់នៅសហគមន៍អេកូទេសចរណ៍ជីផាតនេះ គឺនៅក្រោមការ គ្រប់គ្រងរបស់ប្រធានសហគមន៍ ថែមទាំងមានប្រជាការពារភូមិដែលទទួលបន្ទុកក្នុងការមើលខុសត្រូវចំពោះ សុខសុវត្ថិភាពនៅក្នុងភូមិ ក៏ដូចជាសុខសុវត្ថិភាពរបស់ភ្ញៀវដែលទៅស្នាក់នៅផ្ទាល់តែម្តង។

## ២.៥ ហេដ្ឋារចនាសម្ព័ន្ធដែលបម្រើអោយវិស័យទេសចរណ៍

### ក. ការដឹកជញ្ជូន

បច្ចុប្បន្នសម្រាប់ការដឹកជញ្ជូន គឺមានភាពងាយស្រួលដល់អ្នកធ្វើដំណើរដែលមានគោលបំណងចង់ មកទស្សនាសហគមន៍អេកូទេសចរណ៍ជីផាត។ ដើម្បីធ្វើដំណើរទៅដល់សហគមន៍អេកូទេសចរណ៍ជីផាត ដំបូង គឺយើងត្រូវធ្វើដំណើរចាកចេញពីអណ្តូងទឹកជាមុនសិន ដោយចំណាយពេលប្រហែល ៤០នាទីទើបទៅដល់ (ដោយ១៧ គីឡូម៉ែត្រជាផ្លូវលំ) ឬបើសិនជាយើងចង់ធ្វើដំណើរតាមកាណូតត្រូវចំណាយពេលរហូតដល់២ម៉ោង ទើបដល់តំបន់គោលដៅ។ មួយវិញទៀត យើងក៏អាចធ្វើដំណើរទៅអណ្តូងទឹកបានតាមរយៈរថយន្តក្រុងទំនើបៗ ជាច្រើនដូចជា ឡានក្រុងវីរៈប៊ុនថាំ ឬក្រុមហ៊ុនសូរិយាដឹកជញ្ជូនជាដើម។

បើសិនជាអ្នកបានធ្វើការកក់ទុកលើការស្នាក់នៅរបស់សហគមន៍អេកូទេសចរណ៍ជីផាតតាមរយៈគេហទំព័រជា មុនហើយនោះ ក្រុមការងាររបស់សហគមន៍នឹងមកយកអ្នកដោយផ្ទាល់នៅឯស្ពានអណ្តូងទឹកដើម្បីជូនអ្នកទៅ សហគមន៍ ដែលធ្វើឱ្យការធ្វើដំណើររបស់អ្នកកាន់តែមានភាពងាយស្រួល និងសុវត្ថិភាពជាងមុន។

- ប្រសិនបើ យើងធ្វើដំណើរចេញពី រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកែប ឬក៏ខេត្តកំពត

រថយន្តទាំងអស់ត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ ៤ ឆ្លោះទៅផ្លូវជាតិលេខ ៤៨។ បន្ទាប់ពី ទៅដល់ខេត្តកោះកុង ហើយ យើងនឹងឆ្លងកាត់ស្ពានស្រែអំបិល (យើងក៏អាចឈប់សំរាកនៅទីនេះដើម្បីទទួលទានអាហារថ្ងៃត្រង់សិន

មុនបន្តដំណើរទៅមុខទៀត) ។ បន្ទាប់ពីធ្វើដំណើរចម្ងាយ៣០ គីឡូម៉ែត្របន្ថែមទៀត យើងនឹងទៅដល់ស្ពានទី ២ គឺស្ពានអណ្តូងទឹក។

➢ បើយើងធ្វើដំណើរចេញពីខេត្តកោះកុងផ្ទាល់

អណ្តូងទឹកមានចម្ងាយប្រហែល ១០០ គីឡូម៉ែត្រ (ចំណាយពេលប្រមាណ១ ម៉ោងកន្លះ ទៅ២ ម៉ោង) ពីខេត្តកោះកុង។ បន្ទាប់ពី ឆ្លងស្ពាននៅអណ្តូងទឹកនេះជាស្ពានទី ៣ មកពីខេត្តកោះកុង។

នៅស្ពានអណ្តូងទឹក យើងនឹងឃើញភោជនីយដ្ឋានមួយដែលមានឈ្មោះថា គឹមឈួន ចម្ងាយ៥០ ម៉ែត្រខាងកើតស្ពាន។ យើងអាចសួរអ្នកនៅទីនោះពីរបៀបបន្តដំណើរទៅជីផាត។ ប្រសិនបើយើងបានកក់ការធ្វើដំណើរទៅជីផាតរួចហើយ យើងប្រាកដជាបានជួបនឹងអ្នកបើកកាណូត ឬម៉ូតូចាំមកទទួលយើង។ ប្រសិនបើអ្នកមិនបានកក់ទុកជាមុនទេយើងក៏អាចជួលម៉ូតូនៅទីនោះក៏បាន។

- ពីអណ្តូងទឹករហូតដល់ជីផាត ដោយមធ្យោបាយធ្វើដំណើរជាម៉ូតូឌុប

ប្រសិនបើយើងបានកក់ម៉ូតូរួចហើយ នោះយើងត្រូវចំណាយ ៧ ដុល្លារ។ ហើយយើងក៏មិនចាំបាច់ចំណាយថ្លៃសំបុត្រសាឡាងទៀតនោះដែរ។ ពួកគាត់នឹងនាំយើងទៅដល់មជ្ឈមណ្ឌលផ្តល់ព័ត៌មានរបស់សហគមន៍អេកូទេសចរណ៍ជីផាតតែម្តង។ ម្យ៉ាងបើអ្នកជួលម៉ូតូនៅស្ពានអណ្តូងទឹក យើងគួរបង់ប្រាក់អោយពួកគាត់ផ្តាច់តែម្តងទៅដោយសារយើងមិនចាំបាច់ចំណាយលើថ្លៃផ្សេងៗពេលធ្វើដំណើរឡើយ រហូតដល់មជ្ឈមណ្ឌលផ្តល់ព័ត៌មានរបស់សហគមន៍អេកូទេសចរណ៍ជីផាតតែម្តងដែលចម្ងាយ ២០០ ម៉ែត្រពីទន្លេ។

- ការធ្វើដំណើរដោយ កាណូត

ជាទូទៅកាណូតចាកចេញ បន្ទាប់ពីឡានក្រុងបានមកដល់ ហើយធម្មតាខ្ទង់ម៉ោង ១២:៣០ - ១៣:០០ ។ ប្រសិនបើឡានក្រុងយឺតកាណូតក៏នឹងរង់ចាំរហូតដល់ម៉ោង ១៤:០០ បើសិនអ្នកដំណើរផ្សេងទៀតមានការយល់ព្រម។

បន្ទាប់ពីអ្នកឡើងជិះកាណូតរួចរាល់ហើយ ម្ចាស់កាណូតនឹងផ្តល់អាវពោង ទៅដល់យើងការពារឧបត្តិហេតុផ្សេងៗដូចជាការលង់ទឹកជាដើម។ អ្នកបើកកាណូតនឹងនាំយើងទៅដល់កំពង់ចម្លងតូចមួយនៅភាគខាងជើងនៃទន្លេនៅជីផាត ហើយបន្ទាប់មកពួកគាត់នឹងនាំយើងទៅកាន់មជ្ឈមណ្ឌលផ្តល់ព័ត៌មានទេសចរណ៍របស់សហគមន៍។ ចំពោះតម្លៃគឺ ១០ ដុល្លារក្នុងមួយនាក់ បើអ្នកជិះកាណូតនោះមាន៣នាក់ តែបើយើងជិះម្នាក់ឯងយើងត្រូវចំណាយ៣០ដុល្លា ហើយការដំណើរតាមកាណូតនេះទៀតសោត ចំណាយពេលប្រហែល ២ ម៉ោង។

- ដោយមធ្យោបាយផ្ទាល់ខ្លួន

ផ្លូវលំទៅដល់ជីផាត គឺស្ថិតនៅចម្ងាយ ៤ គីឡូម៉ែត្រខាងលិចអណ្តូងទឹក។ វាមានសញ្ញាបង្ហាញផ្លូវតូចមួយនៅក្បែរនោះ។ យើងត្រូវឆ្លងដ ដោយឡានមួយមានតម្លៃ ៥.០០ ដុល្លារ។ នៅចម្ងាយប្រហែល ៥០ ម៉ែត្រខាងលិចនៃកំពង់ចម្លង មានកន្លែងដើម្បីអោយយើងអាចជួល កង់ ឬ ម៉ូតូ។ ចំពោះតម្លៃជួលកង់ក្នុងមួយថ្ងៃគឺ១០ ដុល្លា ចំណែកតម្លៃជួលម៉ូតូក្នុងមួយថ្ងៃ២០ដុល្លា(សាំងម៉ូតូភ្ញៀវត្រូវចាក់ដោយខ្លួនឯង)។

### ខ. ប្រព័ន្ធគមនាគមន៍

ការគ្រប់គ្រងទៅលើប្រព័ន្ធគមនាគមន៍ក្នុងសហគមន៍អេកូទេសចរណ៍ជីផាត នៅពុំទាន់មានការរីកចម្រើនខ្លាំងនៅឡើយទេ ក៏ដោយសារតែផ្លូវចេញចូលទៅក្នុងសហគមន៍ ជាប្រភេទផ្លូវលំ ដីក្រហមតូចដែលធ្វើអោយភ្ញៀវដែលធ្វើដំណើរទៅកំសាន្តនៅសហគមន៍នៅមានភាពលំបាកច្រើន ប៉ុន្តែទោះជាយ៉ាងណាក៏ដោយប្រធានសហគមន៍បានខិតខំធ្វើកិច្ចសហការជាមួយនឹងអាជ្ញាធរមូលដ្ឋានធ្វើការអភិវឌ្ឍ ផ្លូវចេញចូលទៅសហគមន៍អោយកាន់តែមានភាពងាយស្រួលប្រសើរឡើង ដើម្បីជាហេតុផលមួយក្នុងការទាក់ទាញទេសចរមួយកម្រិតទៀត ម្យ៉ាងបើសិនទេសចរបានគេឃើញផ្លូវធ្វើដំណើរកាន់តែងាយស្រួលគឺពួកគាត់ប្រាកដជាគិតចង់ឃើញចង់មកកំសាន្តសហគមន៍មួយនេះជាមិនខាន។

### គ. ប្រព័ន្ធទឹកស្អាត

យោងតាមការចុះទៅដល់តំបន់អេកូទេសចរណ៍ជីផាតដោយផ្ទាល់ នៅទីនោះគឺពុំទាន់មានការផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាត ដើម្បីឆ្លើយតបទៅនឹងគោលការណ៍របស់ក្រសួងសុខាភិបាលនៅឡើយទេ។ ការរស់នៅប្រចាំថ្ងៃរបស់ប្រជាសហគមន៍ គឺប្រើប្រាស់ស្របតាមវិធីសាស្ត្ររៀងៗខ្លួន ដូចជាការចម្រោះទឹក ការប្រើប្រាស់ទឹកអណ្តូងជាដើម។

### ឃ. ប្រព័ន្ធអគ្គិសនី

ផ្អែកតាមការពិនិត្យដោយផ្ទាល់ ក្រោយពីបានចុះកម្មសិក្សានៅសហគមន៍អេកូទេសចរណ៍ជីផាតរួចមកបានអោយដឹងថា សម្រាប់ប្រព័ន្ធអគ្គិសនីនៅទីនេះ គឺមានភាពរីកចំរើន។ តួយ៉ាងសព្វថ្ងៃ ប្រជាពលរដ្ឋនៅក្នុងសហគមន៍ អាចប្រើប្រាស់ប្រព័ន្ធអគ្គិសនីរដ្ឋ អាចយកជម្រើសដោយប្រើថាមពលសូឡា ឬប្រើប្រាស់អាគុយជាឧបករណ៍ផ្គត់ផ្គង់អគ្គិសនី សម្រាប់ធ្វើជាភ្លើងបំភ្លឺតាមផ្ទះនីមួយៗ។

### ង. ប្រព័ន្ធទូរគមនាគមន៍

សម្រាប់សេវាទូរស័ព្ទនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតឯណោះវិញ គឺមានសេវាល្អប្រសើរដែលអាចផ្តល់ភាពងាយស្រួលក្នុងការទំនាក់ទំនងរវាងគ្នានិងគ្នា។ ចំណែកប្រព័ន្ធទូរគមនាគមន៍ដទៃផ្សេងទៀតដូចជា ទូរទស្សន៍ វិទ្យុជាដើម ក៏មានសេវាល្អផងដែរ។

### ច. ការគ្រប់គ្រងកាកសំណល់

បើក្រឡេកមកមើលពីការគ្រប់គ្រងកាកសំណល់នៅឯសហគមន៍អេកូទេសចរណ៍ជីផាត សង្កេតឃើញថាមានការរៀបចំបានត្រឹមត្រូវគួរសម តាមរយៈការបែងចែកជាប្រព័ន្ធធុងសំរាមចែកជូនសមាជិកតាមកន្លែងនីមួយៗ ដើម្បីផ្តល់ភាពងាយស្រួលទៅដល់ប្រជាសហគមន៍ក្នុងការវេចខ្ចប់ ក៏ដូចជាបោះចោលសំរាមក្នុងធុងសម្រាមបានត្រឹមត្រូវ និងធានាបាននូវអនាម័យ បរិស្ថានល្អក្នុងសហគមន៍ទាំងមូល។ សម្រាប់សំរាមទាំងអស់នោះត្រូវបានគណកម្មការឃុំជួលឡាន ឬគោយន្តដើម្បីធ្វើការប្រមូលសំរាមតាមតំបន់នីមួយៗដែលខ្លួនបានដាក់នោះរួចដឹកសម្រាមទាំងអស់នោះ យកទៅចាក់គរមួយកន្លែង រួចធ្វើការដុតវា។ ការដុតសម្រាម ក៏ត្រូវបានគិតគូរពី

បញ្ហាសុខភាព ព្រោះសំរាមទាំងអស់នោះ ត្រូវបានយកទៅដុតក្នុងឡដែលនៅឆ្ងាយពីសហគមន៍ដែលមានប្រជាពលរដ្ឋកំពុងរស់នៅ។

## ២.៦ ទស្សនៈវិស័យ និងគោលបំណង

### ២.៦.១ ទស្សនៈវិស័យ

យើងជាប្រជាពលរដ្ឋ ក្នុងឃុំជីផាតចង់បាន និងចង់ឃើញសហគមន៍អេកូទេសចរណ៍ឃុំជីផាត ក្លាយជាសហគមន៍អេកូទេសចរណ៍គំរូមួយក្នុងប្រទេសកម្ពុជា ដែលនឹងត្រូវបានផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ដោយសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ ហើយរួមចំណែកការពារធនធានធម្មជាតិ វប្បធម៌ និងអនាម័យបរិស្ថាន ដែលបានជួយលើកកម្ពស់ជីវភាព និងសុខុមាលភាពប្រជាជន ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធត្រូវបានអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព។

### ២.៦.២ គោលបំណង

សហគមន៍អេកូទេសចរណ៍ ឃុំជីផាត បង្កើតឡើងដើម្បីការការពារ ថែរក្សាធនធានធម្មជាតិ វប្បធម៌ អនាម័យបរិស្ថាន ដែលមានការចូលរួម និងគ្រប់គ្រងដោយប្រជាជនក្នុងមូលដ្ឋាន សំដៅដល់ការបង្កើតឱកាសការងារ រកប្រាក់ចំណូល បន្ថែមដល់ប្រជាសហគមន៍ ដោយស្មើភាពគ្នាតាមរយៈការផ្តល់នូវផលិតផលទេសចរណ៍ សេវាកម្មជូនភ្ញៀវទេសចរណ៍ រួមចំណែកកាត់បន្ថយ បទល្មើស ព្រៃឈើ សត្វព្រៃ ព្រមទាំងចូលអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងធនធានមនុស្សប្រកបដោយនិរន្តរភាពសម្រាប់កូនចៅជំនាន់ក្រោយ។

ដើម្បីសម្រេចនូវគោលបំណងខាងលើ សហគមន៍អេកូទេសចរណ៍ឃុំជីផាតមានបេសកកម្មដូចខាងក្រោម៖

- ការចូលរួម និងគាំទ្រពីភាគីពាក់ព័ន្ធរួមមានប្រជាជនមូលដ្ឋាន ភូមិ ឃុំ ស្រុក ខេត្ត ថ្នាក់ជាតិ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ និងដៃគូអភិវឌ្ឍន៍នានា
- ថែរក្សាការពារ និងប្រើប្រាស់ ធនធានធម្មជាតិ វប្បធម៌សម្រាប់សហគមន៍អេកូទេសចរណ៍ប្រកបដោយនិរន្តរភាព
- ត្រូវមានគណកម្មការគ្រប់គ្រងសហគមន៍ ដែលមានឆន្ទៈ ភាពរឹងមាំ ជឿជាក់ អំណត់ ព្យាយាម និងមនសិការផ្សព្វផ្សាយពីផលិតផលទេសចរណ៍ និងសេវាកម្មរបស់សហគមន៍ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍
- ថវិកាសម្រាប់ទ្រទ្រង់ និងបង្កើតសហគមន៍ត្រូវបានផ្តល់ពីសំណាក់អង្គការ សម្ព័ន្ធមិត្តសត្វព្រៃ
- ផលិតផល និងសេវាកម្មរបស់សហគមន៍ ត្រូវមានគុណភាព
- សហគមន៍ត្រូវមានសណ្តាប់ធ្នាប់ សន្តិសុខ និងសុវត្ថិភាព
- ត្រូវមានប្រព័ន្ធសម្របសម្រួលបែងចែកផលប្រយោជន៍ដល់សមាជិកប្រកបដោយតម្លាភាព និងគណនេយ្យភាព

- ត្រូវផ្តល់វគ្គបណ្តុះបណ្តាល និងបច្ចេកទេសដល់សហគមន៍ដូចជា ភាសាអង់គ្លេស កុំព្យូទ័រ ការរៀបចំផ្ទះចុងភៅ មគ្គុទេសក៍។ល។
- បង្កើតឲ្យមាននូវសមាគមស្ត្រីនៅក្នុងសហគមន៍
- មានប្រភពកម្ចីឥណទានសម្រាប់សហគមន៍
- បង្កើតជាក្រុមសន្សំប្រាក់ ផ្តល់កម្ចីឥណទានក្នុងសហគមន៍
- អប់រំ និងផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋពីបញ្ហាបរិស្ថាន និងអនាម័យ ឬបង្កើតជាក្រុមថែរក្សាអនាម័យ និងបរិស្ថានក្នុងសហគមន៍
- បង្កើតក្រុមល្បាត និងអភិវឌ្ឍន៍ផលិតផលរបស់សហគមន៍អេកូទេសចរណ៍។

## ២.៦.៣ ស្ថានភាពសេដ្ឋកិច្ចសង្គម

### ក. ស្ថិតិទេសចរណ៍ ចំណូល និងចំណាយរបស់សហគមន៍អេកូទេសចរណ៍ជីផាត

យោងតាមរបាយការណ៍របស់សហគមន៍អេកូទេសចរណ៍ជីផាត ដែលទទួលបានភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិចូលមកកំសាន្តទស្សនាចាប់តាំងពីឆ្នាំ២០០៨ ដល់ឆ្នាំ២០២០។

ស្ថិតិទេសចរណ៍ សមាជិក និងចំណូលរបស់ ជីផាត

2008-សីហា, 2019

| ឆ្នាំ | ចំនួនទេសចរណ៍ | | | %ទេសចរណ៍ | សរុបចំនូលគ្រប់សមាជិក | សរុបមូលនិធិ CBET | សរុបចំនូល | %ចំនូល | ចំណាយ | សមតុល្យ |
|---|---|---|---|---|---|---|---|---|---|---|
| | ក្នុងស្រុក | បរទេស | សរុប | | | | | | | |
| 2008 | 160 | 266 | 426 | 100% | $ 5,664.55 | $ 1,256.45 | $ 6,921.00 | 100% | $ - | $ 1,256.45 |
| 2009 | 311 | 517 | 828 | 94% | $ 16,650.68 | $ 5,724.78 | $ 22,375.46 | 223% | $ - | $ 5,724.78 |
| 2010 | 398 | 830 | 1228 | 48% | $ 28,489.38 | $ 10,735.77 | $ 39,225.15 | 75% | $ - | $ 10,735.77 |
| 2011 | 329 | 1447 | 1776 | 45% | $ 50,208.94 | $ 19,472.30 | $ 69,681.24 | 78% | $ 9,565.99 | $ 9,906.31 |
| 2012 | 231 | 2084 | 2315 | 30% | $ 73,518.73 | $ 26,023.03 | $ 99,541.76 | 43% | $ 25,159.36 | $ 863.67 |
| 2013 | 401 | 2136 | 2537 | 10% | $ 80,432.85 | $ 29,778.96 | $ 110,211.81 | 11% | $ 29,900.00 | $ (121.04) |
| 2014 | 351 | 2851 | 3202 | 26% | $ 83,274.09 | $ 37,908.63 | $ 121,182.72 | 10% | $ 28,774.00 | $ 9,134.63 |
| 2015 | 404 | 2654 | 3058 | -4% | $ 117,036.98 | $ 33,974.31 | $ 151,011.29 | 25% | $ 40,676.43 | $ (6,702.12) |
| 2016 | 412 | 2723 | 3135 | 3% | $ 134,335.09 | $ 33,456.87 | $ 167,791.96 | 11% | $ 41,107.18 | $ (7,650.31) |
| 2017 | 1118 | 2618 | 3736 | 22% | $ 144,910.09 | $ 35,332.49 | $ 180,242.58 | 7% | $ 33,329.18 | $ 2,003.31 |
| 2018 | 728 | 2711 | 3439 | 10% | $ 161,923.71 | $ 42,481.53 | $ 204,405.24 | 13% | $ 42,468.47 | $ 13.06 |
| 2019 | 911 | 2155 | 3066 | -18% | $ 162,726.13 | $ 25,651.66 | $ 188,377.79 | -8% | $ 56,529.24 | $ (30,877.58) |
| 2020 | 1897 | 697 | 2594 | -25% | $ 101,768.78 | $ 15,548.40 | $ 117,317.18 | -38% | $ 46,560.56 | $ (31,012.16) |

### ខ. សមិទ្ធផលសំខាន់ៗដែលសហគមន៍បានសម្រេចកន្លងមក

នៅក្នុងដំណើរការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាតអស់រយៈពេលជាង១៤ឆ្នាំកន្លងមកនេះ សហគមន៍ទទួលបាននូវសមិទ្ធិផលជាច្រើនដែលគួរអោយកត់សំគាល់ ដូចជា៖

- ❖ អភិវឌ្ឍន៍ធនធានមនុស្សក្នុងសហគមន៍បានមួយផ្នែកធំ តាមរយៈការបណ្តុះបណ្តាលខាងផ្នែកភាសាបរទេសដើម្បីងាយស្រួលធ្វើការទំនាក់ទំនងជាមួយនឹងទេសចរ ក៏ដូចជាការធ្វើបដិសណ្ឋារកិច្ចទៅកាន់ភ្ញៀវទេសចរណ៍។ រៀបចំសេវាកម្មទេសចរណ៍ទាក់ទាញជាច្រើន ដែលជាប្រភពចំណូលសម្រាប់ទ្រទ្រង់ជីវភាពរស់នៅដល់ប្រជាសហគមន៍។ ការកសាងសមត្ថភាពគណៈកម្មការសហគមន៍ និងការចូលរួមគាំទ្រពីសមាជិកសហគមន៍

- ទទួលបានកិច្ចសហប្រតិបត្តិការគាំទ្រពីស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋានលើការងារគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍។
- ពង្រឹងធនធានទំនាក់ទំនង តាមរយៈការធ្វើអោយដីធ្លីនៅសហគមន៍កាន់តែមានតម្លៃ។
- កសាងហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍កាន់តែល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។
- ទទួលបានសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងប្រើប្រាស់ផល-អនុផលព្រៃឈើសម្រាប់ដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាសហគមន៍។
- ទទួលបានទំនុកចិត្ត និងគាំទ្រពីក្រុមហ៊ុនទេសចរណ៍ក្នុងស្រុក និងក្រៅស្រុកនាំភ្ញៀវមកទស្សនាកំសាន្តនៅទីនេះ។
- រៀបចំចងក្រងក្រុមសន្សំប្រាក់ មូលនិធិក្នុងសហគមន៍។
- ទទួលបានរង្វាន់ផ្ទះស្នាក់អាស៊ាន(ASEAN-Home Stay) ក្នុងឆ្នាំ២០១៥។
- ទទួលបានរង្វាន់សហគមន៍ទេសចរណ៍អាស៊ាន(ASEAN Community Based Tourism) ក្នុងឆ្នាំ២០១៧។
- ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាសហគមន៍គំរូ ហើយបានទទួលនូវជ័យលាភីពានរង្វាន់សម្តេចតេជោសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍។
- ទទួលបានពានរង្វាន់ជាតិ និងអន្តរជាតិជាច្រើនទៀត ដូចជា Hidden Treasures for its sustainable development potential 2010 ពី USAID, CAMBODIA, Clean resort 2014ពីក្រសួងទេសចរណ៍កម្ពុជាជាដើម។

**គ. បញ្ហាជួបប្រទះ**

ថ្វីបើសហគមន៍អេកូទេសចរណ៍ជីផាតមានការរីកចម្រើន និងទទួលបាននូវសមិទ្ធផលជាច្រើនដែលគួរអោយកត់សម្គាល់ក៏ពិតមែន។ ប៉ុន្តែទន្ទឹមនឹងនោះ សហគមន៍ក៏បានជួបប្រទះនូវបញ្ហាមួយចំនួនផងដែរ។ បញ្ហាទាំងនោះរួមមានដូចជា៖

- បញ្ហាដីធ្លី ដោយសារមានអ្នកវិនិយោគិនមានទឹកប្រាក់មួយចំនួនចង់បោះទុនវិនិយោគមកលើសហគមន៍ផ្ទាល់ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនជាជាងផលប្រយោជន៍សាធារណៈដោយពុំបានសិក្សា គិតគូរពីផលប៉ះពាល់របស់សហគមន៍។ ហើយបង្កអោយមានការដេញដោលមតិរវាងសហគមន៍ផ្ទាល់និងវិនិយោគិនទាំងនោះ។
- មានក្រុមហ៊ុនទេសចរណ៍មួយចំនួននាំភ្ញៀវទេសចរណ៍មកកំសាន្ត ដោយពុំបានចូលរួមសហការជាមួយនឹងសហគមន៍នោះឡើយ។ ដោយសារតែនៅក្នុងសហគមន៍ទទួលបានអាជ្ញាប័ណ្ណទេសចរណ៍យ៉ាងត្រឹមត្រូវពីក្រសួងទេសចរណ៍ ហេតុនេះសហគមន៍ពុំអនុញ្ញាតិអោយក្រុមហ៊ុនទេសចរណ៍ ឬក្រុមហ៊ុនឯកជនណាមួយមកដោយគ្មានការសហការជាមួយនឹងសហគមន៍នោះទេ។
- ខ្វះធនធានសម្ភារៈមួយចំនួនដើម្បីបម្រើដល់វិស័យអេកូទេសចរណ៍ក្នុងសហគមន៍

- សមាជិកសហគមន៍ និងគណៈកម្មការសហគមន៍ធ្វើការនៅមិនទាន់មានភាពចុះសម្រុងគ្នាល្អនៅឡើយទេ។
- សមាជិកសហគមន៍មួយចំនួនតូច លួចលក់ដីធ្លីទៅអោយឈ្មួញ ដែលឈ្មួញទាំងអស់នោះយកទៅធ្វើការអភិវឌ្ឍផ្សេងៗនាំអោយប៉ះពាល់ដល់បរិស្ថានក្នុងសហគមន៍។
- ចំណេះ ជំនាញរបស់សហគមន៍នៅមានកម្រិតនៅឡើយ។
- ក្នុងអំឡុងពេលផ្ទុះជំងឺកូវីដ ធ្វើឱ្យចំណូលរបស់សហគមន៍មានការធ្លាក់ចុះយ៉ាងខ្លាំង ដែលធ្វើឲ្យប្រជាសហគមន៍មួយចំនួនសម្រេចផ្លាស់ប្តូររបរ ខ្លះទៅធ្វើការនៅទីក្រុង។

## ២.៧ វិស័យសំខាន់ៗដែលបម្រើអោយវិស័យទេសចរណ៍

### ក. វិស័យសេដ្ឋកិច្ច

ប្រជាជនដែលរស់នៅខេត្តកោះកុងភាគច្រើនជាកសិករ និងប្រកបរបរលក់ដូរដើម្បីចិញ្ចឹមជីវិត។ ខេត្តកោះកុងក៏មានសក្តានុពល ជាគោលដៅទេសចរណ៍ផងដែរ(អេកូទេសចរណ៍) នេះជាអ្វីដែលធ្វើឲ្យសហគមន៍អេកូទេសចរណ៍ជីផាតបានដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យទេសចរណ៍ និងកាន់តែធ្វើអោយប្រជាជនមានជីវភាពរស់នៅល្អប្រសើរ ព្រមទាំងសេដ្ឋកិច្ចក្នុងខេត្តកាន់តែលូតលាស់ប្រសើរឡើង។

### ខ. វិស័យអប់រំ

សម្រាប់វិស័យអប់រំនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត បច្ចុប្បន្នគឺស្ថិតក្នុងស្ថានភាពល្អប្រសើរ ដែលអាចជួយកាត់បន្ថយដល់អនក្ខរជនបានមួយផ្នែក ដោយសារតែនៅទីនោះមានសាលារៀនគ្រប់កម្រិតចាប់តាំងពីថ្នាក់បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដែលអាចងាយស្រួលដល់ពួកគេបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សា និងអាចបន្តសិក្សាថ្នាក់បរិញ្ញាបត្របាន។

### គ. វិស័យសុខាភិបាល

យោងតាមការអង្កេតដោយផ្ទាល់ ក៏ដូចជាសាកសួរដោយផ្ទាល់ជាមួយនឹងប្រជាសហគមន៍ ព្រមទាំងសហគមន៍អេកូទេសចរណ៍ជីផាត បានអោយដឹងថា នៅទីនោះគឺមានមណ្ឌលសុខភាពមួយ សម្រាប់បម្រើវិស័យសុខាភិបាល។ ទាំងនេះគឺបង្កលក្ខណៈងាយស្រួលទៅដល់ ប្រជាសហគមន៍ទៅពិនិត្យសុខភាព ក៏ដូចជាភ្ញៀវទេសចរណ៍នៅពេលដែលមានគ្រោះថ្នាក់ដាយថាហេតុអាចបញ្ជូនទៅព្យាបាលទាន់ពេលវេលា។

### ឃ. វិស័យសិប្បកម្ម

ចំពោះវិស័យសិប្បកម្មវិញ សង្កេតឃើញថា នៅទីនេះពុំទាន់មានការផ្តួចផ្តើមគំនិតអោយបង្កើតជាការផលិតនូវវត្ថុដែលធ្វើពីដៃផ្សេងៗ ឬវត្ថុអនុស្សាវរីយ៍សម្រាប់ភ្ញៀវទេសចរណ៍នៅឡើយទេ នេះបើយោងតាមប្រសាសន៍របស់ប្រធានសហគមន៍អេកូទេសចរណ៍ជីផាត។

### ង. វិស័យកសិកម្ម

ប្រជាជនដែលរស់នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត ភាគច្រើនជាកសិករ និងមួយចំនួនតូចជាអ្នកលក់ដូរ។ នៅពេលផុតពីរដូវធ្វើស្រែចំការ ដីដែលទំនេរនោះប្តូរទៅជាដាំដំណាំហូបផ្លែមួយចំនួនដូចជាៈ ឪឡឹក ពោត ដំឡូងមី ជាដើម។ ក្រៅពីនេះក៏មាន អំពៅ ចេក ខ្នុរ ល្ហុង ដែលដំណាំទាំងនេះគឺសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅរបស់ពួកគាត់សព្វថ្ងៃ។

## ២.៨ ផ្នែកផ្សេងៗដែលជាភាគីចូលរួមពាក់ព័ន្ធ

### ២.៨.១ វិស័យឯកជន

ឯកជន ជាផ្នែកមួយនៃការអភិវឌ្ឍ គឺជាម្ចាស់គម្រោងវិនិយោគ ឬជាអ្នករកស៊ីក្នុងអាជីវកម្មទេសចរណ៍នៅតំបន់នោះ។ ដូចនេះផ្នែកឯកជនមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពយូរអង្វែង។ ពោលគឺ រាល់គម្រោងវិនិយោគឯកជនទាំងអស់ចាំបាច់ត្រូវបានគិតគូរបញ្ហានិរន្តរភាព ធ្វើយ៉ាងណាអនុវត្តន៍គម្រោងកុំអោយបង្កនូវផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច វប្បធម៌ សង្គមធម៌ និងបរិស្ថានក្នុងតំបន់។ ផ្នែកនេះក៏ត្រូវគិតគូរអោយបាននូវគោលនយោបាយច្បាប់ និងការណែនាំពីរាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន។ តាមការសង្កេតឃើញជាក់ស្តែង វិស័យឯកជន ពិតជាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការក្លាយជាកាតាលីករជម្រុញអោយការអភិវឌ្ឍកាន់តែមានល្បឿនទៅមុខជាដរាប។

សម្រាប់សហគមន៍អេកូទេសចរណ៍ជីផាតផ្ទាល់មានភ្នាក់ងារទេសចរណ៍កម្ពុជាជាច្រើនបានចាប់ផ្តើមធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយនឹងសហគមន៍ ដោយនាំភ្ញៀវរបស់ពួកគេអោយមកទស្សនាកំសាន្តនៅទីនេះ។ ក្នុងនោះយើងសង្កេតឃើញមាន ក្រុមហ៊ុនទេសចរណ៍ឯកជនជាច្រើន ដូចជា៖ Terre Cambodge, khiri travel, Great Angkor Tours Hanuman Tourismជាដើម (នេះបើយោងតាមប្រសាសន៍របស់ប្រធានសហគមន៍អេកូទេសចរណ៍ជីផាត បច្ចុប្បន្នគិតត្រឹមឆ្នាំ២០២១មានក្រុមហ៊ុនទេសចរណ៍សហការចំនួន៣០) ។

### ២.៨.២ រាជរដ្ឋាភិបាល និងអាជ្ញាធរដែនដី

ក្រុមនេះ គឺជាក្រុមយ៉ាងសំខាន់ និងមានឥទ្ធិពលបំផុតចំពោះការអភិវឌ្ឍវិស័យទេសចរណ៍។ រដ្ឋាភិបាលមានតួនាទីសំខាន់ក្នុងការកំណត់នូវគោលនយោបាយតម្រង់ទិស ការអភិវឌ្ឍថា តើគួរអភិវឌ្ឍន៍នៅតំបន់ណាខ្លះ គួរអភិវឌ្ឍន៍ដោយរបៀបណា ទីណាគួរអនុវត្តន៍សកម្មភាពទេសចរណ៍អ្វី? អ្វីដែលមិនត្រូវបានអនុញ្ញាតអោយបង្កើតក្នុងតំបន់អភិរក្សណាមួយ។ ច្បាប់ និងគោលនយោបាយក្នុងការអភិវឌ្ឍទេសចរណ៍ មានសារៈសំខាន់ណាស់ក្នុងការជួយអោយមាននិរន្តរភាពយូរអង្វែង តម្លាភាព និងទទួលបាននូវផលប្រយោជន៍ខ្ពស់។

ចំពោះអាជ្ញាធរដែនដី ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក៏ដូចជារាជរដ្ឋាភិបាលថ្នាក់លើ គឺមានតួនាទីសំខាន់ក្នុងការជួយសម្រួលរាល់គម្រោងវិនិយោគដែលមាននៅក្នុងដែនដីរបស់ខ្លួនអោយដំណើរការទៅបានយ៉ាងល្អដោយផ្តល់ជា គោលការណ៍ណែនាំអំពីកន្លែងសាងសង់ កន្លែងដែលគួរបង្កើតសកម្មភាពទេសចរណ៍ កន្លែងណាដែលគួរអភិរក្សទុកបានល្អនោះ។ អាជ្ញាធរមូលដ្ឋានត្រូវចេះធ្វើការអប់រំដល់ប្រជាពលរដ្ឋអោយចូលរួមថែរក្សា ការពារ និងស្រូបយកប្រយោជន៍ផងដែរ។

តួយ៉ាង ខេត្តកោះកុង ត្រូវបានរាជរដ្ឋាភិបាល ក៏ដូចជា ក្រសួងទេសចរណ៍បានយកចិត្តទុកដាក់ ក្នុងការអភិវឌ្ឍលើគ្រប់វិស័យ ក្នុងការជំរុញ និង បានដាក់ចេញនូវការរៀបចំកំណត់ផែនការសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ ឲ្យកាន់តែល្អប្រសើរ ក្នុងការរួមចំណែកបង្កើនប្រាក់ចំណូល ឱកាសការងារ កាត់បន្ថយភាពក្រីក្រក្នុងសហគមន៍មូលដ្ឋាន អភិវឌ្ឍន៍សេដ្ឋកិច្ចខេត្ត ការអភិរក្សធនធានធម្មជាតិ វប្បធម៌ ឈរលើគោលការណ៍និរន្តរភាព និង ការទទួលខុសត្រូវ ជំរុញការចូលរួមនិង សហការពីគ្រប់ភាគី ទាំងផ្នែកសាធារណៈ ផ្នែកឯកជន ដៃគូអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ព្រមទាំងភ្ញៀវទេសចរណ៍ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍវិស័យទេសចរណ៍ និងអន្តរវិស័យគាំទ្រនៅក្នុងខេត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។

តួយ៉ាងការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍ជីផាត គឺមិនអាចកាត់ផ្ដាច់បានឡើយនូវការសហការជាមួយនឹងវិស័យសាធារណៈ។ វិស័យសាធារណៈ មានដូចជា មន្ទីរទេសចរណ៍ខេត្ត ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រុមប្រឹក្សា ឃុំសង្កាត់ជាដើម។ ចំពោះអាជ្ញាធរដែនដី គឺត្រូវទាក់ទងយ៉ាងខ្លាំងនឹងសហគមន៍ផ្ទាល់ ព្រោះពួកគេមានតួនាទីយ៉ាងសំខាន់ក្នុងការជួយគាំទ្រ ការអភិវឌ្ឍទេសចរណ៍ក្នុងតំបន់ ពិសេសតាមរយៈការផ្ដល់នូវឯកសារ លិខិតបទដ្ឋានគតិយុត្តិផ្សេងៗដើម្បីអោយសហគមន៍មានដំណើរការបានយ៉ាងរលូន។

## ២.៨.៣ ការចូលរួមពីអង្គការ សហគមន៍ក្នុង និងក្រៅរដ្ឋាភិបាល

អង្គការសហគមន៍ក្នុង និងក្រៅរដ្ឋាភិបាលជាច្រើន ដែលគេបង្កើតឡើងដើម្បីធ្វើការគាំទ្រ និងអង្កេតពិនិត្យមើលទៅលើបរិស្ថាន វប្បធម៌ និងទៅលើសេដ្ឋកិច្ចនៅទូទាំងពិភពលោក។ អង្គការ សហគមន៍នានាមានតួនាទីសំខាន់ក្នុងការជួយផ្ដល់គោលការណ៍ណែនាំអំពីបញ្ហានិរន្តរភាព ធ្វើយ៉ាងណាមិនអោយមានផលប៉ះពាល់ជាអវិជ្ជមានកើតមានឡើងនៅក្នុងតំបន់ណាមួយឡើយ។ គ្រប់បណ្ដាអង្គការ សហគមន៍ជាច្រើន គឺជាសមាសធាតុមួយក្នុងកិច្ចពិភាក្សា ផ្ដល់យោបល់ចំពោះការអភិវឌ្ឍថាតើគួរអភិវឌ្ឍន៍ ឬមិនគួរ ហើយក្រុមនេះក៏ដើរតួយ៉ាងសំខាន់មួយផងដែរ ដែលរង់ចាំអង្កេតមើលសកម្មភាពរបស់ម្ចាស់គម្រោងដែលបានអនុវត្ត និងធ្វើការកែលំអនូវអ្វីដែលមិនសមហេតុផលធ្វើអោយមានប៉ះពាល់បរិស្ថានក្នុងតំបន់ទៅលើសង្គមវប្បធម៌ក៏ដូចជាសេដ្ឋកិច្ច។

ក្នុងនោះផងដែរ សហគមន៍អេកូទេសចរណ៍ជីផាតត្រូវបានអង្គការសម្ព័ន្ធមិត្តសត្វព្រៃ (wildlife alliance) ដែលជាអង្គការគាំទ្រដ៏សំខាន់ក្នុងការផ្ដល់បច្ចេកទេស និងហិរញ្ញវត្ថុដល់ការអភិវឌ្ឍសហគមន៍ជីផាតតាំងពីឆ្នាំ២០០៧មកម្ល៉េះ។ ខណៈដែលអង្គការដទៃផ្សេងទៀត ដូចជា live and learn ដែលទទួលបានមូលនិធិពី IUCN ក៏មានការជួយគាំទ្រតាមរយៈការផ្ដល់ជាជំនាញបណ្ដុះបណ្ដាលផ្សេងៗ ទីផ្សារ ព្រមទាំងការផ្សព្វផ្សាយក្នុងគេហទំព័រផ្លូវការរបស់សហគមន៍អេកូទេសចរណ៍ជីផាតផងដែរ។

## ២.៨.៤ ការចូលរួមពីប្រជាជនក្នុងតំបន់

ប្រជាជនមូលដ្ឋាន ជាផ្នែកមួយដែលមានឥទ្ធិពលចំពោះតំបន់ទេសចរណ៍។ ប្រជាពលរដ្ឋនៅក្នុងតំបន់ទេសចរណ៍ គឺជាមនុស្សសំខាន់ដែលមិនអាចខ្វះបានក្នុងការជួយអភិរក្សបរិស្ថាន ការថែរក្សាវប្បធម៌ក្នុងតំបន់របស់ខ្លួន។ នៅពេលណាដែលមានប្រជាជនទាំងអស់បានយល់ដឹងពីតម្លៃ និងអត្ថប្រយោជន៍របស់ទេសចរណ៍

និងធនធានទាំងនេះនៅក្នុងជីវិតរបស់ពួកគាត់។ មិនតែប៉ុណ្ណោះប្រសិនបើប្រជាពលរដ្ឋក្នុងតំបន់ពុំទទួលយល់ព្រមចំពោះគម្រោងអភិវឌ្ឍន៍ក្នុងតំបន់គាត់ទេ គម្រោងនោះពុំអាចដំណើរការទៅបានហើយ សកម្មភាពទេសចរណ៍ពុំអាចរីកចម្រើនបានដែរ។ តាមការសង្កេតរបស់ក្រុមសិក្សាឃើញថា ប្រជាសហគមន៍ក្នុងសហគមន៍ជីផាត គឺមានការចូលរួម សហការបានយ៉ាងល្អ។

#### ២.៨.៥ ការចូលរួមពីទេសចរ (ក្នុងស្រុក និងបរទេស)

ទេសចរ គឺជាអ្នកដែលប្រើប្រាស់ផលិតផលទេសចរណ៍។ ទេសចរ គឺជាអ្នកចូលមកកំសាន្តក្នុងតំបន់ទេសចរណ៍។ បើសិនជាគ្មានទេសចរ សកម្មភាពនៃការអភិវឌ្ឍទេសចរណ៍ពុំអាចកើតឡើងបានដែរ ហើយអ្វីៗទាំងអស់ក៏មិនអាចកើតមានសកម្មភាពនៅក្នុងតំបន់ទេសចរណ៍បានទេ។ ដូចនេះនៅពេលដែលភ្ញៀវទេសចរណ៍បានទៅទស្សនាកំសាន្តទីណាមួយ ពួកគាត់មានតួនាទីសំខាន់ណាស់សម្រាប់ធ្វើអោយតំបន់នោះក្លាយជាតំបន់ទេសចរណ៍។ ការចូលរួមពីទេសចរ គឺជាផ្នែកមួយក្នុងការជួយអោយតំបន់ទេសចរណ៍។

## ២.៩ ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត

### ២.៩.១ ការវិភាគយុទ្ធសាស្ត្រគ្រប់គ្រងសហគមន៍

#### ២.៩.១.១ ការគ្រប់គ្រងសកម្មភាពទេសចរ និងការបំពេញចិត្តទេសចរ

ការគ្រប់គ្រងសកម្មភាពទេសចរណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត គឺយើងមានប្រព័ន្ធគ្រប់គ្រងកាកសំណល់ និងមានធុងសំរាមសំរាប់អោយភ្ញៀវទេសចរណ៍ងាយស្រួលក្នុងការដាក់សំរាម ហើយក៏មានការរៀបចំជាបង្គន់អនាម័យ និងមានការត្រួតពិនិត្យត្រឹមត្រូវនូវសំភារៈប្រើប្រាស់ទាំងឡាយដែលនាំចូលមកក្នុងសហគមន៍ដែលមិនធ្វើអោយប៉ះពាល់សម្រាប់អ្នករស់នៅក្នុងសហគមន៍ផ្ទាល់ក៏ដូចភ្ញៀវទេសចរណ៍ដែលមកទស្សនា។ ភ្ញៀវទេសចរណ៍ក៏អាចជិះទូក ឬជិះកែយ៉ាក់ដោយខ្លួនឯងលេងកម្សាន្តនៅតាមដងព្រែក ឬមួយក៏បោះតង់ក្នុងព្រៃដោយពួកគាត់មានការទទួលខុសត្រូវខ្ពស់ក្នុងការធានាផ្តល់ជូននូវសុវត្ថិភាពដល់ភ្ញៀវទេសចរណ៍ក្នុងពេលដំណើរកំសាន្ត ។ មួយវិញទៀតសម្រាប់ភ្ញៀវទេសចរណ៍ដែលគាត់ជួបគ្រោះថ្នាក់ផ្សេងៗជាយថាហេតុ គឺខាងសហគមន៍ក៏ពួកគាត់អាចជួយភ្ញៀវដែលជួបគ្រោះថ្នាក់នោះបានយ៉ាងឆាប់រហ័ស និងអាចទាក់ទងទៅខាងសេវាសុខាភិបាលដែលនៅជិតតំបន់បំផុតអោយពួកគាត់មកជួយសង្គ្រោះទាន់ពេលវេលា។ សម្រាប់ខាងសណ្តាប់ធ្នាប់វិញ សហគមន៍ក៏មានអ្នកចាំមើលការខុសត្រូវទាក់ទងនឹងរបៀបរៀបរយរបស់សហគមន៍ ដែលពួកគាត់ជាអ្នកពិនិត្យនៅជុំវិញសហគមន៍ ដើម្បីធានាថាមិនមានសម្រាម។ មិនតែប៉ុណ្ណោះ នៅតាមដងផ្លូវចូលក្នុងព្រៃ គឺសហគមន៍បានរៀបចំ ចាត់ចែងអោយមានធុងសំរាមសម្រាប់អោយភ្ញៀវទេសចរណ៍គាត់ដាក់សំរាម និងធានាថានៅតាមកន្លែងកំសាន្តនីមួយៗមានសោភ័ណភាពស្អាត និងអនាម័យជានិច្ច ។

រីឯការបំពេញចិត្តទេសចរវិញ សហគមន៍អេកូទេសចរណ៍ជីផាត គឺជាសហគមន៍មួយដែលមានភាពល្បីល្បាញយ៉ាងខ្លាំងនៅក្នុងខេត្តកោះកុង ដោយសារតែសហគមន៍នេះសំបូរទៅដោយធនធានធម្មជាតិ ដែលជាគ្រឿងទាក់ទាញអន្ទងចិត្តដល់ទេសចរ ។ កត្តាដែលរីកចម្រើនមកដល់សព្វថ្ងៃនេះដោយសារអ្នកដឹកនាំរបស់សហគមន៍ មានវិធានការក្នុងការអភិវឌ្ឍច្បាស់លាស់ មានការសហការជាមួយនឹងអង្គការព្រមទាំងប្រជាសហ

គមន៍នៅឃុំជីផាត ចូលរួមធ្វើការអភិវឌ្ឍ ស្របទៅតាមផែនការដែលមានអាទិភាពដើរតួជាមាសបៃតងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ និងសង្គមតាមរយៈការបង្កើតការងាររកប្រាក់ចំណូលជូនប្រជាពលរដ្ឋ។ រាល់ការមកទស្សនារបស់ភ្ញៀវទេសចរណ៍តែងតែមានការយកចិត្តទុកដាក់ពីសំណាក់បុគ្គលិក និងប្រជាពលរដ្ឋជាម្ចាស់ស្រុកប្រកបដោយភាពកក់ក្ដៅ មានការបម្រើជូនសេវាកម្មម្ហូបអាហារ និងភេសជ្ជៈបានឆាប់រហ័ស និងមានផាសុខភាព មានសេវាកម្មស្នាក់នៅ និងផ្តល់សេវាកម្មដឹកជញ្ជូនគ្រប់ប្រភេទ សម្រាប់បំពេញតម្រូវការជូនភ្ញៀវទេសចរណ៍។

### ២.៩.១.២ ការគ្រប់គ្រងបរិស្ថាន និងនិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍

វិស័យទេសចរណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតពឹងផ្អែកទាំងស្រុងទៅលើធនធានដែលមានស្រាប់នៅក្នុងសហគមន៍យកមកធ្វើការអភិវឌ្ឍ(ធនធានធម្មជាតិ ធនធានវប្បធម៌)។ ដើម្បីចូលរួមចំណែកក្នុងការអភិឌ្ឍទេសចរណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតកាន់តែប្រសើរឡើងនិងប្រកបដោយនិរន្តភាពចូលរួមក្នុងកិច្ចការពារធនធានដែលមានស្រាប់នៅក្នុងសហគមន៍ និងការទទួលខុសត្រូវខ្ពស់របស់ប្រជាជននៅក្នុងសហគមន៍ផ្ទាល់។ ដើម្បីគ្រប់គ្រងបរិស្ថានយើងចាំបាច់ត្រូវធ្វើការរួមគ្នាជាមួយស្ថាប័នដែលពាក់ព័ន្ធដូចជា៖ អាជ្ញាធរមានសមត្ថកិច្ចដែលគ្រប់គ្រងនៅក្នុងតំបន់ និងអង្គការនានាក្នុងខេត្តដោយធ្វើការរៀបចំផែនការរួមគ្នាដើម្បីធានាដល់ការងារគ្រប់គ្រង និងអភិរក្សធនធានប្រកបដោយចីរភាពដើម្បីគ្រប់គ្រងបរិស្ថាន និងកាកសំណល់កាន់តែប្រសើរឡើងគឺយើងត្រូវលើកកំពស់គុណភាព និងរៀបចំបរិស្ថានអោយបានប្រសើរជាផ្នែកមួយដ៏សំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរណ៍អោយមកទស្សនាកម្សាន្តក្នុងតំបន់និងផ្តល់ផាសុខភាពដល់ភ្ញៀវផងដែរ។ ជាយុទ្ធសាស្ត្រយើងត្រូវជំរុញរៀបចំសកម្មភាពទាំងឡាយក្នុងន័យអប់រំលើកកម្ពស់ចំណេះដឹងស្ដីពីបរិស្ថានដោយអនុវត្តន៍ឆ្ពោះទៅរកសោភណ្ឌភាពទីក្រុងស្អាត និងភាពបៃតងជានិច្ចតាមតំបន់សហគមន៍។ ដើម្បីគាំទ្រដល់ការធ្វើយុទ្ធនាការផ្សព្វផ្សាយកម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈនិងចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត និងសេវាកម្មល្អនិងស្របតាមប្រព័ន្ធស្តង់ដាទីក្រុងស្អាត គឺចាំបាច់ត្រូវធ្វើការជំរុញដល់ការគ្រប់គ្រងកាកសំណល់តាមដងផ្លូវទីប្រជុំជន និងតំបន់គោលដៅទេសចរណ៍ត្រូវតែមានភាពស្រស់ស្អាត មានសោភ័ណភាពដោយធ្វើការរៀបចំអោយមានរបៀបរៀបរយ និងប្រកបដោយការទទួលខុសត្រូវខ្ពស់។ ដើម្បីសម្រេចការគ្រប់គ្រងនិងអភិរក្សបរិស្ថានទេសចរណ៍អោយមាននិរន្តភាព គឺត្រូវមានការចូលរួមគ្រប់គ្រងភាគីពាក់ព័ន្ធគ្រប់ស្ថាប័នប្រតិបត្តិករកំពុងធ្វើអាជីវកម្ម គ្រប់សេវាកម្មទេសចរណ៍ ទាំងអស់ត្រូវចូលវិភាគទានបង្កើតមូលនិធិក្នុងការថែរក្សាបរិស្ថានជុំវិញតំបន់ជីផាតដោយមានការចូលរួមនិងទទួលខុសត្រូវទាំងអស់គ្នាសម្រាប់អ្នកជំនាន់ក្រោយទុកជាគំរូហើយបំបាត់ទម្លាប់ចាស់ចោល។ ការអភិវឌ្ឍធនធានមនុស្សជាផ្នែកមួយ ដ៏សំខាន់មិនអាចខ្វះបានក្នុងដំណើរការនៃការអភិវឌ្ឍវិស័យទេសចរណ៍នៅសហគមន៍អេកូទេសចរណ៍ជីផាតអោយមានការរីកចម្រើន ការបណ្តុះបណ្តាលធនធានមនុស្សជាចលករមួយជំរុញកិច្ចដំណើរធ្វើដំណើរប្រកបដោយគុណភាពស្តង់ដា និងមានចីរភាព។

### ២.៩.១.៣ ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ

ក្នុងខេត្តកោះកុង រដ្ឋាភិបាលបានបន្តធ្វើការអភិវឌ្ឍជាបន្តបន្ទាប់នូវហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបង្កភាពងាយស្រួលសំរាប់ភ្ញៀវទេសចរណ៍ធ្វើដំណើរឆ្លងកាត់។ នៅក្នុងខេត្តកោះកុងក៏មានព្រលានយន្តហោះមួយនៅក្នុងរមណីយដ្ឋានតារាសាគរលោតសន្ទឹងលើផ្ទៃដីសម្បទាទំហំ ៤៥.០០០ហិចតា។ អាកាសយានដ្ឋាននេះបានទទួលអ្នកដំណើរ១០លាននាក់ជារៀងរាល់ឆ្នាំ។ ការរៀបចំអោយបើកដំណើរការ និងមានចរាចរណ៍យ៉ាងទូលំទូលាយតាមផ្លូវគោក និងផ្លូវទឹកដោយឆ្លងកាត់តាមច្រកទ្វារអន្តរជាតិចាំយាម។

ចំពោះហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហគមន៍សង្កេតឃើញថាមិនទាន់មានការអភិវឌ្ឍបានល្អនៅឡើយទេសម្រាប់ការធ្វើដំណើររបស់ទេសចរ ព្រោះផ្លូវទៅកាន់តំបន់នេះជាប្រភេទផ្លូវលំដីក្រហម អាចនឹងពិបាកធ្វើដំណើរនៅរដូវវស្សា។ សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទាំងមូលជាភារកិច្ចរបស់អាជ្ញាធរមូលដ្ឋានជាអ្នកធ្វើប៉ុន្តែសហគមន៍ក៏មានតួនាទីក្នុងការចូលរួមចំណែកថែទាំផ្លូវថ្នល់ទាំងអស់នោះអោយល្អប្រសើរផងដែរ ដោយសហគមន៍ និងអាជ្ញាធរមូលដ្ឋានតែងតែមានកិច្ចប្រជុំពីបញ្ហាអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជារៀងរាល់ខែ។

### ២.៩.១.៤ ការគ្រប់គ្រងវិបត្តិរបស់សហគមន៍

ការរៀបចំផែនការ ការត្រៀមខ្លួន និងការហ្វឹកហាត់សម្រាប់អំឡុងពេលមានវិបត្តិជាចំណុចសំខាន់។ វិបត្តិមួយចំនួនដែលជះឥទ្ធិពលលើភ្ញៀវទេសចរណ៍ រួមមានគ្រោះមហន្តរាយធម្មជាតិ ជាឧទាហរណ៍ដូចជា៖ ព្យុះទីហ្វុង រញ្ជួយដី រលកយក្សស៊ូណាមិ ទឹកជំនន់។ល។ និងហេតុការណ៍ចៃដន្យផ្សេងទៀត អាចជាឆ្លងចរន្តអគ្គិសនី អស្ថេរភាពក្នុងប្រទេស ការហែក្បួនតវ៉ា គ្រោះអគ្គិភ័យ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះ សហគមន៍អេកូទេសចរណ៍ជីផាតក៏បានគិតគូរៀបចំផែនការគ្រប់គ្រងវិបត្តិដែលអាចកើតមានឡើងនៅក្នុងតំបន់ដូចជា ៖

- ការបង្កើត មជ្ឈមណ្ឌលផ្តល់ព័ត៌មាន សម្រាប់ភ្ញៀវទេសចរណ៍នៅពេលមានបញ្ហា និងដើម្បីព្យាយាមស្វែងរកដំណោះស្រាយជូនពួកគាត់អោយបានទាន់ពេលវេលា។
- ការដាក់សញ្ញាបង្ហាញផ្លូវនៅគ្រប់ជុំវិញតំបន់កំសាន្តនីមួយៗ។
- មានការបណ្តុះបណ្តាលដល់សមាជិកសហគមន៍ពីវិធីសង្គ្រោះបឋម ដើម្បីជួយដល់ភ្ញៀវទេសចរណ៍ក្នុងករណីចាំបាច់។

### ២.៩.១.៥ ទិសដៅប្រជាសាស្ត្រ និងយុទ្ធសាស្ត្រទាក់ទាញ

ដោយផ្អែកលើមូលដ្ឋានធនធានធម្មជាតិដ៏ស្រស់បំព្រង ប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះ និងសេវាកម្មយ៉ាងសំបូរបែប ការចុះសិក្សាស្រាវជ្រាវព័ត៌មាន និងធ្វើអង្កេតយើងបានកំណត់នូវទិសដៅប្រជាសាស្ត្រ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សហគមន៍អេកូទេសចរណ៍ជីផាតដើម្បីដាក់ចេញនៅផែនការយុទ្ធសាស្ត្រមានលក្ខណៈច្បាស់លាស់ និងប្រសិទ្ធភាពខ្ពស់។ ការអនុវត្តប្រកបដោយប្រសិទ្ធភាព និងជោគជ័យជាចាំបាច់ត្រូវមានគន្លឹះសំខាន់ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ផ្នែកឯកជន(private sector) វិនិយោគិន( Investors ) ដៃគូអភិវឌ្ឍន៍( Development partner ) និងប្រជាពលរដ្ឋ ( People )នៅក្នុងសហគមន៍។ ហើយវាជាទិសដៅយុទ្ធសាស្ត្រអាទិភាពក្នុងការអភិវឌ្ឍ សហគមន៍ទេសចរណ៍នេះតែម្តងរួមមានចំណុចសំខាន់ៗដូចខាងក្រោម៖

- ❖ ការអភិវឌ្ឍផលិតផល និងការរៀបចំសេវាកម្មទេសចរណ៍
- ❖ ការរៀបចំទីផ្សារ និងផ្សព្វផ្សាយផលិតផលទេសចរណ៍
- ❖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងតភ្ជាប់ដើម្បីសម្រួលដល់ការធ្វើដំណើរទេសចរណ៍
- ❖ ការវិនិយោគ និងការអភិវឌ្ឍវិស័យឧស្សាហកម្មទេសចរណ៍
- ❖ ការអភិរក្ស និងការគ្រប់គ្រងកាកសំណល់ បរិស្ថាន
- ❖ ការអភិវឌ្ឍធនធានមនុស្ស និងសមធម៌យេនឌ័រក្នុងសហគមន៍
- ❖ ការពង្រឹងសន្តិសុខ និងសុវត្ថិភាពដល់ភ្ញៀវទេសចរណ៍នៅសហគមន៍
- ❖ ការពង្រឹងច្បាប់ទេសចរណ៍នៅក្នុងសហគមន៍
- ❖ ធ្វើការផ្សព្វផ្សាយគោលនយោបាយសំខាន់ៗរបស់សហគមន៍ និងក្រសួងទេសចរណ៍
- ❖ ជំរុញភ្ជាប់ខ្សែទស្សនៈកិច្ចតាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ទៅតាមបណ្តាខេត្ត និងប្រទេសជិតខាង
- ❖ ធ្វើផែនការផ្សព្វផ្សាយពីសហគមន៍ទាំងមូលទៅដល់បណ្តាប្រទេសផ្សេងៗមកទស្សនានៅសហគមន៍ទាំងមូល

### ២.៩.១.៦ ការធានាសុវត្ថិភាពនៅក្នុងសហគមន៍

សុវត្ថិភាព ជាគ្រឿងដ៏សំខាន់របស់ភ្ញៀវទេសចរណ៍ទាំងឡាយនៅពេលធ្វើដំណើរតែងតែប្រាថ្នាចង់បាន។ នៅពេលដែលដឹងថាតំបន់នោះមានគ្រោះថ្នាក់ហើយ ភ្ញៀវទេសចរណ៍ប្រាកដជាមិនហ៊ានចង់ទៅកំសាន្ត ឬពេលទៅកំសាន្តតំបន់នោះហើយ មានអារម្មណ៍ថាខ្លួនគ្មានសុវត្ថិភាព។

ដូច្នេះ ការវិភាគជាយុទ្ធសាស្ត្រលើការងារសន្តិសុខ និងសុវត្ថិភាពភ្ញៀវទេសចរណ៍ និងបង្ហាញអោយយើងដឹងកាន់តែច្បាស់នៅបញ្ហាកើតមានឡើងដល់ភ្ញៀវទេសចរណ៍ដូចជាៈ បញ្ហាកេងបន្លំរបស់ជនខិលខូចមួយចំនួន លក់ផលិតផលក្លែងក្លាយ ដើម្បីបោកប្រាស់ភ្ញៀវទេសចរណ៍យ៉ាងអនាធិបតេយ្យរបស់អ្នកនាំភ្ញៀវ និងសេវាកម្មដឹកជញ្ជូនភ្ញៀវយកតម្លៃហួសកម្រិត អនាម័យម្ហូបអាហារ ការស្នាក់នៅ និងបញ្ហាគ្រោះថ្នាក់ជាយថាហេតុផ្សេងៗជាដើម គឺតម្រូវដោយយើងប្រុងប្រយ័ត្នជាមុនដើម្បីធានាបាននូវសន្តិសុខ សុវត្ថិភាព និងសុខដុមរមនារបស់ភ្ញៀវ និងដើម្បីជួយដល់ការលើកមុខមាត់របស់សហគមន៍ទាំងមូលក្នុងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវខ្ពស់ហើយ និងស្របតាមគោលនយោបាយការអភិវឌ្ឍភូមិឃុំមានសុវត្ថិភាពប្រកបដោយស្តង់ដា បទពិសោធន៍បច្ចេកទេសនៃការទាក់ទាញភ្ញៀវទេសចរណ៍ដែលមកទស្សនា។

ជាក់ស្តែង នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត ព្យាយាមធានាសុវត្ថិភាពទេសចរទាំងអស់ មិនថាជាទេសចរជាតិឬអន្តរជាតិក្តីក៏សហគមន៍នូវតែបំពេញតួនាទីរបស់ខ្លួនអោយបានល្អ។ សហគមន៍បានរៀបចំប្រព័ន្ធសន្តិសុខ សុវត្ថិភាពទេសចរណ៍ ដោយចាត់អោយមានការយាមល្បាតពីសន្តិសុខភូមិ អាជ្ញាធរមូលដ្ឋានតាមទីតាំងនីមួយៗ។ មិនត្រឹមតែប៉ុណ្ណោះ សហគមន៍បានរៀបចំផែនទីចង្អុលផ្លូវ និងចំណុចតំបន់គ្រោះថ្នាក់ផ្សេងៗ ដាក់តាមតំបន់នីមួយៗក្នុងសហគមន៍។ ហើយសកម្មភាពទាំងអស់នេះត្រូវបានគ្រូស្តង់ដាថ្នាក់អាស៊ាន មកបើកវគ្គបណ្តុះបណ្តាលបង្រៀនដោយផ្ទាល់ក្នុងសហគមន៍ដោយសិក្សាអំពីប្រព័ន្ធទាំងនេះដល់សហគមន៍ ប្រតិបត្តិករទេសចរណ៍ ព្រមទាំងមគ្គុទ្ទេសក៍ទេសចរណ៍នូវចំណេះដឹងសង្គ្រោះបឋម ដើម្បីមានលទ្ធភាពសង្គ្រោះ

ភ្ញៀវនៅពេលដើរព្រៃពេលមានគ្រោះថ្នាក់ជាយថាហេតុ។ មុននឹងនាំភ្ញៀវទេសចរណ៍ចូលកំសាន្តក្នុងព្រៃ សហគមន៍ក៏មានអោយភ្ញៀវទេសចរណ៍ធ្វើកុងត្រាមួយចំនួនក្នុងករណីកើតបញ្ហាឡើងជាយថាហេតុ ប៉ុន្តែមគ្គុទេសក៍ក៏នៅតែបន្តព្យាយាមថែរក្សាសុវត្ថិភាពភ្ញៀវអស់ពីសមត្ថភាពដែរ។ មិនតែប៉ុណ្ណោះ មុននឹងចេញដំណើរសហគមន៍ ក៏ដូចជាមគ្គុទេសក៍បានណែនាំ ពន្យល់ពីបម្រាម បទបញ្ញត្តិផ្សេងៗដែលភ្ញៀវត្រូវតែប្រកាន់ភ្ជាប់។ ហើយដើម្បីធានាសុវត្ថិភាពនេះទៀតសោត សហគមន៍មិនអនុញ្ញាតិដាច់ខាតអោយភ្ញៀវទេសចរណ៍ណាដែលមានបំណងចង់ចូលកំសាន្តព្រៃតែម្នាក់ឯងដោយគ្មានអ្នកនាំផ្លូវ ឬមគ្គុទេសក៍នោះទេ។ គួរបញ្ជាក់ផងដែរថា កាលពីមុននៅពេលភ្ញៀវទេសចរណ៍ធ្វើដំណើរផ្សងព្រេង បោះតង់ក្នុងព្រៃ សហគមន៍គឺត្រឹមប្រើអេកូម ដើម្បីភ្ជាប់ទំនាក់ទំនងរាយការណ៍គ្នាជាប្រព័ន្ធតែប៉ុណ្ណោះ។ ប៉ុន្តែមកទល់ពេលនេះ សហគមន៍មានការអភិវឌ្ឍដោយប្រើប្រព័ន្ធការពារពេលដើរព្រៃ ដើម្បីភ្ជាប់ទំនាក់ទំនងកាន់តែមានភាពងាយស្រួល និងធានាអាយុជីវិត។

### ២.៩.២ ការដឹកនាំនៅក្នុងសហគមន៍

#### ២.៩.២.១ ការកសាងសមត្ថភាព និងពង្រឹងយន្តការសហគមន៍

សហគមន៍មួយអាចចាក់គ្រឹះទៅមុខបានល្អ ទាមទារអោយគណៈគ្រប់គ្រងទាំងឡាយព្រួតដៃគ្នា សហការ ប្រឹងប្រែងបំពេញការងាររបស់ខ្លួនអស់ពីកម្លាំងកាយ ចិត្ត។ ជាក់ស្តែងនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត តែងតែមានការរៀបចំកិច្ចប្រជុំ ពិភាក្សា ធ្វើបច្ចុប្បន្នភាព ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ និងផ្តល់យោបល់ដែលធ្វើឡើងជាប្រចាំខែរវាងសហគមន៍ផ្ទាល់ និងអាជ្ញាធរមូលដ្ឋានតាមរយៈការដោះស្រាយទៅលើការងារមួយចំនួនដែលជាបញ្ហាប្រឈម និងតាមការសំណូមពរនានាដែលកើតមានឡើងក្នុងមូលដ្ឋានតាមទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពច្បាប់ អោយបានទាន់ពេលវេលា និងទទួលបានប្រសិទ្ធផល។ ព្រមទាំងរៀបចំបទដ្ឋានគតិយុត្តិចាំបាច់នានាដោយដាក់ចេញនូវផែនការ យុទ្ធសាស្ត្រផ្សេងៗស្របតាមស្ថានភាពជាក់ស្តែងរបស់សហគមន៍ ធ្វើយ៉ាងណាអោយការគ្រប់គ្រងអេកូទេសចរណ៍នៅតំបន់ជីផាតប្រកបដោយនិរន្តរភាព ការទទួលខុសត្រូវ និងអនុវត្តន៍ច្បាប់កាន់តែមានប្រសិទ្ធភាពឈានដល់ការអភិវឌ្ឍ។ មិនតែប៉ុណ្ណោះ ដើម្បីកសាងសមត្ថភាពសហគមន៍អោយកាន់តែប្រសើរ សហគមន៍បានខិតខំតាក់តែង រៀបចំផែនការការងារ និងឯកសារសម្រាប់ការបណ្តុះបណ្តាល កសាង សមត្ថភាព ព្រមទាំងយកចិត្តទុកដាក់ក្នុងការរៀបចំបណ្តុះបណ្តាលសម្រាប់អ្នកគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត មគ្គុទ្ទេសក៍ទេសចរណ៍សហគមន៍ដល់ប្រជាសហគមន៍ និងអ្នកល្បាតព្រៃឱ្យយល់ដឹងអំពីសារៈសំខាន់ផ្នែកអេកូទេសចរណ៍ ការគ្រប់គ្រងតំបន់គោលដៅទេសចរណ៍ និងភ្ញៀវទេសចរណ៍ ការគ្រប់គ្រងជម្លោះ ការយល់ដឹងអំពីវប្បធម៌ និងបច្ចេកទេសក្នុងការទំនាក់ទំនង ការសង្គ្រោះបឋមជាដើម។

#### ២.៩.២.២ យន្តការគាំទ្រ គ្រប់គ្រងហិរញ្ញវត្ថុ និងបែងចែកផលប្រយោជន៍

យន្តការគាំទ្រ និងគ្រប់គ្រងហិរញ្ញវត្ថុ ពិតជាមានសារៈសំខាន់ណាស់ ក្នុងការជួយទ្រទ្រង់ដល់សហគមន៍អោយមានដំណើរការទៅមុខបានយ៉ាងរលូន។ ដើម្បីចូលរួមធានានិរន្តរភាពនៃការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍ជីផាតបានរៀបចំឱ្យមានមូលនិធិអេកូទេសចរណ៍ដែលបានមកពីបដិភាគនៃកំរៃនៃការចូលទស្សនា

រមណីយដ្ឋានអេកូទេសចរណ៍ជីផាត បានមកពីភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ អាករលើការស្នាក់នៅរបស់ភ្ញៀវទេសចរណ៍ ចំណូលពីការលក់វត្ថុអនុស្សាវរីយ៍ និងប្រភពស្របច្បាប់ផ្សេងៗទៀត។

ក្រៅពី មានផែនការក្នុងការគ្រប់គ្រងថវិកាយ៉ាងច្បាស់លាស់ហើយ សហគមន៍ក៏មានផែនការក្នុងការបែងចែកផលប្រយោជន៍ផងដែរ។ ការបែងចែកផលប្រយោជន៍ពិតជាមានសារៈសំខាន់ណាស់ ពិសេសក្នុងការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ព្រោះប្រសិនបើមានការបែងចែកដោយមិនមានសមធម៌ គ្មានតម្លាភាព នោះអាចនឹងបង្កឲ្យមានជម្លោះ ការបែងចែកបក្សពួក ឬអាចឈានដល់ការបរាជ័យក្នុងការគ្រប់គ្រងសហគមន៍ទាំងមូលផង។ ហេតុនេះ សហគមន៍មានការរៀបចំផែនការគ្រប់គ្រងបានយ៉ាងច្បាស់លាស់។ ហើយមូលនិធិសហគមន៍នេះត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងច្រើនយ៉ាង ដូចជា៖ ឧបត្ថម្ភដល់សមាជិកគណៈកម្មាធិការគ្រប់គ្រងសហគមន៍ ការចំណាយចរន្តរបស់គម្រោង ការថែទាំ និងជួសជុលសម្ភារៈបម្រើដល់សកម្មភាពអេកូទេសចរណ៍ ឧបត្ថម្ភអ្នកល្បាតសហគមន៍ ការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗបន្ថែមទៀត មូលនិធិសង្គម និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍។

ជាឧទាហរណ៍ជាក់ស្តែង បើសិនជាប្រជាសហគមន៍រត់ទូកអោយភ្ញៀវទេសចរណ៍ក្នុង១ទូកទទួលបាន៣០ដុល្លា នោះពួកគាត់ត្រូវបង់ចូលមូលនិធិសហគមន៍ចំនួន៦ដុល្លា ពោលគឺ២០ភាគរយនៃប្រាក់ដែលពួកគាត់ទទួលបានជាក់ស្តែង។ ចំពោះចំណូលសរុប២០ភាគរយដែលបានពីសមាជិកបដិភាគជូនមូលនិធិសហគមន៍ត្រូវបែងចែកដូចជា៖

- ចំណាយប្រតិបត្តិការ ទិញសម្ភារៈកែលំអគុណភាពសេវាកម្ម និងផ្នែកអនាម័យ(២៥ភាគរយ)
- ប្រាក់ឧបត្ថម្ភគណៈកម្មា និងការងាររដ្ឋបាល(៤៥ភាគរយ)
- សន្សំទុក(១១ភាគរយ)
- រួមចំណែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍(ផ្លូវ ស្ពាន លូ សាលារៀន មន្ទីរពេទ្យ វត្ត) និងសម្បទាសាធារណៈ(០២ភាគរយ)
- ផ្សព្វផ្សាយទីផ្សារ(០៧ភាគរយ)
- ជួយចាស់ជរា កុមារកំព្រា និងកិច្ចការសប្បុរសធម៌(០១ភាគរយ)
- ចំណាយការល្បាត(០៥ភាគរយ)
- គាំទ្រដល់មូលនិធិសម្រាប់ការចូលរួមក្នុងវិស័យទេសចរណ៍ឃុំជីផាត(០១ភាគរយ)។

**២.៩.២.៣ ការអភិវឌ្ឍធនធានមនុស្សក្នុងសហគមន៍**

ការអភិវឌ្ឍធនធានមនុស្សក្នុងមុខជំនាញទេសចរណ៍នៅមានកំរិត តម្រូវការធនធានមនុស្សដែលមានវិជ្ជាជីវៈពិតប្រាកដ និងមានបទពិសោធន៍ ដើម្បីបំរើដល់វិស័យទេសចរណ៍ក្នុងការជំរុញការអភិវឌ្ឍទេសចរណ៍នៅសហគមន៍អេកូទេសចរណ៍ជីផាតប្រកបដោយគុណភាពរីកចម្រើន និងឆ្លើយតបតាមតម្រូវការទីផ្សារ។

បច្ចុប្បន្ននេះកំពុងជាឧបសគ្គនិងចោតជាបញ្ហាខ្លាំង។ ការជួយគាំទ្រដល់ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងរយៈពេលវែងពីបណ្តាដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន ព្រមទាំងការជំរុញដោយ

មានការបណ្ដុះបណ្ដាលវិជ្ជាជីវៈទេសចរណ៍ប្រចាំសហគមន៍គឺត្រូវបានលើកទឹកចិត្ត។ ទោះបីជាសហគមន៍អេកូទេសចរណ៍ជីផាត បច្ចុប្បន្ននេះពុំទាន់ចោទជាបញ្ហាធ្ងន់ធ្ងរចំពោះសន្តិសុខ និងសុវត្ថិភាពភ្ញៀវទេសចរណ៍ ដោយសារតែលំហូរ និងទទួលបានចំណូលភ្ញៀវទេសចរណ៍នៅជិតនិងនៅឆ្ងាយមកកាន់សហគមន៍។ ប៉ុន្តែនាពេលអនាគត នៅពេលកំណើនភ្ញៀវកាន់តែច្រើននោះភាពប្រថុយប្រថាន ផលអវិជ្ជមាន គឺមានកាន់តែខ្ពស់។ ក្នុងអំឡុងពេលផ្ទុះជំងឺកូវីណា សហគមន៍បាត់បង់ភ្ញៀវទេសចរណ៍ស្ទើរតែទាំងស្រុង ដោយពុំមានចំណូលសម្រាប់ផ្គង់ផ្គង់ មិនថាផ្គង់ផ្គង់ជីវភាពប្រជាសហគមន៍ ឬចំណូលដើម្បីទ្រទ្រង់ដល់ដំណើរការសហគមន៍។ ហេតុនេះប្រជាសហគមន៍មួយចំនួនបានបោះបង់បោលនូវអាជីពផ្តល់សេវាកម្មភ្ញៀវទេសចរណ៍ ទៅបម្រើការការងារដទៃផ្សេងទៀត។ នេះជាមូលហេតុនាំអោយធនធានមនុស្សដែលមានក្នុងសហគមន៍ត្រូវបានកាត់បន្ថយ និងគុណភាពនៃការផ្តល់សេវាកម្មត្រូវបានធ្លាក់ចុះមួយកម្រិត។

### ២.៩.៣ ផែនការអភិវឌ្ឍផលិតផល និងសេវាកម្ម

#### ២.៩.៣.១ ការអភិវឌ្ឍផលិតផលយ៉ាងសំបូរបែប និងពង្រឹងគុណភាពសេវាកម្មរបស់សហគមន៍

ការទាក់ទាញភ្ញៀវទេសចរណ៍បន្ថែម និងការជំរុញឱ្យភ្ញៀវទេសចរណ៍មកទស្សនាម្តងហើយចង់មកទស្សនាម្តងទៀត គឺជាការចាំបាច់ណាស់ដែលពឹងផ្អែកទៅលើការគ្រប់គ្រងសម្បទាទេសចរណ៍ថ្មីប្លែកៗ និងប្រកបដោយគុណភាព។ ការគ្រប់គ្រង និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍ វាជាយន្តការ និងយុទ្ធសាស្ត្រដ៏ល្អមួយក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកកម្សាន្ត ហើយការគ្រប់គ្រងផលិតផលទេសចរណ៍នេះទៀតសោតមិនត្រឹមតែពឹងផ្អែកលើធនធានដែលមានស្រាប់នៅក្នុងតំបន់យកមករៀបចំប៉ុណ្ណោះទេ តែយើងត្រូវធ្វើការរៀបចំបន្ថែមទៀត រាល់ប្រភពសក្តានុពលដែលធ្វើការអភិវឌ្ឍច្នៃប្រតិដ្ឋ ធ្វើពិពិធកម្មឱ្យមានលក្ខណៈផ្សេងៗគ្នាដើម្បីបំពេញតម្រូវការអ្នកទស្សនា ហើយផលិតផលនោះត្រូវតែមានគុណភាពនិងមានលក្ខណៈថ្មីៗហើយប្លែកៗ។ ផលិតផលនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតមួយចំនួនមានលក្ខណៈដដែលៗគ្មានការប្រែប្រួល។ ចំណែកផលិតផលមួយចំនួនថ្មីបើមានការរុករកថ្មី ស្រាវជ្រាវអភិវឌ្ឍន៍បន្ថែមក្តី ក៏ការគ្រប់គ្រងទៅលើផលិតផលនិងការរៀបចំសេវាកម្មទេសចរណ៍មានភាពខ្វះចន្លោះ និងគុណភាពមិនទាន់ប្រសើរដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ភ្ញៀវដែលទាមទារឱ្យមានការខិតខំអភិវឌ្ឍន៍បន្តបន្ថែមទៀត។ វាក៏ជាកត្តាប៉ះពាល់ដល់កំណើនភ្ញៀវទេសចរណ៍ មកកាន់សហគមន៍អេកូទេសចរណ៍ជីផាតផងដែរ។ ដើម្បីអភិវឌ្ឍន៍ផលិតផលទេសចរណ៍អោយកាន់តែសម្បូរបែបទាមទារឱ្យមានការយកចិត្តទុកដាក់គ្រប់ផ្នែក ដូចជា៖ ការអង្កេតពីភាពជាក់ស្តែងនៃការពេញចិត្តរបស់ភ្ញៀវទេសចរណ៍ ការធ្វើបទសម្ភាសន៍ជាមួយមគ្គុទេសក៍ទេសចរណ៍ក្នុងមូលដ្ឋាន អ្នកទទួលភ្ញៀវអោយស្នាក់ និងបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយភ្ញៀវទេសចរណ៍។ មួយផ្សេងទៀត ការអភិវឌ្ឍផលិតផលត្រូវមានគន្លឹះដូចជា៖ ការរចនា កែលម្អ និងធ្វើបច្ចុប្បន្នភាពលើផលិតផលរបស់ខ្លួនជានិច្ច ដើម្បីបង្កើនការពេញចិត្តរបស់អតិថិជន ឬការទាក់ទាញទីផ្សារ ឬទាំងពីរ។ ការស្វែងយល់ និងតាមអោយទាន់សភាពការណ៍នៃការគាំទ្រផលិតផលថ្មីក្នុងទីផ្សារ តាមរយៈការបង្កើនការផ្សព្វផ្សាយផលិតផលថ្មីអោយបានទូលំទូលាយ។ ការបង្ហាញពីភាពលេចធ្លោគោលគំនិតនៃការធ្វើឲ្យផលិតផល ឬសេវារបស់សហគមន៍មានភាពល្អប្លែកពីផលិតផល

ឬសេវាដទៃព្រោះទាំងអស់នេះជាប្រការសំខាន់ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍។ ការកំណត់តម្លៃនៃកញ្ចប់សេវាកម្មទេសចរណ៍ ជាការប្រកួតប្រជែង និងបណ្តាប្រទេសជិតខាងដែលជាចំណុចដ៏សំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរណ៍បន្ថែម។ ការរៀបចំសេវាកម្មល្អ និងមានគុណភាពសម្រាប់បំរើដល់ភ្ញៀវទេសចរណ៍ វាជាយុទ្ធសាស្ត្រមួយក្នុងការទាក់ទាញរាល់គ្រប់ភ្ញៀវទេសចរណ៍ មកកាន់តំបន់។ ការរៀបចំបរិស្ថានស្អាត ការគ្រប់គ្រងកាកសំណល់ ការផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាតថាមពលអគ្គីសនីគ្រប់គ្រាន់ ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចដូចជា៖ បង្គន់អនាម័យសាធារណៈ និងតាមតំបន់រមណីយដ្ឋានទេសចរណ៍ ជាចលករមួយជំរុញដល់ការអភិវឌ្ឍទេសចរណ៍ប្រកបដោយគុណភាពនិងទំនួលខុសត្រូវខ្ពស់។

### ២.៩.៣.២ ការបង្កើតផលិតផលថ្មីនៅក្នុងសហគមន៍

យោងតាមការចុះសិក្សាស្រាវជ្រាវ និងសាកសួរពីសំណាក់ប្រធានសហគមន៍អេកូទេសចរណ៍ជីផាតដោយផ្ទាល់ បានអោយដឹងថា ថ្មីៗនេះ សហគមន៍មានការរៀបចំទិសដៅដើម្បីបង្កើតចំនួនភ្ញៀវទេសចរណ៍អោយកាន់តែច្រើនឡើង ដោយការអភិវឌ្ឍបន្ថែមទៅលើសម្បទាដែលមានស្រាប់អោយកាន់តែប្រសើរឡើងដោយសិក្សាពីចំណុចខ្វះខាតផ្សេងៗដែលបានឆ្លងកាត់នាពេលកន្លងមក។ មិនតែប៉ុណ្ណោះ ថ្មីៗនេះសហគមន៍អេកូទេសចរណ៍ជីផាតក៏បានរកឃើញនូវតំបន់ទឹកជ្រោះថ្មីមួយទៀតដែលមានឈ្មោះថា អូរសាឡៅ ដោយសហគមន៍ផ្ទាល់កំពុងតែធ្វើការសិក្សាផែនការ អភិវឌ្ឍន៍ផ្លូវចូល និងរៀបចំផែនទី ធ្វើយ៉ាងណាស្ថាបនាតំបន់ទឹកជ្រោះមួយនេះអោយក្លាយជាទីពេញចិត្តរបស់ភ្ញៀវទេសចរណ៍។ ក្រៅពីទឹកជ្រោះ សហគមន៍អេកូទេសចរណ៍ជីផាតក៏បានទើបនឹងរកឃើញពាងបុរាណដែលស្ថិតនៅតំបន់ផ្សេងទៀតផងដែរ។ ហើយសហគមន៍នៅតែបន្តរុករកនូវធនធានទាំងអស់នោះមិនឈប់ឈរដើម្បីអោយការបម្រើទេសចរណ៍កាន់តែសម្បូរបែបឡើងៗ។

### ២.៩.៣.៣ ការសិក្សាទីផ្សារទេសចរណ៍របស់សហគមន៍

ផ្អែកតាមការសិក្សាបង្ហាញថាការសិក្សាទីផ្សារបានយ៉ាងលំអិត និងច្បាស់លាស់អំពីតម្រូវការរបស់ទេសចរ ជាផ្នែកមួយជំរុញអោយមានកំណើនភ្ញៀវទេសចរណ៍យ៉ាងឆាប់រហ័ស។ កង្វះខាតខាងការស្រាវជ្រាវ និងការសិក្សាអោយបានស៊ីជម្រៅពីទីផ្សារទេសចរណ៍ដោយកំណត់ប្រភេទភ្ញៀវទេសចរណ៍ដែលយើងចង់ទាក់ទាញពុំទាន់បានល្អ។ ការសិក្សាពីទីផ្សារទេសចរណ៍ យើងត្រូវដឹងពីអត្តសញ្ញាណរបស់ពួកគេ និងដឹងពីមូលហេតុនៃការមកកំសាន្តរបស់ពួកគេច្បាស់លាស់។ ជារួម គឺខិតខំប្រឹងប្រែងយ៉ាងណាក្នុងការធ្វើទីផ្សារដើម្បីទាក់ទាញភ្ញៀវទេសចរណ៍កាន់តែច្រើន ជំរុញឲ្យពួកគេចំណាយពេលច្រើន និងប្រាក់កាក់ច្រើន ជំរុញឲ្យពួកគេត្រឡប់មកជាថ្មី និងជំរុញពួកគេឲ្យជួយផ្សព្វផ្សាយពីតំបន់នោះដល់មិត្តភក្តិ និងគ្រួសាររបស់ខ្លួន។

ជាក់ស្តែងក្នុងសហគមន៍អេកូទេសចរណ៍ជីផាត យើងបានឃើញសហគមន៍អនុវត្តន៍នូវគោលការណ៍សំខាន់ៗនៃការធ្វើទីផ្សារដូចជា៖

- **ថ្លៃ ៖** ក្នុងសហគមន៍មានការកំណត់ថ្លៃសម្រាប់ការចូលទស្សនាកំសាន្ត ដោយបានបែងចែកចេញជា២កម្រិត ដោយថ្លៃមួយគឺសម្រាប់អ្នករស់នៅក្នុងមូលដ្ឋាន ឬភ្ញៀវក្នុងស្រុក ចំណែកថ្លៃមួយទៀតសម្រាប់ភ្ញៀវក្រៅស្រុក(បរទេស) ។ ការគិតគូយ៉ាងល្អិតល្អន់មួយនេះ ត្រូវបានគេសិក្សាឃើញថា ការអោយចូលទ

ស្សនាកន្លែងសំខាន់ៗដោយឥតគិតថ្លៃ ឬថ្លៃទាប មានផលប៉ះពាល់ជាវិជ្ជមានលើការទីផ្សារតំបន់នោះ។ ផ្ទុយទៅវិញ ការអោយចូលទស្សនាអាចជាយន្តការបង្កើតប្រាក់ចំណូលដ៏សំខាន់ ដែលមិនធ្វើអោយប៉ះពាល់ជាអវិជ្ជមានលើទស្សនៈរបស់ភ្ញៀវចំពោះតំបន់ទាក់ទាញភ្ញៀវទេសចរណ៍។ ម្យ៉ាងសហគមន៍មានការកំណត់តម្លៃយ៉ាងច្បាស់ត្រឹមត្រូវដល់ភ្ញៀវទេសចរណ៍ ដែលយើងឃើញមាននូវមជ្ឈមណ្ឌលផ្តល់ព័ត៌មានសហគមន៍ជាសំអាងស្រាប់ ដើម្បីធានាថា មិនមានការកិបកេង ឬបំផ្លើសលើតម្លៃដើមដែលសហគមន៍បានកំណត់នោះទេ និងកាន់តែផ្តល់ភាពងាយស្រួលក្នុងការសម្រេចចិត្តរបស់ទេសចរមុននឹងចង់អោយខាងសហគមន៍បម្រើសេវាកម្មមួយណាដល់ខ្លួន។ រីឯ តម្លៃអាហារ ឬភេសជ្ជៈផ្សេងៗដែលមានដាក់លក់នៅក្នុងតំបន់ផ្ទាល់ គឺស្ថិតក្នុងតម្លៃយ៉ាងសមរម្យ មិនកោរភ្ញៀវ ទោះបីជាមានពិធីបុណ្យទាន ឬការកើនឡើងនៃភ្ញៀវទេសចរណ៍ក៏ដោយក្តី។

- **ទីតាំងៈ** ទីតាំងសំដៅដល់បណ្តាញចែកចាយ នៃរបៀបបញ្ជូនទំនិញ ឬសេវាដល់អតិថិជន។ ដូចដែលបានឃើញជាក់ស្តែងនៅសហគមន៍អេកូទេសចរណ៍ជីផាត គឺបង្កើតអោយមានមជ្ឈមណ្ឌលផ្តល់ព័ត៌មានសម្រាប់ភ្ញៀវទេសចរណ៍ព្រមទាំងនៅខាងក្នុងមានកន្លែងលក់សម្លៀកបំពាក់ វត្ថុអនុស្សាវរីយ៍ ជាច្រើន។
- **ការផ្សព្វផ្សាយៈ** ការផ្សព្វផ្សាយសំដៅដល់ការផ្សាយពាណិជ្ជកម្ម និងសកម្មភាពទាំងអស់នៃការលក់យ៉ាងសកម្ម និងការធ្វើទីផ្សារ ដែលរួមមានគោលគំនិតសំខាន់ទាំងអស់នៃការផ្សព្វផ្សាយពីតំបន់ទាក់ទាញភ្ញៀវទេសចរណ៍។ ចំណែកឯ ការផ្សព្វផ្សាយដែលសហគមន៍បានខិតខំយកចិត្តដាក់ មានទាំងការផ្សព្វផ្សាយក្នុងតំបន់ ផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធើណេត។ ការផ្សព្វផ្សាយក្នុងស្រុក គឺការលើកកំពស់ផលិតផលក្នុងស្រុក ដែលប្រសូត្រចេញពីទឹកដៃផ្ទាល់របស់ប្រជាពលរដ្ឋក្នុងខេត្តយកមកលក់ជូនភ្ញៀវទេសចរណ៍។ ម្យ៉ាងពីការផ្សព្វផ្សាយតាមបណ្តាញអ៊ីនធើណេត ដូចជា ការផ្សព្វផ្សាយតាមគេហទំព័រហ្វេកប៊ុក យូធូបដោយផលិតជាវីដេអូទាក់ទងនឹងសហគមន៍របស់ខ្លួនជាដើម។
- **ផលិតផលៈ** ក្នុងសហគមន៍មានផលិតផល និងសេវាកម្មទាក់ទាញជាច្រើន មិនថាជាធនធានធម្មជាតិ ធនធានវប្បធម៌ ធនធានកែច្នៃ សម្រាប់ធ្វើការផ្គត់ផ្គង់រាល់តម្រូវការរបស់ភ្ញៀវទេសចរណ៍។ លើសពីនេះទៅទៀត សហគមន៍នៅតែបន្តខិតខំប្រឹងប្រែង ស្វែងរកផលិតផលថ្មីៗដើម្បីស្វាគមន៍ភ្ញៀវទេសចរណ៍ជានិច្ច។

ក្រៅពីគោលការណ៍ទាំង៤ខាងលើ សហគមន៍អេកូទេសចរណ៍ជីផាត ក៏បានបន្ថែមនូវគោលការណ៍ធនធានមនុស្ស ដោយព្យាយាមអភិវឌ្ឍន៍ធនធានមនុស្ស អភិវឌ្ឍន៍ឥរិយាបថរបស់អ្នកផ្តល់សេវាកម្ម អោយកាន់តែប្រសើរឡើងជាលំដាប់។

### ២.៩.៣.៤ ការកំណត់ថ្លៃសេវាកម្ម

ជាធម្មតាតាមតំបន់ទេសចរណ៍មួយចំនួននៅក្នុងប្រទេសកម្ពុជា ដោយការដើរទស្សនាផ្ទាល់ តាមការអានសៀវភៅ និងសារព័ត៌មានជាច្រើនបានបង្ហាញថាតំបន់ទេសចរណ៍ មួយចំនួនមានការតំឡើងថ្លៃចំពោះផលិតផល និងសេវាកម្មរបស់ខ្លួន នៅពេលដែលមានបុណ្យជាតិផ្សេងៗ ដូចជាការស្នាក់នៅការធ្វើដំណើរម្ហូប

អាហារ និងសេវាផ្សេងៗទៀត។ កត្តាទាំងនេះ ដោយសារតែប្រជាពលរដ្ឋ និងម្ចាស់អាជីវកម្មខ្វះការយល់ដឹងអំពីការដែលធ្វើយ៉ាងណាទើបមានការរីកចម្រើនក្នុងរយៈពេលយូរនិងចំណេញច្រើន ព្រមទាំងបានផ្ដល់ទំនុកចិត្តជូនភ្ញៀវហើយ និងបានការត្រឡប់មកទទួលយកសេវាកម្ម យើងម្តងទៀត។ ដោយមានការតំឡើងថ្លៃបែបនេះ ហើយទើបធ្វើឲ្យប្រទេសជាតិបាត់បង់ភាពទុកចិត្តពីសំណាក់ភ្ញៀវទេសចរណ៍ ទាំងជាតិ និងអន្តជាតិ។ ចំណែកចំពោះសហគមន៍អេកូទេសចរណ៍ជីផាត បើតាមការសិក្សានិងស្រាវជ្រាវ កន្លងមកយើងសង្កេតឃើញថា សហគមន៍មានការគ្រប់គ្រងបានយ៉ាងល្អ មិនមានការដំឡើងថ្លៃ និងសេវាកម្មល្អ ដោយមានការបណ្តុះបណ្តាលប្រជាជននិងម្ចាស់អាជីវកម្មផ្ទាល់ដែលមិនការតំឡើងថ្លៃទេចំពោះ ផលិតផល និងសេវាកម្មដូចជា ការលក់សំបុត្រទស្សនាម្ហូបអាហារក្នុងសហគមន៍ ការជិះទូកសុទ្ធតែមានតម្លៃសមរម្យ។

### ២.៩.៤ ការអភិរក្ស និងគ្រប់គ្រងធនធានរបស់សហគមន៍

ដោយមើលឃើញរយៈពេលវែងការអភិវឌ្ឍវិស័យទេសចរណ៍ធម្មជាតិត្រូវគិតគូដល់ការងារគ្រប់គ្រងព្រមទាំងអភិរក្សធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព។ ធនធានជាច្រើនត្រូវបានមើលឃើញថាកំពុងទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារមិនមានប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងពុំទាន់មានយន្តការច្បាស់លាស់។ ការទទួលរងប៉ះពាល់ពីការជ្រៀតជ្រែងចូលនូវប្បធម៌ ទំនៀមទំលាប់ប្រពៃណីផ្សេងៗ ដល់ប្រជាជនមូលដ្ឋាន ក៏ជាបញ្ហាចោទដល់យើងទាំងអស់គ្នាត្រូវយកចិត្តទុកដាក់លើកិច្ចការពារ ថែរក្សានិងអភិរក្សផងដែរ។ ការជំរុញអោយមានការទទួលខុសត្រូវខ្ពស់ពីភាគីពាក់ព័ន្ធ ដើម្បីស្វែងរកយុទ្ធសាស្ត្ររយៈពេលខ្លី និងវែងក្នុងគោលបំណងរៀបចំយុទ្ធសាស្ត្រដើម្បីគ្រប់គ្រងអភិរក្សសម្បត្តិធនធានធម្មជាតិ ធនធានវប្បធម៌ដែលមានស្រាប់និងការលើកកម្ពស់ក្នុងការអភិវឌ្ឍទេសចរណ៍ប្រកបដោយប្រសិទ្ធភាពស្ថេរភាព និងមានការទទួលខុសត្រូវ។

#### ២.៩.៤.១ ការការពារ អភិរក្សធនធានធម្មជាតិ បរិស្ថាន

ដោយសារនៅតំបន់ជីផាត គឺជាប្រភេទបែបអេកូទេសចរណ៍។ ហេតុនេះរាជរដ្ឋាភិបាល ក្រសួងពាក់ព័ន្ធនានា សហគមន៍ចូលរួមគ្នាការពារ និងអភិរក្សធនធានធម្មជាតិ ព្រៃឈើនិងសត្វព្រៃ រួមនឹងជីវៈចម្រុះជាច្រើនទៀតនៅក្នុងតំបន់ព្រៃសហគមន៍អេកូទេសចរណ៍ជីផាតអោយគង់វង្ស។ សហគមន៍អេកូទេសចរណ៍ជីផាត បានយកចិត្តទុកដាក់រៀបចំចាត់ចែងបែងចែកក្រុមល្បាតការពារធនធានធម្មជាតិក្នុងតំបន់ជីផាតរហូតដល់៨គ្រួសារ ពួកគាត់សុទ្ធសឹងជាបុរសទាំងអស់ ដែលក្នុង១គ្រួសារមានការប្តូរវេនគ្នា៥ថ្ងៃម្តង ក្នុងការទទួលខុសត្រូវគ្រប់គ្រងឃ្លាំមើលអ្នកលួចកាប់បំផ្លាញព្រៃឈើយ៉ាងតឹងរឹង ម៉ត់ចត់ជាទីបំផុត ក៏ដូចជារាយការណ៍ពីស្ថានភាពជាក់ស្តែងក្នុងព្រៃមានលក្ខណៈបែបណា។ សហគមន៍ក៏បានដាក់ចេញនូវបម្រាមមួយចំនួនក្នុងការហាមឃាត់មិនអោយមានការបរបាញ់សត្វខុសច្បាប់នៅក្នុងសហគមន៍ ការហាមមិនអោយប្រើប្រាស់ឧបករណ៍ខុសច្បាប់ផ្សេងៗដែលអាចបំផ្លាញដល់ប្រព័ន្ធអូហ្សូន។ សហគមន៍អេកូទេសចរណ៍ជីផាតក៏មានការជួយគាំទ្រពីអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ដែលបានឧបត្ថម្ភនូវផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុទៅដល់សហគមន៍ក្នុងគោលបំណងជួយការពារប្រព័ន្ធអេកូឡូស៊ី ពីការប្រមាញ់សត្វព្រៃ និងការកាប់បំផ្លាញព្រៃឈើខុសច្បាប់ផងដែរ។

#### ២.៩.៤.២ ការការពារ អភិរក្សធនធានវប្បធម៌

នៅឯសហគមន៍អេកូទេសចរណ៍ជីផាតមិនត្រឹមតែមាននូវសម្បត្តិធម្មជាតិ ដែលបានផុសឡើងអោយឃើញយ៉ាងច្បាស់នោះទេ ក៏ប៉ុន្តែនៅទីនេះក៏មាននូវសម្បត្តិវប្បធម៌ដ៏មានតម្លៃកប់ទុករាប់រយឆ្នាំផងដែរ គឺពាងបូរាណ ម្ឈូសបូរាណរបស់មនុស្សជំនាន់មុនដែលបានបន្សល់ទុកក្នុងតំបន់នេះ ហើយសុទ្ធសឹងជាបេតិកភណ្ឌ។ សម្បត្តិទាំងអស់ត្រូវបាន ក្រុមអភិរក្ស ធនធានវប្បធម៌និងវិចិត្រសិល្បៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចូលរួម ថែរក្សាការពារ។ ក្នុងនោះផងដែរ សហគមន៍បានរៀបចំជារបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំជូនទៅក្រសួងដោយផ្ទាល់ ឬប្រសិនបើមានបញ្ហាណាមួយកើតមានឡើងលើធនធានវប្បធម៌ទាំងអស់នោះសហគមន៍នឹងរាយការណ៍ជូនទៅកាន់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈអោយចុះមកត្រួតពិនិត្យភ្លាម។

### ២.៩.៥ ការផ្សព្វផ្សាយរបស់សហគមន៍

#### ២.៩.៥.១ យុទ្ធសាស្រ្តជម្រុញ ផ្សព្វផ្សាយទីផ្សារក្នុងស្រុក

ការធ្វើយុទ្ធសាស្រ្តជម្រុញលើការផ្សព្វផ្សាយទីផ្សារទេសចរណ៍ក្នុងស្រុក ជាមធ្យោបាយដ៏ល្អឥតខ្ចោះមួយ ដែលជួយសម្រួលភាពតានតឹងសង្គម ដោយអនុញ្ញាតឱ្យប្រជាជនដែលមានចំណូលទាប ដែលមិនមានលទ្ធភាពអាចធ្វើដំណើរកម្សាន្តទៅក្រៅប្រទេស អាចមានឱកាសធ្វើដំណើរលំហែកាយ និងសម្រាកតាមរមណីយដ្ឋាននានានៅក្នុងស្រុក។ ចលនានៃការផ្សព្វផ្សាយទេសចរណ៍ក្នុងស្រុកនេះ ជាឧបករណ៍ធ្វើឱ្យតំបន់ទេសចរណ៍ថ្មីៗ ឬមិនសូវមានភាពល្បីល្បាញទទួលបានការចាប់អារម្មណ៍ និងដំណើរការទៅមុខសម្រាប់បម្រើឱ្យវិស័យទេសចរណ៍។

ស្របជាមួយគ្នានេះដែរ ដើម្បីអោយទីផ្សារទេសចរណ៍ក្នុងតំបន់សហគមន៍មានភាពលូតលាស់ មានមនុស្សម្នាស្គាល់ ច្រើនអ្វីដែលត្រូវធ្វើនោះគឺ ការផ្សព្វផ្សាយទៅដល់ប្រជាជនទាំងក្នុងតំបន់ និងក្រៅតំបន់អោយបានស្គាល់តាមរយៈការឧស្សាហ៍ផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យានានា តួយ៉ាង បណ្តាញសង្គម យូធូប កាសែតទស្សនាវដ្តី ទូរទស្សន៍ ឬមួយក៏ប្រើយុទ្ធសាស្រ្តផ្សេងៗស្របតាមស្ថានភាពជាក់ស្តែងផ្ទាល់។ លើសពីនេះទៅទៀត សហគមន៍ក៏គួរមានយុទ្ធសាស្រ្តរៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ អោយកាន់តែមានភាពងាយស្រួលក្នុងការធ្វើដំណើរ សម្រាប់អោយភ្ញៀវងាយស្រួលក្នុងការធ្វើដំណើរទស្សនា ពេលមកកំសាន្តហើយមានអារម្មណ៍ស្រស់ស្រាយ មានបំណងចង់មកម្តងទៀត និងជួយផ្សព្វផ្សាយផលិតផលខ្លួនទៅកាន់ទេសចរដទៃ។

#### ២.៩.៥.២ ការជម្រុញការផ្សព្វផ្សាយទាក់ទាញទេសចរណ៍

##### ក. ការបង្កើតសកម្មភាពផ្សព្វផ្សាយទេសចរណ៍នានា

ការផ្សព្វផ្សាយមានច្រើនប្រភេទ និងមានរបៀបទៅតាមសភាពការណ៍ក៏ដូចជានិន្នាការទីផ្សារ និងគោលដៅទេសចរណ៍ដើម្បីធ្វើការផ្សព្វផ្សាយបានគឺអាស្រ័យទៅលើលទ្ធភាពនៃធនធានហិរញ្ញវត្ថុ និងធនធានមនុស្សតំបន់សក្តានុពលដើម្បីអោយភ្ញៀវទេសចរណ៍បានដឹង និងទទួលជ្រាបពីព័ត៌មាន។ តួយ៉ាង សហគមន៍អេកូទេសចរណ៍ជីផាតនាពេលកន្លងមកបានធ្វើនូវសកម្មភាពផ្សព្វផ្សាយស្របតាមយុទ្ធសាស្រ្តរបស់សហគមន៍ផ្ទាល់គួបផ្សំនឹងយន្តការរបស់ក្រសួងទេសចរណ៍៖

- បានផ្តល់ព័ត៌មានឯកសារនិងផែនទីផ្សព្វផ្សាយទេសចរជាតិ និងអន្តរជាតិក្នុងមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍។
- ការផ្សព្វផ្សាយពីក្រសួងទេសចរណ៍ អំពីរមណីយដ្ឋាន រឺតំបន់ទាក់ទាញ
- ការលើកទឹកចិត្តអោយមានការផ្សព្វផ្សាយបន្តតាមរយៈទេសចរដែលធ្លាប់បានមកទស្សនាហើយ
- ការបញ្ចូលទៅក្នុងតំបន់សហគមន៍ដែលត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍។

**ខ. បង្កើតប្រព័ន្ធការផ្សព្វផ្សាយតាមប្រព័ន្ធសារអេឡិចត្រូនិក និងគេហទំព័រ**

- ការបង្កើតអោយមានផេក (page ) និងគេហទំព័រ ឬប្រព័ន្ធផ្សព្វផ្សាយផ្ទាល់ខ្លួនរបស់សហគមន៍
- ការថតយករូបភាព ក្នុងតំបន់សហគមន៍ទាំងមូលដើម្បីចែកចាយនៅក្នុងប្រព័ន្ធអ៊ីនធឺណេត
- ការបង្កើតជាវីដេអូ ផ្សព្វផ្សាយនិងបង្ហាញពីតំបន់កំសាន្តទាំងមូល
- ការសរសេរពិពណ៌នាអំពីដើមកំណើត ស្ថានភាពទូទៅ និងភាពទាក់ទាញរបស់តំបន់កំសាន្ត
- ការជំរុញនិងលើកទឹកចិត្តអោយមានការផ្សព្វផ្សាយតាមរយៈការផុសនៅក្នុងប្រព័ន្ធ Facebook Instagram YouTube Google ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតរបស់ភ្ញៀវទេសចរណ៍ដែលធ្លាប់បានមកកំសាន្ត។

### ២.៩.៥.៣ ការបង្កើតព្រឹត្តិការណ៍ផ្សេងៗ

តាមរយៈការចុះស្រាវជ្រាវនិងតាមរយៈការសំភាសន៍ផ្ទាល់ជាមួយ នឹងប្រធានសហគមន៍ក៏ដូចជាបុគ្គលិកផ្ទាល់នៅទីនោះ គឺបានបញ្ជាក់នឹងពិពណ៌នាអំពីព្រឹត្តិការណ៍ជាច្រើនដែលបានធ្លាប់និងតែងតែប្រារព្វធ្វើឡើងនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតផ្ទាល់។ ទោះបីជាយ៉ាងណាក៏ដោយរាល់គម្រោង ឬព្រឹត្តិការណ៍ដែលបាននឹងប្រារព្វឡើង គឺត្រូវបានចូលរួមគាំទ្រយ៉ាងខ្លាំងពីសំណាក់ដៃគូពាក់ព័ន្ធរដ្ឋាភិបាល និងប្រជាជននៅក្នុងសហគមន៍ផ្ទាល់ តែក៏ដូចជាអ្នកដែលមានតួនាទីគ្រប់គ្រងនៅទីនោះផ្ទាល់តែម្តង។ ព្រឹត្តិការណ៍ទាំងនោះផងដែររួមមាន៖

**ក.ការបោះជំរុំ**

សហគមន៍អេកូទេសចរណ៍ជីផាត គឺជាតំបន់ទេសចរណ៍ធម្មជាតិមួយដែលដែលស្ថិតនៅក្នុងខេត្តកោះកុងដែលមានភាពទាក់ទាញ ហើយជាកន្លែងមួយដែលប្រមូលផ្តុំទៅដោយធម្មជាតិដ៏ស្រស់បំព្រង ដែលគួរអោយចាប់អារម្មណ៍ផងដែរ។ ហើយអ្វីដែលពិសេសជាងនេះទៅទៀត នៅក្នុងសហគមន៍ក៏ធ្លាប់មានការបង្កើតនូវកម្មវិធីបោះជំរុំ។ ដោយសារនៅក្នុងព្រៃមានទីធ្លាធំទូលាយដែលវាពិតជាអំណោយផលខ្លាំងសម្រាប់ផ្តល់ជូនដល់ទេសចរ ដែលមានបំណងចង់ធ្វើការបោះជំរុំ រឺបោះតង់នៅទីនោះផ្ទាល់តែម្តង។ គោលបំណងនៃការបង្កើតឡើងនូវកម្មវិធីបោះតង់ ឬបោះជំរុំនេះផងដែរ ត្រូវបានប្រធានសហគមន៍អេកូទេសចរណ៍ជីផាតប្រាប់អោយដឹងថា គឺដើម្បីផ្តល់ឱកាសឱ្យយុវជនដែលចាប់អារម្មណ៍ចំពោះសកម្មភាពការពារធនធានធម្មជាតិ និងយុវជនបរិស្ថានបានសិក្សាឈ្វេងយល់អំពី គោលគំនិតនៃភាពជាអ្នកដឹកនាំរួម ការចងក្រងសហគមន៍ សិទ្ធិបរិស្ថាន សិទ្ធិចូលរួមរបស់យុវជននិងសហគមន៍ក្នុងដំណើរការអភិវឌ្ឍក្នុងកិច្ចការពារធនធានធម្មជាតិ និងបរិស្ថាន។ និងដើម្បីផ្តល់ឱកាសឱ្យអ្នកចូលរួម និងសហគមន៍ធ្វើការចែករំលែកចំណេះដឹង និងកសាងបណ្តាញសម្រាប់ការធ្វើការងាររួមគ្នា

នៅពេលអនាគត។ ព្រមទាំងផ្តល់ឱកាសឱ្យយុវជនបានសិក្សាឈ្វេងយល់អំពីសហគមន៍អេកូទេសចរណ៍ជីផាត និងបន្តការផ្សព្វផ្សាយអំពីសក្តានុពលនៃតំបន់ជីផាតទៅប្រជាពលរដ្ឋ និងយុវជនផ្សេងទៀត។ អ្នកដែលបានមកធ្វើការបោះជំរុំនៅទីនោះភាគច្រើនជា ក្រុមអ្នកដើរផ្សងព្រេងលក្ខណៈជាក្រុមគ្រួសារ និងខ្លះលក្ខណៈជាក្រុមការងារ ក្រុមនិស្សិតតែម្តង។ យ៉ាងណាមិញទេសចរជាតិ និងអន្តរជាតិពិតជាមានការពេញចិត្ត និងសប្បាយរីករាយយ៉ាងខ្លាំងក្នុងការបោះតង់ ឬដែលយើងហៅថាការបោះជំរុំនៅទីនោះ ដោយបានរួមបញ្ចូលជាមួយនឹងអាកាសធាតុដែលអំណោយផល និងទេសភាពដ៏ស្រស់បំព្រង ទេសភាពទាំងនេះគឺជាហេតុធ្វើអោយពួកគេចង់ធ្វើការបោះតង់ដោយគេអាចរំសាយនូវភាពតានតឹងនិងទុក្ខកង្វល់ទាំងប៉ុន្មានរបស់ពួកគេ។

### ខ. ការដាំដើមឈើ

ដោយសារនៅជុំវិញតំបន់ជីផាត គឺពោពេញទៅដោយធនធានធម្មជាតិដ៏ទាក់ទាញ និងមើលឃើញពីអត្ថប្រយោជន៍របស់វាទាំងនោះ ប្រធានសហគមន៍អេកូទេសចរណ៍ជីផាតបានប្រារព្ធនូវកម្មវិធីដាំដើមឈើ និងផ្សព្វផ្សាយដល់សាធារណជនអោយបានចូលរួម។ ការប្រារព្ធទិវានេះ គឺជាការឆ្លុះបញ្ចាំងឲ្យឃើញនូវការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់យើងទាំងអស់គ្នា ក្នុងការស្តារគម្របព្រៃឈើឡើងវិញឲ្យមានពណ៌បៃតង និងដើម្បីរក្សាបាននូវការប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈម និងជាកង្វល់រួមដ៏ធំមួយរបស់ពិភពលោក។ ម្យ៉ាងវិញទៀតការដាំដើមឈើ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយថែរក្សាដំណើរការប្រព័ន្ធអេកូឡូស៊ី តាមរយៈការជួយធ្វើនិយ័តកម្មអាកាសធាតុ ជួយកាត់បន្ថយឥទ្ធិពលអវិជ្ជមាន នៃការប្រែប្រួលអាកាសធាតុ ដូចជាទឹកជំនន់ ខ្យល់ព្យុះ និងការស្រូបយកឧស្ម័នកាបូនិចពីបរិយាកាស។

### គ. ពិព័រណ៍ទេសចរណ៍

សហគមន៍អេកូទេសចរណ៍ជីផាត បានចូលរួមក្នុងកម្មវិធីពិព័រណ៍ទេសចរណ៍ថ្នាក់ខេត្តជាច្រើន ដូចជាពិធីបុណ្យសមុទ្រ ពិធីបុណ្យអុំទូក ដើម្បីចូលរួមផ្សព្វផ្សាយពីសក្តានុពលអេកូទេសចរណ៍ក្នុងតំបន់របស់ខ្លួនក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ទាំងជិត ឆ្ងាយអោយកាន់តែស្គាល់ យល់ច្បាស់ និងចង់ទៅទស្សនាកំសាន្តទីនោះកាន់តែច្រើនឡើងថែមទៀត។ បានទៅទស្សនាកំសាន្តទីណាមួយ ពួកគាត់មានតួនាទីសំខាន់ណាស់សម្រាប់ធ្វើអោយតំបន់នោះក្លាយជាតំបន់ទេសចរណ៍។ ការចូលរួមពីទេសចរ គឺជាផ្នែកមួយក្នុងការជួយអោយតំបន់ទេសចរណ៍។

# ជំពូកទី៣

# ការវិភាគលើលទ្ធផលនៃរបកគំហើញ

## ៣.១ វិភាគលើកម្រងសំណួរ

ក្នុងការសិក្សាវិភាគប្រមូលទិន្នន័យនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត ក្រុមសិក្សាស្រាវជ្រាវរបស់យើងបានធ្វើការបង្កើតនូវកម្រងសំណួរដើម្បីធ្វើការសាកសួរទៅកាន់ទេសចរជាតិ អន្តរជាតិដែលមកកំសាន្ត ព្រមជាមួយនឹងការសម្ភាសន៍ប្រធានសហគមន៍ និងប្រជាជនដែលបានចូលរួមចំណែកបំពីសេវាកម្មជូនដល់ភ្ញៀវទេសចរណ៍នៅសហគមន៍អេកូទេសចរណ៍ជីផាត។ ចំពោះទិន្នន័យដែលយកមកវិភាគគឺត្រូវបានជ្រើសរើសជាប៉ាន់គម្រូដែលនៅក្នុងការសម្ភាសន៍ផ្ទាល់ជាមួយនឹងប្រធានសហគមន៍ ០១នាក់ ព្រមទាំងប្រជាជន និងទេសចរ ៣០នាក់ផ្សេងទៀត អំពីភាពទាក់ទាញរបស់សហគមន៍អេកូទេសចរណ៍ជីផាត កម្រិតសេវាកម្មនៅតាមកន្លែងផ្តល់សេវាកម្មនីមួយៗ ភាពពេញចិត្តរបស់ទេសចរចំពោះសេវាកម្ម ព្រមទាំងបរិស្ថានជុំវិញនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតទាំងមូល។

### ៣.១.១ វិភាគលើភេទនៃទេសចរ

ក្រាភិចទី៣.១ ដែលធ្វើការវិភាគទៅលើភេទទេសចរ




តាមក្រាភិចបានបង្ហាញក្នុងចំណោមទេសចរ៣០នាក់មាន៖

- មានភ្ញៀវទេសចរណ៍ចំនួន ១១នាក់ស្មើនឹង ៣៧ភាគរយ ជាភេទស្រី
- មានភ្ញៀវទេសចរណ៍ចំនួន ១៩នាក់ ស្មើនឹង ៦៣ភាគរយ ជាភេទប្រុស

### ៣.១.២ វិភាគលើអាយុទេសចរ

ក្រាភិចទី៣.២ ដែលវិភាគទៅលើអាយុនៃទេសចរ




តាមក្រាភិចបានបង្ហាញក្នុងចំណោមភ្ញៀវទេសចរណ៍៣០នាក់មានភ្ញៀវចំនួន៖

- មានភ្ញៀវទេសចរណ៍អាយុចន្លោះពី ១៨-២៥ឆ្នាំចំនួន ២៥នាក់ស្មើនឹង ៨៣ភាគរយ
- មានភ្ញៀវទេសចរណ៍អាយុចន្លោះពី ២៦-៣០ឆ្នាំចំនួន ៥នាក់នាក់ ស្មើនឹង ១៧ភាគរយ

### ៣.១.៣ វិភាគទៅលើភ្ញៀវធ្លាប់ទៅកំសាន្តនៅសហគមន៍អេកូទេសចរណ៍ជីផាត

ក្រាភិចទី ៣.៣ ដែលធ្វើការវិភាគទៅលើទេសចរដែលធ្លាប់ទៅសហគមន៍អេកូទេសចរណ៍ជីផាត

តាមក្រាភិចបានបង្ហាញថា៖



ក្នុងចំណោមភ្ញៀវទេសចរណ៍៣០នាក់ ភ្ញៀវ១១នាក់ ស្មើនឹង៣៧ភាគរយ ដែលយើងបានធ្វើការសម្ភាសន៍គាត់ តែគាត់ពុំបានទៅដល់សហគមន៍អេកូទេសចរណ៍ជីផាតនោះទេ។

- អ្នកដែលមិនធ្លាប់ទៅលេងសហគមន៍អេកូទេសចរណ៍ជីផាតមានចំនួន១១នាក់ ស្មើនឹង ៣៧ភាគរយ
- អ្នកដែលធ្លាប់ទៅលេងសហគមន៍អេកូទេសចរណ៍ជីផាតមានចំនួន ១៩នាក់ ស្មើនឹង ៦៣ភាគរយ

### ៣.១.៤ វិភាគទៅលើភ្ញៀវដែលទៅសហគមន៍អេកូទេសចរណ៍ជីផាតតាមរយៈអ្នកណា

ក្រាភិច ៣.៤ ដែលធ្វើការវិភាគទៅលើភ្ញៀវដែលទៅសហគមន៍អេកូទេសចរណ៍ជីផាតជាមួយអ្នកណា




តាមក្រាភិចបានបង្ហាញថា៖

- មានភ្ញៀវចំនួន ១៥នាក់ ស្មើនឹង ៧៨,៣ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានស្គាល់សហគមន៍អេកូទេសចរណ៍ជីផាតតាមរយៈបណ្ដាញសង្គម
- មានភ្ញៀវចំនួន ៣នាក់ ស្មើនឹង ១៧,៤ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានស្គាល់សហគមន៍អេកូទេសចរណ៍ជីផាតតាមរយៈមិត្តភក្តិ ឬសាច់ញាតិ
- មានភ្ញៀវចំនួន ១នាក់ ស្មើនឹង ៤,៣ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានស្គាល់សហគមន៍អេកូទេសចរណ៍ជីផាតតាមរយៈទស្សនាវដ្តី

### ៣.១.៥ វិភាគលើមធ្យោបាយធ្វើដំណើររបស់ភ្ញៀវទេសចរណ៍

ក្រាភិច៣.៥ ដែលធ្វើការវិភាគលើមធ្យោបាយធ្វើដំណើររបស់ភ្ញៀវទេសចរណ៍




តាមក្រាភិចបានបង្ហាញថា៖

- ✓ សម្រាប់ភ្ញៀវដែលធ្វើដំណើរដោយរថយន្តផ្ទាល់ខ្លួនមានចំនួន ៩នាក់ ស្មើនឹង៤៥.៥ភាគរយក្នុងចំណោមទេសចរ១៩នាក់ ដែលធ្លាប់បានទៅដល់សហគមន៍
- ✓ សម្រាប់ភ្ញៀវដែលធ្វើដំណើរដោយរថយន្តដឹកអ្នកដំណើរមានចំនួន៣នាក់ ស្មើនឹង ១៨.២ភាគរយក្នុងចំណោមទេសចរ១៩នាក់ដែលធ្លាប់បានទៅដល់សហគមន៍
- ✓ សម្រាប់ភ្ញៀវដែលធ្វើដំណើរដោយឡានក្រុងមានចំនួន៥នាក់ ស្មើនឹង ២៧,៣ភាគរយក្នុងចំណោមទេសចរ១៩នាក់ដែលធ្លាប់បានទៅដល់សហគមន៍
- ✓ សម្រាប់ភ្ញៀវដែលធ្វើដំណើរដោយម៉ូតូមានចំនួន២នាក់ ស្មើនឹង ១៨,២ភាគរយក្នុងចំណោមទេសចរ១៩នាក់ដែលធ្លាប់បានទៅដល់សហគមន៍

### ៣.១.៦ វិភាគទៅលើគោលបំណងនៃភ្ញៀវដែលមកកំសាន្ត

តាមក្រាភិច ៣.៦ ដែលធ្វើការវិភាគទៅលើគោលបំណងនៃភ្ញៀវដែលមកកំសាន្ត



តាមក្រាភិចបានបង្ហាញថា៖

- មានភ្ញៀវទេសចរណ៍ទៅកំសាន្តនៅទីនេះក្នុងគោលបំណងសិក្សាស្រាវជ្រាវ ចំនួន ២នាក់ ស្មើនឹង១០ ភាគរយក្នុងចំណោមទេសចរ ១៩នាក់ ដែលធ្លាប់ទៅដល់សហគមន៍ផ្ទាល់
- មានភ្ញៀវទេសចរណ៍ទៅកំសាន្តនៅទីនេះក្នុងគោលបំណងលំហែកំសាន្តចំនួន ១៧នាក់ ស្មើនឹង៩០ ភាគរយក្នុងចំណោមទេសចរ ១៩នាក់ ដែលបានទៅដល់សហគមន៍ផ្ទាល់

### ៣.១.៧ វិភាគលើចំនួនដងដែលភ្ញៀវបានមកកំសាន្ត

ក្រាភិច៣.៧ ដែលធ្វើការវិភាគទៅលើចំនួនដងដែលភ្ញៀវបានមកកំសាន្ត




តាមក្រាភិចបានបង្ហាញថា៖

- ភ្ញៀវទេសចរណ៍ទៅកំសាន្តនៅទីនេះ១ដង ចំនួន ១៥នាក់ ស្មើនឹង ៨២ភាគរយក្នុងចំណោមទេសចរ ១៩នាក់ដែលធ្លាប់ទៅដល់សហគមន៍ផ្ទាល់
- ភ្ញៀវទេសចរណ៍ទៅកំសាន្តនៅទីនេះ២ដងចំនួន ២នាក់ ស្មើនឹង ៩ភាគរយក្នុងចំណោមទេសចរ១៩ នាក់ដែលបានទៅដល់សហគមន៍ផ្ទាល់
- ភ្ញៀវទេសចរណ៍ទៅកំសាន្តនៅទីនេះ៣ដងចំនួន ២នាក់ ស្មើនឹង ៩ភាគរយក្នុងចំណោមទេសចរ១៩ នាក់ដែលបានទៅដល់សហគមន៍ផ្ទាល់

### ៣.១.៨ វិភាគនៅលើចំនួនថ្ងៃដែលភ្ញៀវមកកំសាន្ត

ក្រាភិច៣.៨ ដែលវិភាគលើចំនួនថ្ងៃដែលភ្ញៀវមកកំសាន្ត




តាមក្រាភិចបានបង្ហាញថាៈ

- ភ្ញៀវទេសចរណ៍ទៅសម្រាកកំសាន្តនៅទីនេះ១ថ្ងៃ ចំនួន ៥នាក់ ស្មើនឹង២៧,៣ភាគរយក្នុងចំណោមទេសចរ១៩នាក់ដែលធ្លាប់ទៅដល់សហគមន៍ផ្ទាល់
- ភ្ញៀវទេសចរណ៍ទៅសម្រាកកំសាន្តនៅទីនេះ២ថ្ងៃចំនួន ៧នាក់ ស្មើនឹង៣៦.៤ភាគរយក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅដល់សហគមន៍ផ្ទាល់
- ភ្ញៀវទេសចរណ៍ទៅសម្រាកកំសាន្តនៅទីនេះ៣ថ្ងៃចំនួន ៧នាក់ ស្មើនឹង៣៦.៤ភាគរយក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅដល់សហគមន៍ផ្ទាល់

### ៣.១.៩ វិភាគទៅលើពេលវេលាដែលភ្ញៀវមកកំសាន្ត

ក្រាភិច៣.៩ ដែលធ្វើការវិភាគទៅលើពេលវេលាដែលភ្ញៀវមកកំសាន្ត



តាមក្រាភិចបានបង្ហាញថាៈ

- មានភ្ញៀវចំនួន ៦នាក់ ស្មើនឹង ៣២,៣ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតក្នុងឱកាសបុណ្យជាតិ
- មានភ្ញៀវចំនួន ៩នាក់ ស្មើនឹង ៤៩,៣ភាគរយក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតក្នុងឱកាសថ្ងៃឈប់សម្រាក
- មានភ្ញៀវចំនួន ៤នាក់ ស្មើនឹង ១៧,៤ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតក្នុងឱកាសវិស្សមកាល

### ៣.១.១០ វិភាគទៅលើលក្ខណៈភ្ញៀវមកកំសាន្តជាមួយ

ក្រាភិច៣.១០ ដែលធ្វើការវិភាគទៅលើលក្ខណៈភ្ញៀវមកកំសាន្តជាមួយ




តាមក្រាភិចបានបង្ហាញថាៈ

- មានភ្ញៀវចំនួន ១នាក់ ស្មើនឹង ១០ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតតែម្នាក់ឯង
- មានភ្ញៀវចំនួន ៧នាក់ ស្មើនឹង ៣០ភាគរយក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតជាមួយមិត្តភ័ក្តិ
- មានភ្ញៀវចំនួន ៨នាក់ ស្មើនឹង ៤០ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតជាមួយក្រុមគ្រួសារ
- មានភ្ញៀវចំនួន ៣នាក់ ស្មើនឹង ២០ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតតាមរយៈក្រុមហ៊ុនទេសចរណ៍

### ៣.១.១១ វិភាគទៅលើស្ថានភាពផ្លូវធ្វើដំណើរទៅកាន់សហគមន៍

ក្រាភិច៣.១១ ដែលធ្វើការវិភាគទៅលើស្ថានភាពផ្លូវធ្វើដំណើរទៅកាន់សហគមន៍




តាមក្រាភិចបានបង្ហាញថា៖

- ✓ មានភ្ញៀវចំនួន ១២នាក់ ស្មើនឹង ៦៣,៦ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតយល់ថាស្ថានភាពផ្លូវធ្វើដំណើរនៅទីនោះធម្មតា
- ✓ មានភ្ញៀវចំនួន ៣នាក់ ស្មើនឹង ១៨,២ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតយល់ថាស្ថានភាពផ្លូវធ្វើដំណើរនៅទីនោះលំបាក
- ✓ មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ៩,១ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតយល់ថាស្ថានភាពផ្លូវធ្វើដំណើរនៅទីនោះលំបាកខ្លាំង
- ✓ មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ៩,១ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតយល់ថាស្ថានភាពផ្លូវធ្វើដំណើរនៅទីនោះល្អ

### ៣.១.១២ វិភាគទៅលើប្រភេទនៃការទទួលទានអាហាររបស់ភ្ញៀវ

ក្រាភិច៣.១២ ដែលធ្វើការវិភាគទៅលើប្រភេទនៃការទទួលទានអាហាររបស់ភ្ញៀវ




តាមក្រាភិចបានបង្ហាញថា៖

- មានភ្ញៀវចំនួន ១២នាក់ ស្មើនឹង ៦៥ភាគរយ ក្នុងចំណោមទេសចរ ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតទទួលទានអាហាររបស់ផ្ទះសហគមន៍
- មានភ្ញៀវចំនួន ០៣នាក់ ស្មើនឹង ១៥ភាគរយ ក្នុងចំណោមទេសចរ ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតទទួលទានអាហារនៅអាហារដ្ឋាន
- មានភ្ញៀវចំនួន ៤នាក់ ស្មើនឹង ២០ភាគរយ ក្នុងចំណោមទេសចរ ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតទទួលទានអាហារដោយធ្វើខ្លួនឯងផ្ទាល់

### ៣.១.១៣ វិភាគទៅលើការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត

ក្រាភិច៣.១៣ ដែលធ្វើការវិភាគទៅលើការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត



តាមក្រាភិចបានបង្ហាញថា៖

- មានភ្ញៀវចំនួន ១២នាក់ ស្មើនឹង ៦៥ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតយល់ឃើញថា ការគ្រប់គ្រងនៅក្នុងសហគមន៍មានលក្ខណៈល្អ
- មានភ្ញៀវចំនួន ៩នាក់ ស្មើនឹង ៣៥ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតយល់ឃើញថា ការគ្រប់គ្រងនៅក្នុងសហគមន៍មានលក្ខណៈមធ្យម

### ៣.១.១៤ វិភាគទៅលើធនធានទាក់ទាញនៅក្នុងសហគមន៍

ក្រាភិច៣.១៤ ដែលធ្វើការវិភាគទៅលើធនធានទាក់ទាញនៅក្នុងសហគមន៍




តាមក្រាភិចបានបង្ហាញថា៖

- មានភ្ញៀវចំនួន ១០នាក់ ស្មើនឹង ៥៤,៥ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតយល់ឃើញថា នៅក្នុងសហគមន៍មានធនធានទាក់ទាញខ្លាំង
- មានភ្ញៀវចំនួន ៩នាក់ ស្មើនឹង ៤៥,៥ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតយល់ឃើញថា នៅក្នុងសហគមន៍មានធនធានទាក់ទាញ។

### ៣.១.១៥ វិភាគទៅលើការគ្រប់គ្រងកាកសំណល់នៅក្នុងសហគមន៍

ក្រាភិច៣.១៥ ដែលធ្វើការវិភាគទៅលើការគ្រប់គ្រងកាកសំណល់នៅសហគមន៍




តាមក្រាភិចបានបង្ហាញថា៖

- ❖ មានភ្ញៀវចំនួន ១៥នាក់ ស្មើនឹង ៧២,៧ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតយល់ឃើញថា នៅក្នុងសហគមន៍មាការគ្រប់គ្រងកាកសំណល់បានល្អ
- ❖ មានភ្ញៀវចំនួន ៤នាក់ ស្មើនឹង ២៧,៣ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលបានទៅកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតយល់ឃើញថា នៅក្នុងសហគមន៍មាការគ្រប់គ្រងកាកសំណល់បានមធ្យម

### ៣.១.១៦ វិភាគទៅលើសន្តិសុខ និងសុវត្ថិភាពនៅក្នុងសហគមន៍

ក្រាភិច៣.១៦ ដែលធ្វើការវិភាគទៅលើសន្តិសុខ និងសុវត្ថិភាពក្នុងសហគមន៍




តាមក្រាភិចបានបង្ហាញថា៖

- ✓ មានភ្ញៀវចំនួន ៨នាក់ ស្មើនឹង ៤៥,៥ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាល្អចំពោះសន្តិសុខ សុវត្ថិភាពរបស់សហគមន៍អេកូទេសចរណ៍ជីផាត
- ✓ មានភ្ញៀវចំនួន ៨នាក់ ស្មើនឹង ៤៥,៥ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាមធ្យមចំពោះសន្តិសុខ សុវត្ថិភាពរបស់សហគមន៍អេកូទេសចរណ៍ជីផាត
- ✓ មានភ្ញៀវចំនួន ៣នាក់ ស្មើនឹង ៩,១ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាល្អណាស់ចំពោះសន្តិសុខ សុវត្ថិភាពរបស់សហគមន៍អេកូទេសចរណ៍ជីផាត

### ៣.១.១៧ វិភាគទៅលើបរិស្ថាននៅក្នុងសហគមន៍

ក្រាភិច៣.១៧ ដែលធ្វើការវិភាគទៅលើបរិស្ថាននៅក្នុងសហគមន៍




តាមក្រាភិចបានបង្ហាញថា:

- មានភ្ញៀវចំនួន ១៤នាក់ ស្មើនឹង ៧២,៧ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាល្អចំពោះបរិស្ថាននៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត
- មានភ្ញៀវចំនួន ៣នាក់ ស្មើនឹង ១៨,២ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាល្អណាស់ចំពោះបរិស្ថាននៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត
- មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ៩,១ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាមធ្យមចំពោះបរិស្ថាបនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត

### ៣.១.១៨ វិភាគលើសេវាកម្មដែលផ្តល់ដោយប្រជាសហគមន៍

ក្រាភិច៣.១៨ ដែលធ្វើការវិភាគទៅលើសេវាកម្មដែលផ្តល់ដោយប្រជាសហគមន៍




តាមក្រាភិចបានបង្ហាញថា៖

- មានភ្ញៀវចំនួន ១៥នាក់ ស្មើនឹង ៨១,៨ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាសេវាកម្មដែលផ្ដល់ដោយប្រជាសហគមន៍មានលក្ខណៈល្អ
- មានភ្ញៀវចំនួន ៤នាក់ ស្មើនឹង ១៨,២ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាសេវាកម្មដែលផ្ដល់ដោយប្រជាសហគមន៍មានលក្ខណៈមធ្យម

### ៣.១.១៩ វិភាគទៅលើអាកប្បកិរិយារបស់ប្រជាសហគមន៍

ក្រាភិច៣.១៩ ដែលធ្វើការវិភាគទៅលើអាកប្បកិរិយារបស់ប្រជាសហគមន៍



តាមក្រាភិចបានបង្ហាញថា៖

- មានភ្ញៀវចំនួន ១៧នាក់ ស្មើនឹង ៩០ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាអាកប្បកិរិយារបស់ប្រជាសហគមន៍មានលក្ខណៈរួសរាយរាក់ទាក់
- មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ១០ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាអាកប្បកិរិយារបស់ប្រជាសហគមន៍មានលក្ខណៈរួសរាយធម្មតា

**៣.១.២០ វិភាគទៅលើការយល់ឃើញរបស់ភ្ញៀវចំពោះស្លាកសញ្ញាបង្ហាញទិសដៅមានគ្រប់គ្រាន់ឬទេ?**

ក្រាភិច៣.២០ ដែលធ្វើការវិភាគទៅលើការយល់ឃើញរបស់ភ្ញៀវចំពោះស្លាកសញ្ញាបង្ហាញទិសដៅមានគ្រប់គ្រាន់ឬទេ?




តាមក្រាភិចបានបង្ហាញថា៖

- មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ១០ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាសញ្ញាបង្ហាញផ្លូវនៅក្នុងសហគមន៍មិនទាន់គ្រប់គ្រាន់
- មានភ្ញៀវចំនួន ១៧នាក់ ស្មើនឹង ៩០ភាគរយ ក្នុងចំណោមទេសចរ១៩នាក់យល់ឃើញថាសញ្ញាបង្ហាញផ្លូវនៅក្នុងសហគមន៍គ្រប់គ្រាន់

**៣.១.២១ វិភាគទៅលើការពេញចិត្តរបស់ភ្ញៀវទេសចរណ៍**

ក្រាភិច៣.២១ ដែលធ្វើការវិភាគទៅលើការពេញចិត្តរបស់ភ្ញៀវទេសចរណ៍

- ទស្សនាតាមភូមិក្នុងសហគមន៍
- ថតរូបទុកជាអនុស្សាវរីយ៍
- ទិញផលិតផលនិងវត្ថុអនុស្សាវរីយ៍ក្នុងសហគន៍
- ជិះទូកលេងកំសាន្ត
- ជិះកង់កម្សាន្ត
- ទស្សនារូងប្រចៀវ
- ទស្សនាវត្ថុបុរាណ
- ការកំសាន្តនៅទឹកជ្រោះ




តាមក្រាភិចបានបង្ហាញថា៖

- មានភ្ញៀវចំនួន ៣នាក់ ស្មើនឹង ១៨,២ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលពេញចិត្តចំពោះសេវាកម្មទស្សនាតាមភូមិក្នុងសហគមន៍
- មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ៩,១ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលពេញចិត្តចំពោះសេវាកម្មថតរូបអនុស្សាវរីយ៍
- មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ៩,១ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលពេញចិត្តចំពោះការទិញផលិតផលនិងវត្ថុអនុស្សាវរីយ៍ក្នុងសហគមន៍
- មានភ្ញៀវចំនួន ៤នាក់ ស្មើនឹង ២៧,៣ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលពេញចិត្តចំពោះសេវាកម្មជិះកង់កម្សាន្ត
- មានភ្ញៀវចំនួន ៤នាក់ ស្មើនឹង ២៧,៣ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលពេញចិត្តចំពោះសេវាកម្មទស្សនារូងប្រចៀវ
- មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ១៨,២១ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលពេញចិត្តចំពោះសេវាកម្មទស្សនាវត្ថុបុរាណ
- មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ១៨,២ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលពេញចិត្តចំពោះសេវាកម្មកំសាន្តនៅទឹកជ្រោះ

**៣.១.២២ វិភាគទៅលើការមិនពេញចិត្តរបស់ភ្ញៀវទេសចរណ៍**

ក្រាភិច៣.២២ ដែលធ្វើការវិភាគទៅលើការមិនពេញចិត្តរបស់ភ្ញៀវទេសចរណ៍




តាមក្រាភិចបានបង្ហាញថា៖

- មានភ្ញៀវចំនួន ៣នាក់ ស្មើនឹង ១៨,២ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលមិនពេញចិត្តចំពោះសេវាកម្មទស្សនាតាមភូមិក្នុងសហគមន៍
- មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ៩,១ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលមិនពេញចិត្តចំពោះសេវាកម្មថតរូបអនុស្សាវរីយ៍
- មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ៩,១ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលមិនពេញចិត្តចំពោះការទិញផលិតផលនិងវត្ថុអនុស្សាវរីយ៍ក្នុងសហគមន៍
- មានភ្ញៀវចំនួន ៤នាក់ ស្មើនឹង ២៧ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលមិនពេញចិត្តចំពោះសេវាកម្មជិះកង់កម្សាន្ត
- មានភ្ញៀវចំនួន ៤នាក់ ស្មើនឹង ២៧ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលពេញចិត្តចំពោះសេវាកម្មទស្សនារូងប្រចៀវ
- មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ១៨,២១ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលពេញចិត្តចំពោះសេវាកម្មទស្សនាវត្ថុបុរាណ
- មានភ្ញៀវចំនួន ២នាក់ ស្មើនឹង ១៨,២ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលពេញចិត្តចំពោះសេវាកម្មកំសាន្តនៅទឹកជ្រោះ

### ៣.១.២៣ វិភាគទៅលើតម្លៃសេវាកម្ម ម្ហូបអាហារ និងភេសជ្ជៈ ឬសេវាកម្មផ្សេងៗទៀត

ក្រាភិច ៣.១.២៣ ដែលធ្វើការវិភាគទៅលើតម្លៃសេវាកម្ម ម្ហូបអាហារ និងភេសជ្ជៈ ឬសេវាកម្មផ្សេងៗទៀត




តាមក្រាភិចបានបង្ហាញថា៖

- មានភ្ញៀវចំនួន ១២នាក់ ស្មើនឹង ៦៥ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលយល់ថាសេវាកម្មម្ហូបអាហារ និងភេសជ្ជៈឬសេវាកម្មផ្សេងទៀតមានលក្ខណៈធម្មតា
- មានភ្ញៀវចំនួន ៧នាក់ ស្មើនឹង ៣៥ភាគរយ ក្នុងចំណោមទេសចរ១៩នាក់ដែលយល់ថាសេវាកម្មម្ហូបអាហារ និងភេសជ្ជៈឬសេវាកម្មផ្សេងទៀតមានលក្ខណៈពេញចិត្ត។

## ៣.២ ការវិភាគលើភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង

ការវិភាគលើការជះឥទ្ធិពលនៃវិស័យទេសចរណ៍ គឺធ្វើតាមរយៈការសិក្សាលើភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង គឺជាវិទ្យាសាស្ត្រមួយដែលឆ្លុះបញ្ចាំងអោយឃើញនូវភាពខាងក្នុង និងខាងក្រៅនៃមជ្ឈដ្ឋានទេសចរណ៍ដើម្បីធ្វើការសន្និត និងធ្វើការសន្និដ្ឋានដើម្បីស្វែងរកដំណោះស្រាយ ជាពិសេសជំរុញដល់ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព។ ការវិភាគចំណុចសំខាន់ៗខាងលើជាមូលដ្ឋានគ្រឹះដ៏ពេញនិយមគ្រប់បណ្តាអង្គភាពពាក់ព័ន្ធវិស័យទេសចរណ៍ក្នុងការទាក់ទាញយកមកធ្វើការវិភាគអោយឃើញនូវសមាសភាពដៃគូប្រកួតប្រជែង ស្ថានភាពភ្ញៀវទេសចរណ៍ ផ្នែកទីផ្សារ និងរបកគំហើញថ្មីៗជាដើម ព្រោះវាអាចបង្កលក្ខណៈងាយស្រួលក្នុងការរៀបចំផែនការ យុទ្ធសាស្ត្រ សកម្មភាពគ្រប់គ្រងអភិវឌ្ឍន៍វិស័យទេសចរណ៍អោយមានប្រសិទ្ធភាពខ្ពស់។

ដូចនេះ ដើម្បីអោយដឹងច្បាស់ពីការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ក្រោយមកសិក្សាស្រាវជ្រាវបានធ្វើការបកស្រាយដូចខាងក្រោម៖

### ៣.២.១ ការវិភាគលើចំណុចខ្លាំង

ភាពខ្លាំង នៅក្នុងវិស័យទេសចរណ៍គឺជាធនធានដ៏សម្បើមដែលមានលទ្ធភាពផ្តល់ភាពងាយស្រួល និងអាចផ្តល់ការអភិវឌ្ឍនៃវិស័យទេសចរណ៍គ្រប់គ្រាន់ ក៏ដូចជាសម្រួលក្នុងការវិវត្តក្នុងតំបន់បានយ៉ាងរលូនផងដែរ។ ពោលភាពខ្លាំងក្នុងវិស័យទេសចរណ៍ប្រៀបបាននឹងភាពជោគជ័យ ដ៏ធំចម្បងរួចទៅហើយសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ និងរៀបចំយុទ្ធសាស្ត្រនាពេលខាងមុខប្រកបដោយគុណភាពខ្ពស់ ជាពិសេសផ្តល់ប្រយោជន៍ដល់ប្រជាជនសហគមន៍ និងស្ថាប័នពាក់ព័ន្ធនានា។

- ធនធានធម្មជាតិៈ ជាតំបន់ទេសចរណ៍ដែលមានភាពទាក់ទាញបែបអេកូទេសចរណ៍ ដែលធនធានទាំងនោះរួមមាន ផ្នូរបុរាណមានអាយុកាលប្រមាណជា ៥០០ឆ្នាំ ពាងបុរាណ មើលថ្ងៃលិចពីកំពូលភ្នំ លេងទឹកជ្រោះដ៏ស្រស់ស្អាត ជាច្រើនកន្លែង ការចាក់បង្គងពេលរាត្រី មើលអំពិលអំពែក ជិះទូកកម្សាន្តតាមដៃសមុទ្រ មើលថ្ងៃរះ រូងប្រចៀវ។
- កត្តាទាក់ទាញៈ កត្តាទាក់ទាញនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតមានដូចជាៈ
  - ជិះទូក ឬជិះកៃយ៉ាក់កម្សាន្តមើលទេសភាពដ៏ល្អប្រណីត
  - ជិះកង់កម្សាន្តតាមភូមិ
  - បោះតង់ក្នុងព្រៃ
- សន្តិសុខសុវត្ថិភាពៈ សន្តិសុខដែលបម្រើជូនភ្ញៀវទេសចរណ៍ដែលបានទៅកម្សាន្តនៅសហគមន៍អេកូទេសចរណ៍ជីផាតមានលក្ខណៈប្រសើរ ពុំសូវមានបញ្ហាផ្សេងៗកើតឡើងប៉ុន្មានទេ។ ម្យ៉ាងវិញទៀត ប្រជាជនក៏មានភាពរួសរាយរាក់ទាក់ គួបផ្សំនឹងការបម្រើសេវាកម្មយ៉ាងកក់ក្តៅអោយទៅភ្ញៀវទេសចរណ៍ដែលធ្វើអោយពួកគេមិនមានការព្រួយបារម្ភទៅលើហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងចំពោះពួកគេឡើយ។
- សហគមន៍ទាំងមូលមានភាពល្អប្រសើរ និងស្រស់ស្អាតដោយមានការចូលរួមពីសំណាក់ប្រជាជនក្នុងភូមិដែលជួយក្នុងការថែរក្សានូវសណ្តាប់ធ្នាប់។ ជាពិសេសគឺបរិស្ថាននៅជុំវិញផ្ទះ ព្រមទាំងតាមផ្លូវនៅក្នុងភូមិរបស់ខ្លួនសម្រាប់ការចូលរួមអភិវឌ្ឍន៍សហគមន៍អោយល្អប្រសើរ និងទាក់ទាញផងដែរ។
- ការទំនាក់ទំនងៈ ប្រជាជននៅក្នុងសហគមន៍មានភាពរួសរាយរាក់ទាក់ក្នុងការប្រាស្រ័យទាក់ទងជាមួយភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ថ្វីត្បិតតែពួកគេមិនសូវមានការយល់ខ្ពស់ទៅលើភាសា ប៉ុន្តែពួកគេនៅតែព្យាយាមទទួលភ្ញៀវដោយពួកគេទទួលបាននូវភាពកក់ក្តៅនៅពេលបានទៅដល់សហគមន៍របស់ខ្លួន ដែលនេះគឺជាអ្វីអ្នកធ្វើការនៅក្នុងការបម្រើសេវាកម្មត្រូវតែមាន។
- ជាសហគមន៍មួយដែលមានប្រវត្តិសាស្ត្រគួរអោយកត់សម្គាល់ធ្វើអោយមានការចាប់អារម្មណ៍ដល់ភ្ញៀវជាតិ ពិសេសអន្តរជាតិចង់ធ្វើការសិក្សាស្វែងយល់ ចង់ឃើញចង់ស្គាល់ដើម្បីបានជាចំណេះដឹង និងបទពិសោធន៍។

### ៣.២.២ ការវិភាគលើភាពខ្សោយ

យ៉ាងណាមិញ ថ្វីត្បិតតែយើងសង្កេតឃើញថាក្នុងសហគមន៍សម្បូរទៅដោយចំណុចខ្លាំងជាច្រើនដែលអាចទាក់ទាញទេសចរ អោយទៅស្រូបយកនូវបទពិសោធន៍ក៏ពិតមែន ប៉ុន្តែនៅមានចំណុចខ្វះខាតមួយចំនួនដែលសហគមន៍គួរតែមានការបន្ថែមដើម្បីធ្វើអោយសហគមន៍នឹងទទួលបានការទាក់ទាញភ្ញៀវទេសចរណ៍បានច្រើនជាងនេះទៅទៀត។ ចំណុចមួយចំនួនគួរមានការបន្ថែមដូចជា៖

- ការផ្សព្វផ្សាយពីសហគមន៍អេកូទេសចរណ៍ជីផាតនៅពុំទាន់មានភាពទូលំទូលាយនៅឡើយ ដែលទេសចរពិបាកក្នុងការស្វែងរកព័ត៌មានអោយបានគ្រប់គ្រាន់នៅក្នុងដៃ។ យើងបានដឹងហើយថាជីផាតគឺជាសហគមន៍ទេសចរណ៍បែបធម្មជាតិមួយប្រកបដោយសក្តានុពលយ៉ាងខ្លាំងលើវិស័យទេសចរណ៍ ហេតុនេះគួរណាស់តែមានការផ្សព្វផ្សាយអោយកាន់តែច្រើនឡើងដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិបានស្គាល់ និងមកទស្សនាទីនេះ។
- ការយល់ដឹងរបស់ប្រជាសហគមន៍ទៅលើផ្នែកបម្រើសេវាកម្មបដិសណ្ឋារកិច្ច ភាសា និងការចូលរួមនៅមានកម្រិតនៅឡើយ។
- ដៃគូសហការជាមួយក្រុមហ៊ុនទេសចរណ៍ក្នុងស្រុកនៅមានកម្រិតនៅឡើយ
- ទេសចរភាគច្រើនមកទស្សនាជាភ្ញៀវអន្តរជាតិដែលធ្វើអោយបាត់បង់ចំណូលពីទេសចរជាតិ។

**៣.២.៣ ឱកាស**

- ស្ថេរភាពនយោបាយដោយយើងបានដឹងហើយថាកាលណា នយោបាយនៅក្នុងប្រទេសមានស្ថេរភាពល្អអាចធ្វើអោយមានការពាំនាំដល់ភ្ញៀវទេសចរណ៍ទាំងជាតិ និងអន្តរជាតិអោយចូលមកទស្សនា តំបន់ទេសចរណ៍ផ្សេងៗនៅក្នុងប្រទេស ដោយនេះក៏ជាកត្តាមួយអាចអោយភ្ញៀវមកដល់សហគមន៍ជីផាតដែលជាសហគមន៍អេកូទេសចរណ៍ធម្មជាតិពិតៗ ។
- ដោយបច្ចុប្បន្ននេះមានការពង្រឹង និងមានការចាប់អារម្មណ៍ងាកមកលំហែកំសាន្តបែបអេកូទេសចរណ៍ធម្មជាតិ ធ្វើអោយសហគមន៍អេកូទេសចរណ៍ជីផាត ក៏ក្លាយជម្រើសរបស់ភ្ញៀវទេសចរណ៍ផងដែរ។
- ផ្តល់ឱកាសដល់ប្រជាពលរដ្ឋនៅក្នុងស្រុកមានការងារធ្វើដោយបានជួយកាត់បន្ថយភាពក្រីក្រ និងរកប្រាក់ចំណូលបានមកពីការអនុញ្ញាតិ្តឲ្យប្រជាជនអាចលក់ដូរនូវក្នុងតំបន់ទេសចរណ៍ ហើយមិនបានអនុញ្ញាតិ្តឲ្យប្រជាជនដែលនៅក្រៅស្រុកមកធ្វើការងារ ឬក៏ធ្វើការលក់ដូរនៅតំបន់ទេសចរណ៍ឬក៏ធ្វើអាជីវកម្មដោយគ្មានការអនុញ្ញាតិ្តបានឡើយ។
- សហគមន៍មានវគ្គបណ្តុះបណ្តាលដល់ប្រជាជនឲ្យពួកគេមានការយល់ដឹងអំពីទេសចរណ៍ជាពិសេសចេះស្រឡាញ់ធនធានធម្មជាតិ ។
- មានការយកចិត្តទុកលើការផ្តល់នូវគុណភាពសេវាកម្ម និងផលិតផលរបស់ម្ចាស់ស្រុក។
- សហគមន៍មានការបង្រៀនអំពីបរិស្ថាន និងសហការជាមួយអង្គភាពនានាៗ ដើម្បីយកផលមកជូនប្រជាជនក្នុងតំបន់ និងសហគមន៍ដូចជាធុងដាក់សំរាមចែកដល់គ្រប់គ្រួសារ ហើយផ្សេងៗទៀត។
- បណ្តុះបណ្តាលការយល់ដឹងដល់ប្រជាជននៅក្នុងសហគមន៍ ជាពិសេសម្ចាស់អាជីវកម្មជាអ្នកបម្រើសេវាកម្មទេសចរណ៍អំពីបដិសណ្ឋារកិច្ច និងឲ្យមានក្រមសីលធម៌។

### ៣.២.៤ ការគំរាមកំហែង

ផ្អែកទៅលើគ្រប់វិស័យទាំងអស់ព្រមទាំងគ្រប់មជ្ឈដ្ឋានការងារវិស័យសេដ្ឋកិច្ចឬវិស័យណាក៏ដោយ តំបន់ដែលមានការអភិវឌ្ឍ ឬមិនទាន់មានការអភិវឌ្ឍតែងតែទទួលរងនូវការគំរាមកំហែងទៅលើបញ្ហាផ្សេងៗ។ ដូចគ្នានេះដែរ សហគមន៍អេកូទេសចរណ៍ជីផាត ក៏បានទទួលរងនូវការគំរាមកំហែងដូចជា៖

- វិបត្តិសេដ្ឋកិច្ចពិភពលោក តួយ៉ាងដូចដែលកំពុងមានបញ្ហាសព្វថ្ងៃហើយវាបានវាយប្រហារលើផ្នែកសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។ បច្ចុប្បន្ននេះគឺជំងឺឆ្លងកូវីដណាដែលធ្វើអោយសេដ្ឋកិច្ចពិភពលោកមានការទ្រុឌទ្រោមយ៉ាងខ្លាំង ធ្វើឱ្យបាត់បង់ចំណូលមកពីវិស័យទេសចរណ៍ដោយសារទេសចរមានការខ្លាចអាឆ្លងជំងឺរាតត្បាតដ៏កាចសាហាវមួយនេះ ក្នុងនោះសហគមន៍អេកូទេសចរណ៍ជីផាតក៏ទទួលរងវិបត្តិនេះផងដែរ។
- បញ្ហាគ្រោះធម្មជាតិផ្សេងៗ ដែលអាចធ្វើអោយខូចខាតនូវហេដ្ឋារចនាសម្ព័ន្ធ សម្បទាទេសចរណ៍មួយចំនួន។

# សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

# ជំពូកទី៤

# សន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១ សេចក្តីសន្និដ្ឋាន

វិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជា ត្រូវបានផ្តល់ឈ្មោះឱ្យជាមាសបៃតងដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងជម្រុញកំណើនសេដ្ឋកិច្ចពីមួយឆ្នាំទៅមួយឆ្នាំ។ វិស័យនេះត្រូវបានយកចិត្តទុកដាក់ខ្ពស់ទៅលើការអភិវឌ្ឍ និងភាពរីកចម្រើនគួរឱ្យកត់សម្គាល់នេះដោយសារប្រទេសកម្ពុជាជាដែនដីសុវណ្ណភូមិ និងមហាអំណាចនៃវប្បធម៌ ប្រវត្តិសាស្ត្រមិនត្រឹមតែប៉ុណ្ណោះសម្បត្តិបេតិកភណ្ឌជាតិជាច្រើនបានចូលជាបេតិកភណ្ឌពិភពលោក។ បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើប្រធានបទ ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត រួចមក។ ក្រុមយើងខ្ញុំអាចសន្និដ្ឋានបានថា សហគមន៍អេកូទេសចរណ៍ជីផាត ជាតំបន់បៃបអេកូទេសចរណ៍ប្រកបដោយសក្តានុពល និងមានការគ្រប់គ្រងបានយ៉ាងត្រឹមត្រូវ។ សហគមន៍អេកូទេសចរណ៍ជីផាត ជាសហគមន៍ដែលសំបូរទៅដោយធនធានធម្មជាតិ និងវប្បធម៌ជាច្រើនដែលអាចទាក់ទាញទាំងភ្ញៀវទេសចរណ៍ជាតិនិងអន្តរជាតិអោយចូលមកកំសាន្តបានយ៉ាងច្រើនកុះករ។ ក្រៅពីមានទេសភាពដ៏ស្រស់ត្រកាលហើយនោះ ភ្ញៀវទេសចរណ៍ជាតិនិងអន្តរជាតិក៏អាចទទួលបាននូវការបម្រើសេវាកម្មពីសហគមន៍អេកូទេសចរណ៍ជីផាតតាមរយៈការរៀបចំសេវាកម្មកំសាន្តជាច្រើនដូចជា សេវាកម្មស្នាក់នៅ បោះតង់ ជិះទូក ដើម្បីគយគន់ទេសភាពថ្ងៃលិច ជិះកង់ ជិះម៉ូតូទស្សនាតាមភូមិដោយផ្សារភ្ជាប់ទៅនឹងទិដ្ឋភាពជីវភាពរស់នៅរបស់ប្រជាសហគមន៍ ការប្រកបរបរចិញ្ចឹមជីវិត ការដាំដំណាំផ្សេងៗក្នុងភូមិ។ កត្តាទាំងនេះហើយដែលធ្វើឱ្យសហគមន៍អេកូទេសចរណ៍ជីផាត ក្លាយជាសហគមន៍ប្រកបដោយសក្តានុពល គួបផ្សំនឹងការយកចិត្តទុកដាក់លើគ្រប់គ្រងរបស់សហគមន៍តាមរយៈ ការគ្រប់គ្រងសកម្មភាពទេសចរ ការគ្រប់គ្រងបរិស្ថាន ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ការធានាសុវត្ថិភាពទេសចរ ការអភិវឌ្ឍធនធានមនុស្សក្នុងសហគមន៍ ការអភិវឌ្ឍផលិតផលនិងសេវាកម្ម ការសិក្សាទីផ្សារ ការការពារនិងអភិរក្ស ព្រមទាំងការផ្សព្វផ្សាយតាមរយៈរូបភាពផ្សេងៗដើម្បីធ្វើអោយសហគមន៍មួយនេះមានដំណើរការយ៉ាងរលូន។ ប៉ុន្តែទន្ទឹមនឹងភាពល្អប្រសើរលើការគ្រប់គ្រងក៏យើងសង្កេតឃើញមាននូវចំណុចប្រឈមអវិជ្ជមានមួយចំនួនលើការគ្រប់គ្រងផងដែរ ដូចជា ខ្វះខាតធនធានមនុស្ស ការផ្សព្វផ្សាយទេសចរណ៍ក្នុងសហគមន៍នៅមានកម្រិត ការយល់ដឹងរបស់ប្រជាសហគមន៍ទៅលើផ្នែកបម្រើសេវាកម្មបដិសណ្ឋារកិច្ច ភាសា និងការចូលរួមនៅមានកម្រិត។

សរុបសេចក្តីមកថ្វីត្បិតតែ នៅមានភាពខ្វះចន្លោះមួយចំនួនលើការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាតក៏ពិតមែន ប៉ុន្តែ ប្រធានសហគមន៍ អាជ្ញាធរមូលដ្ឋាន មន្ទីរទេសចរណ៍ខេត្ត បានប្តេជ្ញាយ៉ាងម៉ឺងម៉ាត់ក្នុងការពង្រឹងគុណភាពការគ្រប់គ្រងសហគមន៍អោយកាន់តែល្អប្រសើរ និងខិតខំជំរុញវិស័យទេសចរណ៍នៅក្នុងសហគមន៍មានការអភិវឌ្ឍ និងនិរន្តភាពប្រកបដោយចីរកាលព្រមទាំងសម្រាប់កាលានុវត្តភាពមួយចូលរួមប្រកួតប្រជែងក្នុងការលក់ផលិតផល ព្រមទាំងផ្តល់សេវាកម្មទេសចរណ៍របស់ខ្លួននៅទីផ្សារប្រកបដោយជោគជ័យ

ដើម្បីជួយផ្គត់ផ្គង់ និងរួមចំណែកក្នុងការកសាងសេដ្ឋកិច្ចសង្គមប្រជាពលរដ្ឋក្នុងសហគមន៍ និងការកាត់បន្ថយភាពក្រីក្រ។

## ២ ការផ្តល់អនុសាសន៍

ក្រោយពីបានសិក្សាធ្វើការសិក្សាស្រាវជ្រាវ និងធ្វើការសន្និដ្ឋានពាក់ព័ន្ធជាមួយនឹងសហគមន៍អេកូទេសចរណ៍ជីផាតរួចមក យើងសង្កេតឃើញថាសហគមន៍នៅមានចំណុចខ្វះខាតមួយចំនួនដែលជាកត្តាបង្ករាំងស្ទះក្នុងការគ្រប់គ្រងវិស័យទេសចរណ៍ និងជះឥទ្ធិពលដល់ការរីកចម្រើនក្នុងការទាក់ទាញទេសចរជាតិ និងអន្តរជាតិអោយចូលមកកំសាន្តក្នុងសហគមន៍អេកូទេសចរណ៍ជីផាត។ ដូចនេះក្រុមសិក្សាស្រាវជ្រាវយើងខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនដើម្បីកែលំអទៅដល់សហគមន៍ផ្ទាល់ដើម្បីអោយក្លាយទៅជាតំបន់គោលដៅដ៏មានសក្តានុពលខ្លាំងក្លាក្នុងការស្រូបយកទេសចរជាតិ និងអន្តរជាតិដែលមានទិសដៅកំសាន្តនៅភូមិភាគនិរតីដូចខាងក្រោមៈ

- សេវាកម្មផ្សេងៗក្នុងសហគមន៍
  - សេវាកម្មដឹកជញ្ជូន
    - ចំពោះទូកដចម្លងទេសចរ គួរតែជួសជុលបន្ថែមអោយមានសោភ័ណភាពល្អស្អាតជាងមុន និងធំទូលាយដើម្បីបង្កភាពងាយស្រួលក្នុងការដឹកជញ្ជូន
    - ចំពោះតម្លៃទូកដចម្លង គួរតែពិនិត្យតម្លៃសារឡើងវិញ
  - ហេដ្ឋារចនាសម្ព័ន្ធ
    - គួរអភិវឌ្ឍន៍ផ្លូវចេញចូលទៅកាន់សហគមន៍អេកូទេសចរណ៍ជីផាតអោយកាន់តែប្រសើរជាងនេះ
  - សេវាកម្មស្នាក់នៅ
    - គួររៀបចំបង្កើតផ្ទះស្នាក់ ផ្ទះសំណាក់ និងបឹងកាឡូបន្ថែម សម្រាប់ទទួលទេសចរមកកម្សាន្តនៅក្នុងសហគមន៍
    - គួរពង្រឹងបន្ថែមនូវបដិសណ្ឋារកិច្ច និងការប្រាស្រ័យទាក់ទងជាមួយភ្ញៀវសម្រាប់ម្ចាស់ផ្ទះសំណាក់នីមួយៗ ចំពោះទេសចរដែលបានស្នាក់នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត
    - គួររៀបចំអោយមានអនាម័យ និងរបៀបរៀបរយនៅក្នុងកន្លែងស្នាក់នៅនីមួយៗ ដូចជាកន្លែងគេង បន្ទប់ទឹក បរិស្ថានជុំវិញកន្លែងស្នាក់នៅ

- មន្ត្រីពាក់ព័ន្ធគួរឧស្សាហ៍ចុះទៅពិនិត្យមើលពីរបៀបរៀបរយ និងស្តង់ដានៃការរៀបចំកន្លែងស្នាក់នៅរបស់ប្រជាសហគមន៍

- សេវាកម្មម្ហូបអាហារ
  - គួរបង្កើតសេវាកម្មម្ហូបអាហារអោយបានច្រើនជាងនេះ
  - គួរយកចិត្តទុកដាក់លើសោភ័ណភាព រសជាតិ អនាម័យ និងគុណភាពចំណីអាហារសម្រាប់បម្រើជូនភ្ញៀវ
  - សហគមន៍គួរបង្កើតមុខម្ហូបអាហារណាមួយសម្រាប់ធ្វើជាមុខម្ហូបប្រចាំតំបន់ ដើម្បីជាភាពទាក់ទាញការចាប់អារម្មណ៍ពីភ្ញៀវ

- សេវាកម្មកំសាន្ត
  - គួរបង្កើតសកម្មភាពថ្មីៗ ដើម្បីទាក់ទាញភ្ញៀវមកលេងកំសាន្តនៅរដូវខ្សត់ភ្ញៀវ
  - គួរបន្ថែមផ្លាកសញ្ញា និងទិសដៅផ្លូវចូលទៅក្នុងសហគមន៍ ព្រមទាំងផ្លូវចេញចូលតំបន់កំសាន្តនីមួយៗ
  - ត្រូវមានស្លាកសញ្ញាហាមឃាត់ ប្រសិនបើកន្លែងនោះអាចមានគ្រោះថ្នាក់ដល់ភ្ញៀវ

- ធនធានមនុស្ស
  - គួរមានការយកចិត្តទុកដាក់ទៅលើបញ្ហាធនធានមនុស្សជាចាំបាច់ ព្រោះបើសិនចង់អភិវឌ្ឍន៍ទៅលើអ្វីមួយ យើងមិនអាចកាត់ផ្តាច់នូវតម្រូវការមនុស្សដែលមានសមត្ថភាពយកមកធ្វើការនោះទេ ដូច្នេះគួរធ្វើយ៉ាងណារៀបចំជាសាលារៀនបន្ថែមនៅក្នុងសហគមន៍ និងធ្វើការអប់រំដល់ប្រជាពលរដ្ឋក្នុងសហគមន៍អោយយល់ដឹងច្បាស់ពីធនធានមនុស្ស ដើម្បីអោយពួកគាត់ជម្រុញដល់កូនៗរបស់ពួកគាត់បានទៅសិក្សាគ្រប់ៗគ្នាដើម្បីជាទុនក្នុងការធ្វើអោយជីវភាពគ្រួសាររបស់ពួកគាត់នាពេលអនាគតមានភាពល្អប្រសើរ។

- ការផ្សព្វផ្សាយ
  - បង្កើនការផ្សព្វផ្សាយដល់ទេសចរណ៍ក្នុងស្រុកអោយកាន់តែទូលំទូលាយជាងនេះបន្ថែមទៀត។

# ឯកសារយោង

## ឯកសារយោងជាភាសាខ្មែរ


១. សេចក្តីផ្តើមទេសចរណ៍ រៀបរៀងដោយ បណ្ឌិត ឈុន ពហុ ឆ្នាំ២០១៣

២. អេកូទេសចរណ៍ ចក្ខុវិស័យ និងការអភិវឌ្ឍ រៀបរៀងដោយ បណ្ឌិតសួន វ៉ានី បណ្ឌិត ហុងវណ្ណ និងបណ្ឌិត ឈឹមផាន់ណា ឆ្នាំ២០១៤

៣. ការអភិវឌ្ឍ និងផែនការទេសចរណ៍ប្រកបដោយនិរន្តរភាព រៀបរៀងដោយ បណ្ឌិតឈឹម ផាន់ណា ឆ្នាំ២០១៨

៤. គោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩ ២០៣០

៥ សៀវភៅរបាយការណ៍លទ្ធផលស្ថិតិក្រោមជាតិ ខេត្តកែប កំពត កោះកុង និងខេត្តព្រះសីហនុ រៀបចំដោយ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ២០១៧

៦ សេចក្តីបំពេញបន្ថែមវិសោធនកម្មលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសម្រាប់សហគមន៍អេកូទេសចរណ៍ជីផាត រៀបរៀងដោយ គណៈកម្មការសហគមន៍អេកូទេសចរណ៍ជីផាត អាជ្ញាធរក្នុងតំបន់ និងឃុំជីផាត អង្គការសម្ព័ន្ធមិត្តសត្វព្រៃឆ្នាំ២០១៧

៧ គោលការណ៍នៃការអនុវត្តល្អសម្រាប់ការគ្រប់គ្រងតំបន់ទាក់ទាញភ្ញៀវទេសចរ ដោយអង្គការអន្តរជាតិខាងការងារ(ILO)


## ឯកសារយោងជាភាសាអង់គ្លេស


- Tourism Destination Management by Professor Sro Rithy
- Ecotourism program planning by D.A Fennel
- Ecotourism policy and planning Edit by David A. fennel and Ross Dowling

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ "ក"

# កម្រងសំណួរសម្រាប់មន្ទីរទេសចរណ៍

សូមគោរពជូនលោក សុខ ចាន់គ្រឹះស្នា ប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុង

ពួកយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំទី០៤ ជំនាន់ទី០៧ មានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះខេត្តកោះកុង។

## ក្រោមប្រធានបទ

"**ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ខេត្តកោះកុង**" ដូចនេះហើយបានជាក្រុមយើងខ្ញុំរៀបចំជាសំណួរ ដែលទាក់ទងទៅនឹងការគ្រប់គ្រងរបស់ខេត្តកោះកុង។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាជួយផ្តល់នូវព័ត៌មាន ឯកសារ និងអនុសាសន៍មួយចំនួន ដល់ក្រុមយើងខ្ញុំដើម្បីមានមូលដ្ឋានក្នុងការសរសេរសារណាសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយក្តីអនុគ្រោះ។

១. សូមមេត្តាបង្ហាញ និងពន្យល់ពីស្ថានភាពទូទៅនាពេលបច្ចុប្បន្នរបស់ខេត្តកោះកុង។

២. តើនៅឆ្នាំនេះមានភ្ញៀវទេសចរណ៍ចូលមកកំសាន្តក្នុងខេត្តកោះកុងប៉ុន្មាននាក់? បើប្រៀបធៀបទៅនឹងឆ្នាំមុន តើចំនួនភ្ញៀវទេសចរណ៍មានការកើនឡើង ឬថយចុះ? ប៉ុន្មានភាគរយ?

៣. តើភ្ញៀវទេសចរណ៍ដែលចូលមកកំសាន្តក្នុងខេត្តកោះកុង ភាគច្រើនជាជនជាតិអ្វី? ហើយតើជនជាតិណាដែលចូលមកកំសាន្តនៅទីនេះតិចជាងគេ?

៤. អ្នកទេសចរណ៍ដែលចូលមកកំសាន្តក្នុងខេត្តនេះភាគច្រើននៅក្នុងរដូវកាល ឬខែណាច្រើនជាងគេ? តើភាគច្រើនពួកគេចូលចិត្តទៅទស្សនាតំបន់ណាច្រើនជាងគេ? ហើយពួកគេមកលក្ខណៈបែបណា?

៥. តើមានភ្ញៀវទេសចរណ៍ប៉ុន្មានភាគរយ ដែលទៅកំសាន្តនៅសហគមន៍អេកូទេសចរណ៍ជីផាត។ តើជនជាតិណាដែលចូលមកកំសាន្តក្នុងតំបន់នេះច្រើនជាងគេ។ បើប្រៀបធៀបទៅនឹងតំបន់អេកូទេសចរណ៍ដទៃទៀតក្នុងខេត្តនេះ តំបន់ជីផាតស្ថិតក្នុងលំដាប់ទីប៉ុន្មាន?

៦. តើមានអង្គភាព ឬស្ថាប័នណាខ្លះដែលចូលរួមពាក់ព័ន្ធ ក្នុងការធ្វើអោយវិស័យទេសចរណ៍ក្នុងខេត្តនេះមានការគ្រប់គ្រងប្រកបដោយការអភិវឌ្ឍ និងនិរន្តរភាព?

៧. តើដំណើរការនៃការប្រតិបត្តិគំរោងនានារបស់មន្ទីរទេសចរណ៍ខេត្តកោះកុងមានដំណើរការបែបណា?

៨. តើមន្ទីរទេសចរណ៍ខេត្តកោះកុងមានផែនការ និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធខេត្តទាំងមូលយ៉ាងដូចម្តេច?

៩. តើប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុងមានផែនការ និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងបែបណាដើម្បីពង្រឹងគុណភាព និងផលិតផល សេវាកម្មទេសចរណ៍ក្នុងខេត្តអោយកាន់តែប្រសើរឡើង?

១០. តើមន្ទីរទេសចរណ៍មានផែនការ និងយុទ្ធសាស្រ្តក្នុងការគ្រប់គ្រងបែបណាដើម្បីអភិវឌ្ឍន៍ធនធានទាក់ទាញ និងសេវាសម្បទាទេសចរណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍ទាំងអស់អោយកាន់តែរីកចម្រើន?

១១. តើការផ្សព្វផ្សាយពីសក្តានុពលខេត្តមានលក្ខណៈទូលំទូលាយដែរឬទេ? ហើយកន្លែងផ្តល់ព័ត៌មានក្នុងតំបន់នីមួយៗមានគ្រប់គ្រាន់ឬនៅ?

១២. តើនាពេលកន្លងមក មន្ទីរទេសចរណ៍ខេត្ត មានការផ្សព្វផ្សាយ ឬរៀបចំព្រឹត្តិការណ៍សំខាន់ៗជាលក្ខណៈសាធារណៈដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ដែរឬទេ? ប្រសិនបើមាន តើមានដំណើរការបែបណា?

១៣. តើសហគមន៍អេកូទេសចរណ៍ជីផាត មានបានកំណត់ទំហំផ្ទៃដី សម្រាប់គ្រប់គ្រងហើយឬនៅ?

១៤. តើមន្ទីរទេសចរណ៍មានយុទ្ធសាស្រ្ត និងផែនការគ្រប់គ្រងបែបណា ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍អោយចូលមកកំសាន្តក្នុងខេត្តកោះកុង ជាពិសេសសហគមន៍អេកូទេសចរណ៍ជីផាត អោយកាន់តែប្រសើរឡើង?

១៥. តើមន្ទីរទេសចរណ៍មានផែនការ និងយុទ្ធសាស្រ្តសម្រាប់គ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត យ៉ាងដូចម្តេចក្នុងពេលបច្ចុប្បន្ន និងអនាគត។

# កម្រងសំណួរសម្រាប់សហគមន៍អេកូទេសចរណ៍ជីផាត

សូមគោរពជូនលោក ប្រធានសហគមន៍អេកូទេសចរណ៍ជីផាត ខេត្តកោះកុង

ពួកយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែក ទេសចរណ៍ និងបដិសណ្ឋារកិច្ច ឆ្នាំទី០៤ ជំនាន់ទី០៧ មានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះខេត្តកោះកុង

## ក្រោមប្រធានបទ

"**ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ខេត្តកោះកុង**" ដូចនេះហើយបានជាក្រុមយើងខ្ញុំរៀបចំជាសំណួរ ដែលទាក់ទងទៅនឹងការគ្រប់គ្រងរបស់ខេត្ត កោះកុង។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាជួយផ្តល់នូវព័ត៌មាន ឯកសារ និងអនុសាសន៍មួយចំនួន ដល់ក្រុមយើងខ្ញុំដើម្បីមានមូលដ្ឋានក្នុងការសរសេរសារណាសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយក្តីអនុគ្រោះ។

១ តើសហគមន៍អេកូទេសចរណ៍ជីផាត ត្រូវបានផ្តួចផ្តើមកសាងឡើងដោយនរណា? បង្កើតឡើងក្នុងឆ្នាំណា? តើអ្នកណាខ្លះដែលចូលរួមគាំទ្រ?

២ តើមានហេតុផលអ្វីខ្លះដែលនាំអោយបង្កើតសហគមន៍អេកូទេសចរណ៍ជីផាតនេះឡើង? មានគោលបំណងចម្បងអ្វីខ្លះ?

៣ តើសហគមន៍អេកូទេសចរណ៍ជីផាត បានចូលរួមសកម្មភាពអ្វីខ្លះនៅទីនេះ? ហើយលោកប្រធានមានការគ្រប់គ្រង និងបែងចែករចនាសម្ព័ន្ធយ៉ាងដូចម្តេច?

៤ តើសហគមន៍អេកូទេសចរណ៍បបានចូលរួមបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ អ្វីខ្លះទៅដល់ប្រជាសហគមន៍?

៥ តើសហគមន៍អេកូទេសចរណ៍ជីផាតមានគោលការណ៍ណែនាំ និងបទបញ្ជាផ្ទៃក្នុងយ៉ាងដូចម្តេចសម្រាប់ប្រជាជនដែលរស់នៅក្នុងសហគមន៍?

៦ ជាមធ្យម តើសហគមន៍ទទួលបានចំណូលប៉ុន្មានប្រចាំឆ្នាំ ចាប់តាំពីមានការផ្លាស់ប្តូរទម្រង់នៃការគ្រប់គ្រងថ្មីមក? ហើយចំណូលដែលទទួលបាននោះមានការបែងចែកនិង គ្រប់គ្រងយ៉ាងដូចម្តេច?

៧ តើសហគមន៍អេកូទេសចរណ៍ជីផាតមានភាគីពាក់ព័ន្ធ និងដៃគូសហការណាខ្លះក្នុងការចូលរួមគ្រប់គ្រងអភិវឌ្ឍន៍សហគមន៍នេះ? តើស្ថាប័នទាំងនោះបានជួយអ្វីខ្លះដល់សហគមន៍?

៨ តើសហគមន៍អេកូទេសចរណ៍ជីផាតមានផែនការ និងការគ្រប់គ្រងបែបណាក្នុងការបណ្តុះបណ្តាលប្រជាជនក្នុងសហគមន៍?

៩ តើសហគមន៍អេកូទេសចរណ៍ជីផាតមានផែនការ និងយុទ្ធសាស្ត្របែបណាក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធតំបន់អោយកាន់តែល្អប្រសើរ។

១០ តើសហគមន៍អេកូទេសចរណ៍ជីផាត មានផែនការ និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងតំបន់ជីផាតយ៉ាងដូចម្តេច ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍អោយបានច្រើន?

១១ តើសហគមន៍អេកូទេសចរណ៍ជីផាតមានផែនការ និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងបែបណា ដើម្បីធានាសុវត្ថិភាពជូនភ្ញៀវទេសចរដែលចូលមកកំសាន្ត?

១២ តើសហគមន៍អេកូទេសចរណ៍ជីផាតមានផែនការ និងយុទ្ធសាស្ត្រយ៉ាងណាដើម្បីគ្រប់គ្រងធនធានដែលមានស្រាប់មិនអោយបាត់បង់ និងកាន់តែមានភាពទាក់ទាញថែមឡើងទៀត?

១៣ តើសហគមន៍អេកូទេសចរណ៍ជីផាត មានគម្រោងផែនការបែបណាសម្រាប់បម្រើនូវសម្បទាទេសចរណ៍ដើម្បីបំពេញតម្រូវការភ្ញៀវទេសចរណ៍ដែលមកកំសាន្ត?

១៤ តើសហគមន៍អេកូទេសចរណ៍ជីផាតមានគម្រោងផែនការ និងយុទ្ធសាស្ត្រក្នុងការកែលំអសហគមន៍យ៉ាងដូចម្តេច?

១៥ តើសហគមន៍អេកូទេសចរណ៍ជីផាតមានផែនការ និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងបែបណា ដើម្បីធានានិរន្តរភាពខាងបរិស្ថាន?

១៦ តើសហគមន៍អេកូទេសចរណ៍ជីផាតមានផែនការ និងយុទ្ធសាស្ត្រក្នុងការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ក្នុងសហគមន៍យ៉ាងដូចម្តេចខ្លះ?

១៧ តើពេលកន្លងមក សហគមន៍អេកូទេសចរណ៍ជីផាតមានផលប៉ះពាល់ និងផលវិបាកអ្វីខ្លះ ក្នុងការគ្រប់គ្រងនៅក្នុងសហគមន៍?

១៨ ចូរបង្ហាញពីភាពខ្លាំង ភាពខ្សោយ និងឱកាសនៃការគ្រប់គ្រងនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត។

១៩ តើនាថ្ងៃអនាគត សហគមន៍អេកូទេសចរណ៍មានគម្រោងផែនការ និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងតំបន់នេះយ៉ាងដូចម្តេច?

## កម្រងសំណួរសិក្សាស្រាវជ្រាវ

## សម្រាប់ ៖ ទេសចរ

## ក្រោមប្រធានបទ "ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ខេត្តកោះកុង"

ជំរាបសួរ លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរព យើងខ្ញុំជានិស្សិតឆ្នាំទី០៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ផ្នែកទេសចរណ៍ និងបដិសណ្ឋារកិច្ចដែលបានចុះសិក្សាស្រាវជ្រាវប្រមូលទិន្នន័យយកមកសិក្សា ដើម្បីរៀបចំធ្វើកិច្ចការស្រាវជ្រាវរបស់សាលា។ អាស្រ័យហេតុនេះ សូមលោក លោកស្រី អ្នកនាងកញ្ញា មេត្តាចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក ដើម្បីជួយផ្តល់នូវចម្លើយដែលលោកអ្នកពេញចិត្ត។ យើងខ្ញុំសូមជម្រាបថា រាល់ទិន្នន័យដែលបានពីកម្រង សំណួរនេះ គឺប្រើប្រាស់ក្នុងគោលដៅសំរាប់សិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

### I. ព័ត៌មានផ្ទាល់ខ្លួន

១. ភេទ

☐ ប្រុស ☐ ស្រី

២. អាយុ

☐ ១៨ឆ្នាំ -២៥ឆ្នាំ ☐ ២៦ឆ្នាំ -៣០ឆ្នាំ ☐ ៣០ឆ្នាំ -៣៥ឆ្នាំ ☐ ៣៦ឆ្នាំ -៤០ឆ្នាំ

៣. មុខរបរ

☐ និស្សិត ☐ មន្ត្រីរាជការ ☐ កសិករ ☐ អ្នកជំនួញ

☐ លក់ដូរ ☐ មេផ្ទះ ☐ បុគ្គលិកអង្គការ ☐ ផ្សេងៗ

### II. ព័ត៌មានទូទៅ

១. តើអ្នកស្គាល់សហគមន៍អេកូទេសចរណ៍ជីផាតតាមរយៈអ្វី?

☐ ទូរទស្សន៍ ☐ ទស្សនាវត្តី ☐ ក្រុមហ៊ុនទេសចរណ៍ ☐ មិត្តភក្តិ

☐ បងប្អូន

២. តើអ្នកធ្លាប់មកទស្សនាសហគមន៍អេកូទេសចរណ៍ជីផាតប៉ុន្មានដង?

☐ លើកទី១ ☐ ១ដង ☐ ២ដង ☐ ៣ដង ☐ លើសពី៣ដង

៣. តើអ្នកប្រើមធ្យោបាយបែបណា ក្នុងការធ្វើដំណើរមកកាន់សហគមន៍អេកូទេសចរណ៍ជីផាតនេះ?

☐ រថយន្តផ្ទាល់ខ្លួន ☐ រថយន្តឈ្នួល ☐ ម៉ូតូ ☐ ឡានក្រុង ☐ ផ្សេងៗ

៤. តើអ្នកមកទស្សនាសហគមន៍អេកូទេសចរណ៍ជីផាត ក្នុងគោលបំណងអ្វី?

☐ លំហែកំសាន្ត ☐ សិក្សាស្រាវជ្រាវ ☐ សួរសុខទុក្ខបងប្អូន មិត្តភក្តិ ☐ ផ្សេងៗ

៥. តើអ្នកមានគោលបំណងមកកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតប៉ុន្មានថ្ងៃ?

☐ ១ថ្ងៃ ☐ ២ថ្ងៃ ☐ ៣ថ្ងៃ ☐ លើសពី៣ថ្ងៃ

៦. តើអ្នកធ្លាប់ទៅទស្សនាសហគមន៍អេកូទេសចរណ៍ ក្នុងឱកាសអ្វី?

☐ បុណ្យជាតិ ☐ ថ្ងៃឈប់សម្រាក ☐ វិស្សមកាល ☐ ផ្សេងៗ

៧. តើអ្នកមកទស្សនាកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាត ក្នុងលក្ខណបែបណា?

☐ បុគ្គល ☐ ក្រុមគ្រួសារ ☐ មិត្តភក្តិ ☐ ផ្សេងៗ

៨. តើអ្នកចំណាយទៅលើអ្វីខ្លះ នៅក្នុងអំឡុងពេលដែលអ្នកមកទស្សនាកំសាន្ត នៅសហគមន៍អេកូទេសចរណ៍ជីផាត?

☐ សេវាកម្មដឹកជញ្ជូន ☐ សេវាកម្មស្នាក់នៅ ☐ សេវាកម្មម្ហូបអាហារ ☐ ផ្សេងៗ

៩. តើផ្លូវចូលទៅកាន់សហគមន៍អេកូទេសចរណ៍ជីផាត មានលក្ខណៈបែបណា?

☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១០. តើអ្នកទទួលទានអាហារនៅកន្លែងណា នៅពេលដែលអ្នកទៅទស្សនាកំសាន្តនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត?

☐ ផ្ទះស្នាក់សហគមន៍ ☐ អាហារដ្ឋាន ☐ ផ្ទាល់ខ្លួន

១១. តើអ្នកគ្រប់គ្រងក្នុងសហគមន៍អេកូទេសចរណ៍ជីផាត មានលក្ខណៈបែបណាដែរ?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១២. តើធនធានទាក់ទាញទេសចរណ៍ នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតមានលក្ខណៈបែបណា?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១៣. តើអ្នកយល់យ៉ាងណាដែរ ចំពោះសន្តិសុខ និងសុវត្ថិភាពនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១៤. តើការគ្រប់គ្រងកាកសំណល់ នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតយ៉ាងដូចម្តេច?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១៥. តើអ្នកយល់យ៉ាងណាដែរ ចំពោះបរិស្ថាននៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ កង្វក់ ☐ កង្វក់ណាស់

១៦. តើអ្នកយល់យ៉ាងណាដែរ ចំពោះសេវាកម្មដែលផ្តល់ដោយប្រជាសហគមន៍អេកូទេសចរណ៍ជីផាត?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១៧. តើអ្នកយល់យ៉ាងណាដែរ ចំពោះអាកប្បកិរិយារបស់ប្រជាជននៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត?

☐ រួសរាយ ☐ គំរូសគំរើស ☐ ឆ្មើងឆ្មៃ ☐ ធម្មតា ☐ ផ្សេងៗ

១៨. តើសកម្មភាពណាខ្លះដែលអ្នកចូលចិត្ត និងមិនចូលចិត្តនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត?

| | ចូលចិត្ត | មធ្យម | មិនចូលចិត្ត |
|---|---|---|---|
| ទស្សនាតាមភូមិក្នុងសហគមន៍ | ☐ | ☐ | ☐ |
| ថតរូបអនុស្សាវរីយ៍ | ☐ | ☐ | ☐ |
| ទិញផលិតផលក្នុងសហគមន៍ | ☐ | ☐ | ☐ |
| ទិញវត្ថុអនុស្សាវរីយ៍ | ☐ | ☐ | ☐ |
| ជិះទូកកំសាន្ត | ☐ | ☐ | ☐ |
| ជិះកង់កំសាន្ត | ☐ | ☐ | ☐ |
| ទស្សនារូងប្រចៀវ | ☐ | ☐ | ☐ |
| ទស្សនាពាងបុរាណ និងម្ឈូសបុរាណ | ☐ | ☐ | ☐ |

១៩. តម្លៃសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ ឬសេវាកម្មដទៃទៀត នៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតមានលក្ខណៈយ៉ាងណាដែរ?

| | ចូលចិត្ត | មធ្យម | មិនចូលចិត្ត |
|---|---|---|---|
| សេវាកម្មម្ហូបអាហារ និងភេសជ្ជៈ | ☐ | ☐ | ☐ |
| សេវាកម្មស្នាក់នៅ | ☐ | ☐ | ☐ |
| វត្ថុអនុស្សាវរីយ៍ | ☐ | ☐ | ☐ |
| ផលិតផលក្នុងតំបន់ | ☐ | ☐ | ☐ |

ជិះទូកកំសាន្ត ☐ ☐ ☐

ជិះកង់កំសាន្ត ☐ ☐ ☐

២០. តើស្លាកសញ្ញាបង្ហាញទិសនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាតមានគ្រប់គ្រាន់ដែរឬទេ?

☐ គ្រប់គ្រាន់ ☐ មិនទាន់គ្រប់គ្រាន់ ☐ មិនទាន់មាន

២១. បើមានឱកាស តើអ្នកចង់មកទស្សនាកំសាន្តសហគមន៍អេកូទេសចរណ៍ជីផាតនេះម្តងទៀតដែរឬទេ?

☐ ចង់ ☐ មិនចង់ ☐ ពិចារណាម្តងទៀត

២២. សម្រាប់គំនិតរបស់អ្នក តើអ្នកចង់អោយសហគមន៍អេកូទេសចរណ៍បង្កើតនូវផលិតផលឬសេវាកម្មថ្មីអ្វីទៀតដែរឬទេ?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

២៣. តើអ្នកមានមតិយោបល់ ឬសំណូមពរ ក្នុងការកែលម្អ គ្រប់គ្រង និងអភិវឌ្ឍន៍ ក៏ដូចជាអភិរក្សសហគមន៍អេកូទេសចរណ៍ជីផាត អោយមានការរីកចម្រើន ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ទាំងជាតិ និងអន្តរជាតិអោយចូលមកកំសាន្តកាន់តែច្រើនឡើងដែរឬទេ?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

## កម្រងសំណួរសិក្សាស្រាវជ្រាវ

## សម្រាប់ ៖ អាជីវករ និងប្រជាពលរដ្ឋមូលដ្ឋាន

## ក្រោមប្រធានបទ "ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត ខេត្តកោះកុង"

ជំរាបសួរ លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរព យើងខ្ញុំជានិស្សិតឆ្នាំទី០៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកទេសចរណ៍ និងបដិសណ្ឋារកិច្ចដែលបានចុះសិក្សាស្រាវជ្រាវប្រមូលទិន្នន័យយកមកសិក្សា ដើម្បីរៀបចំធ្វើកិច្ចការស្រាវជ្រាវរបស់សាលា។ អាស្រ័យហេតុនេះ សូមលោក លោកស្រី អ្នកនាងកញ្ញា មេត្តាចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក ដើម្បីជួយផ្តល់នូវចម្លើយដែលលោកអ្នកពេញចិត្ត។ យើងខ្ញុំសូមជម្រាបថា រាល់ទិន្នន័យដែលបានពីកម្រង សំណួរនេះ គឺប្រើប្រាស់ក្នុងគោលដៅសំរាប់សិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

### I. ព័ត៌មានផ្ទាល់ខ្លួន

១. ភេទ

☐ ប្រុស ☐ ស្រី

២. អាយុ

☐ ១៨ឆ្នាំ -២៥ឆ្នាំ ☐ ២៦ឆ្នាំ -៣០ឆ្នាំ ☐ ៣០ឆ្នាំ -៣៥ឆ្នាំ ☐ ៣៦ឆ្នាំ -៤០ឆ្នាំ

៣. មុខរបរ

☐ និស្សិត ☐ មន្ត្រីរាជការ ☐ កសិករ ☐ អ្នកជំនួញ

☐ លក់ដូរ ☐ មេផ្ទះ ☐ បុគ្គលិកអង្គការ ☐ ផ្សេងៗ

### II. ព័ត៌មានទូទៅ

១. តើអ្នកប្រកបអាជីពនេះអស់រយៈពេលប៉ុន្មានឆ្នាំមកហើយ?

☐ ១ឆ្នាំ ☐ ២ឆ្នាំ ☐ ៣ឆ្នាំ ☐ លើសពី៣ឆ្នាំ

២. តើអ្នកចេះពីរបៀបធ្វើម្ហូបនេះមកពីណា?

☐ គ្រួសារ ☐ ខ្លួនឯង ☐ បណ្តុះបណ្តាល

៣. តើគ្រឿងផ្សំដែលអ្នកយកមកប្រើប្រាស់ក្នុងការធ្វើម្ហូបមានប្រភពមកពីណា?

☐ ផ្សារ ☐ ដាំដុះដោយខ្លួនឯង ☐ ផលិតផលក្នុងស្រុក

៤. តើចំណូលជាមធ្យមរបស់អ្នកជាប្រចាំថ្ងៃទទួលបានប៉ុន្មាន?

.............................................................................................................................................

.............................................................................................................................................

៥. ក្រៅពីរបរនេះ តើអ្នកមានមុខរបរចិញ្ចឹមជីវិតផ្សេងទៀតដែរឬទេ?

☐ មាន ☐ មិនមាន

៦. តើអ្នកមានផ្ទះសំរាប់ជួលអោយភ្ញៀវទេសចរណ៍ស្នាក់អាស្រ័យដែរឬទេ? បើមានក្នុងតម្លៃប៉ុន្មាន?

.............................................................................................................................................

.............................................................................................................................................

៧. តើពេលកន្លងមក អ្នកតែងតែជួបបញ្ហាអ្វីខ្លះ សម្រាប់អាជីពមួយនេះ?

.............................................................................................................................................

.............................................................................................................................................

៨. តើអ្នកមានដំណោះស្រាយលើបញ្ហាទាំងអស់នោះដោយរបៀបណា?

.............................................................................................................................................

.............................................................................................................................................

៩. តើនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត មានប្រព័ន្ធទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ហើយឬនៅ?

☐ គ្រប់គ្រាន់ ☐ មិនទាន់គ្រប់គ្រាន់

១០. តើនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត មានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ហើយឬនៅ?

☐ គ្រប់គ្រាន់ ☐ មិនទាន់គ្រប់គ្រាន់

១១. តើស្ថាប័នពាក់ព័ន្ធ ឬអាជ្ញាធរមូលដ្ឋានដែលធ្វើការបណ្តុះបណ្តាលលើផ្នែកសេវាកម្មដល់អ្នកដែរឬទេ?

☐ម្តងម្កាល ☐ ញឹកញាប់ ☐ មិនដែលទាល់តែសោះ

១២. តើកាកសំណល់ដែលអ្នកប្រើប្រាស់រួចហើយ តើអ្នកយកវាទៅបោះចោលទីណា?

.............................................................................................................................................

.............................................................................................................................................

# ឧបសម្ព័ន្ធ “ខ”

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីបំពេញបន្ថែមវិសោធនកម្ម
# លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង
# សម្រាប់សហគមន៍អេកូទេសចរណ៍ជីផាត

រៀបរៀងឡើងដោយៈ
គណៈកម្មការសហគមន៍អេកូទេសចរណ៍ជីផាត
សមាជិកគំរោងសហគមន៍អេកូទេសចរណ៍ជីផាត អាជ្ញាធរក្នុង
តំបន់ និងឃុំជីផាត
អង្គការសម្ព័ន្ធមិត្តសត្វព្រៃ (WILDLIFE ALLIANCE)

ខែមករា ឆ្នាំ២០១៧

## ឧបសម្ព័ន្ធទី១៖ ផែនទី សហគមន៍អេកូទេសចរណ៍ ឃុំជីផាត



| ១. និយាមកាកន្លែងតំបន់ទាក់ទាញ និងកន្លែងកែលំអផ្លូវដើរព្រៃក្នុងសហគមន៍អេកូទេសចរណ៍ ឃុំជីផាត | | | |
|---|---|---|---|
| ល.រ | ទីតាំង | និយាមកា(UTM) | |
| | | X | Y |
| 1 | ឆាយជ្រៃ | | |
| 2 | ឆាយខ្ពស់ | | |
| 3 | អូរទឹកវេត | | |
| 4 | អរស្អត់ | | |
| 5 | ពាងបុរាណ | | |
| 6 | ទឹកធ្លាក់អូរម្លូរ | | |
| 7 | ទឹកធ្លាក់អូរស្រឡៅ | | |
| 8 | ឆាយថ្មទើង | | |
| 9 | ត្រពាំងគិត | | |
| 10 | ត្រពាំងថ្ម | | |
| 11 | វាលតាមាស | | |
| 12 | វាលតាប្រាក់ | | |
| 13 | ដំណាក់ខូស | | |
| 14 | ភ្នំត្រងោល | | |
| 15 | អូរពាមក្រវាញ | | |
| 16 | | | |
| 17 | | | |
| 18 | | | |
| 19 | | | |
| 20 | | | |
| 21 | | | |

**ឧបសម្ព័ន្ធទី២៖**

## និមិត្តសញ្ញា សហគមន៍អេកូទេសចរណ៍ ឃុំជីផាត

**ឧបសម្ព័ន្ធទី ៣៖**

គំរូត្រាសហគមន៍អេកូទេសចរណ៍ ឃុំជីផាត



## ឧបសម្ព័ន្ធទី ៤៖

### បញ្ជីឈ្មោះ គណៈកម្មការសហគមន៍អេកូទេសចរណ៍ ឃុំជីផាត

| ល.រ | ឈ្មោះ | ភេទ | តួនាទី | ផ្សេងៗ |
|---|---|---|---|---|
| ១ | ព្រំ ហឹង | ប្រុស | ប្រធានសហគមន៍ | |
| ២ | ស៊ីន សុភឿន | ប្រុស | អនុប្រធាន/ប្រធានគណនេយ្យ | |
| ៣ | ប៊ួយ សឿង | ស្រី | ប្រធានផ្នែកកក់/អនុប្រធានគណនេយ្យ | |
| ៤ | សុខ ស៊ីណាំ | ប្រុស | អ្នកទទួលភ្ញៀវទី១ | |
| ៥ | មិន ម៉ាណែត | ស្រី | អ្នកទទួលភ្ញៀវទី២ | |
| ៦ | តេង ដារ៉ុង | ប្រុស | ប្រធានសេវាកម្ម | |
| ៧ | ចក់ ចិន្តា | ស្រី | អនុប្រធានអាហារដ្ឋាន | |
| ៨ | ឈឿង កួន | ប្រុស | ប្រធានក្រុមល្បាត | |
| ៩ | សុខ ថានី | ស្រី | ប្រធានបារ និងភេសជ្ជៈ | |

## ឧបសម្ព័ន្ធទី ៥៖

### រចនាសម្ព័ន្ធគ្រប់គ្រងរបស់ គណៈកម្មការសហគមន៍អេកូទេសចរណ៍ ឃុំជីផាត



**ឧបសម្ព័ន្ធទី ៦៖**

## ប្រភពចំណូល និងការបែងចែកមូលនិធិ សហគមន៍អេកូទេសចរណ៍ ឃុំជីផាត




**ឧបសម្ព័ន្ធទី៧៖**

## លក្ខខណ្ឌ និងបទបញ្ជាផ្ទៃក្នុង នៃការជ្រើសរើសសមាជិកសេវាកម្ម សម្រាប់សហគមន៍អេកូទេសចរណ៍ ឃុំជីផាត

**១.បទបញ្ញាផ្ទៃក្នុងទូទៅ**

- ដំណើរការនៃការជ្រើសរើសសមាជិក

- សហគមន៍អេកូទេសចរណ៍ឃុំជីផាតនឹងប្រកាសជាសាធារណៈ អំពីការ ជ្រើសរើស សមាជិកសេវាស្នាក់នៅ ជាមួយនឹងចំនួនជាក់លាក់ និងលក្ខណៈវិនិច្ឆ័យ ច្បាស់លាស់។
- ការទទួលការដាក់ពាក្យ(តាមរយៈប្រធានក្រុមសេវាកម្មតាមភូមិ)
- ធ្វើការវាយតម្លៃបេក្ខជនជាមួយអាជ្ញាធរមូលដ្ឋាន
- ធ្វើការសំភាសន៍បេក្ខជន និងទៅពិនិត្យផ្ទះបេក្ខជន
- ប្រកាសជាសាធារណៈនូវគ្រួសារដែលត្រូវបានជ្រើសរើស
- គ្រប់សមាជិកសេវាកម្មទាំងអស់ ត្រូវតែចុះហត្ថលេខាលើកុងត្រា មានការចុះហត្ថលេខា ដោយលោកមេឃុំ និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ។

- **លក្ខណៈវិនិច្ឆ័យទូទៅសម្រាប់ការអភិវឌ្ឍ**
  - ផ្តល់ជម្រើសជីវភាពសម្រាប់ អ្នកបរបាញ់សត្វ អ្នកកាប់ឈើ អ្នកជួញដូរសត្វព្រៃ អ្នកប្រមូលអនុផលព្រៃឈើ និងអ្នកធ្វើចំការដោយកាប់និងដុតព្រៃ។
  - កាត់បន្ថយភាពក្រីក្រ
  - គាំទ្រការអភិវឌ្ឍរបស់ឃុំ

## ២. សេវាស្នាក់នៅ

លក្ខណៈវិនិច្ឆ័យសម្រាប់ចូលរួមជាសមាជិកសេវាស្នាក់នៅក្នុងសហគមន៍អេកូទេសចរណ៍៖

- អ្នកបរបាញ់សត្វព្រៃ អ្នកកាប់ឈើ អ្នកជួញដូរសត្វព្រៃ អ្នកប្រមូលអនុផលព្រៃឈើ អ្នកធ្វើចំការដោយកាប់ និងដុតព្រៃ
- យល់ព្រមបញ្ឈប់បរបាញ់សត្វព្រៃ កាប់ព្រៃឈើ ជួញដូរសត្វព្រៃ ធ្វើអាជីវកម្មលើអនុផលព្រៃឈើ ធ្វើចំការដោយកាប់ និងដុតព្រៃ បោះចោលសំរាម និងផ្លាស្ទិកពាសវាលពាសកាល។
- ពិតជាគ្រួសារក្រីក្រ ដែលមានការបញ្ជាក់ពីក្រុមប្រឹក្សាឃុំ
- ជាមនុស្សពេញវ័យ ដែលអាចបំរើសេវាកម្មនៅពេលមានភ្ញៀវ

- ត្រូវមានផ្ទះផ្ទាល់ខ្លួន
- ត្រូវចំណាយពេលវេលា និងធនធានខ្លះ សម្រាប់កែលំអសេវាកម្មរបស់ខ្លួន
- ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ និងចូលរួមបង្កើតអោយមានឃុំមួយផលិតផលមួយ
- យល់ព្រមចូលរួមវិភាគទានជាមួយមូលនិធិសហគមន៍២០%។
- យល់ព្រមចូលរួមសំអាតភូមិ និងប្រើប្រាស់សេវាកម្មប្រមូលសំរាមរបស់សហគមន៍
- យល់ព្រមគោរព និងជួយសមាជិកសហគមន៍ និងគណកម្មការសហគមន៍អេកូទេសចរណ៍តំបន់ជីផាត
- យល់ព្រមថែរក្សាសម្ភារៈ សហគមន៍ និងមិនប្រើជារបស់ផ្ទាល់ខ្លួន
- យល់ព្រមគោរពលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍របស់សហគមន៍ អេកូទេសៈចរណ៍ តំបន់ជីផាត
- សមាជិកផ្ទះស្នាក់ ត្រូវតែមានក្រុម ហើយត្រូវមានមេក្រុមម្នាក់ដើម្បីគ្រប់គ្រង ដែលចាត់ចែងដោយប្រធានក្រុមសេវាតាមភូមិ
- សមាជិកមិនត្រូវលក់ ឬប្រើប្រាស់សម្ភារៈរបស់សហគមន៍ សម្រាប់ហេតុផលណាមួយក្រៅពីក្រុមសេវាកម្មរបស់ខ្លួនឡើយ
- រាល់វិស័យឯកជនទាំងអស់ ដែលមានបំណងចង់ប្រកបអាជីវកម្មទេសចរណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍ ឃុំជីផាត ត្រូវតែមានការអនុញ្ញាតិពីអាជ្ញាធរមូលដ្ឋាន និងគណៈកម្មការសហគមន៍អេកូទេចរណ៍ជាមុនសិន
- **<u>ការឧបត្ថម្ភដល់សមាជិកសេវាស្នាក់នៅរួមមាន៖</u>**
  - ការកែលំអផ្ទះតាមភូមិ ឬផ្ទះតូចៗសម្រាប់ភ្ញៀវទេសចរ
  - ការរួមចំណែកក្នុងការសាងសង់បង្គន់អនាម័យ និងបន្ទប់ទឹក
  - សម្ភារៈដូចជា ពូក ខ្នើយ មុងភួយ កំរាលពូក ទូមានធ្នើរ និងធុងសំរាម
  - ការបណ្តុះបណ្តាលឲ្យចេះទទួលភ្ញៀវ (បដិសណ្ឋារកិច្ច) យល់ដឹងពីអនាម័យ និងបរិស្ថាន ព្រមទាំងភាសាអង់គ្លេស។

- **<u>កាតព្វកិច្ចរបស់សមាជិកសេវាស្នាក់នៅ</u>**

- សមាជិកសេវាស្នាក់នៅ ត្រូវលះបង់ពេលវេលា ដើម្បីកសាង និងកែលំអផ្ទះក៏ដូចជាការបោសសំអាតផ្ទះ
- សមាជិកសេវាស្នាក់នៅ ត្រូវតែសំអាតផ្ទះ និងបង្គន់ រួមទាំងបរិវេណ ជុំវិញផ្ទះឲ្យបានស្អាតជាប្រចាំ
- សមាជិកសេវាស្នាក់នៅ ត្រូវបោសសំអាតសម្ភារៈក្រោយពេលភ្ញៀវ ប្រើរួច
- សមាជិកសេវាស្នាក់នៅ ត្រូវផ្តល់ឲ្យភ្ញៀវដែលស្នាក់នៅប្រចាំថ្ងៃនូវទឹក២ដប ធុងសំរាម១ ក្រដាសអនាម័យ១ដុំ សាប៊ូ១ដុំ កន្សែងជូតខ្លួន២ ពូកដែលមានកំរាលស្អាត ខ្នើយ២ មុង១ ស្បែកជើងផ្ទាត់២គូរ
- សមាជិកសេវាស្នាក់នៅត្រូវចូលរួមគ្រប់វគ្គបណ្តុះបណ្តាល ដែលទាក់ទងនឹងសេវាកម្ម របស់ខ្លួនដែលបានផ្តល់ឲ្យ ដូចជាអនាម័យ និងការយល់ ដឹងពីបរិស្ថានជាដើម
- សមាជិកសេវាស្នាក់នៅត្រូវផ្តល់ពេលវេលា និងធនធានខ្លះសម្រាប់ការអភិវឌ្ឍន៍ និងដើម្បីឲ្យផលិតផលរបស់ខ្លួនកាន់តែប្រសើរឡើង
- សមាជិកសេវាស្នាក់នៅត្រូវចូលរួមប្រជុំប្រចាំខែក្នុងសេវាកម្មក្រុមរបស់ខ្លួន
- សមាជិកសេវាស្នាក់នៅត្រូវធានាសុវត្ថិភាព និងធ្វើឲ្យភ្ញៀវពេញចិត្ត
- សមាជិកសេវាស្នាក់នៅត្រូវយល់ដឹងឲ្យបានច្បាស់លាស់ និងអនុវត្តន៍តាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ។
- គ្មានការជួញដូរផ្លូវភេទ និងគ្រឿងញៀនសម្រាប់ភ្ញៀវទេសចរណ៍

- **<u>ការបែងចែកប្រាក់កម្រៃសម្រាប់សមាជិកសេវាស្នាក់នៅ</u>**
  - ភ្ញៀវទេសចរ និងកក់សេវាស្នាក់នៅហើយត្រូវបង់ប្រាក់នៅការិយាល័យសហគមន៍
  - ការិយាល័យសហគមន៍នឹងរៀបចំការកក់ឲ្យភ្ញៀវជូន សមាជិកសេវាស្នាក់នៅ
  - សមាជិកសេវាស្នាក់នៅ នឹងទទួលបានប្រាក់ថ្លៃសេវាកម្មរបស់ខ្លួននៅការិយាល័យសហគមន៍ពីប្រធានគណនេយ្យ

- តម្លៃផ្ទះសេវាស្នាក់នៅគឺផ្អែកលើកិច្ចព្រមព្រៀងជាក់ស្តែងរវាងសហគមន៍អេកូទេសចរណ៍ជីផាត និងសមាជិក។ស្ន

**៣. ទូកចែវ**

លក្ខណៈវិនិច្ឆ័យសម្រាប់ចូលរួមជាសមាជិកទូកចែវក្នុងសហគមន៍អេកូទេសចរណ៍ ឃុំជីផាត៖

- អ្នកបរបាញ់សត្វព្រៃ អ្នកកាប់ឈើ អ្នកជួញដូរសត្វព្រៃ អ្នកប្រមូលអនុផលព្រៃឈើ អ្នកធ្វើចំការដោយកាប់ និងដុតព្រៃ
- យល់ព្រមបញ្ឈប់បរបាញ់សត្វព្រៃ កាប់ព្រៃឈើ ជួញដូរសត្វព្រៃ ធ្វើអាជីវកម្មលើអនុផលព្រៃឈើ ធ្វើចំការដោយកាប់ និងដុតព្រៃ បោះចោលសំរាម និងផ្លាស្ទិកពាសវាលពាសកាល។
- ពិតជាគ្រួសារក្រីក្រ ដែលមានការបញ្ជាក់ពីក្រុមប្រឹក្សាឃុំ
- ជាមនុស្សពេញវ័យ ដែលអាចបំរើសេវាកម្មនៅពេលមានភ្ញៀវ
- ត្រូវមានទូកចែវផ្ទាល់ខ្លួន
- ត្រូវចំណាយពេលវេលា និងធនធានខ្លះសម្រាប់កែលំអសេវាកម្មរបស់ខ្លួន និងប្រាកដថាភ្ញៀវមានការពេញចិត្ត
- ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ
- យល់ព្រមចូលរួមវិភាគទានជាមួយមូលនិធិសហគមន៍២០%។
- យល់ព្រមក្នុងការការពារបរិស្ថាន
- យល់ព្រមចូលរួមសំអាតភូមិ និងប្រើប្រាស់សេវាកម្មប្រមូលសំរាមរបស់សហគមន៍
- យល់ព្រមគោរព និងជួយសមាជិកសហគមន៍ និងគណកម្មការសហគមន៍អេកូទេស-ចរណ៍តំបន់ជីផាត
- យល់ព្រមថែរក្សាសម្ភារៈ សហគមន៍ និងមិនប្រើជារបស់ផ្ទាល់ខ្លួន
- យល់ព្រមគោរពលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍របស់សហគមន៍ អេកូទេស-ចរណ៍តំបន់ជីផាត

- សមាជិកទូកចែវ ត្រូវតែមានក្រុម ហើយត្រូវមានមេក្រុមម្នាក់ដើម្បីគ្រប់គ្រង ដែលចាត់ចែងដោយប្រធានក្រុមសេវាតាមភូមិ
- សមាជិកទូកចែវ គឺជាមនុស្សពេញវ័យ ហើយស្គាល់តំបន់ដែលខ្លួនបំរើសេវាកម្មច្បាស់
- ត្រូវថែរក្សាបរិស្ថាន និងមិនចោលសំរាមទៅក្នុងស្ទឹង(ទឹក) ឬព្រៃ និងប្រមូលសំរាមទាំងអស់មកភូមិវិញ
- មិនត្រូវរុកគួន ឬស្រែករំខានសត្វព្រៃឡើយដូចជា៖ សត្វស្វា សត្វឈ្លូស ឬសត្វស្លាប និងប្រមូលឬ កាប់អ្វីពីព្រៃឡើយ
- ត្រូវគោរពកន្លែងដែលគួរជូនភ្ញៀវទៅ និងមិនគួរជូនទៅ និងជួយសំរួលកន្លែងស្នាក់នៅ ចម្អិនអាហារ ដូតទឹក បង្គន់អនាម័យ និងប្រមូលសំរាម។
- ជាអប្បរមាទូកចែវមួយ មានភ្ញៀវយ៉ាងច្រើនពីរនាក់និង មានអាវសុវត្ថិភាពជូនភ្ញៀវទេសចរ
- សមាជិកមិនត្រូវលក់ ឬប្រើប្រាស់សម្ភារៈរបស់សហគមន៍ សម្រាប់ហេតុផលណាមួយក្រៅពី ក្រុមសេវាកម្មរបស់ខ្លួនឡើយ

- **<u>ការឧបត្ថម្ភដល់សមាជិកសេវាទូកចែវរួមមាន៖</u>**
  - ចូលរួមវគ្គបណ្តុះបណ្តាល និង របៀបប្រើប្រាស់ឧបករណ៍
  - សម្ភារៈសម្រាប់កែលំអទូកចែវ(ថ្នាំលាបការពារទូកចែវ កៅអី)
  - អាវយឺតសហគមន៍ និងកាតខ្លួនសំគាល់ជាសមាជិកសគមន៍
- **<u>កាតព្វកិច្ចរបស់សមាជិកសេវាទូកចែវ</u>**
  - ត្រូវប្រាកដថាភ្ញៀវមានសុវត្ថិភាព និង មានភាពពេញចិត្ត
  - ត្រូវគោរពសមាជិកសហគមន៍ផ្សេងទៀត
  - ត្រូវតែសំអាតទូកចែវអោយស្អាតជានិច្ច
  - ចូលរួមវគ្គបណ្តុះបណ្តាល ដូចជា បដិសណ្ឋារកិច្ច អនាម័យ និងការយល់ដឹងពីបរិស្ថាន ភាសាអង់គ្លេស សង្គ្រោះបឋមជាដើម
  - ចូលរួមរាល់ប្រជុំជាមួយសមាជិកសហគមន៍

- សមាជិកសេវាស្នាក់នៅត្រូវផ្តល់ពេលវេលា និងធនធានខ្លះសម្រាប់ការអភិវឌ្ឍន៍ និងដើម្បីឲ្យផលិតផលរបស់ខ្លួនកាន់តែប្រសើរឡើង
- សមាជិកសេវាទូកចែវត្រូវយល់ដឹងឲ្យបានច្បាស់លាស់ និងអនុវត្តន៍តាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ។

- **ការកក់ និងបែងចែងប្រាក់កំរៃ**
  - ភ្ញៀវទេសចរនឹងកក់សេវាទូកចែវ ហើយត្រូវបង់ប្រាក់នៅការិយាល័យសហគមន៍ ដោយអ្នកផ្តល់សេវាទូកចែវគោរពតាមការបែងចែកវេន
  - សមាជិកសេវាទូកចែវ នឹងទទួលបានប្រាក់ថ្លៃសេវាកម្មរបស់ខ្លួននៅការិយាល័យសហគមន៍ ពីប្រធានគណនេយ្យ
  - តម្លៃទូកចែវគឺអាស្រ័យទៅលើសមាជិកពិភាក្សាគ្នា
  - សមាជិកមិនត្រូវទទួលការបង់ថ្លៃពីភ្ញៀវផ្ទាល់បានទេ ដោយណែនាំអោយភ្ញៀវទៅបង់នៅសហគមន៍

## ៤.ម៉ូតូឌុប

លក្ខណៈវិនិច្ឆ័យសម្រាប់ចូលរួមជាសមាជិកម៉ូតូឌុបក្នុងសហគមន៍អេកូទេសចរណ៍៖

- អ្នកបរបាញ់សត្វព្រៃ អ្នកកាប់ឈើ អ្នកជួញដូរសត្វព្រៃ អ្នកប្រមូលអនុផលព្រៃឈើ អ្នកធ្វើចំការដោយកាប់ និងដុតព្រៃ
- យល់ព្រមបញ្ឈប់បរបាញ់សត្វព្រៃ កាប់ព្រៃឈើ ជួញដូរសត្វព្រៃ ធ្វើអាជីវកម្មលើអនុផលព្រៃឈើ ធ្វើចំការដោយកាប់ និងដុតព្រៃ បោះចោលសំរាម និងផ្លាស្ទិកពាសវាលពាសកាល។
- ពិតជាគ្រួសារក្រីក្រ និងអាកប្បកិរិយាល្អ ដែលមានការបញ្ជាក់ពីក្រុមប្រឹក្សាឃុំ
- ជាមនុស្សពេញវ័យ ដែលអាចបំរើសេវាកម្មនៅពេលមានភ្ញៀវ
- ត្រូវមានម៉ូតូផ្ទាល់ខ្លួន

- ត្រូវចំណាយពេលវេលានិងធនធានខ្លះ សម្រាប់កែលំអសេវាកម្មរបស់ខ្លួន និងប្រាកដថាភ្ញៀវពេញចិត្ត
- ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ
- យល់ព្រមចូលរួមវិភាគទានជាមួយមូលនិធិសហគមន៍
- យល់ព្រមថែរក្សា ការពារបរិស្ថាន
- យល់ព្រមចូលរួមសំអាតភូមិ និងប្រើប្រាស់សេវាកម្មប្រមូលសំរាមរបស់សហគមន៍
- យល់ព្រមគោរព និងជួយសមាជិកសហគមន៍ និងគណកម្មការសហគមន៍អេកូទេសចរណ៍ តំបន់ជីផាត
- យល់ព្រមថែរក្សាសម្ភារៈ សហគមន៍ និងមិនប្រើជារបស់ផ្ទាល់ខ្លួន
- យល់ព្រមគោរព លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍របស់សហគមន៍អេកូទេសចរណ៍ តំបន់ជីផាត
- សមាជិកម៉ូតូឌុប ត្រូវតែមានក្រុម ហើយត្រូវមានមេក្រុមម្នាក់ដើម្បីគ្រប់គ្រង ដែលចាត់ចែងដោយប្រធានក្រុមសេវាតាមភូមិជីផាត
- សមាជិកម៉ូតូឌុប គឺជាមនុស្សពេញវ័យ ហើយស្គាល់តំបន់ដែលខ្លួនបំរើសេវាកម្មច្បាស់
- ត្រូវថែរក្សាបរិស្ថាន និងមិនចោលសំរាមទៅក្នុងស្ទឹង(ទឹក) ឬព្រៃ និងប្រមូលសំរាមទាំងអស់មកភូមិវិញ
- មិនត្រូវរុកកួន ឬស្រែករំខានសត្វព្រៃឡើយដូចជា៖ សត្វស្វា សត្វឈ្លូស ឬសត្វស្លាប និងប្រមូលឬ កាប់អ្វីពីព្រៃឡើយ
- ត្រូវគោរពនិងដឹងថាកន្លែងណាដែលត្រូវជូនភ្ញៀវទៅ និងកន្លែងណាដែលមិនត្រូវជូនភ្ញៀវទៅ និងជួយសំរួលដល់ការ ហែលទឹក ងូតទឹក បង្គន់អនាម័យ និងប្រមូលសំរាម។
- ជាអប្បរមាម៉ូតូឌុបមួយ មានភ្ញៀវម្នាក់និង មានមួកសុវត្ថិភាពជូនភ្ញៀវទេសចរ
- សមាជិកមិនត្រូវលក់ ឬប្រើប្រាស់សម្ភារៈរបស់សហគមន៍ សម្រាប់ហេតុផលណាមួយក្រៅពី ក្រុមសេវាកម្មរបស់ខ្លួនឡើយ

- **<u>ការឧបត្ថម្ភដល់សមាជិកសេវាម៉ូតូឌុបរួមមាន៖</u>**

- ចូលរួមវគ្គបណ្តុះបណ្តាល និង របៀបប្រើប្រាស់សម្ភារៈ
- កែលំអ និងជួសជុលម៉ូតូ(អាចខ្ចីលុយទិញម៉ូតូថ្មី បើសិនមានលុយ)
- អាវយឺតសហគមន៍ និងប័ណ្ណសំគាល់ខ្លួនជាសមាជិកសហគមន៍

- **<u>កាតព្វកិច្ចរបស់សមាជិកសេវាម៉ូតូឌុប</u>**
  - ត្រូវប្រាកដថាភ្ញៀវមានការពេញចិត្ត និងមានសុវត្ថិភាព
  - គោរពសមាជិកសហគមន៍
  - ត្រូវចេះសំអាតទុក ម៉ូតូ និងថែទាំឲ្យបានល្អ
  - ត្រូវចូលរួមគ្រប់វគ្គបណ្តុះបណ្តាល ដូចជា បដិសណ្ឋារកិច្ច ការយល់ដឹងពីបរិស្ថាន ភាសាអង់គ្លេស និងសង្គ្រោះបឋម
  - ត្រូវចូលរួមប្រជុំប្រចាំខែក្នុងក្រុមរបស់ខ្លួន
  - ត្រូវផ្តល់ពេលវេលា និងធនធានខ្លះៗសម្រាប់ការអភិវឌ្ឍន៍ ដើម្បីឲ្យសេវាកម្មរបស់ខ្លួនកាន់តែប្រសើរឡើង
  - ត្រូវគោរពលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍

- **<u>ការកក់ និងការបែងចែកប្រាក់កម្រៃ</u>**
  - ភ្ញៀវទេសចរនឹងកក់សេវាកម្មម៉ូតុឌុប ហើយបង់ប្រាក់នៅការិយាល័យសហគមន៍។ ការិយាល័យសហគមន៍ នឹងរៀបចំការកក់ឲ្យភ្ញៀវលើសេវាកម្ម តាមតារាងវេនរបស់អ្នកផ្តល់សេវាកម្ម
  - ម៉ូតូឌុប នឹងទទួលប្រាក់ចំណាយរបស់ភ្ញៀវនៅការិយាល័យសហគមន៍ពីប្រធានគណនេយ្យ ឬប្រធានសេវាកម្ម។
  - តំលៃម៉ូតូឌុប នឹងធ្វើការសម្រេចចិត្តនៅពេលអនាគត
  - សមាជិកមិនត្រូវទទួលការបង់ថ្លៃពីភ្ញៀវផ្ទាល់បានទេ ដោយណែនាំអោយភ្ញៀវទៅបង់នៅសហគមន៍

**<u>៥. មគ្គុទេសក៍ដើរព្រៃ (អភិវឌ្ឍន៍សៀវភៅណែនាំ)</u>**

លក្ខណៈវិនិច្ឆ័យសម្រាប់ចូលរួមជាសមាជិកមគ្គុទេសក៍ក្នុងសហគមន៍អេកូទេសចរណ៍៖

- អ្នកបរបាញ់សត្វព្រៃ អ្នកកាប់ឈើ អ្នកជួញដូរសត្វព្រៃ អ្នកប្រមូលអនុផលព្រៃឈើ អ្នកធ្វើចំការដោយកាប់ និងដុតព្រៃ
- យល់ព្រមបញ្ឈប់បរបាញ់សត្វព្រៃ កាប់ព្រៃឈើ ជួញដូរសត្វព្រៃ ធ្វើអាជីវកម្មលើអនុផលព្រៃឈើ ធ្វើចំការដោយកាប់ និងដុតព្រៃ បោះចោលសំរាម និងប្លាស្ទិកពាសវាលពាសកាល។
- ពិតជាគ្រួសារក្រីក្រ ដែលមានការបញ្ជាក់ពីក្រុមប្រឹក្សាឃុំ
- ជាមនុស្សពេញវ័យ ដែលអាចបំរើសេវាកម្មនៅពេលមានភ្ញៀវ
- ត្រូវចំណាយពេលវេលា និងធនធានខ្លះ សម្រាប់កែលំអសេវាកម្មរបស់ខ្លួន និងត្រូវប្រាកដថាភ្ញៀវមានការពេញចិត្ត
- ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ
- យល់ព្រមចូលរួមវិភាគទានជាមួយមូលនិធិសហគមន៍
- យល់ព្រមថែរក្សា ការពារបរិស្ថាន
- យល់ព្រមចូលរួមសំអាតភូមិ និងប្រើប្រាស់សេវាកម្មប្រមូលសំរាមរបស់សហគមន៍
- យល់ព្រមគោរព និងជួយសមាជិកសហគមន៍ និងគណកម្មការសហគមន៍ អេកូទេសចរណ៍ តំបន់ជីផាត
- យល់ព្រមថែរក្សាសម្ភារៈសហគមន៍ និងមិនប្រើជារបស់ផ្ទាល់ខ្លួន
- យល់ព្រមគោរព លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍របស់សហគមន៍អេកូទេសចរណ៍ តំបន់ជីផាត
- សមាជិកមគ្គុទេសក៍ដើរព្រៃ ត្រូវតែមាន "ក្រុមមគ្គុទេសក៍ដើរព្រៃ" ហើយត្រូវមានសមាជិកម្នាក់ នឹងក្លាយជាមេក្រុម
- សមាជិកមគ្គុទេសក៍ដើរព្រៃ គឺជាមនុស្សពេញវ័យ ហើយស្គាល់តំបន់ដែលខ្លួនបំរើសេវាកម្មច្បាស់

- ត្រូវថែរក្សាបរិស្ថាន និងមិនត្រូវចោលសំរាមទៅក្នុងស្ទឹង(ទឹក) ឬព្រៃ និងត្រូវប្រមូលសំរាមមិនងាយរលួយទាំងអស់នោះមកភូមិវិញ
- មិនត្រូវរំខានឬស្រែកបំភ័យសត្វព្រៃឡើយដូចជា៖ សត្វស្វា សត្វឈ្លូស ឬសត្វស្លាប និងប្រមូលឬ កាប់អ្វីពីព្រៃឡើយជីផាត
- ត្រូវគោរពទីកន្លែងណាដែលគួរនាំ ឬមិនគួរនាំភ្ញៀវទៅ និងជួយសម្រួលសម្រាប់កន្លែងគេង ចម្អិនអាហារ ងូតទឹក បង្គន់ និងសំរាមផ្សេងៗ
- មគ្គុទេសក៍ដើរព្រៃ១នាក់អាចនាំភ្ញៀវបាន៤នាក់ និងត្រូវតែមានសម្ភារៈសង្គ្រោះបឋម
- សមាជិកមិនត្រូវលក់ ឬប្រើប្រាស់សម្ភារៈរបស់សហគមន៍ សម្រាប់ហេតុផលណាមួយ ក្រៅពីក្រុមសេវាកម្មរបស់ខ្លួនឡើយ

• **<u>ការឧបត្ថម្ភដល់សមាជិកមគ្គុទេសក៍ដើរព្រៃ</u>**

- បណ្តុះបណ្តាល និងបង្ហាញពីរបៀបប្រើប្រាស់សម្ភារៈ (សៀវភៅអំពីសត្វ និងសៀវភៅ ជានជើងសត្វ)
- សម្ភារៈរួមមាន៖ សាក់កាដូវ អង្រឹង ឧបករណ៍មើលពីចំងាយ កូនកាំបិត ចានស្លាបព្រា
- បណ្ណ័សំគាល់សមាជិក និងអាវយឺតសហគមន៍

• **<u>កាតព្វកិច្ចរបស់សមាជិកមគ្គុទេសក៍ដើរព្រៃ</u>**

- ត្រូវប្រាកដថាភ្ញៀវមានការពេញចិត្ត មានសុវត្ថិភាព និងត្រូវចេះជួយភ្ញៀវ
- ត្រូវគោរពសមាជិកសហគមន៍
- ត្រូវថែទាំសម្ភារៈឲ្យបានល្អ ហើយត្រូវសំអាតនៅរាល់ក្រោយពេលដំណើរកំសាន្ត
- ចូលរួមវគ្គបណ្តុះបណ្តាល ដូចជា៖ បដិសណ្ឋារកិច្ច អនាម័យ បរិស្ថាន ភាសាអង់គ្លេស និងសង្គ្រោះបឋម
- ចូលរួមប្រជុំសមាជិកក្រុម

- ត្រូវផ្តល់ពេលវេលា និងធនធានខ្លះៗសម្រាប់ការអភិវឌ្ឍន៍ ដើម្បីឲ្យសេវាកម្មរបស់ខ្លួនកាន់តែប្រសើរឡើង
- ត្រូវគោរពលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍

- <u>**ការកក់ និងការបែងចែកប្រាក់កម្រៃ**</u>
  - ភ្ញៀវទេសចរនឹងកក់សេវាកម្មមគ្គុទេសក៍ ហើយបង់ប្រាក់នៅការិយាល័យសហគមន៍។ ការិយាល័យសហគមន៍អេកូទេសចរណ៍ ឃុំជីផាត នឹងរៀបចំការកក់ឲ្យភ្ញៀវទេសចរ លើសេវាកម្មនាំភ្ញៀវ តាមតារាងវេនអ្នកផ្តល់សេវាកម្មនេះ
  - សមាជិកក្រុមមគ្គុទេសក៍ នឹងទទួលប្រាក់ចំណាយរបស់ភ្ញៀវនៅការិយាល័យសហគមន៍
  - មគ្គុទេសក៍អាចនាំភ្ញៀវមួយក្រុមដល់១នាក់៥នាក់៖
    - ភ្ញៀវ១នាក់ដល់៥នាក់=៦០,០០០រៀលក្នុងមួយថ្ងៃ។ មគ្គុទេសក៍ទទួលបាន៤៨,០០០រៀល និង១២,០០០រៀលត្រូវបង់ចូលមូលនិធិសហគមន៍។
    - តម្លៃគេងក្នុងព្រៃរបស់មគ្គុទេសក៍ក្នុងមួយយប់ ស្មើរនឹង៦០,០០០រៀល ក្នុងនោះ មគ្គុទេសក៍ទទួលបាន៤៨,០០០រៀល និង១២,០០០រៀលត្រូវបង់ចូលមូលនិធិ សហគមន៍។
  - សមាជិកមិនត្រូវទទួលការបង់ថ្លៃពីភ្ញៀវផ្ទាល់បានទេ ដោយណែនាំអោយភ្ញៀវទៅបង់នៅសហគមន៍

### ៧. ការដួលសម្ភារៈនិងបរិក្ខារ

- សមាជិកត្រូវតែជាមនុស្សពេញវ័យដែលអាចបម្រើសេវាកម្មបានដូចជាដួលសម្ភារៈ
- មិនត្រូវបោះសំរាមទៅក្នុងស្ទឹង ឬតាមព្រៃ ឬក្នុងភូមិឡើយ និងត្រូវតែប្រើប្រាស់សេវាកម្មប្រមូលសំរាមសហគមន៍
- ត្រូវគោរពទីកន្លែងដែលមិនអាចដួលអ្វីមួយឲ្យភ្ញៀវបាន

- សមាជិកជួលសម្ភារៈមិនអាចលក់ដូរឬប្រើប្រាស់សម្ភារៈសហគមន៍សម្រាប់ហេតុផលណាមួយក្រៅពី ក្រុមសេវាកម្មជួលសម្ភារៈបានឡើយ

- **ការឧបត្ថម្ភដល់សមាជិកក្រុមជួលសម្ភារៈ**
  - បណ្តុះបណ្តាល និងបង្ហាញពីរបៀបប្រើប្រាស់សម្ភារៈ (ឈ្មោះជាភាសាខ្មែរ និងភាសាអង់គ្លេស)
  - សម្ភារៈថ្មីសម្រាប់ជួល ឬកែលំអសម្ភារៈណាដែលចាស់
  - សម្ភារៈ និងឧបករណ៍ត្រូវទុកសម្រាប់ជួលឲ្យភ្ញៀវទេសចរ
  - បណ្ណ័សំគាល់ខ្លួន និងអាវយឺតសមាជិកក្រុមសេវាកម្មជួលសម្ភារៈរបស់សហគមន៍អេកូទេសចរណ៍ឃុំជីផាត។

- **កាតព្វកិច្ចរបស់សមាជិកក្រុមជួលសម្ភារៈ**
  - ត្រូវប្រាកដថាភ្ញៀវមានការពេញចិត្ត
  - ត្រូវគោរពសមាជិកសហគមន៍
  - ត្រូវថែទាំសម្ភារៈ ជួសជុល និងជូតសំអាតសម្ភារៈឧបករណ៍ឲ្យស្អាតជានិច្ច ក្រោយពេលប្រើរួច
  - ត្រូវតែចូលរួមវគ្គបណ្តុះបណ្តាលក្នុងសេវាកម្មបំរើភ្ញៀវដូចជាៈបដិសណ្ឋារកិច្ច(របៀបស្វាគមន៍ភ្ញៀវ) ការយល់ដឹងពីអនាម័យបរិស្ថាន ភាសាអង់គ្លេស ការថៃរក្សាកង់
  - ត្រូវចូលរួមការប្រជុំរបស់ក្រុមសមាជិកសេវា
  - ត្រូវផ្តល់ពេលវេលា និងធនធានខ្លះសម្រាប់ការអភិវឌ្ឍន៍ ដើម្បីឲ្យផលិតផលរបស់ខ្លួន កាន់តែប្រសើរឡើង។
  - ត្រូវគោរពលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង របស់សហគមន៍អេកូទេសចរណ៍ តំបន់ឃុំ ជីផាត

- **ការបែងចែកប្រាក់កម្រៃ**
  - ភ្ញៀវទេសចរណ៍នឹងជួលសម្ភារៈពីការិយាល័យសហគមន៍
  - អ្នកដឹកនាំក្រុមនឹងរៀបចំ តាមតារាងវេនអ្នកផ្តល់សេវាកម្មនោះ

- តម្លៃក្នុងការជួលសម្ភារៈ
    - សម្ភារៈហែលទឹក តម្លៃ២០០០រៀល ហើយ១០០០រៀលសម្រាប់បង់ចូលមូលនិធិសហគមន៍
    - សាក់កាដូ តម្លៃ៨០០០រៀល ៦០០០រៀលត្រូវបង់ចូលមូលនិធិសហគមន៍
    - អង្រឹង ជាមួយមុង និងតង់ តម្លៃ៨០០០រៀល
    - ភួយ តម្លៃ៤០០០រៀល ២០០រៀលត្រូវបង់ចូលមូលនិធិសហគមន៍
    - កង់ធម្មតាសម្រាប់ជិះក្នុងសហគមន៍ តម្លៃ៨០០០រៀលក្នុងមួយថ្ងៃ
    - កង់ពិសេសសម្រាប់ជិះក្នុងព្រៃតម្លៃ ៤០០០០រៀលក្នុងមួយថ្ងៃ

**ក្រុមចុងភៅ**

- លក្ខណៈវិនិច្ឆ័យសម្រាប់ចូលរួមជាសមាជិកចុងភៅក្នុងសហគមន៍អេកូទេសចរណ៍៖
    - អ្នកបរបាញ់សត្វព្រៃ អ្នកកាប់ឈើ អ្នកជួញដូរសត្វព្រៃ អ្នកប្រមូលអនុផលព្រៃឈើ អ្នកធ្វើចំការដោយកាប់ និងដុតព្រៃ
    - យល់ព្រមបញ្ឈប់បរបាញ់សត្វព្រៃ កាប់ព្រៃឈើ ជួញដូរសត្វព្រៃ ធ្វើអាជីវកម្មលើអនុផលព្រៃឈើ ធ្វើចំការដោយកាប់ និងដុតព្រៃ បោះចោលសំរាម និងផ្លាស្ទិក។
    - ពិតជាគ្រួសារក្រីក្រ ដែលមានការបញ្ជាក់ពីក្រុមប្រឹក្សាឃុំ
    - ជាមនុស្សពេញវ័យ ដែលអាចបំរើសេវាកម្មនៅពេលមានភ្ញៀវ
    - ត្រូវចំណាយពេលវេលា និងធនធានខ្លះ សម្រាប់កែលំអសេវាកម្មរបស់ខ្លួន និងត្រូវប្រាកដថាភ្ញៀវពេញចិត្ត
    - ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ
    - យល់ព្រមចូលរួមវិភាគទានជាមួយមូលនិធិសហគមន៍
    - យល់ព្រមថែរក្សា ការពារបរិស្ថាន
    - យល់ព្រមចូលរួមសំអាតភូមិ និងប្រើប្រាស់សេវាកម្មប្រមូលសំរាម

- យល់ព្រមគោរព និងជួយសមាជិកសហគមន៍ និងគណកម្មការសហគមន៍ អេកូទេសចរណ៍ តំបន់ជីផាត
- យល់ព្រមថែរក្សាសម្ភារៈសហគមន៍ និងមិនប្រើជារបស់ផ្ទាល់ខ្លួន
- យល់ព្រមគោរព លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍របស់សហគមន៍ អេកូទេសចរណ៍ តំបន់ជីផាត
- សមាជិកចុងភៅ ត្រូវតែមាន "ក្រុមចុងភៅ" ហើយត្រូវមានសមាជិកម្នាក់ នឹងក្លាយជាមេក្រុម
- ក្នុងមួយភូមិត្រូវមានសមាជិកចុងភៅ១០នាក់ ដូចនេះសរុបសមាជិកចុងភៅ ៨០ នាក នឹងបម្រើសេវាកម្មអាហារតាមអាហារដ្ឋាន
- សមាជិកចុងភៅគឺជាមនុស្សពេញវ័យ និងត្រូវមានចុងភៅ៣នាក់សម្រាប់បម្រើភ្ញៀវ
- អាហារដ្ឋានតាមឃុំជាកម្មសិទ្ធិរបស់ឃុំ និងគ្រប់គ្រងដោយក្រុមចុងភៅ
- ត្រូវថែរក្សាបរិស្ថាន និងមិនត្រូវចោលសំរាមទៅក្នុងស្ទឹង(ទឹក) ឬព្រៃ ឬ តាមភូមិ ហើយត្រូវប្រើប្រាស់សេវាកម្មប្រមូលសំរាម និងទុកដាក់កាកសំណល់អាហារនៅកន្លែងសមស្រប។
- ត្រូវតែថែរក្សាអនាម័យ និងភាពស្អាតៈ
  - ត្រូវលាងដៃមុននឹងចម្អិនអាហារ និងមិនអនុញ្ញាតឲ្យចម្អិនឡើយ ក្នុងករណីមានជម្ងឺក្រពះ
  - ត្រូវលាងបន្លែ ផ្លែឈើឲ្យបានស្អាតមុននឹងចម្អិន និងមុនពេលបម្រើដល់ភ្ញៀវ
  - ត្រូវលាងសំអាតសម្ភារៈផ្ទះបាយដូចជាៈ ចាន ស្លាបព្រា សម ឆ្នាំង ក្រោយពេលប្រើប្រាស់រួច
  - សំអាតតុអាហារ កៅអី និងទីធ្លាឲ្យបានស្អាតជារៀងរាល់ថ្ងៃ
- មិនអាចលក់ដូរឬប្រើប្រាស់សម្ភារៈសហគមន៍សម្រាប់ហេតុផលណាមួយក្រៅពីក្រុមសេវាកម្មចុងភៅបានឡើយ

- **ការឧបត្ថម្ភសមាជិកក្រុមសេវាកម្មចុងភៅ**

- បណ្តុះបណ្តាល និងបង្ហាញពីរបៀបប្រើប្រាស់សម្ភារៈ (បញ្ជីមុខម្ហូបជាភាសាខ្មែរ និងភាសាអង់គ្លេស)
- បង្កើតអាហារដ្ឋានរួមតាមឃុំ

• <u>កាតព្វកិច្ចរបស់សមាជិកក្រុមចុងភៅ</u>

- ត្រូវតែជានាថាភ្ញៀវពេញចិត្ត និងមានសុវត្ថិភាព
- ត្រូវគោរពសមាជិកសហគមន៍
- ត្រូវសំអាតអាហារដ្ឋាន ធ្វើយ៉ាងណាឲ្យមានអនាម័យ និងលក្ខណៈល្អ
- ថែរក្សាសម្ភារៈដូចជា៖ លាងសំអាតសម្ភារៈបន្ទាប់ពីប្រើហើយ
- ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗដូចជា៖ បដិសណ្ឋារកិច្ច អនាម័យបរិស្ថាន ភាសាអង់គ្លេស ការចម្អិនអាហារ និងការគ្រប់គ្រងជំនួញ
- ចូលរួមការប្រជុំរបស់សមាជិកក្រុម
- សមាជិកក្រុមចុងភៅភូមិ ត្រូវផ្តល់ពេលវេលា និងធនធានខ្លះសម្រាប់ការអភិវឌ្ឍន៍ ដើម្បីឲ្យម្ហូប និងសេវាកម្មរបស់ខ្លួនកាន់តែប្រសើរឡើង
- គោរពលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងរបស់សហគមន៍

**ឧបសម្ព័ន្ធទី ៨៖**

**គោលការណ៍សហប្រតិបត្តិការរវាង គណៈកម្មការសហគមន៍អេកូទេសចរណ៍ ឃុំជីផាត ជាមួយនឹង វិស័យឯកជន (ការីទេសចរណ៍ ភ្នាក់ងារទេសចរណ៍)**

**គោលការណ៍ទូទៅ៖**

១. វិស័យឯកជនត្រូវតែគោរពច្បាប់នៃព្រះរាជាណាចក្រកម្ពុជា

២. វិស័យឯកជន ត្រូវធ្វើការបញ្ជាក់លក្ខខណ្ឌនៃការអនុវត្តន៍វិស័យទេសចរណ៍ និងគោរពទៅតាមគោលការណ៍នៃការការពារបរិស្ថាន

៣. វិស័យឯកជន ត្រូវតែគោរពសហគមន៍ ព្រមទាំងលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងសហគមន៍អេកូ-ទេសចរណ៍ ឃុំជីផាត។

**ការព្រមព្រៀង៖**

ក. វិស័យឯកជន ត្រូវទទួលស្គាល់ថា អាជ្ញាធរមូលដ្ឋាន និងគណៈកម្មការសហគមន៍អេកូទេសចរណ៍ ឃុំជីផាត ជាអ្នកមានសិទ្ធិ គ្រប់គ្រងវិស័យទេសចរណ៍ ក្នុងឃុំជីផាត ព្រមទាំងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍អេកូទេសចរណ៍ ឃុំជីផាត។

ខ. គណៈកម្មការសហគមន៍អេកូទេសចរណ៍ ឃុំជីផាត និងវិស័យឯកជន ត្រូវយល់ព្រមក្នុងការសហការរួមគ្នា សម្រាប់ការបែងចែកផលប្រយោជន៍រវាងសហគមន៍ និងវិស័យឯកជន។

គ. គណៈកម្មការសហគមន៍អេកូទេសចរណ៍ ឃុំជីផាត និងវិស័យឯកជន ត្រូវធ្វើកិច្ចព្រមព្រៀងមួយច្បាស់លាស់ ដោយបញ្ជាក់ពីគោលការណ៍ គោរពបរិស្ថាន និងកាតព្វកិច្ច របស់វិស័យឯកជន និងសហគមន៍។

ឃ. គណៈកម្មការសហគមន៍អេកូទេសចរណ៍ ឃុំជីផាត និងវិស័យឯកជនអាចធ្វើការសំរេចចិត្តរួមគ្នាបាន ដើម្បីបញ្ជាក់ទៅលើចំណុចមួយចំនួន នៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង សហគមន៍អេកូទេសចរណ៍ឃុំ ជីផាតថាតើវាសមស្របទៅនឹងករណីពិសេសៗដែរឬទេ ប៉ុន្តែមិនអាចសំរេចតែភាគីម្ខាងនោះទេ។

ង. វិស័យឯកជន នឹងមិនធ្វើសកម្មភាពណា ដែលប៉ះពាល់ដល់ធនធានធម្មជាតិ សត្វព្រៃ បរិស្ថាន ឬវប្បធម៌ក្នុងសហគមន៍ឡើយ។

**ឧបសម្ព័ន្ធទី ៩៖**

# គោលការណ៍សម្រាប់ការបោះឆ្នោត សហគមន៍អេកូទេសចរណ៍ជីផាត

## ១. ការគ្រប់គ្រង

### ១.១. គណៈកម្មការរៀបចំការបោះឆ្នោត (គ.រ.ប)

- គណៈកម្មការរៀបចំការបោះឆ្នោត (គ.រ.ប) មានចំនួន ០៦ រូប។
- គ.រ.ប ត្រូវបានបង្កើតឡើងដោយមានការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗ រួមមាន៖ តំណាងឃុំជីផាត ២រូប តំណាងសាលាស្រុកថ្មបាំង ១រូប តំណាងការិយាល័យបរិស្ថានស្រុក ១រូប តំណាងមន្ទីរទេសចរណ៍ខេត្ត ១រូប តំណាងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ១រូប។
- សមាជិកនៃ គ.រ.ប មិនអាចឈរឈ្មោះបោះឆ្នោតបានទេ។

- គ.រ.ប ត្រូវបានបង្កើតឡើងដើម្បីជួយសម្របសម្រួល និងធានាថាដំណើរការនៃការបោះឆ្នោត ជ្រើសរើសគណៈកម្មការសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង មានតម្លាភាព និងយុត្តិធម៌
- គ.រ.ប នឹងដើរតួនាទីចម្បង ក្នុងការដោះស្រាយរាល់វិវាទផ្សេងៗ ដែលនឹងអាចកើតមានឡើង មុនពេលបោះឆ្នោត អំឡុងពេលបោះឆ្នោត និងបន្ទាប់ពីការប្រកាសលទ្ធផលសន្លឹកឆ្នោត។ គ.រ.ប នឹងទទួលពាក្យបណ្តឹង ឬការចោទប្រកាន់ទាំងឡាយណាដែលពាក់ព័ន្ធទៅនឹង៖
    - សិទ្ធិអ្នកបោះឆ្នោត និងការចុះឈ្មោះ
    - សិទ្ធិនៃបេក្ខជនឈរឈ្មោះបោះឆ្នោត និងការចុះឈ្មោះ
    - ការធ្វើផ្ទុយពីក្រមសីលធម៌បោះឆ្នោត ឬការតំណាងជួសរបស់បេក្ខជនក្នុងយុទ្ធនាការឃោសនាបោះឆ្នោតរបស់ពួកគេ
    - លទ្ធផលនៃការបោះឆ្នោត។
- គ.រ.ប ទុកពេល ២ ថ្ងៃ សម្រាប់ទទួលពាក្យបណ្តឹង និងការតវ៉ាជំទាស់ផ្សេងៗ បន្ទាប់ពីការប្រកាសលទ្ធផលសន្លឹកឆ្នោត។
- ក្នុងការប្រជុំដំបូង គ.រ.ប នឹងបោះឆ្នោតជ្រើសរើសប្រធាន ១រូប អនុប្រធាន ១រូប និងលេខា ១រូប ។
- . រាល់ការសំរេចចិត្តរបស់ គ.រ.ប គឺផ្អែកលើសំឡេង ៥០ ភាគរយបូក ១។
- គ.រ.ប តំរូវអោយមាន ៥ កូរ៉ុមដើម្បីអាចដំណើរការកិច្ចប្រជុំបាន។
- គ.រ.ប នឹងត្រូវបានរំសាយ បន្ទាប់ពីលទ្ធផលនៃការបោះឆ្នោតត្រូវបានទទួលស្គាល់ជាផ្លូវការ និងចូលជាធរមាន។

**១.២. តួនាទីរបស់ គ.រ.ប**

គ.រ.ប ត្រូវបានបង្កើតឡើងដើម្បីជួយសម្របសម្រួល និងធានាថាដំណើរការនៃការបោះឆ្នោត ជ្រើសរើស គណៈកម្មការសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង មានតម្លាភាព យុត្តិធម៌ និងប្រសិទ្ធិភាព។ តួនាទីរបស់ គណៈកម្មការរៀបចំការបោះឆ្នោត មានដូចតទៅ៖

- ពិនិត្យ និងអនុម័ត លើគោលការណ៍បោះឆ្នោតសម្រាប់សហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង
- ផ្សព្វផ្សាយពីការបោះឆ្នោត តាមភូមិទាំង៤ ក្នុងឃុំជីផាត និងគ្រប់ភាគីពាក់ព័ន្ធសំខាន់ៗ
- ទទួលបន្ទុករៀបចំបញ្ជីឈ្មោះអ្នកចូលរួមបោះឆ្នោត និងបេក្ខជនឈរឈ្មោះបោះឆ្នោត

- រៀបចំ ត្រួតពិនិត្យ និងវាយតម្លៃ ការប្រឡង និងការសម្ភាសន៍ បេក្ខជនឈរឈ្មោះបោះឆ្នោត
- ត្រួតពិនិត្យដំណើរការឃោសនាបោះឆ្នោត របស់បេក្ខជនឈរឈ្មោះបោះឆ្នោត
- រៀបចំ និងត្រួតពិនិត្យ ស្នាក់ការបោះឆ្នោតតាមភូមិទាំងបួន ក្នុងឃុំជីផាត
- ទទួលបន្ទុកក្នុងដំណើរការនៃការរាប់សន្លឹកឆ្នោត ប្រកាសលទ្ធផលនៃការបោះឆ្នោត ទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត និងអនុម័តលើលទ្ធផលនៃការបោះឆ្នោត
- ដោះស្រាយវិវាទ ឬបណ្ដឹងតវ៉ាផ្សេងៗ ដែលនឹងអាចកើតមានឡើង មុនពេលបោះឆ្នោត អំឡុងពេលបោះឆ្នោត និងបន្ទាប់ពីការប្រកាសលទ្ធផលសន្លឹកឆ្នោត
- សម្របសម្រួលកិច្ចការចាំបាច់នានា ដើម្បីធានាឲ្យការបោះឆ្នោតមានភាពរលូន និងទទួលបានជោគជ័យ។

**<u>១.៣. អ្នកសង្កេតការណ៍</u>**

- សមាសភាពនៃអ្នកសង្កេតការណ៍មានដូចខាងក្រោម៖
  - សមាជិក គ.រ.ប គ្រប់ស្នាក់ការបោះឆ្នោត
  - តំណាងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ឬអង្គការឯករាជ្យផ្សេងៗ (ចំនួនតាមស្ថានភាពជាក់ស្ដែង)។
- អ្នកសង្កេតការណ៍មិនអាចឈរឈ្មោះបោះឆ្នោតបានទេ។
- អ្នកសង្កេតការណ៍ត្រូវឃ្លាំមើលគ្រប់សកម្មភាពនៅក្នុង ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ប្រព្រឹត្តិទៅដោយតម្លាភាព និងយុត្តិធម៌។

**<u>១.៤. ថវិកា</u>**

អង្គការសម្ព័ន្ធមិត្តសត្វព្រៃ រីសហគមន៍ និងឧបត្ថម្ភថវិកាមួយចំនួនដូចខាងក្រោម៖

- ការធ្វើដំណើរ និងការស្នាក់នៅសំរាប់សមាជិក គ.រ.ប ចូលរួមប្រជុំ ហើយដែលជាអ្នកមិនមានទីលំនៅក្នុងឃុំជីផាត
- អាហារសំរ៉ន់សំរាប់កិច្ចប្រជុំ
- ជួលមេក្រូ
- បោះពុម្ពបញ្ជីឈ្មោះអ្នកបោះឆ្នោត គោលការណ៍បោះឆ្នោត សន្លឹកឆ្នោត
- ហិបឆ្នោត
- ទឹកថ្នាំជ្រលក់ដៃ
- ការចំណាយរបស់ឃុំសំរាប់រៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត
- សិក្ខាសាលាជាសាធារណៈចំនួន ១ លើក ដើម្បីផ្សព្វផ្សាយពីគោលការណ៍សម្រាប់ការបោះឆ្នោត។

### ១.៥. ការប្រើប្រាស់គោលការណ៍បោះឆ្នោត

- គោលការណ៍នេះសម្រាប់គ្រប់គ្រងការបោះឆ្នោត និងការសាកល្បងការងារ ៣ ខែក្រោយការប្រកាសលទ្ធផលបោះឆ្នោត។
- គោលការណ៍នេះគឺត្រូវបានអនុវត្ត និងបកស្រាយដោយ គ.រ.ប។
- គោលការណ៍នេះតំរូវអោយធ្វើវិសោធនកម្មនៅក្នុងការប្រជុំទី ១ របស់ គ.រ.ប ដោយធ្វើការឯកភាព សំរាប់ការអនុវត្តន៍គោលការណ៍នេះ
- គ.រ.ប នឹងផ្សព្វផ្សាយគោលការណ៍ដែលបានឯកភាពហើយ នៅតាមភូមិនីមួយៗ សាលាឃុំ និងទីសាធារណៈ។
- អ្នកបោះឆ្នោត និងបេក្ខជនអាចស្វែងរកការពន្យល់បញ្ជាក់ពីគោលការណ៍ទាំងនេះពីសមាជិក គ.រ.ប ណាមួយ។
- អ្នកមានសិទ្ធិបោះឆ្នោតម្នាក់ៗ រឺសមាជិក គ.រ.ប អាចអោយយោបល់ ក្នុងការធ្វើវិសោធនកម្មគោលការណ៍ទាំងនេះទៅកាន់ប្រធាន គ.រ.ប។ គ.រ.ប គឺត្រូវការពេលវេលាពិចារណាចំពោះការស្នើសុំធ្វើការកែប្រែនេះ។ ក្នុងករណីមានកំហុសធំដុំណាមួយត្រូវបានរាយការណ៍ ប្រធាន គ.រ.ប អាចកោះហៅអោយមានការប្រជុំវិសាមញ្ញមួយដើម្បីកែតំរូវគោលការណ៍នេះ។ សមាជិក គ.រ.ប បិទផ្សាយគោលការណ៍ដែលកែតំរូវនោះនៅទីសាធារណៈ។
- គ.រ.ប អាចកែតំរូវគោលការណ៍នេះត្រឹម ២ សប្តាហ៍មុនថ្ងៃបោះឆ្នោត។

## ២. ការប្រកាសការបោះឆ្នោតជាផ្លូវការ

- ការបោះឆ្នោតនឹងធ្វើឡើងរៀងរាល់រយះពេលប្រាំឆ្នាំម្តង។
- កាលបរិច្ឆេទអាចនឹងត្រូវបានផ្លាស់ប្តូរត្រឹម ១ សប្តាហ៍មុនថ្ងៃបោះឆ្នោត។
- សមាជិក គ.រ.ប នឹងប្រកាសពីការបោះឆ្នោត ដោយមេក្រូតាមភូមិទាំងប្រាំបី ហើយការប្រកាសនេះនឹងជំរាបជូនពីទីកន្លែងដែលបិទគោលការណ៍បោះឆ្នោត និងកាលបរិច្ឆេទបោះឆ្នោត រួមទាំងទីកន្លែងសំរាប់ការប្រជុំសារធារណៈ។

## ៣.អ្នកបោះឆ្នោត

- អាជ្ញាធរឃុំនឹងរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត សំរាប់ភូមិនីមួយៗ។
- ឈ្មោះអ្នកបោះឆ្នោតត្រូវមានតែមួយគត់នៅក្នុងបញ្ជីឈ្មោះតែមួយ។
- គ.រ.ប នឹងប្រកាសឈ្មោះជាក់លាក់អ្នកបោះឆ្នោត ដែលនឹងត្រូវបានបង្ហាញនៅលើបញ្ជីឈ្មោះបោះឆ្នោត។
- បេក្ខជនឈរឈ្មោះបោះឆ្នោតអាចមានសិទ្ធិបោះឆ្នោតបាន។
- គ.រ.ប នឹងបិទបញ្ជីឈ្មោះអ្នកបោះឆ្នោតទាំង ៨ ភូមិ នៅកន្លែងសាធារណៈ។

- អ្នកដែលមានសិទ្ធិបោះឆ្នោតអាចរាយការណ៍ពីការបាត់ឈ្មោះ ឈ្មោះស្ទួន ឈ្មោះអ្នកមិនមានសិទ្ធិបោះឆ្នោត ឈ្មោះខុសអក្ខរាវិរុទ្ធ និងកំហុសដ៏ទៃផ្សេងទៀត ទៅ គ.រ.ប ជាអ្នកដោះស្រាយបញ្ហានៅក្នុងកិច្ចប្រជុំបន្ទាប់។
- សមាជិក គ.រ.ប នឹងបិទផ្សាយពីការផ្លាស់ប្តូរចំពោះ បញ្ជីឈ្មោះបោះឆ្នោតនៅទីសាធារណៈក្នុងអំឡុងពេល ២ ថ្ងៃបន្ទាប់ពីការបើកសាវនាការរបស់ គ.រ.ប។

## ៤. មុខតំណែង

- ប្រធានសហគមន៍ (១រូប)
- អនុប្រធានសហគមន៍(១រូប)
- ប្រធានគណនេយ្យ/ប្រធានផ្នែកកក់ (១រូប)
- អ្នកទទួលភ្ញៀវ(១)
- អ្នកទទួលភ្ញៀវ(២)
- អនុប្រធានគណៈគណនេយ្យ (១រូប)
- ប្រធានក្រុមសេវាកម្មតាមភូមិ(១)។
- ប្រធានក្រុមផ្នែកបារ និងភេសជ្ជៈ(១)
- ប្រធានក្រុមល្បាត(១)

## ៥. លក្ខខណ្ឌសម្រាប់អ្នកចូលរួមបោះឆ្នោត

- ជាជនជាតិខ្មែរទាំងពីរភេទ និងមានទីលំនៅអចិន្ត្រៃយ៍ ឃុំជីផាត។
- មានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ គិតត្រឹមថ្ងៃបោះឆ្នោត។
- ត្រូវមានឯកសារបញ្ជាក់អត្តសញ្ញាណ រួមមាន អត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត ឬសៀវភៅគ្រួសារ ពេលមកចុះឈ្មោះ និងក្នុងអំឡុងពេលធ្វើការបោះឆ្នោត។
- ប្រជាពលរដ្ឋ មន្ត្រីរាជការ ព្រះសង្ឃ មានសិទ្ធិស្មើគ្នា១ ក្នុងការចូលរួមបោះឆ្នោត។

## ៦. បេក្ខជនឈរឈ្មោះបោះឆ្នោត

### ៦.១. លក្ខខណ្ឌទូទៅសម្រាប់បេក្ខជនឈរឈ្មោះបោះឆ្នោត

- មានអាយុចន្លោះចាប់ពី ១៨-៥៥ ឆ្នាំ ។

- ជាជនជាតិខ្មែរទាំងពីរភេទ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងៗ។
- មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងឃុំ ឃុំជីផាត។
- មិនធ្លាប់មានប្រវត្តិជាប់ចោទពីបទឧក្រិដ្ឋ ឬពិរុទ្ធផ្សេងៗ។
- មិនជាប់ពាក់ព័ន្ធនឹងនិន្នាការនយោបាយឡើយ។
- មិនមានពាក់ព័ន្ធបម្រើការងារក្នុងស្ថាប័នណាមួយឡើយ។
- មានអត្តចរិកល្អ ស្មោះត្រង់ រួសរាយ មានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការធ្វើការងារ។
- ចេះសាមគ្គីគ្នា និងអាចធ្វើការងារជាក្រុមបាន។
- ត្រូវគោរពតាមគោលការណ៍នៃការបោះឆ្នោតរបស់សហគមន៍អេកូទេសចរណ៍ជីផាត។
- បេក្ខជនឈរឈ្មោះបោះឆ្នោត បានតែម្នាក់ប៉ុណ្ណោះក្នុងមួយគ្រួសារ។
- បេក្ខជនឈរឈ្មោះបោះឆ្នោត អាចជ្រើសរើសមុខតំណែងបានតែមួយគត់។

## ៦.២. លក្ខខណ្ឌជាក់លាក់សម្រាប់បេក្ខជនឈរឈ្មោះបោះឆ្នោតតាមមុខតំណែងនីមួយៗ

### ៦.២.១. ប្រធាន

- មានចំណេះដឹងអាចអាន និងសរសេរភាសាខ្មែរបានល្អ។
- មានសមត្ថភាពយល់ដឹងពីការអភិវឌ្ឍន៍គម្រោងសហគមន៍អេកូទេសចរណ៍។
- មានភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង (ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ការធ្វើផែនការ ការត្រួតពិនិត្យនិងតាមដាន ។ល។)។
- មានចំណេះដឹងភាសាអង់គ្លេសក្នុងការទំនាក់ទំនងបាន។
- មានជំនាញប្រើប្រាស់កុំព្យូទ័រកាន់តែប្រសើរ។

### ៦.២.២. អនុប្រធាន (ទទួលបន្ទុកផ្នែកបរិស្ថាន សេវាកម្មអេកូទេសចរណ៍ និងអនាម័យ ហិរញ្ញវត្ថុ និងកែលម្អផលិតផលទេសចរណ៍)

- មានចំណេះដឹងអាចអាន និងសរសេរភាសាខ្មែរបានល្អ។
- មានសមត្ថភាពយល់ដឹងពីការអភិវឌ្ឍន៍គម្រោងសហគមន៍អេកូទេសចរណ៍។
- មានចំណេះដឹង និងគំនិតច្នៃប្រឌិតផ្នែកអនាម័យ បរិស្ថាន។

- មានបទពិសោធន៍ខ្លះៗក្នុងការដើរល្បាតព្រៃ និងមានចំណេះដឹងក្នុងការប្រើប្រាស់ ជីភីអេស (GPS) ផែនទី និងត្រីវិស័យ។
- មានសមត្ថភាពគ្រប់គ្រងសេវាកម្មអេកូទេសចរណ៍ និងអាចសម្របសម្រួលភ្ញៀវទេសចរបាន។
- មានចំណេះដឹងភាសាអង់គ្លេសក្នុងការទំនាក់ទំនងបាន។
- មានជំនាញប្រើប្រាស់កុំព្យូទ័រកាន់តែប្រសើរ។
- មានចំណេះដឹងផ្នែកគណនេយ្យ។
- មានសមត្ថភាពគ្រប់គ្រងសេវាកម្មអេកូទេសចរណ៍ និងអាចសម្របសម្រួលភ្ញៀវទេសចរបាន។
- មានចំណេះដឹងភាសាអង់គ្លេសក្នុងការទំនាក់ទំនង។
- មានជំនាញប្រើប្រាស់កុំព្យូទ័រកាន់តែប្រសើរ។

**៦.២.៣. ប្រធានផ្នែកល្បាត**

- កំរិតវប្បធម៌ ចេះអាន និងសរសេរអក្សរខ្មែរ។
- មានបទពិសោធន៍ដើរព្រៃ និងមានសុខភាពល្អរឹងមាំ។
- មានចំណេះដឹងក្នុងការប្រើប្រាស់ ជីភីអេស (GPS) ផែនទី និងត្រីវិស័យ។
- មានការយល់ដឹងពីការអភិរក្ស និងសង្គ្រោះ ព្រៃឈើ និងសត្វព្រៃ។
- មានសមត្ថភាពយល់ដឹងពីការអភិវឌ្ឍន៍គម្រោងសហគមន៍អេកូទេសចរណ៍។
- មានភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង។

**៦.២.៤. ប្រធានផ្នែកកក់**

- មានចំណេះដឹងអាចអាន និងសរសេរភាសាខ្មែរបានល្អ។
- មានជំនាញប្រើប្រាស់កុំព្យូទ័រ អ៊ីនធើណែត និងអ៊ីម៉ែល (Email)។
- មានចំណេះដឹងភាសាអង់គ្លេសក្នុងការទំនាក់ទំនងទាំងនិយាយ និងសរសេរ។
- មានជំនាញទំនាក់ទំនងសាធារណៈ និងជំនាញក្នុងការសម្របសម្រួលភ្ញៀវទេសចរ។
- មានសមត្ថភាពក្នុងការសរសេរកម្មវិធីសេវាកម្ម និងតំលៃ។

- មានសមត្ថភាពយល់ដឹងពីការអភិវឌ្ឍន៍គម្រោងសហគមន៍អេកូទេសចរណ៍។

**៦.២.៥. ប្រធានគណនេយ្យ (ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល)**

- មានចំណេះដឹងអាចអាន និងសរសេរភាសាខ្មែរបានល្អ។
- មានសមត្ថភាពក្នុងការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ចំណូល និងចំណាយ បញ្ជីសារពើភ័ណ្ឌ។
- មានសមត្ថភាព និងជំនាញផ្នែករដ្ឋបាល។
- មានសមត្ថភាពយល់ដឹងពីការអភិវឌ្ឍន៍គម្រោងសហគមន៍អេកូទេសចរណ៍។
- មានចំណេះដឹងពីការបម្រើសេវាកម្មអេកូទេសចរណ៍។
- មានចំណេះដឹងភាសាអង់គ្លេសក្នុងការទំនាក់ទំនង។
- មានជំនាញប្រើប្រាស់កុំព្យូទ័រកាន់តែប្រសើរ។

**៦.២.៦. អនុប្រធានគណនេយ្យ (ទទួលបន្ទុកទូទាត់ថ្លៃសេវាកម្មជាមួយភ្ញៀវទេសចរ និងជួយការងារប្រធានគណនេយ្យ)**

- មានចំណេះដឹងអាចអាន និងសរសេរភាសាខ្មែរបានល្អ។
- មានចំណេះដឹងផ្នែកហិរញ្ញវត្ថុ ចំណូល និងចំណាយ បញ្ជីសារពើភ័ណ្ឌ។
- មានជំនាញក្នុងធ្វើកំណត់ត្រាហិរញ្ញវត្ថុ។
- មានសមត្ថភាពយល់ដឹងពីការអភិវឌ្ឍន៍គម្រោងសហគមន៍អេកូទេសចរណ៍។
- មានចំណេះដឹងពីការបម្រើសេវាកម្មអេកូទេសចរណ៍ និងសម្របសម្រួលភ្ញៀវទេសចរ។
- មានចំណេះដឹងភាសាអង់គ្លេសក្នុងការទំនាក់ទំនងកាន់តែប្រសើរ។
- មានជំនាញប្រើប្រាស់កុំព្យូទ័រកាន់តែប្រសើរ។
- ចេះធ្វើការងារជាក្រុម។

**៦.២.៧. ប្រធានក្រុមសេវាកម្ម**

- មានចំណេះដឹងអាចអាន និងសរសេរភាសាខ្មែរបានល្អ។
- មានភាពជាអ្នកដឹកនាំ និងគ្រប់គ្រងលើផ្នែកសេវាកម្មអេកូទេសចរណ៍។
- មានជំនាញក្នុងការសម្របសម្រួលភ្ញៀវទេសចរ។

- មានជំនាញក្នុងការដោះស្រាយបញ្ហា។
- មានសមត្ថភាពយល់ដឹងពីការអភិវឌ្ឍន៍គម្រោងសហគមន៍អេកូទេសចរណ៍។
- មានចំណេះដឹងភាសាអង់គ្លេសក្នុងការទំនាក់ទំនងកាន់តែប្រសើរ។
- មានជំនាញប្រើប្រាស់កុំព្យូទ័រកាន់តែប្រសើរ។
- ចេះធ្វើការងារជាក្រុម។

**៦.៣. ការឈរឈ្មោះសំរាប់មុខតំណែង**

- ក្នុងករណីដែលមិនមានបេក្ខជនឈរឈ្មោះសំរាប់មុខតំណែងណាមួយ គណៈកម្មការសហគមន៍អេកូទេសចរណ៍ថ្មី សហការជាមួយអាជ្ញាធរមូលដ្ឋាន អាចដាក់បំពេញមុខតំណែងទាំងនោះដោយការចាត់តាំង បន្ទាប់ពីការបោះឆ្នោត។
- ក្នុងករណីដែលមិនមានបេក្ខជនណាឈរឈ្មោះសំរាប់តំណែងទាំងអស់ គ.រ.ប នឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន ធ្វើការបំពេញមុខតំណែងទាំងនោះដោយការតែងតាំង។
- បេក្ខជនដែលត្រូវបានជ្រើសរើស ដោយការចាត់តាំង ត្រូវមានសមត្ថភាពសមស្របទៅតាមមុខតំណែងនីមួយៗ។

**៦.៤. ការចុះឈ្មោះ**

- បុគ្គលដែលមានសិទ្ធិបោះឆ្នោតគ្រប់រូប អាចចុះឈ្មោះឈរជា បេក្ខជនអោយគេបោះឆ្នោត លើកលែងតែលក្ខណៈដូចខាងក្រោម៖
    - ជាមន្ត្រីរាជការ រឺជាគណបក្សនយោបាយ ជាបុគ្គលិកស្ថាប័នណាមួយ រឺជាបុគ្គលដែលមានមុខតំណែងក្នុងនយោបាយ រឺមានមុខតំណែងប្រឹក្សានយោបាយ ទោះជាមានប្រាក់បៀវត្សរ៍ រឺមិនមានប្រាក់បៀវត្សរ៍ក៏ដោយ
    - ជាសមាជិក គ.រ.ប។
- បេក្ខជននឹងចុះឈ្មោះជាមួយ គ.រ.ប នៅការិយាល័យសហគមន៍អេកូទេសចរណ៍ ដោយប្រើប្រាស់ទំរង់ចុះឈ្មោះដែលបានសំរេចដោយ គ.រ.ប។
- ការចុះឈ្មោះមិនមានការបង់ថ្លៃទេ។
- ក្នុងមួយគ្រួសារមានតែសមាជិកម្នាក់ប៉ុណ្ណោះដែលអាចឈរឈ្មោះអោយគេបោះឆ្នោតបាន (សមាជិកគ្រួសារមានន័យថា ជាបុគ្គលដែលមានឈ្មោះក្នុងសៀវភៅគ្រួសារតែមួយ)។
- បេក្ខជនត្រូវតែចុះឈ្មោះយ៉ាងតិចបំផុតមួយខែមុនថ្ងៃបោះឆ្នោត។
- គ.រ.ប នឹងថតរូបបេក្ខជន ហើយរូបថតទាំងនេះនឹងបង្ហាញនៅលើសន្លឹកឆ្នោត។

- បេក្ខជននឹងត្រូវអាចសុំអោយបង្ហាញឯកសារអម ដើម្បីបញ្ជាក់ពីភាពមានសិទ្ធិនៅពេលដែលធ្វើការ ចុះឈ្មោះ។
- បេក្ខជនត្រូវបញ្ជាក់អោយបានច្បាស់ពីមុខតំណែង រឺតួនាទីដែលពួកគេចង់ឈរឈ្មោះ នៅពេលចុះឈ្មោះ។
- បេក្ខជននឹងទទួលបានបរិយាយការងារសំរាប់មុខតំណែងនៅពេលចុះឈ្មោះ។
- បេក្ខជនអាចផ្លាស់ប្តូរមុខតំណែងពេលណាក៏បានរហូតដល់ ២ថ្ងៃ មុនការធ្វើតេស្តវាស់ស្ទង់សមត្ថ ភាព បន្ទាប់ពីនេះទៅ ពួកគេមិនអាចផ្លាស់ប្តូរបានទេ។
- ក្រោយពេលចុះឈ្មោះហើយ គ.រ.ប នឹងបិទបញ្ជីឈ្មោះបេក្ខជន និងមុខតំណែងរបស់ពួកគេនៅទីសារធារណៈ។

**៦.៥. គណៈកម្មការចាស់ និងសមាជិក**

- សមាជិកគណៈកម្មការចាស់អាចនឹងឈរឈ្មោះបោះឆ្នោតជាថ្មី ពួកគេរក្សាមុខតំណែងរបស់ពួកគេរហូតទាល់តែការប្រកាសលទ្ធផលចុងក្រោយ។
- សមាជិកគណៈកម្មការចាស់មិនអាចប្រើប្រាស់តួនាទីរបស់ពួកគេ ដើម្បីដាក់សំពាធទៅលើសមាជិកឡើយ។
- គណៈកម្មការចាស់អាចឈរឈ្មោះសំរាប់មុខតំណែងណាមួយក៏បាន មិនសំដៅទៅលើមុខតំណែងដែលគេកាន់សព្វថ្ងៃទេ។
- ប្រសិនបើសមាជិកគណៈកម្មការចាស់ណាម្នាក់ ឈរឈ្មោះសំរាប់ការបោះឆ្នោតហើយ មិនបានជាប់មុខតំណែង ពួកគេអាចចូលរួមជាសមាជិកបម្រើសេវាកម្មធម្មតា (អ្នកនាំភ្ញៀវ ផ្ទះស្នាក់ចុងភៅ ។ល។)។
- ប្រសិនបើសមាជិកគណៈកម្មការចាស់មិនបានចុះឈ្មោះជាបេក្ខជន ពួកគេនឹងមិនមានសិទ្ធិជាស្វ័យប្រវត្តិដើម្បីចុះឈ្មោះជាសមាជិកសេវាសហគមន៍ទេ។
- សមាជិកសេវាសហគមន៍ដូចជា ( អ្នកនាំភ្ញៀវ ចុងភៅ ។ល។) ដែលឈរឈ្មោះបោះឆ្នោតត្រូវរក្សាតួនាទី និងការងាររបស់ពួកគេធម្មតាអំឡុងពេលនៃការបោះឆ្នោត។ ប្រសិនបើពួកគេជាប់ឆ្នោត ពួកគេត្រូវលាឈប់ពីសមាជិកធម្មតា។ ប្រសិនបើពួកគេមិនបានជាប់ឆ្នោតវិញនោះពួកគេនៅតែអាចបន្តសមាជិកភាពរបស់ខ្លួនជាសមាជិកធម្មតាដដែល។
- ប្រសិនបើបេក្ខជនដែលជាប់ឆ្នោតមានសមាជិកគ្រួសាររបស់ខ្លួនជាសមាជិកសេវាសហគមន៍ នោះសមាជិកសេវាសហគមន៍ ដែលជាសមាជិកគ្រួសាររបស់បេក្ខជន នឹងត្រូវលាឈប់ពីភាពជាសមាជិករបស់ខ្លួនបន្ទាប់ពីការបោះឆ្នោត។ ក្នុងនេះសំដៅលើ មនុស្សដែលមានឈ្មោះក្នុងសៀវភៅគ្រួសារតែមួយជាមួយបេក្ខជនដែលជាប់ឆ្នោត។

**៦.៦. ការដកខ្លួនចេញ**

- បេក្ខជនអាចលាឈប់ពីការបោះឆ្នោត ដោយជូនដំណឹងទៅប្រធាន គ.រ.ប យ៉ាងហោចណាស់ ១ សប្តាហ៍មុនពេលបោះឆ្នោត។
- ប្រសិនបើបេក្ខជនលាឈប់ពីការបោះឆ្នោត បន្ទាប់ពីការបន្សាំការងារ ការប្រឡង និងការសម្ភាសន៍នោះបេក្ខជនដ៏ទៃទៀត មិនមានសិទ្ធិជំនួសកន្លែងអ្នកនោះដោយស្វ័យប្រវត្តិទេ។ ទោះជាយ៉ាងណាក៏ដោយ វាអាស្រ័យលើ គ.រ.ប ជាអ្នកសំរេច ក្នុងគោលដៅមិនអោយវាមានការប៉ះពាល់ដល់ដំណើរការនៃការគ្រប់គ្រង ដូចជាកាលវិភាគនៃការបន្សាំការងារជាដើម។

**<u>៦.៧. ការជ្រើសរើសបេក្ខជន</u>**

- រាល់បេក្ខជនទាំងអស់នឹងចូលរួម ការបន្សាំការងារ ធ្វើតេស្ត និងសម្ភាសន៍ មុនឈានដល់ការឈរឈ្មោះបោះឆ្នោត។
- គ.រ.ប ដោយមានជំនួយបច្ចេកទេស និងគាំទ្រពី អង្គការសម្ព័ន្ធមិត្តសត្វព្រៃ ជាអ្នកទទួលបន្ទុក រៀបចំ និងគ្រប់គ្រងការធ្វើតេស្ត និងសម្ភាសន៍។

**<u>៦.៨. ការប្រឡងសំណេរ</u>**

- ការប្រឡងសំណេរនឹងធ្វើឡើង រយៈពេលពីរថ្ងៃក្រោយបញ្ចប់ការចុះឈ្មោះបេក្ខជន (១ខែមុនថ្ងៃបោះឆ្នោត)។
- នឹងមានការប្រឡងសំណេរជុំគ្នា ពីគ្រប់បេក្ខជនទាំងអស់។
- បេក្ខជននឹងតំរូវអោយសរសេរឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួន រួមទាំងលេខកូដសំងាត់នៅលើទំព័រទី១នៃវិញ្ញាសារប្រឡង។ លើសពីនេះត្រូវសរសេរលេខកូដសំងាត់នៅលើទំព័របន្ទាប់ទៀត ដូចគ្នាទៅនឹងលេខសំងាត់ទំព័រទី១។ នៅពេលចាប់ផ្តើមប្រឡង ប្រធាន គ.រ.ប នឹងដកយកទំព័រទីមួយរក្សាទុក។ ដូចនេះរាល់វិញ្ញាសារប្រឡងទាំងអស់ អាចសំគាល់បានដោយត្រឹមតែ លេខកូដសំងាត់ប៉ុណ្ណោះ មិនមែនដោយឈ្មោះបេក្ខជនទេ។
- បុគ្គលិកអង្គការសម្ព័ន្ធមិត្តសត្វព្រៃពីររូប និងប្រធាន គ.រ.ប រឺក៏អ្នកតំណាងរបស់គាត់នឹងត្រួតពិនិត្យការប្រឡង (មេប្រយោគចំនួនបីរូប)។
- ការបញ្ឈប់បេក្ខជនណាម្នាក់ពីការប្រឡងចំពោះការធ្វើខុសក្រមសីលធម៌ គឺយកតាមការសំរេចចិត្តភាគច្រើនរបស់មេប្រយោគ។ ហើយបេក្ខជននោះនឹងត្រូវលាឈប់ពីការចូលរួមឲ្យគេបោះឆ្នោត។ ចំពោះការសំរេចចិត្តហើយនឹងមិនមានការសំរេចចិត្តជាថ្មីទៀតទេពីសំណាក់មេប្រយោគ។ ការធ្វើខុសក្រមសីលធម៌រួមមាន៖
    - លួចមើលសំណៅឯកសារ

  - អនុញ្ញាត ឬផ្តល់ឱកាសឲ្យបេក្ខជនផ្សេងទៀតលួចចំលង
  - ការបង្ករភាពអសណ្តាប់ធ្នាប់ក្នុងពេលប្រឡង
  - ការប្រើពាក្យសំដីមិនសមរម្យជាមួយមេប្រយោគ
  - ការបង្ករហឹង្សា និងការយកអាវុធ ជាតិផ្ទុះផ្សេងៗក្នុងបន្ទប់ប្រឡង។
- គ.រ.ប ជាអ្នកដាក់ពិន្ទុលើវិញ្ញាសារប្រឡង។
- ប្រសិនបើអ្នកកែវិញ្ញាសាររកឃើញថាមាន ហេតុផលបន្លំការប្រឡង នោះមេប្រយោគទីបី (ប្រធាន គ.រ.ប) គឺត្រូវបានអញ្ជើញចូលរួមជួយពិនិត្យ ហើយមេប្រយោគទាំងបីជាអ្នកសំរេចថាតើបេក្ខជននោះគួរតែលុបចោលពីការបោះឆ្នោត រឺយ៉ាងណា។
- សមាជិក គ.រ.ប នឹងស្រង់ពិន្ទុដាក់ក្នុងទំព័រទី១នៃវិញ្ញាសារ តាមលេខកូដសំងាត់។

## ៦.៩. ការសម្ភាសន៍

- គ.រ.ប ទទួលបន្ទុករៀបចំការសម្ភាសន៍បេក្ខជន។
- ការសម្ភាសន៍នឹងផ្តោតទៅលើចំណេះដឹងទូទៅ និងជំនាញតាមមុខតំណែងនីមួយៗដែលបេក្ខជនឈរឈ្មោះឲ្យគេបោះឆ្នោត។

## ៦.១០. លក្ខណៈវិនិច្ឆ័យ

- បេក្ខជនដែលមានពិន្ទុខ្ពស់ជាងគេចំនួន ៥ រូបតាមមុខតំណែងនីមួយៗ នឹងនៅឈរជាបេក្ខជន ហើយពិន្ទុគឺត្រូវមាន ៥០% ឡើង ដែលយកពីពិន្ទុប្រឡងសំណេរ និងពិន្ទុក្នុងការសម្ភាសន៍។
- ក្នុងករណីមានបេក្ខជនដែលមានពិន្ទុស្មើគ្នានឹងអ្នកទី ៥ នោះបេក្ខជនទាំងអស់ដែលមានពិន្ទុស្មើគ្នានឹងត្រូវបានអនុញ្ញាតអោយឈរឈ្មោះសំរាប់ការបោះឆ្នោត។
- ក្នុងករណីមិនមាននរណាម្នាក់បានពិន្ទុយ៉ាងហោចណាស់ ៥០% សំរាប់មុខតំណែង នោះមុខតំណែង នោះនឹងត្រូវទុកឲ្យទំនេរ និងត្រូវបានបំពេញបន្ថែមដោយ គ.រ.ប ទៅតាមស្ថានភាពជាក់ស្តែង។
- បេក្ខជនដែលមិនបានពិន្ទុស្តង់ដារ (៥០%) នឹងត្រូវដកចេញពីការបោះឆ្នោត និងមិនមានការតវ៉ាជំទាស់ចំពោះដំណើរការនេះទេ។

## ៦.១១. កាបន្សាំការងារ

- បេក្ខជន ត្រូវតែចូលរួមការបន្សាំការងាររយៈពេល ៧ ថ្ងៃជាប់ៗគ្នាទៅតាមមុខតំណែងរបស់ពួកគេ មុនពេលប្រឡង និងសម្ភាសន៍។ ការបន្សាំការងារនេះនឹងមិនត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភឡើយ។
- កាបន្សាំកាងារនេះ គឺត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱកាសអោយបេក្ខជន រៀនបំពេញការងារតាមភាពជាក់ស្តែង ដែលពួកគេនឹងធ្វើនៅពេលដែលពួកគេជាប់ឆ្នោត។

- បេក្ខជននឹងមិនធ្លាក់ទេក្នុងវគ្គបន្សាំការងារនេះ
  លើកលែងតែលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖
    - ការធ្វើមិនត្រឹមត្រូវ (ទៅតាមការសំរេចរបស់ គ.រ.ប)
    - ខកខានក្នុងការបំពេញការងារពេញម៉ោង (ដែលនឹងត្រូវត្រួតពិនិត្យយ៉ាង[illegible] ដោយគ.រ.ប)។

## ៧. ក្រុមក្រមនៃការបោះឆ្នោត

### ៧.១. អ្វីជាធាតុផ្សំនៃការធ្វើខុសពីក្រមការបោះឆ្នោត

- ការគំរាមកំហែង អូសទាញទឹកចិត្ត ផ្តល់កាដូរ ការផ្តល់លុយអោយខ្ចី រឺការផ្តល់ជូនដ៏ទៃផ្សេងទៀត ចំពោះការសន្យា រឺការផ្តល់ជូនរង្វាន់ ក្នុងអំឡុងពេល រឺក្រោយការបោះឆ្នោត ក្នុងគោលដៅ ជួយបេក្ខជនអោយជាប់ឆ្នោត គឺជាទង្វើរខុស។
- ការផ្សព្វផ្សាយព័ត៌មានមិនពិតអំពីបទពិសោធន៍របស់បេក្ខជន ក្នុងការឈរឈ្មោះបោះឆ្នោត គឺជាទង្វើរខុស។
- ការនិយាយមួលបង្កាច់បេក្ខជនជាគូរប្រកួតប្រជែង គឺមិនត្រូវបានអនុញ្ញាតឡើយ។
- រាល់ការអះអាងទាំងឡាយណារបស់បេក្ខជន ដែលហួសពីសម្ថភាពរបស់ខ្លួនដែលអាចធ្វើ រឺការសន្យានានាទៅការផ្លាស់ប្តូរណាមួយដែលហួសពីការពិតជាក់ស្តែង។
- មុខតំណែងសហគមន៍អេកូទេសចរណ៍ គឺជាមុខតំណែង ដែលមិនពាក់ព័ន្ធនឹងនយោបាយ។ យក្ខជនទោះបីជាសមាជិកគណបក្សនយោបាយ រឺមិនមែនក៏ដោយ មិនត្រូវ៖
    - ធ្វើជាតំណាង និងឃោសនាអោយគណបក្សនយោបាយ
    - ឃោសនាគោលនយោបាយបក្ស
    - ប្រើប្រាស់ធនធានបក្សដើម្បីគាំទ្រយុទ្ធនាការឃោសនាបោះឆ្នោតរបស់ខ្លួន
    - ទទួលជំនួយ រឺការឧបត្ថម្ភផ្សេងៗពីគណបក្សនយោបាយ និងពីអ្នកគាំទ្របក្ស។
- បេក្ខជន នឹងមានសិទ្ធិ ទទួលការឧបត្ថម្ភគ្រប់រូបភាពពីអ្នកទាំងឡាយណា ដែលចូលរួមការពារធនធានធម្មជាតិ។
- ការធ្វើអោយខូចខាតដល់បញ្ជីឈ្មោះផ្លូវការ រឺការប្រកាសដែលបានបិទជាសាធារណៈ គឺមិនត្រូវបានអនុញ្ញាតឡើយ។
- ការធ្វើអោយខូចខាតដល់សំភារៈ រឺស្លាកសញ្ញានៃបេក្ខជនដ៏ទៃទៀត គឺមិនត្រូវបានអនុញ្ញាតឡើយ
- គណៈកម្មការសហគមន៍អេកូទេសចរណ៍ចាស់ ដែលឈរឈ្មោះបោះឆ្នោត មិនត្រូវប្រើតំណែងរបស់ពួកគេដាក់សំពាធដល់សមាជិក ដូចជាការសន្យាផ្តល់ផលប្រយោជន៍នានាដល់សមាជិក

ម្នាក់ជាថ្នូរនឹងការបោះឆ្នោតអោយខ្លួនឡើយ។ មិនត្រូវសន្យាទាំងឡាយណាដែលខុសពីគំរោងការដែលមានស្រាប់ឡើយ។

- គណៈកម្មការសហគមន៍អេកូទេសចរណ៍ចាស់ នឹងមិនត្រូវផ្តល់ឱកាសអំពីការចុះឈ្មោះ រឺការឃោសនា រឺបកស្រាយគោលការណ៍បោះឆ្នោត ដល់បេក្ខជន រឺអ្នកបោះឆ្នោតឡើយ។ ការបកស្រាយជាតួនាទីរបស់ គ.រ.ប។ គ.រ.ប នឹងអាចកោះហៅប្រធានសហគមន៍នាពេលបច្ចុប្បន្នដើម្បីណែនាំអោយដឹង ហើយគាត់ត្រូវអនុវត្តតាមដោយឥតលំអៀង។
- បេក្ខជនត្រូវជៀសវាងពីទង្វើរមិនសមរម្យនានាដែលកំណត់ដោយ គ.រ.ប។
- បេក្ខជនអាចនឹងជ្រើសរើសជំនួយការ ដើម្បីជួយផ្សព្វផ្សាយយុទ្ធនាការឃោសនារបស់ពួកគេតាមរយៈការរកជំនួយហិរញ្ញវត្ថុសំរាប់សំភារៈឃោសនា។ សំភារៈឃោសនារួមបញ្ចូលទាំងនិយាយ សរសេរ និងការផ្សាយព័ត៌មាន ប៉ុន្តែមិនបញ្ចូលពិធីកំសាន្តនានា ក្នុងរូបភាពនៃការអូសទាញ ទាំងនេះចាត់ទុកជាទង្វើរខុសឆ្គង។
- បេក្ខជនអាចប្រើប្រាស់មេក្រូចល័តបាន តែមិនអោយប្រើមេក្រូនៅជាប់មួយកន្លែងទេ ក្នុងការផ្សព្វផ្សាយយុទ្ធនាការរបស់ពួកគេ។ កាប្រើប្រាស់មេក្រូគឺអនុញ្ញាតអោយប្រើចន្លោះម៉ោង ០៩ ដល់ម៉ោង១២ និងចន្លោះម៉ោង១៤ ដល់ម៉ោង១៧។
- រាល់សកម្មភាពយុទ្ធនាការទាំងអស់នឹងត្រូវបញ្ឈប់ ២ថ្ងៃ មុនថ្ងៃបោះឆ្នោត។
- ចំពោះបេក្ខជនណាដែលមិនគោរពតាមក្រិតក្រមបោះឆ្នោតនេះ អ្នកនោះនឹងត្រូវបញ្ឈប់បេក្ខភាពដោយស្វ័យប្រវត្តិ។

## ៧.២. ការចោទដោយគ្មានភស្តុតាង

- អ្នកបោះឆ្នោត បេក្ខជន សមាជិក រឺក៏ ទីប្រឹក្សា អាចនឹងចាំបាច់ត្រូវតែបញ្ជូនរាល់ការចោទប្រកាន់ដោយគ្មានភស្តុតាងពីទង្វើរខុសឆ្គងនឹងក្រមបោះឆ្នោត ទៅ គ.រ.ប ដែលជាអ្នកដោះស្រាយនៅក្នុងកិច្ចប្រជុំបន្ទាប់របស់ពួកគេ។
- គ.រ.ប អាចនឹងពន្យាពេលដើមចោទ និងចុងចោទនៅពេលមានការចោទប្រកាន់ រហូតដល់ជំលោះនោះត្រូវបានដោះស្រាយ ប្រសិនបើបេក្ខជននៅតែបន្តយុទ្ធនាការឃោសនារបស់ខ្លួនក្នុងអំឡុងពេលនៃការពន្យាពេលនេះ នោះបេក្ខភាពរបស់ពួកគេនឹងត្រូវបញ្ឈប់ពីការបោះឆ្នោតដោយស្វ័យប្រវត្តិ និងដោយគ្មានការតវ៉ា។
- រាល់បេក្ខជនដែលធ្វើខុសពីក្រមបោះឆ្នោត នឹងអាចបញ្ឈប់បេក្ខភាពរបស់ខ្លួនដោយ គ.រ.ប។
- បេក្ខជនអាចតវ៉ាពីការសំរេចរបស់ គ.រ.ប ហើយ គ.រ.ប នឹងដោះស្រាយក្នុងរយៈពេល ២ ថ្ងៃ។
- បេក្ខជនណាដែលត្រូវបានបញ្ឈប់បេក្ខភាព នឹងមិនមានសិទ្ធិជាសមាជិកសេវារយៈពេល១ឆ្នាំ។
- ប្រសិនបើអ្នកជួយឃោសនារបស់បេក្ខជន ធ្វើមិនត្រឹមត្រូវ ទៅនឹងក្រមបោះឆ្នោត នោះបេក្ខជននឹងត្រូវបានបញ្ឈប់ពីបេក្ខភាព។

## ៨. ដំណើរការថ្ងៃបោះឆ្នោត

### ៨.១. ស្នាក់ការ

- ស្នាក់ការបោះឆ្នោតនឹងត្រូវបានបង្កើតឡើងនៅតាមភូមិនីមួយៗ
- ស្នាក់ការបោះឆ្នោតនឹងចាប់បើកដំណើរការពីម៉ោង ៧ ព្រឹករហូតដល់ម៉ោង ៣ រសៀល។
- ស្នាក់ការនីមួយៗ នឹងមានបញ្ជីឈ្មោះអ្នកមានសិទ្ធិបោះឆ្នោត ដែលបញ្ជាក់ដោយ គ.រ.ប។
- បុគ្គលិករបស់អង្គការសម្ព័ន្ធមិត្តសត្វព្រៃនឹងប្រគល់ជូនសន្លឹកឆ្នោត និងប្រអប់ឆ្នោតទៅតាមស្នាក់ ការនីមួយៗនៅម៉ោង ៧ ព្រឹក។ រាល់សន្លឹកឆ្នោតទាំងអស់ត្រូវប្រថាប់ត្រាទាំងបីឃុំ នៅលើខ្នង សន្លឹកឆ្នោត។

### ៨.២. មន្ត្រីគ្រប់គ្រងប្រចាំស្នាក់ការបោះឆ្នោត

- គ.រ.ប នឹងចាត់តាំង មន្ត្រីគ្រប់គ្រង ចំនួនពីររូបប្រចាំស្នាក់ការនីមួយៗ រួមមាន មេភូមិ ក្រុមប្រឹក្សាឃុំ និងតំណាងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ។ បេក្ខជនឈរឈ្មោះមិនអាចជ្រើសរើសជាមន្ត្រីគ្រប់គ្រងបានទេ។ មន្ត្រីគ្រប់គ្រងទាំងពីររូបត្រូវរក្សាវត្តមាននៅតាមស្នាក់ការបោះឆ្នោតដែលបានចាត់តាំងនៅក្នុងពេលបោះឆ្នោត។
- ត្រូវមានប៉ូលីស ១រូប នៅប្រចាំការតាមស្នាក់ការនីមួយៗ ប៉ុន្តែការប្រចាំការគឺត្រូវស្ថិតនៅខាងក្រៅស្នាក់ការ។
- មន្ត្រីគ្រប់គ្រងស្នាក់ការទាំងអស់ត្រូវរាប់សន្លឹកឆ្នោតទទេ និងចុះហត្ថលេខាទទួល។
- សមាជិក គ.រ.ប អ្នកអង្កេតការណ៍ឯករាជ្យ ដែលបានឯកភាពដោយ គ.រ.ប ទាំងអស់ គឺជាមន្ត្រីគ្រប់គ្រង នឹងត្រូវមានវត្តមាននៅតាមស្នាក់ការបោះឆ្នោតក្នុងអំឡុងពេលថ្ងៃបោះឆ្នោត។
- នៅមុនពេលចាប់ផ្តើមបោះឆ្នោត មន្ត្រីគ្រប់គ្រងស្នាក់ការទាំងអស់ត្រូវប្រាកដថាប្រអប់ឆ្នោតគឺទទេ បន្ទាប់មក ត្រូវចាក់សោរនៅលើប្រអប់ឆ្នោតនោះ។
- មន្ត្រីគ្រប់គ្រងប្រចាំស្នាក់ការបោះឆ្នោត នឹងត្រូវបានកំណត់អត្តសញ្ញាណជាលក្ខណៈបុគ្គល ( មិនប្រើអត្តសញ្ញាណប័ណ្ណទេ)។
- មន្ត្រីគ្រប់គ្រងស្នាក់ការ ត្រូវណែនាំអ្នកបោះឆ្នោតពី គោលការណ៍នៃការបោះឆ្នោត ប៉ុន្តែមិនត្រូវណែនាំពីបេក្ខជនដែលត្រូវបោះឆ្នោតឲ្យនោះទេ។
- ក្នុងករណីមានជម្លោះកើតឡើង នៅតាមស្នាក់ការបោះឆ្នោតណាមួយនោះ មន្ត្រីគ្រប់គ្រងត្រូវទាក់ទងមកកាន់ប្រធាន គ.រ.ប ដើម្បីដោះស្រាយបញ្ហានោះជាបន្ទាន់។

### ៨.៣. អ្នកបោះឆ្នោត

- អ្នកបោះឆ្នោតទាំងអស់ត្រូវធ្វើការបោះឆ្នោត នៅតាមភូមិដែលពួកគាត់បានចុះឈ្មោះ ក្នុងបញ្ជីបោះឆ្នោត។
- អ្នកបោះឆ្នោតទាំងអស់ នឹងត្រូវទាមទារឲ្យបង្ហាញនូវ ឯកសារបញ្ជាក់អត្តសញ្ញាណ មុនពេលធ្វើការបោះឆ្នោត។
- អ្នកបោះឆ្នោតដែលមានលក្ខខណ្ឌគ្រប់គ្រាន់ត្រូវចូលក្នុងបន្ទប់សម្ងាត់ដើម្បីបោះឆ្នោត។
- អ្នកបោះឆ្នោតនៅតាមស្នាក់ការទាំងអស់អាចបោះឆ្នោតបានតែម្តងប៉ុណ្ណោះ បន្ទាប់ពីបោះឆ្នោតរួចមន្ត្រីគ្រប់គ្រង នឹងលុបឈ្មោះចេញពីបញ្ជីអ្នកបោះឆ្នោត និងជ្រលក់ម្រាមដៃក្នុងទឹកថ្នាំ។
- អ្នកបោះឆ្នោតអាចចូលទៅក្នុងបន្ទប់សម្ងាត់ម្នាក់ម្តងៗបានតែម្តងប៉ុណ្ណោះ។
- ក្រៅពីមន្ត្រីគ្រប់គ្រង គ្មានបុគ្គលណាម្នាក់ត្រូវបានអនុញ្ញាត ឲ្យស្ថិតនៅក្នុងស្នាក់ការបោះឆ្នោតចំងាយ២០ម៉ែត្រ លុះត្រាតែ បុគ្គលនោះកំពុងបោះឆ្នោត។

## ៨.៤. ការិយាល័យសហគមន៍អេកូទេសចរណ៍នៅថ្ងៃបោះឆ្នោត

- មួយថ្ងៃមុនថ្ងៃបោះឆ្នោត បុគ្គលិករបស់ សហគមន៍អេកូទេសចរណ៍នឹង៖
  - រៀបចំវិក្កយបត្រសម្រាប់ភ្ញៀវ ដែលនឹងត្រូវចាកចេញនៅថ្ងៃបោះឆ្នោតមកដល់។ ភ្ញៀវនឹងធ្វើការបង់ថ្លៃជូនបុគ្គលិករបស់អង្គការសម្ព័ន្ធមិត្តសត្វព្រៃ។
  - បង្ហាញបញ្ជីកាលបរិច្ឆេទទៅកាន់អង្គការសម្ព័ន្ធមិត្តសត្វព្រៃ ដើម្បីឲ្យបុគ្គលិកអង្គការនេះធ្វើការ ត្រួតពិនិត្យសាច់ប្រាក់ និងទ្រព្យសម្បត្តិផ្សេងៗទៀត
  - ទូទាត់ប្រាក់ជំពាក់ដែលនៅសល់ទៅឲ្យសមាជិកទាំងអស់
  - បុគ្គលិកអង្គការសម្ព័ន្ធមិត្តសត្វព្រៃ នឹងបង្កើតលេខសំងាត់ថ្មីសំរាប់កុំព្យូទ័រ
  - រាល់ការផ្ទេរ ឬទទួលត្រូវមានការចូលរួមដឹងលឺពីអាជ្ញាធរមូលដ្ឋាន។
- ដើម្បីឲ្យមានសន្តិសុខល្អ បុគ្គលិកសហគមន៍អេកូទេសចរណ៍ នឹងធ្វើការចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ជាមួយនឹងការទទួលខុសត្រូវដែលពួកគេនឹងបង្ហាញឲ្យឃើញពីការរៀបចំមួយដែលមានសុវត្ថិភាព និងធ្វើការប្រគល់សោរទាំងអស់នៅពេលមានការផ្លាស់ប្តូរនៅថ្ងៃបោះឆ្នោតបន្ទាប់។
- មួយរយៈខ្លីមុនពេលថ្ងៃបោះឆ្នោតមកដល់ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ នឹងដឹកនាំក្រុមអ្នកត្រួតពិនិត្យបញ្ជីទ្រព្យ សម្ភារៈដែលកាន់កាប់ដោយ សហគមន៍អេកូទេសចរណ៍។
- នៅក្នុងថ្ងៃបោះឆ្នោត ការិយាល័យសហគមន៍អេកូទេសចរណ៍ នឹងត្រូវដំណើរការដោយបុគ្គលិករបស់អង្គការសម្ព័ន្ធមិត្តសត្វព្រៃ។ បុគ្គលិកគ្រប់គ្រងសហគមន៍អេកូទេសចរណ៍នឹងមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងការិយាល័យនេះឡើយ លើកលែងតែមានការរៀបចំវិក្កយបត្រសម្រាប់ភ្ញៀវដែលត្រូវចាកចេញនៅថ្ងៃបន្ទាប់។

## ៨.៥. ការរាប់សន្លឹកឆ្នោត

### ៨.៥.១. ការរាប់សន្លឹកឆ្នោត និងអ្នករាប់សន្លឹកឆ្នោត

- សន្លឹកឆ្នោត ដែលបានបោះឆ្នោតហើយនៅតាមភូមិទាំងប្រាំបី នឹងត្រូវបានរាប់រួមគ្នានៅស្នាក់ការសហគមន៍អេកូទេសចរណ៍។
- អ្នកដែលមានសិទ្ធិនៅក្នុងស្នាក់ការរាប់សន្លឹកឆ្នោតរួមមាន៖ សមាជិក គ.រ.ប មន្ត្រីគ្រប់គ្រងស្នាក់ការ បេក្ខជនឈរឈ្មោះបោះឆ្នោត និងអ្នកសង្កេតការណ៍។ ប្រជាពលរដ្ឋ ឬអ្នកបោះឆ្នោតមានសិទ្ធិឈរមើលពីចម្ងាយបាន។

### ៨.៥.២. ប្រអប់ឆ្នោត

- ប្រអប់ឆ្នោតនឹងត្រូវបិទនៅម៉ោង ៣ រសៀល ដែលនឹងត្រូវបោះត្រា និងរក្សាសុវត្ថិភាព ដោយមន្ត្រីគ្រប់គ្រងប្រចាំស្នាក់ការនីមួយៗ។ ប្រអប់ឆ្នោតនឹងត្រូវរក្សាទុកនៅកន្លែងដែលអាចមើលឃើញ ជាមួយនឹងវត្តមានរបស់ មន្ត្រីគ្រប់គ្រងស្នាក់ការបោះឆ្នោត និងអ្នកសង្កេតការណ៍នៅពេលដែលការបោះឆ្នោត ត្រូវបានបញ្ចប់រួចរាល់។
- ប្រអប់ឆ្នោតនឹងត្រូវបានដឹកជញ្ជូន មកស្នាក់ការសហគមន៍អេកូទេសចរណ៍ ដើម្បីរាប់សន្លឹកឆ្នោត ដោយមានការអមដំណើរដោយស្ថាប័នពាក់ព័ន្ធ ប៉ូលីស និងប្រជាពលរដ្ឋ។
- មន្ត្រីគ្រប់គ្រងស្នាក់ការបោះឆ្នោតទាំងពីររូប នឹងប្រគល់ប្រអប់ឆ្នោតដោយផ្ទាល់ទៅកាន់ គ.រ.ប។
- មន្ត្រីគ្រប់គ្រងស្នាក់ការទាំងអស់នឹងបញ្ជូនត្រឡប់មកវិញនូវ សន្លឹកឆ្នោតដែលមិនបានប្រើមកឲ្យ គ.រ.ប ដែលជាអ្នករាប់ និងចុះហត្ថលេខាទទួល។
- សន្លឹកឆ្នោតសរុបដែលបានប្រើនៅក្នុងស្នាក់ការនីមួយៗនឹងត្រូវរាប់ ហើយ គ.រ.ប នឹងបញ្ជាក់ពី ចំនួនសរុបនៃសន្លឹកឆ្នោតដែលបានប្រើ និងសន្លឹកឆ្នោតដែលមិនបានប្រើ ថាតើវាត្រូវនឹងចំនួន សន្លឹកឆ្នោតដែលបានប្រគល់ទៅដល់ស្នាក់ការនីមួយៗដែរឬទេ។

### ៨.៥.២. ការរាប់

- មុនចាប់ផ្តើមរាប់សន្លឹកឆ្នោត គ.រ.ប នឹងផ្តល់នូវ កាពិពណ៌នាដ៏ខ្លី អំពីអត្ថន័យនៃសន្លឹកឆ្នោតមិនបានការ និងបង្ហាញពីវិធីសាស្ត្រក្នុងការបកស្រាយ ពីគោលបំណងនៃការបោះឆ្នោតដែលមិនសូវច្បាស់។
- អ្នករាប់សន្លឹកឆ្នោតនឹងកត់ត្រាចំនួនសន្លឹកឆ្នោតនៃបេក្ខជន ឬមុខតំណែងនីមួយៗទៅក្នុងទម្រង់បែបបទរបាយការណ៍ដែលត្រូវបានផ្តល់ជូនដោយ គ.រ.ប។

- អ្នករាប់សន្លឹកឆ្នោត នឹងគូសសម្គាល់លើសន្លឹកឆ្នោតទាំងនោះ ដើម្បីបង្ហាញថាសន្លឹកឆ្នោតនីមួយៗត្រូវបានរាប់។
- សន្លឹកឆ្នោតមិនបានការ ឬសន្លឹកឆ្នោតដែលគូសមិនច្បាស់លាស់នោះ នឹងត្រូវរក្សាទុកមួយកន្លែង ដើម្បីឲ្យ គ.រ.ប និងបេក្ខជនឈរឈ្មោះទាំងអស់ធ្វើការពិភាក្សា និងកាត់សេចក្តី។
- ការជ្រើសទុកសន្លឹកឆ្នោតមិនបានការអាចប្រើការបានសម្រាប់មុខតំណែងនីមួយៗដោយឡែក ពីគ្នាដូចជាៈ សន្លឹកឆ្នោតមួយសន្លឹកអាចបានការសម្រាប់មុខតំណែងមួយ ប៉ុន្តែមិនបានការសម្រាប់ មុខតំណែងដទៃផ្សេងទៀត។ ឆ្នោតមួយសន្លឹកដែលត្រូវបានគូសច្រើនជាងមួយដង ឬគូសមិនច្បាស់លាស់នោះនឹងត្រូវ ចាត់ទុកថាមិនបានការ។
- គ.រ.ប នឹងបូកសរុបចំនួនសន្លឹកឆ្នោតសរុបសម្រាប់បេក្ខជន និងមុខតំណែងនីមួយៗ។
- បេក្ខជនដែលមានសម្លេងឆ្នោតច្រើនជាងគេសម្រាប់មុខតំណែងនីមួយៗនឹងត្រូវបានជ្រើសរើស
- ក្នុងករណីស្មើគ្នា នឹងមានបេក្ខជនម្នាក់អាចស្ម័គ្រចិត្តដកខ្លួនចេញ។ ប្រសិនបើមិនមានបេក្ខជនដកខ្លួនចេញទេ បេក្ខជនត្រូវចាប់ឆ្នោតដើម្បីជ្រើសរើសអ្នកឈ្នះ។ ប្រធាន គ.រ.ប ជាអ្នកគ្រប់គ្រងការចាប់ឆ្នោត ការចាប់ឆ្នោតនឹងកើតឡើងភ្លាមបន្ទាប់ពីការរាប់សន្លឹកឆ្នោតដោយមានបេក្ខជនពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ចូលរួម។
- ក្នុងករណីដែលបេក្ខជនបីអ្នកមានសំលេងស្មើគ្នា ការចាប់ឆ្នោត នឹងត្រូវធ្វើឡើងដើម្បីកំណត់ថា តើបេក្ខជនណាមួយនឹងត្រូវបានជ្រើសរើស។
- ប្រធាន គ.រ.ប នឹងសរសេរសេចក្តីបង្គាប់ចុងក្រោយនៃបេក្ខជនទាំងអស់ សម្រាប់មុខតំណែងនីមួយៗ គ្រប់បេក្ខជនទាំងអស់នឹងត្រូវផ្តិតមេដៃក្នុងបញ្ជីនេះ ដើម្បីបញ្ជាក់ថាពួកគេទទួលយកលទ្ធផលនេះ។
- ប្រធាន គ.រ.ប នឹងរក្សាទុកសេចក្តីបង្គាប់ចុងក្រោយនោះ។

## ៨.៦. ការស្នើសុំតវ៉ា

- បេក្ខជនដែលបានបដិសេធមិនបញ្ជាក់សុពលភាព នៃការជ្រើសតាំងនៅថ្ងៃបញ្ចប់ការបោះឆ្នោត នឹងត្រូវបញ្ជូនករណីនេះ ទៅកាន់ គ.រ.ប។ គ.រ.ប អាចអញ្ជើញអ្នកអង្កេតការណ៍បោះឆ្នោត ឯករាជ្យចូលរួមក្នុងដំណើរការនេះ។
- ការតវ៉ានឹងត្រូវបើកដំណើរការនៅវេលាម៉ោង ៨ ព្រឹកនាថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។
- ក្នុងករណីដែលមានការតវ៉ាច្រើន គ.រ.ប នឹងត្រូវកំណត់កាលបរិច្ឆេទ សម្រាប់ករណីទាំងនោះទៅតាមពេលវេលាសមរម្យណាមួយ ប៉ុន្តែការតវ៉ាទាំងអស់ត្រូវតែដោះស្រាយឲ្យបានចប់សព្វគ្រប់ក្នុងរយៈពេលពីរថ្ងៃ។
- ដើមចោទមានពេលមិនលើសពី ៣០ នាទីក្នុងការបង្កើតសំណុំរឿងរបស់ខ្លួន។

- ចុងចោទអាចបង្ហាញខ្លួន និងមានពេលមិនលើសពី ៣០ នាទីក្នុងការការពារសំណុំរឿងរបស់ ពួកគេ។
- បន្ទាប់ពីការជជែកវែកញែករវាងអ្នកតវ៉ា គ.រ.ប អាចកោះហៅសាក្សីមក បកស្រាយសំណុំរឿង។
- គ.រ.ប អាចជ្រើសរើស សកម្មភាពមួយក្នុងចំណោមសកម្មភាព ខាងក្រោម៖
  - មិនចាំបាច់ដូរលទ្ធផល ដោយសម្រេចជ្រើសរើសអ្នកដែលឈ្នះ
  - រៀបចំបោះឆ្នោតជាថ្មីសម្រាប់មុខតំណែង
  - ដំណើរការសម្រាប់បញ្ហានេះមិនត្រូវបាន កំណត់នៅក្នុងឯកសារនេះទេ
  - លុបចោលលទ្ធផលបោះឆ្នោតសំរាប់មុខតំណែង ហើយនឹងអនុញ្ញាតគណៈកម្មការសហគមន៍អេកូទេសចរណ៍ ដែលជ្រើសថ្មី អាចតែងតាំងមនុស្សម្នាក់ទៅកាន់មុខតំណែងមួយបាន
  - សម្គាល់ថា គ.រ.បមិនអាចដូរការបោះឆ្នោតទៅខាងភាគីតវ៉ាណាមួយបាន នោះទេ
  - ចំពោះភាពមិនប្រក្រតីនៃការចាំបាច់ដើម្បីរក្សាការបោះឆ្នោតថ្មីមួយ គ.រ.ប អាចធ្វើការប្រកាសជាលើកចុងក្រោយទៅគ្រប់មុខតំណែងទាំងអស់។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
ការិយាល័យស្រាវជ្រាវ

# ទំរង់ជ្រើសរើសសាស្ត្រាចារ្យណែនាំ

## ក្នុងការសរសេរសារណា ឬរបាយការណ៍កម្មសិក្សា និងការពារបញ្ចប់ការសិក្សា
## របស់និស្សិតបរិញ្ញាបត្រឆ្នាំទី៤

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ១. វ៉ាន់ ករុណា ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត ១៨ មិថុនា ១៩៩៩

លេខទូរស័ព្ទ ០១៧ ៤៤១ ៦៦២ Email Vannkarona1@gmail.com

អាសយដ្ឋានបច្ចុប្បន្ន ផ្ទះ... សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

និស្សិតថ្នាក់បរិញ្ញាបត្រ ទេសចរណ៍និងបដិសណ្ឋារកិច្ច (អាហារូបករណ៍ ឬបង់ថ្លៃ) ឆ្នាំទី៤ ជំនាន់ទី ៧

ក្រុម T4A1 ឆ្នាំសិក្សា២០២០ - ២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

២. ឈុំ គីរី ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត ១០ ធ្នូ ១៩៩៩

លេខទូរស័ព្ទ ០៩៦ ៦០៣ ០០៣៩ Email Chhumsovannkiryc@gmail.com

អាសយដ្ឋានបច្ចុប្បន្ន ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

និស្សិតថ្នាក់បរិញ្ញាបត្រ ទេសចរណ៍និងបដិសណ្ឋារកិច្ច (អាហារូបករណ៍ ឬបង់ថ្លៃ) ទី៤ ជំនាន់ទី ៧

ក្រុម T4A1 ឆ្នាំសិក្សា២០២០ - ២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

កន្លែងចុះស្រាវជ្រាវឯកសារ ឬកម្មសិក្សា សហគមន៍អេកូទេសចរណ៍ជីផាត ខេត្តកោះកុង

សំណូមពរយកសាស្ត្រាចារ្យឈ្មោះ ស្រូ រិទ្ធី ដើម្បីណែនាំក្នុងការ

សរសេរសារណាឬរបាយការណ៍កម្មសិក្សា និងការពារបញ្ចប់ការសិក្សាលើប្រធានបទស្តីពី៖

ការគ្រប់គ្រងសហគមន៍អេកូទេសចរណ៍ជីផាត

ខេត្តកោះកុង

ចាប់ពីថ្ងៃទី......... ខែ............. ឆ្នាំ២០២១ ដល់ថ្ងៃទី......... ខែ............ ឆ្នាំ២០២១។

ថ្ងៃ សៅរ៍ ៧ កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១

ហត្ថលេខា និងឈ្មោះសាមីនិស្សិត

បានឃើញ និងឯកភាព

ហត្ថលេខា និងឈ្មោះសាស្ត្រាចារ្យណែនាំ

សាស្ត្រាចារ្យ ស្រូ រិទ្ធី

វ៉ាន់ ករុណា ឈុំ គីរី

# ឧបសម្ព័ន្ធ “គ”

រូបភាពទី០១ ផ្លូវលំទៅកាន់សហគមន៍អេកូទេសចរណ៍ជីផាត



រូបភាពទី០២ សាឡាងទៅកាន់សហគមន៍អេកូទេសចរណ៍ជីផាត



រូបភាពទី០៣ ទឹកធ្លាក់នៅក្នុងសហគមន៍អេកូតេសចរណ៍ជីផាត



រូបភាពទី០៤ ទិដ្ឋភាពនៃទន្លេក្នុងសហគមន៍អេកូទេសចរណ៍ជីផាត



រូបភាពទី០៥ ពាងបូរាណនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត



រូបភាពទី០៦ ម្ឈុសបូរាណនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត



រូបភាពទី០៦ បឹងកាឡូនៅក្នុងសហគមន៍អេកូទេសចរណ៍ជីផាត



រូបភាពទី០៧ ផ្នែកខាងក្នុងនៃបឹងកាឡូរបស់សហគមន៍អេកូទេសចរណ៍ជីផាត



រូបភាពទី០៨ មជ្ឈមណ្ឌលសហគមន៍អេកូទេសចរណ៍ជីផាត




រូបភាពទី០៩ ផ្នែកខាងក្នុងមជ្ឈមណ្ឌលសហគមន៍អេកូទេសចរណ៍ជីផាត

